## ថ្ងៃទី០៤ ខែ មករា ឆ្នាំ២០២១

### សម្តេចតេជោ បញ្ជាឱ្យអាជ្ញាធរគ្រប់គ្រងឱ្យបានហ្មត់ចត់ ចំពោះអ្នកឆ្លងមកពីថៃ

http://btv.com.kh/ 01/01/2021

ភ្នំពេញ ៖ អំឡុងពេលនេះ ពលករខ្មែរ បានវិលត្រឡប់មកពីប្រទេសថៃ ចូលមកកាន់កម្ពុជាវិញ ដោយសារភ័យខ្លាចចំពោះបញ្ហាកូវីដ–១៩ ដែលកំពុងតែឆ្លងរាលដាលក្នុងសហគមន៍ នៃប្រទេសថៃ។ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានដាក់បទបញ្ជាឱ្យអាជ្ញាធរដែលឈរជើងនៅតាមព្រំដែន គ្រប់គ្រងឱ្យបានហ្មត់ចត់ ចំពោះអ្នកឆ្លងដែនមកពីថៃទាំងអស់។ សម្តេចតេជោ ហ៊ុន សែន បានចេញបទបញ្ជាឲ្យកម្លាំងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងអាជ្ញាធរខេត្តជាប់ព្រំដែនថៃ ធ្វើការគ្រប់គ្រងឲ្យបានហ្មត់ចត់ជាទីបំផុតចំពោះអ្នកឆ្លងដែនមកពីថ្ងៃ ដាច់ខាតមិនឲ្យមានការលួចឆ្លងដែនចូលមកក្នុងផ្ទៃក្នុងប្រទេស ដោយមិនបានធ្វើការត្រួតពិនិត្យ មិនបានយក សំណាក និងធ្វើចត្តាឡីស័ក ត្រឹមត្រូវនោះទេ។ សម្តេចតេជោ បានដាក់បទបញ្ជាដល់កងដឹកជញ្ជូនរបស់កងយោធពលខេមរភូមិន្ទ ឲ្យផ្អាកជា បន្ទាន់ ក្នុងការដឹកពលករពីប្រទេសថៃ ចូលមកក្នុងផ្ទៃក្នុងប្រទេស ដែលធ្លាប់តែដឹកទៅតាមខេត្ត-ក្រុងនានា ដោយធ្វើចត្តាឡីស័កពួកគេនៅតំបន់ព្រំដែន ល្មជាជាងដឹកពួកគេចូលមកក្នុងផ្ទៃក្នុងប្រទេស ដែលនាំឲ្យមានករណីឆ្លងនៅក្នុងសហគមន៍សារជាថ្មី។ សម្តេចតេជោ បានបញ្ជាឲ្យត្រៀមលក្ខណៈពង្រឹងការធ្វើចត្តាឡីស័កនៅព្រំដែន ព្រមទាំងឲ្យត្រៀម បន្ថែមក្រុមគ្រូពេទ្យប្រយុទ្ធប្រឆាំងកូវីដ–១៩ ថវិកា ព្រមទាំងសម្ភារៈ បច្ចេកទេសទៅកាន់តំបន់ព្រំដែន ប្រសិនបើមានករណីចាំបាច់ ដោយត្រូវធ្វើយ៉ាងណាដើម្បីប្រាកដថា អាចទប់ទល់នឹងករណីនេះបាន។

នៅថ្ងៃនេះ ក្រសួងសុខាភិបាល បានប្រកាសថា បានរកឃើញករណីវិជ្ជមានកូវីដ–១៩ ចំនួន១២ នាក់ទៀត ដែលសុទ្ធសឹងជាពលករខ្មែរធ្វើដំណើរមកពីប្រទេសថៃ។ ដែលគិតមកដល់ពេលនេះ មាន ពលករខ្មែរមកពីប្រទេសថៃ សរុប១៤នាក់ហើយ បានឆ្លងមេរោគកូវីដ–១៩៕ អត្ថបទ៖ ពៅ រក្សា

### ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប សរុបចំនួន ៤៥នាក់

https://www.facebook.com/tvkchannel7 03-01-2021

នៅថ្ងៃអាទិត្យ ទី០៣ ខែមករា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៥នាក់ ស្រី ២០នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ១នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១០នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

3-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៨នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ០២នាក់។

4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៤នាក់ ស្រី ១១នាក់ កុមារី ១នាកើ

+សរុបរួមចំនួន ២១នាក់ ស្រី ០៩នាក់ កុមារា ០២នាក់ កុមារី ០២នាក់។

+សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក នៅវិទ្យាល័យកូប ១៤នាក់ និង ២៨នាក់ នៅសាលាវិទ្យាល័យម៉ាឡៃ និងនៅមណ្ឌលសុខភាពប៉ោយប៉ែត១ ០៣នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ប្រភព: ក្រុមការងារប្រចាំការរបស់រដ្ឋបាលខេត្តសៀមរាប!!!

# រដ្ឋមន្ត្រីការងារប្រាប់ពលករកុំទាន់មកស្រុក ព្រោះប្រឈមបញ្ហាសុខភាព និងអាជ្ញាធរថៃពិន័យ

https://thmeythmey.com/ 01, Jan 2021 , 4:19 pm ដោយ: ថ្មីៗ

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ បានចេញសេចក្តីអំពាវនាវមួយ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ទៅកាន់ពលករកម្ពុជាក្នុងប្រទេសថៃ។ តាមរយៈសេចក្តីអំពាវនាវ ក្នុងនាមជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ លោក អ៊ិត សំហេង សុំឲ្យពលករកម្ពុជានៅប្រទេសថៃ គោរពតាមការអំពាវនាវរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការមិនឲ្យវិលត្រឡប់មកស្រុកកំណើតក្នុងដំណាក់កាលនេះ ដែលអាជ្ញាធរថៃ កំពុងដាក់បម្រាមប្រជាពលរដ្ឋថៃ និងជនបរទេស មិនឲ្យចល័តពីតំបន់មួយទៅតំបន់មួយ និងកំពុងដាក់ចេញវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩។ លោករដ្ឋមន្ត្រី បានអំពាវនាវឲ្យពលករកម្ពុជា រក្សាភាពនឹងននិងជឿទុកចិត្តលើសមត្ថភាពរបស់អាជ្ញាធរថៃ ក្នុងការទប់ស្កាត់និងការព្យាបាលជំងឺកូវីដ-១៩។ លោកប្រាប់ទៅពលករកម្ពុជានៅថៃដូច្នេះថា៖«បងប្អូនពលករ ដែលមានបំណងវិលត្រឡប់មកស្រុកកំណើតវិញក្នុងដំណាក់កាលនេះ គឺមានហានិភ័យខ្ពស់ទាំងផ្នែកសន្តិសុខនិងផ្នែកសុខភាព។ បងប្អូន អាចប្រឈមនឹងការឃាត់ខ្លួននិងរងការពិន័យរបស់អាជ្ញាធរថៃ ក្នុងពេលធ្វើដំណើរដោយខុសនឹងបម្រាមរបស់អាជ្ញាធរថៃ»។ យ៉ាងណាលោក អះអាងថា អាជ្ញាធរថៃ មិនឃាត់ខ្លួនឬពិន័យពលករបរទេសនិងនិយោជកណាមួយឡើយ បើពួកគេ អនុវត្តតាមការណែនាំរបស់អាជ្ញាធរថៃ។ លោក បន្តថា ក្នុងពេលដ៏ខ្លីខាងមុខនេះ ក្រសួងមហាផ្ទៃថៃនិងក្រសួងការងារថៃនឹងរួមគ្នាស្រង់ឈ្មោះពលករបរទេសនិងចេញបណ្ណពណ៌ស៊ីជម្ពូដល់ពលករបរទេស ក្នុងនោះ ក៏មានពលករកម្ពុជាដែរ។

នៅយប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបង្ហោះសារជាសំឡេងលើទំព័រហ្វេសប៊ុក អំពាវនាវឲ្យពលករកម្ពុជា កុំអាលប្រញាប់មកស្រុកកំណើតក្នុងដំណាក់កាលនេះ ដើម្បីទប់ស្កាត់ការរាលជំងឺកូវីដ-១៩ កុំឲ្យចូលមកកម្ពុជា។ ជាមួយគ្នានេះ សម្តេចនាយករដ្ឋមន្ត្រី បញ្ជាទៅអាជ្ញាធរខេត្ត ឲ្យពង្រឹងការធ្វើចត្តាឡីស័កចំពោះពលករដែលវិលមកពីថៃ។ ប្រមុខរដ្ឋាភិបាល ណែនាំថា ពេលពលករឆ្លងដែនចូលមកដល់ទឹកដីកម្ពុជា អាជ្ញាធរ ត្រូវទុកពួកគេ ឲ្យនៅធ្វើចត្តាឡីស័ក ក្នុងខេត្តជាប់ព្រំដែននោះតែម្តង ដោយមិនត្រូវដឹកពួកគេ ទៅស្រុកកំណើតនៅតាមបណ្តាខេត្តផ្សេងៗឡើយ។ រដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមបង្កើនការប្រុងប្រយ័ត្នខ្ពស់ ចំពោះការវិលត្រឡប់របស់ពលករពីថៃ បន្ទាប់ពីថៃ បានផ្ទុះខ្លាំងនូវការរាលជំងឺកូវីដ-១៩ សាជាថ្មី ដោយផ្តើមចេញពីខេត្ត សាមុត សាខន។ គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១នេះ ថៃ មានអ្នកឆ្លងជំងឺកូវីដ-១៩ ជាង៧,១ពាន់នាក់ហើយ ក្នុងនោះ ស្លាប់៦៣នាក់ និងបានជាសះស្បើយវិញ៤,៣ពាន់នាក់។

នៅព្រឹកថ្ងៃទី១ ខែមករានេះ ក្រសួងសុខាភិបាល ប្រកាសថា ពលករកម្ពុជា១២នាក់ ដែលមកពីថៃ បានផ្ទុកជំងឺកូវីដ-១៩។ មកដល់ពេលនេះ កម្ពុជា មានអ្នកឆ្លងជំងឺកូវីដ-១៩ សរុប៣៧៨នាក់ហើយ តែបានជាសះស្បើយវិញ៣៦២នាក់៕

# អភិបាលខេត្តប៉ៃលិន ចុះសួរសុខទុក្ខកងកម្លាំង ឈរជើងតាមបន្ទាត់ព្រំដែន ទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2021-01-03 09:03am

(ប៉ៃលិន)៖ លោកស្រី បាន ស្រីមុំ អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន និងលោក សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន នៅសៀលថ្ងៃសៅរ៍ ទី២ ខែមករា ឆ្នាំ២០២១ បានចុះសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកគ្រឿងឧបភោគបរិភោគ ជូនកងកម្លាំងការពារតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់ និងបទល្មើសជួញដូរផ្សេងៗ។ ជាពិសេសត្រៀមទទួលពលករដែលចំណាកស្រុកចូលមកពីប្រទេសថៃតាមច្រករបៀងនានា ដើម្បីបញ្ជូនមកធ្វើចត្តាឡីស័ក ក្រោមការពិនិត្យ និងតាមដានសុខភាពដោយយកចិត្តទុកដាក់ពីក្រុមគ្រូពេទ្យជំនាញ ក្នុងការបង្ការនិងទប់ស្កាត់ការរីករាលដាលវីរុសកូវីដ១៩ចូលក្នុងសហគមន៍។ លោកស្រីអភិបាលខេត្ត បាននាំបណ្ដាំផ្ញើសាកសួរសុខទុក្ខ ពីសំណាក់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ជូនកងកម្លាំង និងសារក្រើនរំលឹករបស់សម្ដេចឱ្យរួមគ្នាបំពេញតួនាទីភារកិច្ចឱ្យបានល្អ មានសាមគ្គីភាព ឯកភាពផ្ទៃក្នុងឱ្យបានរឹងមាំ ដើម្បីទប់ស្កាត់កុំឱ្យវីរុសកូវីដ១៩ឆ្លងចូលសហគមន៍។ លោកស្រីអភិបាលខេត្ត ក៏បានរំលឹកនូវប្រសាសន៍របស់សម្ដេច ដែលណែនាំកងកម្លាំងក្នុងពេលបំពេញភារកិច្ច ត្រូវរក្សាអនាម័យ ពាក់ម៉ាស់ លាងដៃនឹងអាល់កុល ដែល ជាប្រចាំ និងមិនត្រូវទៅប៉ះពាល់ ឬប្រាស្រ័យទាក់ទងពលករ ដែលស្ថិតក្នុងការសង្ស័យមានផ្ទុកវីរុសកូវីដ១៩ នោះឡើយ ត្រូវរាយការណ៍ជាបន្ទាន់មក្រុមការងារ និងគ្រូពេទ្យជំនាញ។

សូមបញ្ជាក់ថា ការចុះរឹតបន្តឹងការចេញចូលនៅតាមព្រំដែន និងការនាំពលករធ្វើចត្តាឡីស័ក បានធ្វើឡើងបន្ទាប់ពីការរកឃើញពលករខ្មែរមួយចំនួនបានវិជ្ជមានជំងឺកូវីដ១៩ ពេលត្រឡប់មកពីប្រទេសថៃ។ ជាពិសេសវិធានការទាំងនេះ ធ្វើតាមការណែនាំ និងបទបញ្ជាដ៏មុឺងម៉ាត់របស់ប្រមុខរាជរដ្ឋាភិបាល សម្ដេចតេជោ ហ៊ុន សែន និងការណែនាំរបស់ក្រសួងសុខាភិបាល។ ដើម្បីបង្ការកុំឱ្យមានជំងឺកូវីដ១៩ឆ្លងចូលក្នុងសហគមន៍នោះ លោកស្រី បាន ស្រីមុំ បានយកចិត្តទុកដាក់ខ្ពស់ ចំពោះពលករខ្មែរត្រឡប់មកពីថៃ ដោយតម្រូវឲ្យធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កនៅកន្លែងដែលបានកំណត់ដើម្បីយកសំណាកទៅវិភាគឲ្យបានគ្រប់ចំនួន៣ដង តាមការកំណត់របស់ក្រសួងសុខាភិបាល៕

# អាជ្ញាធរខេត្តសៀមរាបនៅតែបន្តទទួលពលករមកពីប្រទេសថៃដើម្បីធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ

http://nokorwatnews.com/ 03-01-2021

ខេត្តសៀមរាប៖ បើតាមសេចក្ដីរាយការណ៍ ពីរដ្ឋបាលសាលាខេត្តសៀមរាបនៅព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០២១ គឺ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី០២ ខែមករា ឆ្នាំ២០២១ នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ នៅថ្ងៃនេះដែរទទួលបានចំនួនសរុប ៦នាក់ ស្រីចំនួន ៤នាក់ ដែលចូលមកតាមច្រកដូងខេត្តបាត់ដំបង , តាមច្រកប៉ោយប៉ែត និងច្រកអូរបីជាន់ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។

គិតចាប់ពីថ្ងៃទី១០ ខែមីនា២០២០ មកដល់ថ្ងៃទី០២ ខែមករាឆ្នាំ២០២១នេះ សម្រាប់ខេត្តសៀមរាប តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើមានចំនួន ២០,១៥៦នាក់ ស្រីចំនួន ៨,៨៨០នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន២០,១៥៦នាក់ ស្រី ៨,៨៨០នាក់ គឺពិនិត្យសុខភាព

បានទាំងអស់។ សូមបញ្ជាក់ជូនថា ប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃក្នុងមួយថ្ងៃៗ មានចន្លោះពីជាង ១០០ នាក់ហូតដល់ជាង ៥០០នាក់ សម្រាប់ទូទាំងប្រទេសកម្ពុជា។

សូមជម្រាបជូនផងដែរថា, នៅព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០២១ ក្រសួងសុខាភិបាលបានជូនព័ត៌មានប្រកាសរកឃើញអ្នកវិជ្ជមានជំងឺកូវីដ-១៩ ថ្មីចំនួនពីរនាក់ ដែលជាពលករមកពីប្រទេសថៃ ។ អ្នកទាំងពីរនៅស្រុកកំរៀង ខេត្តបាត់ដំបង។ បច្ចុប្បន្នកំពុងឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តបាត់ដំបង៕

## ពលករខ្មែរនៅតែបន្តលួចឆ្លងដែនដោយខុសច្បាប់ចូលប្រទេសថៃ

https://kampucheathmey.com/ January 3, 2021By Bo Doula

ទោះបីជាមានការហាមឃាត់ពីរាជរដ្ឋាភិបាលកម្ពុជា មិនឲ្យចូលទៅប្រទេសថៃ ដោយខុសច្បាប់ក៏ដោយ ក៏សកម្មភាពលួចឆ្លងដែនចូល ពីសំណាក់ពលរដ្ឋខ្មែរមួយចំនួន នៅតែបន្តកើតមាន និងត្រូវបានអាជ្ញាធរថៃ ចាប់បញ្ជូនត្រឡប់មកវិញស្ទើររាល់ថ្ងៃ។ ជាក់ស្តែងកាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ មានពលករប្រមាណជាង៤០នាក់ ក្នុងនោះមានជាង២០នាក់ ត្រូវបានអាជ្ញាធរថៃ ចាប់បញ្ជូនត្រឡប់មកវិញ និងជាង១០នាក់ទៀត លួចឆ្លងដែនពីប្រទេសថៃ ចូលមកកម្ពុជាវិញ។

យោងតាមគេហទំព័ររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ បានឲ្យដឹងថា ថ្ងៃទី០២មករា ឆ្នាំ២០២១ អាជ្ញាធរថៃ បានចាប់បញ្ជូនពលករខ្មែរ ឆ្លងដែនខុសច្បាប់ ត្រឡប់មកកម្ពុជាវិញចំនួន២៦នាក់ ស្រី១៣នាក់ និងកុមារ២នាក់ ក្នុងនោះបញ្ជូនតាមច្រកទ្វារអន្តរជាតិព្រំ ចំនួន៤នាក់ស្រី៤នាក់ បានបញ្ជូនទៅធ្វើចត្តាឡីស័ក ១៤ថ្ងៃ និងបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ចំនួន២២នាក់ ស្រី៩នាក់ និងកុមារ២នាក់ បានបញ្ជូនទៅធ្វើចត្តាឡីស័ករួចរាល់ហើយដែរ។ ក្រៅពីនេះមានពលករខ្មែរចំនួន១៥នាក់ទៀត បានលួចឆ្លងដែនចូលមកតាមច្រកព្រំដែនខេត្តកោះកុង កាលពីវេលាម៉ោង៩យប់ ថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ត្រូវបានអាជ្ញាធរច្រកទ្វារអន្តរជាតិចាំយាមឃាត់ខ្លួនបានផងដែរ ដោយពួកគេទាំងនោះ មានលិខិតបញ្ជាក់ពីស្ថានទូតថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា និងលិខិតបញ្ជាក់សុខភាព របស់មន្ទីរពេទ្យខេត្តកោះកុង។ ពលករខ្មែរទាំង១៥នាក់នោះ ត្រូវបានសមត្ថកិច្ចប្រគល់ជូនមន្ត្រីចត្តាឡីស័ក ប្រចាំមាត់ច្រក ដើម្បីអនុវត្តនីតិវិធីបន្តនូវវិធានការរបស់ក្រសួងសុខាភិបាល។

គួរបញ្ជាក់ថា ភាគីថៃនៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ យ៉ាងហ្មត់ចត់ដើម្បីទប់ស្កាត់កូវីដ-១៩៕ **អត្ថបទ ៖ សំអឿន**

## គិតត្រឹមថ្ងៃ១មករា ខេត្តបាត់ដំបងទទួលបានពលករខ្មែរមកពីថៃ ចំនួន១៥៦៨នាក់

https://kampucheathmey.com/ January 2, 2021 ByKang Tola

លោក ឱសថ បណ្ឌិត រឿង ប៊ុនរេត ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបងបានឲ្យដឹងថា គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២១មាន ពលករខ្មែរមកពីចូលតាមច្រកព្រំដែនខេត្តនិងក្រៅខេត្តទាំងអស់សរុប ១៥៦៨ នាក់បានយកសំណាកសរុប ១២៣៨ នាក់ ក្នុងនោះទទួលបានលទ្ធអវិជ្ជមានចំនួន ១០៣៥ នាក់ និងលទ្ធផលវិជ្ជមានចំនួន ៤នាក់កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្ត។ លោកបានបន្តថា បច្ចុប្បន្ននេះមានពលករខ្មែរមកពីថៃចំនួន ១២៥១នាក់ កំពុងធ្វើចត្តាឡីស័កនៅមណ្ឌល១ ស្រី៥០៨នាក់ និង២០នាក់ ស្រី១៣នាក់ ធ្វើចត្តាឡីស័កនៅមណ្ឌល២។

លោកសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលកាលពីថ្ងៃទី០១មករាឆ្នាំ២០២១បានអញ្ជើញចុះពិនិត្យទីតាំងមណ្ឌលចត្តាឡីស័ក នៅតាមស្រុកជាប់ព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តបាត់ដំបង។ ក្នុងឱកាសនោះ

លោករដ្ឋមន្ត្រីបានណែនាំដល់អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធត្រូវពង្រឹងការធ្វើចត្តាឡីស័កទៅលើពលករខ្មែរមកពីថៃឲ្យបានគ្រប់១៤ថ្ងៃ ដើម្បីការពារកុំឲ្យមានការឆ្លងរីករាលដាលជំងឺកូវីដ១៩លក្ខណៈទ្រង់ទ្រាយធំ និងឆ្លងចូលទៅក្នុងសហគមន៍៕ **ដោយ ៖ សំអឿន**

## ឃាត់ខ្លួនពលករខ្មែរ១៥នាក់ ឆ្លងដែនចូលប្រទេសដោយខុសច្បាប់ និងជនជាតិថៃម្នាក់ចាកចេញពីប្រទេសកម្ពុជា

https://khmernote.com.kh/ January 3, 2021 Khmernote Media

កោះកុង៖ យោងតាមការចុះផ្សាយនៅលើគេហទំព័រ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ២១និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតក្នុងភូមិសាស្ត្រស្លាបស្ដាំ ពិនិត្យឃើញពលករខ្មែរ ឆ្លងដែនចូលប្រទេសដោយខុសច្បាប់ចំនួន ១៥នាក់ មានលិខិតបញ្ជាក់ពីស្ថានទូតថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា និងលិខិតបញ្ជាក់សុខភាព របស់មន្ទីរពេទ្យខេត្តកោះកុង។

នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ១៥នាក់នេះ មាន ១-ឈ្មោះ គង់ ហ៊ីន ភេទប្រុស អាយុ ២២ឆ្នាំ, ២-ឈ្មោះ ហេង សុគៀនប្រុស អាយុ ៤៨ឆ្នាំ, ៣-ឈ្មោះ ហេង សៀវម៉េង ប្រុស អាយុ ២៣ឆ្នាំ មានទីលំនៅភូមិចុងដាច ឃុំចុងដាច ស្រុករមៀកថ្មី ខេត្តត្បូងឃ្មុំ, ៤-ឈ្មោះ ស៊ីន អ៊ួច ភេទស្រី អាយុ ៤៨ឆ្នាំ, ៥-ឈ្មោះ ផាន សាភេទប្រុស អាយុ ៤៨ ឆ្នាំ, ៦-ឈ្មោះ សូរិយា សា អាយុ ០៩ឆ្នាំនៅភូមិដើមចង្ក្រាន ឃុំចក ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ, ៧-ឈ្មោះ អ៊ូ ឈៀង ភេទប្រុស អាយុ ២៩ឆ្នាំ នៅភូមិព្រៃទទឹង ឃុំអង្គសុភីស្រុក កំពង់ត្រាច ខេត្តកំពត, ៨-ឈ្មោះ ម៉េង លាន ភេទប្រុស អាយុ ៣១ឆ្នាំ មានទីលំនៅភូមិទួលជង្គោ ឃុំជ្រៃវៀន ស្រុកព្រៃឈរខេត្តកំពង់ចាម, ៩-ឈ្មោះ ជៀង វុធទុំ ភេទប្រុស អាយុ ៤៦ឆ្នាំ មានទីលំនៅភូមិទ្រឡើក ឃុំអង្គទ្រេត ស្រុកព្រៃវែង ខេត្តព្រៃវែង, ១០-ឈ្មោះ ប៊ុន ចិត្រា ភេទប្រុស អាយុ ៣៧ឆ្នាំ មានទីលំនៅភូមិស្វាយជង្គំ ឃុំស្វាយជង្គំ ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង, ១១-ឈ្មោះសុងបទ្រី ភេទប្រុស អាយុ ៥១ឆ្នាំ, ១២-ឈ្មោះ សំចន្ថា ភេទប្រុស អាយុ ៥០ឆ្នាំ មានទីលំនៅភូមិស្នាច់មានជ័យ ឃុំស្ទឹងវែង ស្រុកទងទុង ខេត្តកោះកុង, ១៣-ឈ្មោះ ចាន់ ថន ភេទស្រី អាយុ ២១ឆ្នាំ, ១៤-ឈ្មោះ ស្រី អូនភេទស្រី អាយុ ៣៣ឆ្នាំ, ១៥-ឈ្មោះ ឈិន កាក់ភេទស្រី អាយុ ៤៤ឆ្នាំ មានទីលំនៅភូមិដើមចង្ក្រាន ឃុំចក ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ និងបានធ្វើការសាកសួរ អប់រំណែនាំ រួចប្រគល់ជូនមន្ត្រីចត្តាឡីស័ក ប្រចាំមាត់ច្រក ដើម្បីអនុវត្តនិតិវិធីបន្ត នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។

ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបរថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ០២នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 03-01-2021

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៣និង៥០នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន

មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៩៦នាក់

https://www.facebook.com/GDIOfficial 03-01-2021

ឧត្តរមានជ័យ៖ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៦នាក់ ស្រី ៤១នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ២២នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 02-01-2021

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២២នាក់ ស្រី ០៩នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ០៤នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនមក តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ

https://www.facebook.com/GDIOfficial 02-01-2021

ប៉ៃលិន៖ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៦និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ បានទទួលពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៤នាក់ ស្រី ០៤នាក់។ ចំណែកឯពលរដ្ឋទាំងអស់នោះ កម្លាំងនគរបាលប៉ុស្តិ៍បានសហការជាមួយ ក្រុមការងារចត្តាឡីស័ក អប់រំណែនាំ បញ្ជូនទៅធ្វើចត្តាឡីស័ក ១៤ថ្ងៃ នៅមន្ទីរសុខាភិបាលខេត្តប៉ៃលិន៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៩០នាក់

https://www.facebook.com/GDIOfficial 02-01-2021

ឧត្តរមានជ័យ៖ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩០នាក់ ស្រី ៣០នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៨៧នាក់

https://www.facebook.com/GDIOfficial 01-01-2021

ឧត្តរមានជ័យ៖ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៧នាក់ ស្រី ៣៤នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ៕

## ឃាត់ខ្លួនពលករខ្មែរ០៦នាក់ និងបុរសជនជាតិខ្មែរ ០១នាក់ ដែលលើកជញ្ជូនកាបូប សម្ភារៈ ពលករខ្មែរធ្វើការឆ្លងដែនខុសច្បាប់ចូលមកកម្ពុជា

https://www.facebook.com/GDIOfficial 01-01-2021

បាត់ដំបង៖ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ នៅវេលាម៉ោង ០៩និង៣០នាទី កម្លាំងប្រចាំការគោលដៅស្លាបឆ្មេង របស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការឃាត់បានបុរសជនជាតិខ្មែរ ០១នាក់ ដែលបានលើកជញ្ជូនកាបូប សម្ភារៈ ពលករខ្មែរធ្វើការឆ្លងដែនចូលមកប្រទេសកម្ពុជា។ បន្ទាប់ពីបានធ្វើការសួនាំ និងទទួលបានព័ត៌មានរបស់ពលករខ្មែរ ដែលឆ្លងដែនចូលមកកម្ពុជា កម្លាំងប៉ុស្តិ៍បានធ្វើការស្រាវជ្រាវកំណត់អត្តសញ្ញាណ និងទីតាំងដែលពួកគាត់កំពុងធ្វើដំណើរចាកចេញពីស្រុកសំពៅលូន ខេត្តបាត់ដំបង ហើយក៏បានធ្វើការសហការជាមួយ កម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន ជាមួយនឹងកម្លាំងអធិការដ្ឋាននគរបាលស្រុកបវេលរហូតឈានដល់ធ្វើការឃាត់ដំណើរពួកគាត់បាន នៅក្នុងស្រុកបវេល ខេត្តបាត់ដំបង។ ចំពោះពលករដែលឆ្លងដែន

ចូលមកកម្ពុជា មានចំនួន ០៤នាក់ ស្រី ០១នាក់ ក្នុងនោះរួមមានកុមារ ០២នាក់ និងអ្នកពាក់ព័ន្ធដែលត្រូវជាឪពុក-ម្តាយ របស់ពលករទាំងពីរខាងលើ មានចំនួន០២នាក់ ដែលសរុបទាំងអស់មានចំនួន ០៦នាក់។

បច្ចុប្បន្នអ្នកទាំង ០៦នាក់ ត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក អនុវិទ្យាល័យសាមគ្គី ស្រុកបវេល ខេត្តបាត់ដំបង រីឯអ្នកលើកជញ្ជូនកាបូន សម្ភារៈ ឲ្យពលករខ្មែរត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក សាលាបឋមសិក្សា ហ៊ុន សែន ជ្រៃសីមា ខេត្តបាត់ដំបង៕

## ពលករចំណាកស្រុកដែលធ្វើការក្នុងប្រទេសថៃ នឹងទទួលបានប័ណ្ណការងាររយៈពេល ២ ឆ្នាំ និងធានារ៉ាប់រងសុខភាព

https://business.khmernote.com.kh/ December 31, 2020 Nita

យោងតាមការចុះផ្សាយរបស់សារព័ត៌មាន Thethaiger របស់ប្រទេសថៃបានឱ្យដឹងថា ពលករចំណាកស្រុកគ្មានឯកសារមកពី ៣ ប្រទេសនឹងអាចចុះឈ្មោះសម្រាប់ការងារស្របច្បាប់ដែលអនុញ្ញាតឱ្យមានការស្នាក់នៅរយៈពេល ២ ឆ្នាំ។ គណៈរដ្ឋមន្រ្តីថៃ បានយល់ព្រមលើវិធានការណ៍នេះក្នុងកិច្ចប្រឹងប្រែងមួយដើម្បីគ្រប់គ្រងការរីករាលដាលនៃជំងឺ Covid-19 បន្ទាប់ពីមានការផ្ទុះឡើងនៅផ្សារអាហារសមុទ្រសាមុតសាខុន បានធ្វើឱ្យប៉ះពាល់ដល់ពលករចំណាកស្រុកដែលធ្វើការនៅមជ្ឈមណ្ឌលនេសាទ។ ពលករចំណាកស្រុកមកពីប្រទេស កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា នឹងអាចចុះឈ្មោះជាមួយនាយកដ្ឋានការងារនៃក្រសួងការងារថៃចាប់ពីថ្ងៃទី ១៥ ខែមករា រហូតដល់ថ្ងៃទី ១៣ ខែកុម្ភៈ។ កម្មករត្រូវឆ្លងកាត់ការត្រួតពិនិត្យសុខភាពមុនពេលដាក់ពាក្យស្នើសុំប័ណ្ណការងារ។ កម្មករ និងកូនៗរបស់ពួកគេ នឹងទទួលបានការធានារ៉ាប់រងសុខភាពរយៈពេល ២ ឆ្នាំ។ ពលករត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតការងារឲ្យបានមុនថ្ងៃទី ១៣ ខែកញ្ញា។ ពួកគេត្រូវចុះឈ្មោះជាជនមិនមែនថៃនៅត្រឹមថ្ងៃទី ១២ ខែវិច្ឆិកា។ ជនចំណាកស្រុក ឬនិយោជករបស់ពួកគេត្រូវបង់ប្រាក់ ៧,២០០ បាតដើម្បីពិនិត្យសុខភាព និងធានារ៉ាប់រងសុខភាពរយៈពេល ២ ឆ្នាំ។ ជនចំណាកស្រុកគ្មានឯកសារ និងគ្មាននិយោជកត្រូវរកការងារធ្វើក្នុងរយៈពេល ៩០ ថ្ងៃ។

គួឱ្យដឹងផងដែរថា ការផ្ទុះឡើងនៅខេត្តសាមុតសាខុន បានឆ្លងដល់កម្មករចំណាកស្រុករាប់រយនាក់ និងបានឆ្លុះបញ្ចាំងពីការជួញដូរពលកម្ម និងការងារគ្មានឯកសារ។ កងយោធពលខេមរភូមិន្ទថៃ កាលពីពេលថ្មីៗនេះបាននិយាយថា ពួកគេមិនអាចបញ្ឈប់ការរំលោភបំពានព្រំដែនបានទេហើយឥឡូវនេះប៉ូលីសបានផ្លាស់ប្តូរការចាប់របស់ពួកគេ ពីការចាប់ជនចំណាកស្រុកចូលដោយខុសច្បាប់ទៅនឹងការបង្រ្កាបអ្នកជួញដូរការងារ៕

# ថ្ងៃទី០៥ ខែ មករា ឆ្នាំ២០២១

## ពលករមកពីថៃជាង១៤០០នាក់ ត្រូវបានធ្វើតេស្តក្នុងនោះ៤នាក់ វិជ្ជមានកូវីដ-១៩

http://btv.com.kh/ 04/01/2021

បាត់ដំបង ៖ ពលករធ្វើដំណើរពីប្រទេសថៃ មកស្រុកកំណើតវិញ ហើយកំពុងធ្វើចត្តាឡីស័កតាមមណ្ឌលនានា ក្នុងខេត្តបាត់ដំបង ត្រូវបានមន្ត្រីសុខាភិបាលយកសំណាក ពិនិត្យរកជំងឺកូវីដ១៩ មានជាង ១៤០០នាក់ ដោយក្នុងចំណោមនេះ មានពលករចំនួន ៤នាក់ បានរងឃើញវិជ្ជមានជំងឺកូវីដ១៩ ហើយពួកគេកំពុងសម្រាកព្យាបាល នៅក្នុងមន្ទីរពេទ្យខេត្ត ។

យោងតាមរបាយការណ៍របស់រដ្ឋបាលខេត្តបាត់ដំបង នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២១ បានបង្ហាញថាបច្ចុប្បន្នមានពលករទាំងអ្នករស់នៅខេត្តបាត់ដំបង និងខេត្តផ្សេងៗ បានត្រឡប់មកពីថៃ អំឡុងនៃការឆ្លងរីករាលដាលជំងឺកូវីដ១៩ ក្នុងខេត្តសាមុទសាខន កំពុងធ្វើចត្តាឡីស័កនៅខេត្តបាត់ដំបង មានចំនួន ១៤១៨នាក់ ។ របាយ

ការណ៍ បន្តថា ដោយសារចំនួននៃពលករ កើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ អាជ្ញាធរខេត្ត បានបន្ថែមនូវមណ្ឌលចត្តាឡីស័កសរុប ៩មណ្ឌល ក្នុងនោះមណ្ឌលចត្តាឡីស័ក សម្រាប់ទទួលពលករចូលតាមច្រកព្រំដែន កម្ពុជា-ថៃ ជាប់ខេត្តបាត់ដំបង មាន ៦មណ្ឌល រួមមាន នៅស្រុកកំរៀង ស្រុកសំពៅលូន ស្រុកភ្នំព្រឹក ស្រុកបវេល ស្រុកសំឡូត ស្រុកឯកភ្នំ និងស្រុកមោងឫស្សី ។ ដោយឡែកមណ្ឌលចត្តាឡីស័កចំនួន ៣មណ្ឌលទៀត សម្រាប់ទទួលពលករចូលតាមច្រកព្រំដែនខេត្តបន្ទាយមានជ័យ និងខេត្តឧត្តមានជ័យ រួមមាននៅវិទ្យាល័យព្រះមុនីវង្ស ស្ថិតក្នុងក្រុងបាត់ដំបង, វិទ្យាល័យជ្រៃ ក្នុងស្រុកថ្មគោល និងវិទ្យាល័យអន្លង់វិល ក្នុងស្រុកសង្កែ ។ ប្រភពដដែល បានបន្ថែមថា ពលករចូលតាមច្រកព្រំដែន កម្ពុជា-ថៃ ជាប់ខេត្តបាត់ដំបង និងជាប់ខេត្តផ្សេងៗ កំពុងធ្វើចត្តាឡីស័កក្នុងខេត្តបាត់ដំបង មានមកពីខេត្តសាមុតសាខន ក្រុងថេប ខេត្តចន្ទបុរី ខេត្តស្រះកែវ ខេត្តសាមុតបាកាន ខេត្តនគរភ្នំ ខេត្តសុផានបុរី ខេត្តរាធាបុរី និងខេត្តមិនបុរី នៃប្រទេសថៃ ។

ដោយពលករ កំពុងធ្វើចត្តាឡីស័កទាំងអស់នេះ ត្រូវបានយកចិត្តទុកដាក់ពីរដ្ឋបាលខេត្ត មន្រ្តីសុខាភិបាល កងកម្លាំងនានា ក្នុងការផ្តល់អាហារ ៣ពេល ការពិនិត្យសុខភាព និងការយកសំណាករកជំងឺកូវីដ១៩ និងការការពារសន្តិសុខសុវត្ថិភាពជាដើម ហើយការត្រឡប់មកពីថៃ របស់ពលករ តាមច្រកព្រំដែនជាប់ខេត្តបាត់ដំបងនេះ មិនមានសម្រុកមកខ្លាំងនោះទេ ខណៈនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ មានពលករឆ្លងមកចំនួន ៦៧នាក់ ។ អត្ថបទ ៖ បាន សុខរិទ្ធ

## នៅបន្ទាយមានជ័យត្រូវសម្រុកបង្កើតមណ្ឌលចត្តាឡីស័កបន្ថែមទៀតព្រោះពលករខ្មែរត្រឡប់ពីថៃកើនឡើង

https://www.rasmeinews.com/ 4 January, 2021

**ដោយ: ភ្នំស្វាយ / បន្ទាយមានជ័យ:** *នៅបន្ទាយមានជ័យ ត្រូវសម្រុកបង្កើតមណ្ឌលចត្តាឡីស័កបន្ថែមទៀតព្រោះពលករខ្មែរត្រឡប់ពីថៃកើនឡើង។ នេះបើតាមលោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានប្រាប់កាសែតរស្មីកម្ពុជា នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ បន្ទាប់ពីលោកទៅសួរសុខទុក្ខ ក្រុមការងារចំរុះ និងបងប្អូនប្រជាពលរដ្ឋ(ឬពលករខ្មែរ) ទើបវិលត្រឡប់មកពីប្រទេសថៃ តាមមណ្ឌលចត្តាឡីស័ក ស្រុកស្វាយចេក ស្រុកថ្មពួក ព្រះនេត្រព្រះ ភ្នំស្រុក អូរជ្រៅ ក្រុងប៉ោយប៉ែត កាលពីសៀល ល្ងាច ថ្ងៃទី៣ និងព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ ។* លោកអភិបាលខេត្តបានបន្តថា លោកត្រូវតែបន្តចុះពិនិត្យមើលមណ្ឌលធ្វើចត្តាឡីស័ក បងប្អូនប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ហើយប៉ាន់ប្រមាណថា នឹងត្រូវសម្រុកបង្កតមណ្ឌលបន្ថែមទៀត ទើបទ្រោលសភាពការណ៍ដែលពលករខ្មែរដែលសម្រុកវិលត្រឡប់ពីប្រទេសថៃ ខណៈជម្ងឺកូវីត១៩ បានផ្ទុះរីករាលដាលខ្លាំងក្នុងសហគមន៍នោះ។ ជាងនេះទៅទៀត ថៃកាពីថ្ងៃទី៣ ខែមករាមក ក៏បានបិទខេត្តជាច្រើន រួមទាំងរាជធានីបាងកក ខេត្តឈុនបូរី ខេត្តឆាក់ឈើងសាវ សាមុតប្រាកាន ច័ន្ទបូរី ត្រាតនិងខេត្តស្រះកែដែលមានពលករខ្មែរទៅធ្វើការ ហាលយជាប់ព្រំដែនកម្ពុជាផងនោះ ។

លោក អ៊ុំ រាត្រី បានបន្តថា ៖ សម្រាប់បណ្តោយព្រំដែនកម្ពុជា ថៃ ក្នុងភូមិសាស្រ្តខេត្តបន្ទយមានជ័យ គឺពលករខ្មែរត្រូវបានភាគថៃបញ្ជូនមកតាមច្រករបៀង២ គឺច្រកព្រំដែនអូរបីជាន់ឃុំអូរបីជាន់ ក្នុងស្រុកអូរជ្រៅ និងច្រករបៀងនៅឃុំបឹងបេង ស្រុកម៉ាឡៃ ដែលជាមធ្យមមានពលករចំនួន២០០នាក់/១ថ្ងៃ។ ។ លោកបន្តថា ៖ បរិមាណនេះ នាំអោយមណ្ឌលចត្តាឡីស័កកម្រិត១(QC1)និងកម្រិត២(QC2) ចំនួន១២កន្លែងដែលមានស្រាប់ ត្រូវហៀរហូរដោយពលករព្រោះពួកគេត្រូវត្រួតពិនិត្យសុខភាពនិងធ្វើចត្តាឡីស័ក ហើយស្នាក់នៅដាច់ដោយឡែក១៤ថ្ងៃ បើអត់បញ្ហាទើបអោយបន្តដំណើរទៅផ្ទះបាន។ ហេតុនេះរដ្ឋបាលខេត្តមានតែបើកមណ្ឌលចតកតាឡីស័កបន្ថែម ។ក្នុង

នោះ សម្រុកជួសជុលបន្ទប់និងអគារនៃអតីតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការដោយសារសង្គ្រាមហៅ ស៊ីវ៉រ (CWAR. Center ) នៅភូមិកងវ៉ា សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណមួយទៀត ដែលអាចទទួលមនុស្ស បាន៨០០នាក់ ។ ក្រៅពីនោះគឺបើកមណ្ឌលនៅតាមសាលារៀននានានៅបណ្តាស្រុកដែលមិនជាប់តំបន់ព្រំដែន ៕

## អភិបាលខេត្តប៉ៃលិន៖ ស្ត្រីពលករពីថៃភាគច្រើនធ្វើដំណើរជាក្រុមម្តង៥នាក់

https://thmeythmey.com/ 04, Jan 2021 , 10:39 pm ដោយ: អ៊ូ សុខមាន (OU Sokmean)

មកដល់ថ្ងៃទី៤ មករា មានពលករខ្មែរដែលមកពីប្រទេសថៃចំនួន១៧នាក់ហើយ បានឆ្លងនូវជំងឺកូវីដ-១៩។ អ្វីដែលគួរកត់សម្គាល់គឺថាពលករខ្មែរដែលបានឆ្លងកូវីដ-១៩នោះគឺសុទ្ធតែជាស្ត្រី មានវ័យចន្លោះពី២០ទៅ៣០ឆ្នាំ។ ពាក់ព័ន្ធទៅបញ្ហាដែលពលករសុទ្ធតែស្ត្រីបានឆ្លងនូវជំងឺនេះ អ្នកស្រី បាន ស្រីមុំ អភិបាលប៉ៃលិន បានផ្តល់ការសន្និដ្ឋាន ថា គឺបណ្តាលមកពីពលករជាស្ត្រីទាំងនោះ ធ្វើដំណើរពីថៃមកខ្មែរជាមួយគ្នា មានលក្ខណៈជាក្រុមៗ។ « ស្ត្រីជាពលករដែលបានឆ្លងកូវីដ-១៩នោះ បានដំណើរជាមួយគ្នាជាក្រុមៗ ដោយមួយក្រុមមានគ្នា៥នាក់ៗ»។ នេះជាការលើកឡើងរបស់អ្នកស្រី បាន ស្រីមុំ ដោយបញ្ជាក់ថា ពលករជាស្ត្រីបានធ្វើដំណើរពីប្រទេសថៃមកដល់ដីខ្មែរជាក្រុមគឺមានគ្នាពី៥នាក់តែម្តង។

ក្រៅពីនេះ មូលហេតុមួយទៀត ដែលពលករខ្មែរមានតែស្ត្រីឆ្លងនូវជំងឺនេះ អាចមកពីពួកគាត់ធ្វើការងារនៅទីតាំងជាមួយគ្នាក្នុងប្រទេសថៃ ស្នាក់នៅ និងហូបអាហារជាមួយគ្នា។ អ្នកស្រី បាន ស្រីមុំ បាននិយាយប្រាប់សារព័ត៌មានថ្មីៗតាមទូរសព្ទដូច្នេះ៖«ក្រុមស្ត្រីជាពលករខ្មែរ នៅប្រទេសថៃ គឺពួកគាត់ធ្វើការងារជាមួយគ្នា ហើយពួកគាត់ជាដំណើរជាមួយគ្នា។ អ៊ីចឹង វាអាចធ្វើឱ្យប៉ះពាល់ឬឆ្លងទាំងអស់គ្នា ជាក្រុមបែបនេះ»។ បើតាមអភិបាលខេត្តប៉ៃលិនរូបនេះ ពលករខ្មែរដែលធ្វើការងារនៅប្រទេសថៃ គឺមានចម្រុះវិស័យ ដូចជា៖ វិស័យកសិកម្ម, រោងចក្រ និងសំណង់ជាដើម។

សូមជម្រាបថា ក្នុងចំណោមពលរកមកពីថៃសរុប១៧នាក់ ដែលជាស្ត្រីបានឆ្លងជំងឺកូវីដ-១៩នេះ មាន១១នាក់នៅក្នុងនៅខេត្តប៉ៃលិន និង៦នាក់ទៀត នៅខេត្តបាត់ដំបង។ បច្ចុប្បន្ន អ្នកជំងឺទាំងនេះ កំពុងព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តរៀងៗខ្លួន។ ដោយឡែក គិតត្រឹមថ្ងៃទី៤មករា ឆ្នាំ២០២០ កម្ពុជា បានរកអ្នកជំងឺកូវីដ-១៩ សរុប ៣៨២នាក់ ដោយក្នុងនោះ មាន៣៦២នាក់ បានជាសះស្បើយ៕

## អភិបាលខេត្តកោះកុង ប្រាប់ដល់កងកម្លាំងតាមព្រំដែនត្រូវហ្មត់ចត់ចំពោះពលករខ្មែរចេញពីថៃ

http://btv.com.kh/ 04/01/2021

កោះកុង ៖ អភិបាលខេត្តកោះកុង បានក្រើនរម្លឹកដល់កងកម្លាំងប្រដាប់អាវុធ នៅតាមខ្សែបន្ទាត់ព្រំដែនជាប់ជាមួយខេត្តត្រាតប្រទេសថៃ ឱ្យបង្កើនភាពហ្មត់ចត់ចំពោះវិធានការទប់ស្កាត់ និងទទួលពលករខ្មែរមកពីប្រទេសថៃ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលកូវីដ–១៩ ។ លោកជំទាវ មិថុនា ភូថង អភិបាលខេត្តកោះកុង បានដាក់ផែនការពិនិត្យតាមដានដល់កងកម្លាំង ប្រដាប់អាវុធនៅគ្រប់ច្រកល្ហកទាំងអស់ ដើម្បីធានាបាននូវការទប់ស្កាត់ការលួចចូលនៃពលករខ្មែរមកពី ប្រទេសថៃ តាមរយៈព្រំដែនខេត្តកោះកុង ក្បែរនឹងខេត្តត្រាតប្រទេសថៃ។ ក្នុងពេលចុះពិនិត្យស្ថានភាពតំបន់ទីតាំងឈរជើងរបស់កម្លាំងនគរបាល និងយោធាការពារព្រំ ដែន កាលពីម្សិលមិញ លោក ទូ សាវុធ អភិបាលរងខេត្តកោះកុងបានបញ្ជាក់ថាការតម្រូវឱ្យមានការប្រុងប្រយ័ត្នខ្ពស់យ៉ាងដូច្នេះដោយសារខេត្តត្រាតប្រទេសថៃ ជាប់ខេត្តកោះកុង កំពុងរងការរាលត្បាត នៃមេ រោគកូវីដ–១៩។

គិតចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ មកដល់ពេលនេះ អាជ្ញាធរខេត្តកោះកុង ទទួលបានពលករ ខ្មែរមកពីប្រទេសថៃ ចំនួន៥២នាក់ហើយ ក្នុងនោះបានធ្វើតេស្តរកកូវីដ–១៩ ចំនួន១៨នាក់ ក្រៅពីនេះកំពុងបន្តយកសំណាកទៅពិនិត្យ។

ឧត្តមសេនីយ៍ទោ សុខ សុវត្ថិទុម មេបញ្ជាការសឹករងខេត្តកោះកុង បានឱ្យដឹងថា ស្ថានភាពបច្ចុប្បន្ន តាមគោលដៅនីមួយៗរបស់កងកម្លាំងយោធាឈរជើងតាមបណ្តោយខ្សែបន្ទាត់ព្រំដែន ពុំទាន់មានហេតុការណ៍ណាមួយកើតឡើងគួរឱ្យកត់សម្គាល់ឡើយ។ តែទោះបែបនេះក៏ពិតមែន ក៏លោកបាន ដាក់បទបញ្ជាដល់កងកម្លាំង ឱ្យប្រុងប្រយ័ត្នតាមដាពិនិត្យមើលរំហូរពលករខ្មែរ ដែលលួចចូលឆ្លងដែនខុសច្បាប់ ដោយចាប់បញ្ជូនមកមណ្ឌលធ្វើចត្តាឡីស័ក ដែលត្រៀមទុកជាស្រេច។

ថ្មីៗនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជណាចក្រកម្ពុជា ក៏បានបញ្ជាឱ្យអាជ្ញាធរខេត្តជាប់ព្រំដែនថៃ ត្រូវគ្រប់គ្រងរំហូរពលករខ្មែរ ដែលវិលត្រឡប់ពីថៃ ត្រូវឆែកសុខភាពឲ្យបានហ្មត់ចត់ បំផុត ធ្វើតេស្តសំណាក និងត្រូវធ្វើចត្តាឡីស័ក ឲ្យគ្រប់១៤ថ្ងៃជាចាំបាច់ ដើម្បីការពារការឆ្លងរាលដាលក្នុង ប្រទេស៕ អត្ថបទ ៖ ឈឹម មករា

## គិតត្រឹមថ្ងៃទី៤ ប្រជាពលរដ្ឋដែលវិលចូលប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ១២៧នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់

https://khmernote.com.kh/ January 5, 2021 srey nuch

ខេត្តឧត្តរមានជ័យ៖ យោងតាមការចុះផ្សាយរបស់ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា នៅថ្ងៃទី ០៤ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៧នាក់ ស្រី ៥០នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអាជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ ៕

## បុរសខ្មែរម្នាក់លះបង់ពេលផ្ទាល់ខ្លួនជួយការពារសិទ្ធិពលករខ្មែរនៅថៃ ដោយមិនគិតប្រាក់កម្រៃ

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2021-01-04

ពលរដ្ឋខ្មែរម្នាក់ ចំណាយពេលវេលាផ្ទាល់ខ្លួនអស់ច្រើនឆ្នាំមកហើយ ដើម្បីជួយការពារសិទ្ធិដល់ពលករខ្មែរដែលរងគ្រោះដោយថៅកែរំលោភបំពានសិទ្ធក្នុងពេលធ្វើការនៅប្រទេសថៃ។ យុវជនរូបនេះ ជួយពលករខ្មែរដោយមិនគិតប្រាក់កម្រៃ ដោយសារលោកឃើញពលករខ្មែរជាច្រើននាក់ត្រូវថៅកែថៃធ្វើបាបជាបន្តបន្ទាប់ដោយមិនទទួលបានយុត្តិធម៌ឡើយ។ តើយុវជនរូបនេះ ធ្វើការងារបែបណាខ្លះជួយដល់ពលករខ្មែរ?

បុរសសម្បុរស្រអែម មានស្រុកកំណើតនៅខេត្តពោធិ៍សាត់ លោក ប្រាក់ ភត្រា រៀបរាប់ប្រាប់អាស៊ីសេរីថា លោកធ្វើការងារនៅប្រទេសថៃប្រមាណ ២០ឆ្នាំហើយ ដោយដំបូងឡើយលោកធ្វើការជាកម្មករសំណង់ ធ្វើការផ្នែកកសិកម្ម និងផ្នែកសន្តិសុខជាដើម។ ពលរដ្ឋវ័យ៣៧ឆ្នាំរូបនេះ បន្តថា លោកចាប់ផ្ដើមធ្វើការងារសង្គម បន្ទាប់ពីលោកជួបប្រទះឃើញពលករខ្មែរជាច្រើននាក់ ត្រូវថៅកែថៃរំលោភបំពានសិទ្ធិការងារ មានដូចជា ធ្វើការមិនបើកប្រាក់ឈ្នួលឱ្យ ថៅកែវាយធ្វើបាបពលករ ដកហូតលិខិតឆ្លងដែន និងថៅកែយកកាំភ្លើងខ្លីបាញ់គំរាមសម្លាប់ពលករខ្មែរជាដើម ប៉ុន្តែភាគច្រើនពួកគេមិនហ៊ានប្ដឹងរកយុត្តិធម៌ឡើយ។ ពលកររូបនេះបន្តថា ដោយឃើញការលំបាករបស់ពលករទាំងនោះ ទើបលោកសម្រេចប្ដូរជីវិតជួយសម្របសម្រួលរកយុត្តិធម៌ដល់ពួកគេ ដោយមិនគិតប្រាក់កម្រៃរហូតមក។ លោកប្រាប់ថា លោកធ្វើការងារនេះបានជោគជ័យតាមរយៈទំនាក់ទំនងអង្គការក្រៅរដ្ឋាភិបាលរបស់ថៃ ធ្វើការផ្នែកពលករបរទេស។ លោកបន្ថែមទៀតថា លោកប្រមូលរឿងរ៉ាវរបស់ពលករតាមបណ្ដាញហ្វេសប៊ុក ( Facebook ) រួចនាំរឿងពលករខ្មែររងគ្រោះប្ដឹងទៅអាជ្ញាធរពាក់ព័ន្ធរបស់ថៃជួយដោះស្រាយតាមច្បាប់ការងារប្រទេសថៃ៖ «បើសិនជាបងប្អូនខ្មែរយើងមកធ្វើការប្រទេសស្របច្បាប់ ហើយរងការគាបសង្កត់ឬការជិះជាន់ កម្លាំងពលកម្មពីសំណាក់ថៅកែហ្នឹងយើង អាចទាន់ទំនងសុំការប្រឹក្សា ឬទាក់ទងទៅស្ថាប័នពាក់ឱ្យជួយអន្តរាគមន៍យើងបាន។ប្រសិនជាយើងស្គាល់ថៅកែហ្នឹងច្បាស់ហើយ មានឯកសារមានអីគ្រប់គ្រាន់ អាហ្នឹងខ្ញុំជឿថា បងប្អូនអាចទទួលបានការជួយយ៉ាងពេញលេញពីស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេសថៃ»។

លោកឱ្យដឹងថា ការងាររបស់លោកនេះ ថៅកែថៃ មិនចូលចិត្តនោះទេ ពីព្រោះប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ។ ទោះជាយ៉ាងណា លោកនឹងបន្តធ្វើការងារនេះទៀត ដោយមិនព្រួយបារម្ភអ្វីឡើយ ព្រោះលោកថា រឿងនេះជាការធ្វើដើម្បីប្រយោជន៍របស់ពលករ ជាពិសេសជួយដល់ពលរដ្ឋក្រីក្រដែលគ្មានទីពឹង ឱ្យរួចផុតពីការកេងប្រវ័ញ្ចលើកម្លាំងរបស់ពលករ។ លោកប្រាប់ថា លោកបានចំណាយពេលវេលា និងថវិកាផ្ទាល់ខ្លួនធ្វើការងារមនុស្សធម៌មួយនេះ ប្រមាណ៥ឆ្នាំមកហើយ ដោយមិនទទួលបានប្រាក់កម្រៃអ្វីឡើយ។ លោកថា យ៉ាងហោចណាស់មានពលករខ្មែរប្រហែល១០ករណីក្នុងមួយឆ្នាំទទួលបានយុត្តិធម៌ បន្ទាប់ពីលោកអន្តរាគមន៍ផ្លូវច្បាប់ដល់ពួកគេ ក្នុងនោះករណីចុងក្រោយកាលពីខែធ្នូកន្លងទៅ លោកបានជួយពលករខ្មែរមួយគ្រួសារ ទទួលបានយុត្តិធម៌ពីថៅកែ៖ «យើងជួយទាំងអ្នកស្របច្បាប់ និងអ្នកខុសច្បាប់ ប្រសិនបើពលករខុសច្បាប់ហ្នឹងរងការរំលោភបំពានជិះជាន់កេងប្រវ័ញ្ចកម្លាំង រហូតដល់ប្រើអំពើហិង្សា អាហ្នឹងក៏យើងជួយដែរ។ បើយើងមិនធ្វើទេយើងអាណិតជាតិសាសន៍យើងដែលមកស្រុកគេ ត្រូវគេជិះជាន់គេធ្វើបាបហើយមិនសូវមានអ្នកយកចិត្តទុកដាក់។ យើងធ្វើទៅដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋយើងផង ដើម្បីប្រយោជន៍ប្រទេសទាំងពីរផង។ ព្រោះថា បើសិនជាអ្នកឯងយកជនជាតិខ្ញុំមកជិះជាន់ធ្វើបាបកេងប្រវ័ញ្ចកម្លាំងពលកម្មអីចឹងគឺវា អត់ត្រឹមត្រូវតាមច្បាប់របស់ប្រទេសអ្នកឯង ហើយរំលោភមនុស្សពលករចំណាកស្រុក»។ លោក ប្រាក់ ភត្រា ថា អំពាវនាវដល់ពលករខ្មែរទាំងអស់ឱ្យក្លាហ៊ានប្ដឹងរកយុត្តិធម៌ ប្រសិនថៅកែរបស់ពួកគេ រំលោភបំពានសិទ្ធិការងារ ឬប្រើហិង្សាមកលើពួកគេក្នុងពេលធ្វើការនៅប្រទេសថៃ។លោកថា ការធ្វើបែបនេះ ដើម្បីកុំឱ្យថៅកែថៃចេះតែវាយធ្វើបាបពលករខ្មែរតាមអំពើចិត្តបន្តទៀត។

ពលករខ្មែរម្នាក់មានស្រុកកំណើតនៅខេត្តបាត់ដំបង លោក រេត កញ្ញា ថ្លែងថា លោក ប្រាក់ ភត្រា គឺជាកូនខ្មែរម្នាក់ចិត្តល្អកម្ររកបាន ដោយលះបង់ក្ដីសុខផ្ទាល់ខ្លួន ធ្វើការដើម្បីប្រយោជន៍របស់ពលករខ្មែរ។ ពលករវ័យ៣២ឆ្នាំរូបនេះបន្ថែមថា យុវជនខ្មែររូបនេះ បានជួយរកយុត្តិធម៌ឱ្យលោកនិងក្រុមគ្រួសារឱ្យទទួលបានលិខិតឆ្លងដែនពីថៅកែជនជាតិថៃមកវិញ កាលពីដើមខែធ្នូកន្លងទៅ។លោកបន្តថា គ្រានោះថៅកែថៃបានកាន់កាំភ្លើងខ្លីមួយដើមគំរាមបាញ់លោកស្លាប់ក្នុងពេលធ្វើការនៅខេត្តប្រាជីនបូរី ( Pra Chinbori ) ដោយសារតែលោកសុំអនុញ្ញាតថៅកែត្រឡប់ទៅកម្ពុជា ប៉ុន្តែថៅកែរូបនោះមិនឱ្យលោកទៅនោះទេ ដោយចោទប្រកាន់ពួកលោកថា ជំពាក់ប្រាក់ថ្លៃធ្វើ

លិខិតឆ្លងដែនមិនទាន់សង្សរួចនៅឡើយ។ លោក វេត កញ្ញា ឱ្យដឹងថា រឿងនេះ ប្រសិនលោក ប្រាក់ ភត្រា មិនបានជួយអន្តរាគមន៍លោកទេ នោះថៅកែថៃនឹងមិនប្រគល់លិខិតឆ្លងដែនឱ្យលោកវិញឡើយ ហើយអាចនឹងតាមធ្វើបាបលោក និងពលករខ្មែរដទៃទៀតដែលធ្វើការជាមួយថៅកែរូបនោះជាមិនខានឡើយ៖ «ខ្ញុំសរសើរទឹកចិត្តគាត់ បានជួយខ្ញុំ ហើយគាត់ទិញបាយទិញទឹកឱ្យខ្ញុំហូប គាត់ដឹងថា ខ្ញុំអត់មានលុយមានកាក់ មានន័យថា ខ្មែរជួយ។ បើសិនថាគាត់មិនជួយខ្ញុំមិនសង្ឃឹមថា បានលិខិតឆ្លងមកវិញទេ។ ហើយគាត់ជួយលើកទឹកខ្ញុំរហូត គាត់ប្រាប់ខ្ញុំថា មិនបាច់ភ័យអីទេ គេមកជួយយើង ឱ្យយើងបានលិខិតឆ្លងដែនវិញ។ កាលពីដំបូងខ្ញុំភ័យព្រួយដែរ ខ្ញុំគិតថា ទៅផ្ទះតែខ្ញុំអត់មានលុយទៅផ្ទះ»។ ពលកររូបនេះឱ្យដឹងថា មូលហេតុដែលលោកនិងពលករខ្មែរជាច្រើននាក់ទៀតមិនហ៊ានប្ដឹងថៅកែថៃ ដោយសារពួកគេគ្មានទីពឹងផ្នែកច្បាប់ និងខ្លាចចាញ់ក្ដីនៅតុលាការហើយអាជ្ញាធរថៃអាចនឹងចាប់ដាក់គុកនាំឱ្យប៉ះពាល់ដល់ជីវភាពគ្រួសារ។

ដូចគ្នានេះដែរពលករខ្មែរម្នាក់ទៀត លោក សែង ឌឿន ឱ្យដឹងថា លោកមកធ្វើការនៅប្រទេសថៃជិត១០ឆ្នាំហើយ តែងជួបបញ្ហាជាច្រើន ក៏ប៉ុន្តែលោកមិនហ៊ានប្ដឹងឱ្យរកយុត្តិធម៌នោះទេ ព្រោះខ្លាចដំណើរការក្ដីមិនឈ្នះនាំឱ្យមានបញ្ហាដល់ខ្លួន។ ពលកររូបនេះប្រាប់ថា លោក ប្រាក់ ភត្រា គឺជាមនុស្សដំបូងដែលបានជួយអន្តរាគមន៍ឱ្យលោកអាចធ្វើលិខិតស្នាមដឹកសាកសពពលករខ្មែរម្នាក់បានស្លាប់នៅប្រទេសថៃ ត្រឡប់ទៅធ្វើបុណ្យនៅកម្ពុជាវិញបាន។ លោកបន្តថា កាលពីខែតុលាកន្លងទៅប្រសិនបើលោក ប្រាក់ ភត្រា មិនបានជួយគាត់ទេនោះ លោកនឹងមិនអាចដឹកសពទៅកម្ពុជាបានឡើយ ។ លោកចាត់ទុក បុរសខ្មែររូបនេះថា ជាមនុស្សចិត្តធម៌កម្ររកបាន ព្រោះធ្វើការដើម្បីប្រយោជន៍របស់ពលរដ្ឋខ្មែរពិតប្រាកដ៖ «ខ្ញុំក៏មិននឹកស្មានថា មានមនុស្សចិត្តល្អអីចឹងទេ បង ភត្រា ជាមនុស្ស គួរឱ្យយកគំរូ ព្រោះគាត់មានចិត្តសប្បុរសធម៌ ពេលដែលខ្មែរមានទុក្ខលំបាកអីចឹងគាត់ជួយ។ ខ្ញុំចេះតែឆ្ងល់ដែរមិនដឹងថា គាត់ធ្វើការផ្នែកអីដែរ ខ្ញុំចង់បានណាស់មនុស្សបែបហ្នឹងនៅក្នុងសង្គម មូលហេតុ គាត់ជាមនុស្សមានចិត្តសប្បុរសដែលអាចជួយខ្មែរបានច្រើន។ ពលករខ្មែរភាគច្រើនមិនដឹងថា ទៅរកអ្នកណាគេឱ្យមកជួយបានទេ»។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ដើម្បីសុំអត្ថាធិប្បាយជុំវិញសកម្មភាពរបស់ពលករខ្មែរនេះបានទេនៅថ្ងៃទី៣ មករា ដោយទូរស័ព្ទជាច្រើនដងពុំមានអ្នកទទួល។

របាយការណ៍របស់អង្គការសង់ត្រាល់ (CENTRAL) ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការស្របច្បាប់ និងមិនស្របច្បាប់ប្រមាណ ពី ១លាន ៨សែននាក់ ទៅ ២លាននាក់ ធ្វើការនៅប្រទេសថៃ។

ពលករខ្មែរលោក ប្រាក់ ភត្រា មានបំណងរកមូលនិធិដើម្បីពង្រីកការងាររបស់លោកជួយពលករខ្មែរឱ្យបានច្រើនបន្ថែមទៀតទៅថ្ងៃអនាគត៕

## ថ្ងៃទី០៦ ខែ មករា ឆ្នាំ២០២១

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៦នាក់

https://www.facebook.com/tvkchannel7/ 05-01-2021

ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអង្គារ ទី០៥ ខែមករា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៦នាក់ ស្រី ២៥នាក់ ក្នុងនោះកុមារា ៥នាក់ កុមារី ៥នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ១នាក់ កុមារី ០០នាក់។
2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១០នាក់ ស្រី ៥នាក់ កុមារា ២នាក់ កុមារី ២នាក់។
3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៧នាក់ ស្រី ៨នាក់ កុមារា ១នាក់ កុមារី ៣នាក់។
4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣៦នាក់ ស្រី ១១នាក់ កុមារា ១នាក់ ។
5- សម្រាប់ច្រកអន្តរជាតិដូង÷ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ១នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក នៅវិទ្យាល័យកូប ១០នាក់, នៅសាលាវិទ្យាល័យម៉ាឡៃ ១៧នាក់, នៅវិទ្យាល័យខេត្តឧត្តរមានជ័យចំនួន ៣៦នាក់ និងអនុវិទ្យាល័យបឹងរាំងចំនួន ៣នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ប្រភព: រដ្ឋបាលខេត្តសៀមរាប

## ៧៦នាក់ ឆ្លងដែនខុសច្បាប់ នៅបន្ទាយមានជ័យ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២១ ម៉ោង ១៩:០៨ សុខ សារ៉ាយ

ខេត្តបន្ទាយមានជ័យ៖ លោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២១ បានអញ្ជើញប្រជុំផ្សព្វផ្សាយផែនការដល់មេបញ្ជាការកម្លាំងអន្តរាគមន៍ តាមបណ្តាលគោលដៅរបស់កងពល ត្រូវសហការជាមួយកម្លាំងចម្រុះ និងអាជ្ញាធរមូលដ្ឋាន ដែលកំពុងឈរជើង និងល្បាតតាមព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺឆ្លងកូវីដ-១៩ ។ ក្នុងឱកាសនោះ លោកមេបញ្ជាការ បានដាក់បទបញ្ជាដល់កងកម្លាំងគ្រប់បណ្តាគោលដៅ ត្រូវយកចិត្តទុកដាក់ ល្បាតត្រួតពិនិត្យ ២៤ម៉ោង លើ ២៤ម៉ោង មិនឲ្យមានប្រជាពលរដ្ឋឆ្លងដែនខុសច្បាប់ដាច់ខាត នៅគ្រប់បណ្តាគោលដៅ ដែលបានកំណត់។

សូមបញ្ជាក់ថា ទោះបីមានការអំពាវនាវរបស់ប្រមុខរាជរដ្ឋាភិបាល ចំពោះពលករខ្មែរ ដែលវិលត្រលប់មកពីប្រទេសថៃ តាមច្រកព្រំដែន ដែលបានកំណត់យ៉ាងណាក៏ដោយ ក៏មានប្រជាពលរដ្ឋមួយចំនួន នៅតែបន្តលួចឆ្លងដោយខុសច្បាប់ ចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ គិតមកដល់ថ្ងៃទី៣ ខែមករា ឆ្នាំ២០២១ កម្លាំងអន្តរាគមន៍របស់កងពលតូចថ្មើរជើងលេខ៥១ សហការជាមួយកម្លាំងចម្រុះ បានឃាត់ខ្លួនប្រជាពលរដ្ឋប្រុសស្រីសរុប ៧៦នាក់ និងបានបញ្ជូនពួកគាត់ ទៅមន្ត្រីជំនាញ ដើម្បីធ្វើការត្រួតពិនិត្យ និងធ្វើចត្តាឡីស័ក។

លោកមេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ សូមអរគុណចំពោះថ្នាក់ដឹកនាំ អាជីវករ និងប្រជាពលរដ្ឋនៅជិតព្រំដែន ដែលតែងតែយកចិត្តទុកដាក់ និងលើកទឹកចិត្ត ដល់កងកម្លាំង បាននាំយកនូវគ្រឿងឧបភោគបរិភោគ ម៉ាស់ អាល់កុល និងជែល សម្រាប់កងកម្លាំង កំពុងប្រតិបត្តិការ ដើម្បីការពារប្រជាជន និងជាតិមាតុភូមិ៕ ដោយ៖ សុខ សារ៉ាយ

## ឃាត់ខ្លួនពលរដ្ឋ ៥ នាក់ ឆ្លងដែលចូលថៃ ដើម្បីកាប់ឈើគ្រញូង

https://www.rasmeinews.com/ 5 January, 2021

*ដោយ: បាយ័ន / បាត់ដំបង: នៅវេលាម៉ោង ១៤និង១៥ នាទីរសៀល ថ្ងៃទី៥ ខែមករា ឆ្នាំ២០២១ នេះ កម្លាំងប៉ុស្តិ៍ច្រកទ្វាតំបន់ ៤០០ ដឹកនាំដោយលោក វរសេនីយ៍ត្រី ម៉ី ណាន់ នាយប៉ុស្តិ៍ច្រកទ្វារតំបន់ ៤០០ បានសហការជាមួយ កម្លាំងយោធានៅជួរមុខ បានឃាត់ខ្លួនពលរដ្ឋ ចំនួន៥នាក់ នៅចំណុចផ្ទះខៀវ ខាងក្រោយដីលោកសេរី កុសល ក្នុងស្រុកសំឡូត ខេត្តបាត់ដំបង ដែលពួកលួចឆ្លងដែន ចូលទៅប្រទេសថៃ កាប់ឈើគ្រញូង*។ ពលរដ្ឋទាំង ៥ នាក់នោះ ជាមនុស្សប្រុសទាំងអស់ រួមមាន: ១.ឈ្មោះ ញឹន ទូន អាយុ២៧ឆ្នាំ , ២.ឈ្មោះ ហាន់ វៃ អាយុ

៤០ឆ្នាំ , ៣.ឈ្មោះ ជ័យ រីន អាយុ៣០ឆ្នាំ, ៤.ឈ្មោះ ធន ញ៉ាញ់ អាយុ២០ឆ្នាំ និង៥.ឈ្មោះ ឈឿន ធុង អាយុ៤០ឆ្នាំ។ អ្នកទាំង ៥ នាក់ រស់នៅភូមិស្រែអណ្តូង ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង៕/V

## ពលករខ្មែរចំនួន១០៦នាក់ដែលឆ្លងកូវីដ-១៩ត្រូវបានយកចិត្តទុកដាក់ព្យាបាលពីភាគីថៃ

https://www.information.gov.kh/ ថ្ងៃទី 6 ខែ មករា ឆ្នាំ 2021 វិទ្យុជាតិកម្ពុជា៖អត្ថបទ លោក ភី សុខ

បាត់ដំបង៖ មន្ត្រីមន្ទីរសុខាភិបាលខេត្តបាត់ដំបងបានឱ្យដឹងថា ប្រជាពលរដ្ឋខ្មែរ ដែលធ្វើការនៅប្រទេសថៃ គិតត្រឹមថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ មានចំនួន ១០៦នាក់ បានរកឃើញមាន ឆ្លងជំងឺកូវីដ-១៩ កំពុងត្រូវបានយកចិត្តទុកដាក់ព្យាបាលពីមន្ត្រីសុខាភិបាលថៃ ។

លោក វេជ្ជបណ្ឌិត អ៊ុក វិទ្យា អនុប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង បានមានប្រសាសន៍ណែនាំប្រជាពលរដ្ឋខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃថា ស្របពេលដែលប្រទេសថៃកំពុងផ្ទុះជំងឺកូវីដ-១៩ រីករាលដាលដូច្នេះ សូមពលករខ្មែរកុំជ្រួលច្របល់ វិលត្រឡប់មកស្រុកវិញ ពោលគឺធ្វើការនៅទីណា សូមនៅទីនោះសិន ព្រោះប្រទេសថៃ ក៏មានកន្លែងធ្វើចត្តាឡីស័ក និង ពិនិត្យព្យាបាលជំងឺកូវីដ-១៩ គ្រប់គ្រាន់ ដោយមិនគិតលុយដែរ ។ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា បើសិនជាបានវិលត្រឡប់មកវិញ តាមច្រករបៀងក្តី តាមច្រកផ្លូវកាត់ក្តី សូមស្ម័គ្រចិត្តចូលខ្លួនមកធ្វើចត្តាឡីស័ក១៤ថ្ងៃសិន មុនចូលទៅកាន់សហគមន៍ និង បើចូលដល់សហគមន៍ហើយ សាមីខ្លួន សាច់ញាតិ ឬ អ្នកជិតខាង សូមរាយការណ៍ ជាបន្ទាន់មកកាន់អាជ្ញាធរមូលដ្ឋាន ឱ្យបានដឹង ដើម្បីបញ្ជូនមកធ្វើចត្តាឡីស័ក១៤ថ្ងៃ ឬ ធ្វើចត្តាឡីស័ក នៅផ្ទះផ្ទាល់ដោយគោរពទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល។ លោកវេជ្ជបណ្ឌិតមានប្រសាសន៍នេះក្នុងពេលចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ តាមវិទ្យុជាតិចំការចេក នាថ្ងៃទី៥ ខែមករា ឆ្នាំ២០២០ នេះ ។

លោក រឿង ប៊ុនរ៉េត ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង បានបញ្ជាក់បន្ថែមថា បច្ចុប្បន្ននេះ សភាពការណ៍គ្រប់គ្រងពលករត្រឡប់មកពីប្រទេសថៃ គឺអាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ និងមន្ត្រីសុខាភិបាល គ្រប់គ្រងបានល្អហើយ ពុំមានធ្លាយចូលសហគមន៍ ដោយពុំទាន់ ធ្វើចត្តាឡីស័កនោះទេ។ ទោះបីយ៉ាងណា លោកចង់ឱ្យពលរដ្ឋចូលរួមបន្ថែមទៀត គឺពលរដ្ឋទាំងអស់ត្រូវក្លាយ ជាភ្នាក់ងារផ្តល់ព័ត៌មានទៅកាន់អាជ្ញាធរមូលដ្ឋាន នៅពេលពិនិត្យឃើញថាមានពលករ ទើបត្រឡប់ មកពីប្រទេសថៃចូលសហគមន៍ ឬ សង្ស័យ មានការកើតជំងឺកូវីដ-១៩ នៅសហគមន៍របស់ខ្លួន ។ លោករឿង ប៊ុនរ៉េត បញ្ជាក់ថា ពលករត្រឡប់មកពីប្រទេសថៃ តាមច្រកព្រំដែនខេត្តបាត់ដំបង គឺកម្រិតធម្មតាពុំមានគំហុកនោះទេ គឺចន្លោះពី ២០ ទៅ៥០នាក់ ពេលខ្លះ ១០០ ទៅ១០០នាក់ ជាង ក្នុងមួយថ្ងៃ។

តួលេខសរុប ពលករដែលត្រឡប់មកពីប្រទេសថៃ គិតត្រឹមព្រឹកថ្ងៃទី០៥ មករានេះ មានចំនួន ១៨១៥នាក់ ស្រី ៧៥៤នាក់ ក្នុងនោះបានយកសំណាក ១៤៨៩នាក់ ស្រី៦២២នាក់ រកឃើញអ្នកវិជ្ជមានកូវីដ-១៩ ៦នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តបាត់ដំបង(ពេទ្យធំ ) នៅសល់ ពលករ១៤២៤ នាក់ មានស្រី ៥៩២នាក់ ទៀតមិនទាន់យកសំណាកនៅឡើយ ៕

## មន្ត្រីសុខាភិបាល អះអាងថា គ្មានការចល័តពលករខ្មែរមកពីថៃ ទៅខេត្តផ្សេងៗ នោះទេ

http://btv.com.kh/ 05/01/2021

ភ្នំពេញ ៖ មន្ត្រីជាន់ខ្ពស់ក្រសួងសុខាភិបាល បានអះអាងថា គ្មានការចល័តពលករខ្មែរ ឆ្លងដែនមកពីប្រទេសថៃ ទៅខេត្តផ្សេងៗនោះទេ គឺពួកគេ ត្រូវបានតម្រូវឱ្យធ្វើចត្តាឡីស័កនៅតំបន់ព្រំដែន ហើយបើពិនិត្យឃើញថាមានវិជ្ជមានកូវីដ–១៩ មន្ត្រីសុខាភិបាល នឹងព្យាបាលពួកគេនៅមន្ទីរពេទ្យ ដែលនៅជាប់ព្រំដែនតែម្តង។

លោកជំទាវវេជ្ជបណ្ឌិត យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាល បានបញ្ជាក់ប្រាប់ BTV នៅថ្ងៃនេះថា មកទល់ពេលនេះ ពលករខ្មែរមកពីប្រទេសថៃ ចំនួនជាង១០នាក់ ដែលត្រូវបានរកឃើញថា វិជ្ជមានកូវីដ–១៩ កំពុងត្រូវបានដាក់ឱ្យសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យខេត្តប៉ៃលិន និងនៅក្នុងមន្ទីរពេទ្យខេត្តបាត់ដំបង ។ បច្ចុប្បន្ននេះ ក្រសួងសុខាភិបាល មានក្រុមគ្រូពេទ្យជំនាញ និងបទពិសោធន៍ខ្ពស់ ក្នុងការពិនិត្យ ព្យាបាលអ្នកជំងឺកូវីដ–១៩ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលកំពុងធ្វើការនៅក្នុង មន្ទីរពេទ្យខេត្តប៉ៃលិន ជាមួយនឹងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃក្រសួងសុខាភិបាល ដែលមានលោក វេជ្ជបណ្ឌិត លី សុវណ្ណ កំពុងដឹកនាំការងារនៅទីនោះផ្ទាល់។ លោកជំទាវ បានឱ្យដឹងថា ឯកឧត្តម សាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក៏បាន ដឹកនាំគណៈប្រតិភូពិនិត្យមើលស្ថានភាពតាមព្រំដែនខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ និងធ្វើការជាមួយអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ ដើម្បីទទួលពលករមកធ្វើចត្តាឡីស័ក។

លោកជំទាវ បានបញ្ជាក់ទៀតថា ក្រោមការគ្រប់គ្រង និងបញ្ជាផ្ទាល់របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានគ្រប់គ្រង និងទប់ស្កាត់ការឆ្លងរីករាលដាលកូវីដ–១៩ បានទាន់ពេលវេលា។ ប្រជាពលរដ្ឋទាំងអស់ បានដឹងហើយថា ព្រឹត្តិការណ៍«សហគមន៍ ២៨ វិច្ឆិកា» ត្រូវបាន គ្រប់គ្រងទាំងស្រុង និងមួយរយៈពេលចុងក្រោយនេះ មានករណីកូវីដ–១៩ ផ្ទុះនៅក្នុងខេត្តសាមុតសាខន និងស្រុកមួយចំនួនទៀត នៅប្រទេសថៃ។ ក្រសួងសុខាភិបាល កំពុងខិតខំគ្រប់គ្រងសភាពការណ៍នៅក្នុង ខេត្តដែលជាប់ព្រំដែនថៃ រួមមានខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តពោធិ៍សាត់ និងខេត្តកោះកុង ដែលមានពលករចូលទៅធ្វើការនៅថៃនោះ៕ អត្ថបទ ៖ រដ្ឋា

## ករណីវិជ្ជមានកូវីដ-១៩ មួយទៀត ដែលជាករណីទី១៨ ក្នុងចំណោមពលករមកពីថៃ

https://thmeythmey.com/ 06, Jan 2021 , 7:07 am

បុរសអាយុ២៨ឆ្នាំ ម្នាក់ ដែលមានអាសយដ្ឋាននៅឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ មានកូវីដ-១៩ ដែលជាករណីទី១៨ក្នុងចំណោមពលករមកថៃ ខណៈ១៧នាក់កន្លងមកសុទ្ធតែជាស្ត្រី។ តាមក្រសួងសុខាភិបាល បុរសនោះមកដល់កម្ពុជានៅថ្ងៃទី២ ខែមករា ដោយបច្ចុប្បន្នសម្រាកព្យាបាលនៅពេទ្យបង្អែកខេត្តប៉ៃលិន។ គិតត្រឹមថ្ងៃពុធនេះ ករណីកូវីដ-១៩នៅកម្ពុជា មាន៣៨៣នាក់ ដោយ៣៦២នាក់បានជាសះស្បើយ។ ករណីនាំចូល២ និង១ទៀតពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍២៨វិច្ឆិកា បន្តសម្រាកព្យាបាលនៅភ្នំពេញ ខណៈពលករពីថៃ ១២នាក់ព្យាបាលនៅមន្ទីរពេទ្យបង្អែកប៉ៃលិន និង៦នាក់នៅមន្ទីរពេទ្យបង្អែកបាត់ដំបង៕

# ពលករខ្មែរប្រមាណ ៥ ពាន់នាក់ បានសម្រុកចេញពីថៃ ដោយសារខ្លាចឆ្លងកូវីដ ១៩ ដែលផ្ទុះនៅប្រទេសនេះ

https://www.postkhmer.com/

**ភ្នំពេញៈ** ពលករខ្មែរប្រមាណ ៥ ពាន់នាក់ បានសម្រុកចេញពីប្រទេសថៃ តាមច្រកនានានៅតាមបណ្ដោយព្រំដែននៃប្រទេសទាំង ២ ក្នុងរយៈពេលប្រមាណជាង ១០ ថ្ងៃ ក្រោយពីផ្ទុះរីករាលដាលនូវវីរុសកូវីដ ១៩ ក្នុងខេត្តសាមុតសាខន ដោយហេតុពួកគេមានក្ដីកង្វល់អំពីការឆ្លងមេរោគនេះ។ អាជ្ញាធរកម្ពុជានៅតាមខេត្តជាប់បណ្ដោយព្រំដែននៅតែបន្តចំណាត់ការ និងវិធានការចម្បងៗរបស់ខ្លួនក្នុងការការពារ និងអនុវត្តនូវបទបញ្ជារបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលដោយប្រកាន់ខ្ជាប់នូវការណែនាំ និងដាក់ពលករដែលទើបបានឆ្លងមកពីប្រទេសថៃធ្វើចត្តាឡីស័កយ៉ាងត្រឹមត្រូវចំនួន ១៤ ថ្ងៃ។ គិតចាប់ពីថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២០ រហូតដល់ពេលនេះពលករខ្លះត្រូវបានអនុញ្ញាតឱ្យចាកចេញពីមណ្ឌលចត្តាឡីស័ក បន្ទាប់ពីការធ្វើចត្តាឡីស័កគ្រប់ ១៤ ថ្ងៃ និងការធ្វើតេស្តសំណាកលើកទី ២ របស់ពួកគេមិនមានវិជ្ជមានកូវីដ ១៩។

លោក ឌី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យបានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ កាលពីម្សិលមិញថា ពលករខ្មែរប្រមាណជា ១ ៩០០ នាក់ បានវិលត្រឡប់មកពីប្រទេសថៃមកកាន់ខេត្តឧត្តរមានជ័យចាប់ពីថ្ងៃទី ២០ ខែធ្នូ រហូតមកដល់ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ហើយសំណាករបស់ពួកគាត់ត្រូវបានយកធ្វើតេស្តប៉ុន្តែសម្រាប់ខេត្តឧត្តរមានជ័យគឺមិនទាន់មានពលករណាម្នាក់មានវិជ្ជមានវីរុសកូវីដ ១៩ ទេ មកដល់ពេលនេះ។ លោកបានថ្លែងថា៖ «វិធានការចម្បងរបស់ខេត្តយើងគឺធ្វើការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋរបស់យើងយល់ គោរព និងអនុវត្តតាមវិធានរបស់ក្រសួងសុខាភិបាលដោយយើងត្រូវធ្វើយ៉ាងណានាំពលករដែលបានចូលមកដល់ក្នុងខេត្តយើងនេះ បានធ្វើចត្តាឡីស័កឱ្យគ្រប់ ១៤ ថ្ងៃ តាមមណ្ឌលចត្តាឡីស័កដែលយើងបានត្រៀមរួចស្រេច»។ លោក ឌី រ៉ាដូ បានបន្ថែមថា មណ្ឌលធ្វើចត្តាឡីស័កក្នុងខេត្តឧត្តរមានជ័យមានចំនួន ១៤ កន្លែង សម្រាប់ទទួលពលករមកពីប្រទេសថៃដោយក្នុងនោះអាជ្ញាធរខេត្តមានការរៀបចំនូវការផ្គត់ផ្គង់ម្ហូបអាហារ និងសម្ភារប្រើប្រាស់ដោយមិនឱ្យពួកគាត់មានការខ្វះខាតឡើយ។ លោកបានថ្លែងថា៖ «យើងបានប្រើប្រាស់ថវិកាដែលផ្តល់ដោយសម្ដេចតេជោ ហ៊ុន សែន ទៅលើពលករក្នុងពេលធ្វើចត្តាឡីស័កដោយមិនឱ្យពួកគាត់មានការបារម្ភពីការខ្វះខាតឡើយដូចជាអាហារ ៣ ពេល មុង ភួយ ខ្នើយ កន្ទេលរួមនឹងសាប៊ូជាដើម»។ លោក ឌី រ៉ាដូ បញ្ជាក់ថា ករណីមានពលករម្នាក់ដែលបានមកពីថៃហើយមិនបានធ្វើចត្តាឡីស័កត្រូវបាននាំខ្លួនគាត់ និងសមាជិកគ្រួសារចំនួន ៨ នាក់ផ្សេងទៀតមកធ្វើចត្តាឡីស័ករួចហើយកាលពីថ្ងៃអាទិត្យទី ០៣ ខែមករា។

ចំណែកលោក លី សារី អភិបាលរងខេត្តបន្ទាយមានជ័យក៏បានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ ម្សិលមិញដែរថា ជាង ២ សប្ដាហ៍កន្លងមកនេះ ពលករខ្មែរជាង ១ ០០០ នាក់ បានវិលត្រឡប់មកពីប្រទេសថៃចូលតាមខេត្តបន្ទាយមានជ័យនេះ ដោយក្នុងនោះពួកគាត់ត្រូវបានធ្វើចត្តាឡីស័កនៅតាមទីតាំងចំនួន ១២ យ៉ាងត្រឹមត្រូវតាមវិធានរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល។ លោកថា ថ្នាក់ដឹកនាំខេត្តបានណែនាំទៅដល់អាជ្ញាធរភូមិ ឃុំ-សង្កាត់ទាំងអស់ត្រូវធ្វើការគ្រប់គ្រង និងនាំពលករដែលចូលតាមច្រកខុសច្បាប់ដែលមិនបានធ្វើចត្តាឡីស័កត្រូវនាំមកពិនិត្យ និងធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ មិនឱ្យមានការធ្វេសប្រហែសឡើយ។ លោក លី សារី បានប្រាប់ថា៖ «ទោះបីជាខេត្តរបស់យើងមិនមានពលករណាម្នាក់ឆ្លងវីរុសកូវីដ ១៩ ក៏ដោយ ប៉ុន្តែយើងមិនទាន់អាចធ្វេសប្រហែស ឬបន្ធូរបន្ថយបានឡើយ។ យើងនៅតែបន្តការរឹតបន្តឹងចំពោះការត្រួតពិនិត្យ និងការដាក់ឱ្យធ្វើចត្តាឡីស័កផងដែរ។ សមត្ថកិច្ច និងមន្ត្រីសុខាភិបាលបានធ្វើការប្រចាំការរយៈពេល ២៤ ម៉ោងលើ ២៤ ម៉ោងនៅតាមច្រកព្រំដែនសំខាន់ៗ និងច្រករបៀងទាំងអស់នៅក្នុងខេត្តរបស់យើង»។ លោកអភិបាលរងខេត្តរូបនេះបានបន្ថែមថា លើសពីនេះអាជ្ញាធរខេត្ត

បន្ទាយមានជ័យបានសហការជាមួយនឹងអាជ្ញាធរថៃដើម្បីធ្វើការផ្សព្វផ្សាយដល់ពលករពីការការពារ និងទប់ស្កាត់ការឆ្លងនូវជំងឺនេះ។

បើតាមអាជ្ញាធរខេត្តបាត់ដំបងចាប់តាំងពីមានការផ្ទុះវីរុសកូវីដ ១៩ ចូលក្នុងសហគមន៍ក្នុងប្រទេសថៃ មកមានពលករខ្មែរដែលបានវិលត្រឡប់ពីថៃមកវិញឆ្លងតាមខេត្តបាត់ដំបងគិតត្រឹមថ្ងៃម្សិលមិញគឺមានចំនួន ១ ៨១៥ នាក់ ហើយក្នុងចំណោមនោះមានពលករចំនួន ៦ នាក់ ត្រូវបានរកឃើញមានវីរុសកូវីដ ១៩។ លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបងបានថ្លែងថា៖ «វិធានអាទិភាពរបស់ខេត្តយើងគឺនៅតែគោរពតាមការណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី និងពង្រឹងការធ្វើចត្តាឡីស័កចំនួន ១៤ ថ្ងៃ ដល់គ្រប់ពលករទាំងអស់ដោយមិនឱ្យមានអ្នកណាម្នាក់ទៅគេហដ្ឋានដោយមិនបានធ្វើនោះទេ»។ លោកបានបញ្ជាក់ថាសម្រាប់ខេត្តបាត់ដំបងមានមណ្ឌលចត្តាឡីស័កចំនួន ៧ កន្លែង។ លោក ងួន រតនៈ បានបន្តថា មានពលករខ្លះកំពុងរង់ចាំលទ្ធផលតេស្តលើកទី២ របស់ខ្លួនដោយសារពួកគាត់គ្រប់ចំនួន ១៤ ថ្ងៃ នៃការធ្វើចត្តាឡីស័ក។ លោកថ្លែងថា៖ «ប្រសិនបើពួកគាត់លទ្ធផលអវិជ្ជមាននោះ អាជ្ញាធរនឹងអនុញ្ញាតបញ្ជូនពួកគាត់ទៅតាមគេហដ្ឋានវិញ»។

នៅខាងខេត្តព្រះវិហារវិញ ពលករដែលបានធ្វើចត្តាឡីស័កគ្រប់ចំនួន ១៤ ថ្ងៃ និងធ្វើតេស្តសំណាកលើកទី២ មិនមានវីរុសកូវីដ ១៩ ត្រូវបានអាជ្ញាធរអនុញ្ញាតឱ្យត្រឡប់ទៅកាន់គេហដ្ឋានវិញជាបណ្តើរៗហើយបើតាមលោក គង់ ឡូ ប្រធានមន្ទីរសុខាភិបាលខេត្តបានឱ្យដឹងថា មានពលករប្រមាណ ១០ នាក់ទៀតប៉ុណ្ណោះ ដែលនៅធ្វើចត្តាឡីស័ក។

យោងតាមក្រសួងសុខាភិបាលបានឱ្យដឹងថា នៅថ្ងៃទី ៣ ខែមករា ពលការិនី អាយុ ២១ ឆ្នាំ ស្នាក់នៅភូមិកូនភ្នំ ឃុំអណ្តូង ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ដែលបានធ្វើដំណើរមកពីប្រទេសថៃ មកដល់កម្ពុជាថ្ងៃទី ១ ខែមករា និងបានធ្វើតេស្តវិជ្ជមានកូវីដ ១៩ ត្រូវបានដាក់សម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន។ គិតត្រឹមថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ កម្ពុជាមានអ្នកមាន វីរុសកូវីដ ១៩ ចំនួន ៣៨២ នាក់ ក្នុងនោះព្យាបាលជាសះស្បើយចំនួន ៣៦២ នាក់ និងអ្នកជំងឺកំពុងសម្រាកព្យាបាលមានចំនួន ២០ នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ១៣ នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial/ 05-01-2021

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៧ និង៣៥នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៣ នាក់ ស្រី ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ០៦នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ 05-01-2021

កោះកុង៖ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៧និង១៥នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៦នាក់នេះ មាន ១-ឈ្មោះ សឹង កញ្ញា ភេទស្រី អាយុ ២៥ឆ្នាំ នៅភូមិបឹងត្រាញ់ ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ, ២-ឈ្មោះ នុត សាអែម ប្រុស អាយុ ២៨ឆ្នាំ នៅភូមិត្រពាំងជ័រ ឃុំម្រាម ស្រុករមាសហែក ខេត្តស្វាយរៀង, ៣-ឈ្មោះ ហេង ហួយ ប្រុស អាយុ ២៥ឆ្នាំ នៅភូមិល្បើកឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប, ៤-ឈ្មោះ តាន់ សុន ភេទប្រុស អាយុ ៣០ឆ្នាំ នៅភូមិស្វាយពុល ឃុំព្រៃក្រឡាញ់តូច ស្រុកព្រៃក្រឡាញ់ ខេត្តព្រៃវែង, ៥-ឈ្មោះ ធឹម ធីម ភេទប្រុស អាយុ ៣៩ឆ្នាំ, ៦-ឈ្មោះ វង្ស កុយ ភេទប្រុស អាយុ ៣០ឆ្នាំ នៅភូមិស្នួល ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។

ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៧៥នាក់

https://www.facebook.com/GDIOfficial/ 05-01-2021

ឧត្តរមានជ័យ៖ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៥នាក់ ស្រី ២៣នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអាជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងបានទទួលពលរដ្ឋខ្មែរចំនួន ២៤នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

## ឃាត់ខ្លួនពលករខ្មែរ០៤នាក់ ឆ្លងដែនចូលប្រទេសកម្ពុជាដោយខុសច្បាប់

https://www.facebook.com/GDIOfficial/ 04-01-2021

កោះកុង៖ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៥និង០៥នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតក្នុងភូមិសាស្ត្រស្លាបស្ដាំ ពិនិត្យឃើញពលករខ្មែរឆ្លងដែនចូលប្រទេស ដោយខុសច្បាប់ចំនួន ០៤នាក់ ស្រី ០២នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ

ឈួន សុម៉ាលី ភេទប្រុស អាយុ ២៩ឆ្នាំ នៅភូមិតាព្រឹក ឃុំស្តេចគង់ ស្រុកបន្ទាយមាស ខេត្តកំពត, ២-ឈ្មោះ អ៊ុត ពៅ ភេទស្រី អាយុ ៣៧ឆ្នាំ នៅភូមិឈើទាល ឃុំឈូក ស្រុកឈូក ខេត្តកំពត, ៣-ឈ្មោះ ម៉ាប់ ចិន្តា ភេទស្រី អាយុ ៣០ឆ្នាំ, ៤-ឈ្មោះ សង ក្រិល ភេទប្រុស អាយុ ៣១ឆ្នាំ នៅភូមិដងទង់ ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តកំពត និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។

ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ១២៧នាក់

https://www.facebook.com/GDIOfficial/ 04-01-2021

ឧត្តរមានជ័យ៖ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៧នាក់ ស្រី ៥០នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់៕

## ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ០៤នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនមក តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ

https://www.facebook.com/GDIOfficial/ 04-01-2021

ប៉ៃលិន៖ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១០និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ បានទទួលពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៤នាក់ ស្រី ០៣នាក់។ ចំណែកឯពលរដ្ឋទាំងអស់នោះ កម្លាំងនគរបាលប៉ុស្តិ៍បានសហការជាមួយ ក្រុមការងារចត្តាឡីស័ក អប់រំណែនាំបញ្ជូនទៅធ្វើចត្តាឡីស័ក ១៤ថ្ងៃ នៅមន្ទីរសុខាភិបាលខេត្តប៉ៃលិន៕

## ថ្ងៃទី០៨ ខែ មករា ឆ្នាំ២០២១

## មន្ត្រីសុខាភិបាលខេត្តបាត់ដំបង អះអាងថា ការគ្រប់គ្រងសភាពការណ៍ពលករវិលមកពីថៃគឺបានល្អ

http://btv.com.kh/ 06/01/2021

បាត់ដំបង ៖ មន្ត្រីសុខាភិបាលខេត្តបាត់ដំបង បានអះអាងថា មកទល់ពេលនេះ ការគ្រប់គ្រងសភាពការណ៍នៃចល នាវិលត្រឡប់មកពីប្រទេសថៃ វិញរបស់ពលករខ្មែរ គឺបានល្អប្រសើរ មិនមានការឆ្លាយចូលក្នុងសហគមន៍នោះទេ។ តែទោះជាយ៉ាងណាក៏ដោយ មន្ត្រីសុខាភិបាលខេត្តបាត់ដំបង បានអំពាវនាវដល់ពលករទាំងអស់ នៅពេលមកពីថៃ ត្រូវស្ម័គ្រចិត្តចូលខ្លួនមកធ្វើចត្តាឡីស័ក១៤ថ្ងៃសិន មុនចូលទៅសហគមន៍ ទៅតាមការ ណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលមេរោគកូវីដ–១៩ ក្នុងសហគមន៍ ក្នុង ករណីប្រសិនបើពលករណាមួយបានឆ្លងមេរោគនេះ មកពីប្រទេសថៃនោះ។ មន្ត្រីសុខាភិបាល ក៏ស្នើឱ្យពលរដ្ឋទាំងអស់ត្រូវក្លាយជាភ្នាក់ងារផ្តល់ព័ត៌មានទៅអាជ្ញាធរមូលដ្ឋាន នៅពេលពិនិត្យឃើញថា មានពលករ ទើបត្រឡប់មកពីប្រទេសថៃ ចូលសហគមន៍ ឬសង្ស័យ មានកូវីដ–១៩ នៅក្នុងសហគមន៍របស់ខ្លួន ។

តាមការឱ្យដឹងពីមន្ត្រីសុខាភិបាល គឺមានពលករវិលមកពីថៃ តាមច្រកព្រំដែនខេត្តបាត់ដំបង ចន្លោះពី២០ទៅ១០០នាក់ក្នុងមួយថ្ងៃ ដែលជាកម្រិតធម្មតា មិនគំហុកនោះទេ ដែលជាសរុបគិតមកទល់ ពេលនេះ គឺមានពលករជិតពីរពាន់បានមកពីថៃ ក្នុងនោះបានយកសំណាកជិត១៥០០នាក់ ទៅធ្វើតេស្ត និងរកឃើញវិជ្ជមានកូវីដ–១៩ ចំនួន៦នាក់ ដែលកំពុងត្រូវបានព្យាបាលនៅមន្ទីរពេទ្យខេត្តបាត់ដំបង៕ អត្ថបទ៖ បាន សុខវិទ្ធ

## ខេត្តឧត្តរមានជ័យ និងខេត្តសុរិន្ទ ប្តេជ្ញារួមគ្នាលុបបំបាត់ការឆ្លងជំងឺកូវីដ-១៩ និងការលួចឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2021-01-06 04:30pm

**(ឧត្តរមានជ័យ)៖** លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ របស់កម្ពុជា និងលោក ស៊ុ វ៉ះផុង គិទិផាត់ភិប៊ូន អភិបាលខេត្តសុរិន្ទ របស់ថៃ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២១នេះ បានឯកភាពគ្នាបន្តកិច្ចសហប្រតិបត្តិការ លុបបំបាត់ជំងឺកូវីដ-១៩ ឆ្លងដែន និងបញ្ហាមួយចំនួនទៀត។ ការប្តេជ្ញាចិត្តរបស់អភិបាលខេត្តជាប់ព្រំដែន នៃប្រទេសទាំង២នេះ បានធ្វើឡើងក្នុងឱកាស ដែលលោកអភិបាលខេត្តឧត្តរមានជ័យ បានដឹកនាំក្រុមការងារនិងសមត្ថកិច្ចពាក់ព័ន្ធ អញ្ជើញជួបពិភាក្សាការងារ និងពង្រឹងចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការល្អជាមួយលោកអភិបាលខេត្តសុរិន្ទ របស់ថៃ នាបរិវេណមាត់ច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់-ឆងចម នារសៀលថ្ងៃទី៦ ខែមករា ឆ្នាំ២០២១នេះ។ កិច្ចពិភាក្សានេះភាគីកម្ពុជា និងភាគីថៃ បានឯកភាពបន្តរួមសហការគ្នាទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ឆ្លងដែន និងបន្តសហការសម្របសម្រួលដល់ការឆ្លងដែនចេញចូលការដឹកទំនិញមានលក្ខណៈពាណិជ្ជកម្ម និងស្របតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវនៃប្រទេសទាំងពីរ (ប្រគល់ឱ្យសមត្ថកិច្ចគយប្រចាំតំបន់ច្រកបន្តមុខការ)។

ជាមួយគ្នានោះ ភាគីទាំង២ ថៃមទាំងបានបន្តរួមគ្នាទប់ស្កាត់ការឆ្លងដែនខុសច្បាប់របស់ប្រជាពលរដ្ឋ ក៏ដូចជាបទល្មើសឆ្លងដែននានា និងបន្តទំនាក់ទំនង ផ្តល់ព័ត៌មានគ្នាទៅវិញទៅមកជាប់ជាប្រចាំផងដែរ៕

## លោក ហេង សួរ៖ យន្តការដែលថៃដាក់ចេញសម្រាប់ពលករបរទេសគឺជាយន្តការសមស្រប

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 06/01/2021 - 11:55 ដោយ៖ញឹម សុផល

រដ្ឋាភិបាលថៃបានប្រកាសច្បាប់ថ្មីមួយ ដោយអនុញ្ញាតឲ្យពលករចំណាកស្រុកខុសច្បាប់ មកពីប្រទេសឡាវ ភូមា និងកម្ពុជា ទៅចុះឈ្មោះទទួលប័ណ្ណស៊ីជម្ពូ ដើម្បីទទួលបានភាពស្របច្បាប់ក្នុងការធ្វើការងារ និងស្នាក់នៅក្នុងប្រទេសថៃរយៈពេល២ឆ្នាំ អំឡុងពេលដែលថៃកំពុងប្រយុទ្ធប្រឆាំងដ៏ខ្លាំងក្លានឹងជំងឺកូវីដ១៩ ។ លោក ហេង សួរ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារកម្ពុជាថ្លែងថា ចំណាត់ការរបស់អាជ្ញាធរថៃ ដែលផ្ដល់ភាពស្របច្បាប់ដល់ពលករចំណាកស្រុកបរទេស អាចស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃរយៈពេល២ឆ្នាំទៀត គឺជាចំណាត់ការដ៏សមស្រប និងស្របទៅតាមគោលបំណង ដែលក្រសួងការងារកម្ពុជាស្នើសុំ។

## ពលករខ្មែរ ១០៨នាក់នៅថៃ ឆ្លងកូវីដ-១៩

https://thmeythmey.com/ 07, Jan 2021 , 10:59 am

ភ្នំពេញ៖ ពលករខ្មែរ ដែលកំពុងរស់នៅប្រទេសថៃ ១០៨នាក់ ឆ្លងជំងឺកូវីដ-១៩ គិតត្រឹមព្រឹកថ្ងៃទី ៧ មករា ។ នេះបើតាមរបាយការណ៍ក្រសួងសុខាភិបាលថៃ។ របាយការណ៍ក្រសួងសុខាភិបាលថៃ បានបង្ហាញតួលេខថា ក្នុងចំណោមអ្នកឆ្លងកូវីដ-១៩ ជាង៩ពាន់នាក់ មានពលករខ្មែរ១០៨នាក់ ។ ក្រៅពីនោះ ក៏មានពលករមីយ៉ាន់ម៉ា ៦២៣នាក់ ឥណ្ឌា៨២នាក់ ថៃជាង៥ពាន់ និងសញ្ជាតិផ្សេងទៀតជាង១ពាន់នាក់។ របាយការណ៍ក្រសួងសុខាភិបាលថៃ ក៏មិនបានបញ្ជាក់ថា ពលករខ្មែរឆ្លងជំងឺកូវីដ-១៩ ពីតំបន់ណាដែរ។ សារព័ត៌មានថ្មីៗ មិនទាន់អាចទាក់ទងស្ថានទូតខ្មែរប្រចាំប្រទេសថៃ និងអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជុំវិញករណីឆ្លងជំងឺកូវីដ-១៩ នេះ បាននៅឡើយ។ ចំណែកអ្នកនាំពាក្យក្រសួងសុខាភិបាល លោកស្រី ឱ វណ្ណឌីន បានបញ្ជាក់ថា ក្រសួងមិនមានព័ត៌មានទាក់ទងនឹងករណីពលករខ្មែរឆ្លងកូវីដ-១៩ នៅប្រទេសថៃនេះដែរ។

តែយ៉ាងណាស្ថានទូតខ្មែរប្រចាំប្រទេសថៃ ក៏បានអំពាវនាវឲ្យនិស្សិត និងពលករខ្មែរ ដែលកំពុងសិក្សា និងធ្វើការនៅទីនោះ មានការប្រុងប្រយ័ត្ន និងការពារខ្លួនពីជំងឺកូវីដ-១៩នេះ។ ជាពិសេសសហការ និងអនុវត្តតាមបម្រាមរបស់អាជ្ញាធរថៃឲ្យបានត្រឹមត្រូវ។ រដ្ឋាភិបាលថៃ បានប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន ចាប់ពីថ្ងៃទី១៦ មករា ដល់២៨ កុម្ភៈ ខាងមុខ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នេះ។ ជុំវិញករណីផ្ទុះកូវីដ-១៩ នៅប្រទេសថៃនេះ នាំឲ្យពលករខ្មែរនៅទីនោះ សម្រុកមកកម្ពុជាវិញជាបន្តបន្ទាប់។ បើតាមរបាយការណ៍លោក កែវ វណ្ណថន អគ្គនាយករង និងជាអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ពលករខ្មែរ៤,៤១៥នាក់ហើយ បានត្រឡប់មកកម្ពុជាវិញ គិតត្រឹមថ្ងៃទី៦ មករា។ ក្រៅពីពលករខ្មែរសម្រុកមកវិញ ក៏មានពលរដ្ឋខ្មែរជិត២៤០នាក់ លួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃដែរ។ នេះបើតាមរបាយការណ៍ពីលោក កែវ វណ្ណថន ដដែល។

គិតត្រឹមថ្ងៃទី៧ មករា ក្រសួងសុខាភិបាល ក៏បានរកឃើញពលករខ្មែរ២០នាក់ហើយ ដែលត្រឡប់ពីប្រទេសថៃវិញ មានជំងឺកូវីដ-១៩ ។ ពួកគេទាំងនោះ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅតាមមណ្ឌលសុខភាពនានា ក្នុងខេត្តប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ។ បច្ចុប្បន្នកម្ពុជាមានអ្នកឆ្លងជំងឺកូវីដ-១៩ សរុប ៣៨៥នាក់ ដោយក្នុងនោះ មាន៣៦២នាក់បានជាសះស្បើយ ខណៈថៃ មានអ្នកឆ្លងជាង៩ពាន់នាក់ ជាសះស្បើយជាង៤ពាន់នាក់ និងស្លាប់៦៦នាក់៕

# ក្រសួងផែនការលើកទឹកចិត្តឲ្យពលករមកពីថៃ ស្នើសុំបណ្ណសមធម៌

https://www.postkhmer.com/ នៀម ឆេង | Publication date 07 January 2021 | 11:02 ICT

**ភ្នំពេញៈ** ក្រសួងផែនការលើកទឹកចិត្តឱ្យពលករដែលត្រឡប់មកពីប្រទេសថៃ វិញ ហើយមានជីវភាពខ្វះខាត ត្រូវដាក់ពាក្យស្នើសុំបណ្ណសមធម៌នៅអាជ្ញាធរមូលដ្ឋានរបស់ខ្លួន ប៉ុន្តែមានពលករតិចតួចប៉ុណ្ណោះ ដែលបានដាក់ពាក្យស្នើសុំបណ្ណនេះ បើទោះបីជាពលករជាច្រើនបានត្អូញត្អែរពីការខ្វះខាតខាងជីវភាពក៏ដោយ។ គិតចាប់ពីមានការផ្ទុះឡើងជំងឺកូវីដ ១៩ កាលពីដើមឆ្នាំ ២០២០ ពលករចំណាកស្រុកកម្ពុជាដែលធ្វើការនៅប្រទេសថៃជាង ១២ ម៉ឺននាក់ ក្នុងចំណោមពលករសរុបដែលមានជិត ១ លាន ២ សែននាក់ បានត្រឡប់មកកម្ពុជាវិញ និងប្រឈមនឹងការខ្វះខាតជីវភាព។

លោក ផន ចន្ថា អាយុ ៥១ ឆ្នាំ គឺជាកសិកររស់នៅភូមិធ្នាល់មាន់ ឃុំធ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ធ្លាប់បានធ្វើការនៅខេត្ត Pathum Thani ប្រទេសថៃអស់រយៈពេល ៤ ឆ្នាំ។ លោកបានធ្វើការជាអ្នកថែសួននៅក្រុមហ៊ុនលក់អចលនទ្រព្យមួយក្នុងខេត្តនេះរួមជាមួយនឹងគ្រួសារដែលមានកូន ២ នាក់។ នៅទីនោះលោកទទួលបានប្រាក់ខែទៀងទាត់ជាង ៤០០ ដុល្លារ ក្នុង ១ ខែ ដោយធ្វើការទាំងថ្ងៃទាំងយប់។ ប៉ុន្តែក្រោយពេលជំងឺកូវីដ ១៩ បានផ្ទុះឡើង នៅទូទាំងសកលលោករួមទាំងនៅប្រទេសថៃផងនោះលោក ចន្ថា មានការភ័យខ្លាចឆ្លងជំងឺនេះ ហើយក៏បានសម្រេចចិត្តវិលត្រឡប់មកកម្ពុជាវិញ នៅក្នុងអំឡុងខែសីហា ឆ្នាំ ២០២០។ នាពេលបច្ចុប្បន្ននេះលោកបានធ្វើស្រែរបស់លោកវិញ ដែលលោកបានទិញដោយប្រាក់កម្ចីចំនួន ២ ពាន់ដុល្លារកាលពី ៤ ឆ្នាំមុន មុនពេលលោកទៅប្រទេសថៃ។ ក្រៅពីធ្វើស្រែលោកដើរស៊ីឈ្នួលដកជំឡូងមី ដើម្បីទទួលបានប្រាក់កម្រៃប្រចាំថ្ងៃដែលមិនទៀងទាត់ប្រមាណ ៣ ម៉ឺនរៀល។ ចំណែកប្រពន្ធ និងកូន ២ នាក់របស់លោក ក៏រកការងារធ្វើ និងចិញ្ចឹមមាន់ប្រមាណ ៦០ ក្បាលនៅផ្ទះ។ លោកធ្លាប់ទទួលបានជំនួយជាអង្ករចំនួន ២៥ គីឡូក្រាមពីអង្គការសង់ត្រាល់ ប៉ុន្តែលោកមិនធ្លាប់ទទួលបានអ្វីពីរដ្ឋាភិបាលទេ ដោយសារបណ្ណក្រីក្ររបស់លោកដែលមានតាំងពីឆ្នាំ ២០០៨ បានផុតកំណត់។ លោកចង់បានបណ្ណនេះឡើងវិញ ប៉ុន្តែអាជ្ញាធរមូលដ្ឋានប្រាប់លោកថា លោកមិនអាចទទួលបណ្ណនេះបានទេ ដោយសារលោកមានផ្ទះរស់នៅសមរម្យហើយ។ លោកនិយាយថាៈ «គួរតែចែកឲ្យបានគ្រប់គ្នាទៅ កុំឲ្យប្រណែនគ្នា។ អ្នកខ្លះ ផ្ទះគ្នាមានមែន តែមានតែផ្ទះ ចងការប្រាក់គេធ្វើផ្ទះ។ ដល់ឃើញគ្នាមានផ្ទះអត់ឲ្យគ្នា។ ដល់ពេលអត់ផ្ទះ ថានៅយូរយារនឹងគេដែរ អត់ធ្វើផ្ទះនៅ។ វាពិបាកដែរពាក្យនេះ។ ខ្ញុំឮពាក្យនេះដូចខ្ញុំអីគេថា មានផ្ទះនៅប៉ុណ្ណឹងដែរ រកបណ្ណក្រីក្រអីទៀត។ ដល់យើងអត់ធ្វើ ផ្ទះរខេករខាក គេថា ងាប់ហើយ អត់ធ្វើផ្ទះ»។

ចំណែកអ្នកស្រី ឈាង អុន អាយុ ៣៧ ឆ្នាំជាប្រជាពលរដ្ឋរស់នៅភូមិគ ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប នៅដើមឆ្នាំ ២០២០ អ្នកស្រី ប្តី និងប្អូនប្រុសបានចំណាយប្រាក់ជាង ១ ពាន់ដុល្លារ ដើម្បីធ្វើលិខិតឆ្លងដែនទៅធ្វើការនៅប្រទេសថៃ។ ក្រោយពេលធ្វើការបានប្រមាណ ៣ ខែនៅក្នុងរោងចក្រសម្អាតឈើ ១ កន្លែង អ្នកទាំង ៣ បានជួបនូវហានិភ័យអត់ការងារធ្វើ ដោយសារតែការផ្ទុះឡើងនៃជំងឺកូវីដ ១៩។ កូវីដ ១៩ បានធ្វើឲ្យប៉ះពាល់ដល់កន្លែងការងាររបស់អ្នកស្រីដែលធ្វើឲ្យអ្នកស្រីមិនបានទទួលប្រាក់ខែអស់ជាច្រើនខែ ហើយត្រូវបានម្តាយផ្ញើប្រាក់ទៅឲ្យចាយពីប្រទេសកម្ពុជា។ ដោយមិនអាចបន្តរស់នៅទីនោះបានអ្នកទាំង ៣ បានត្រឡប់មកកម្ពុជាវិញនៅខែសីហា។ បច្ចុប្បន្ននេះ បើទោះជាបានត្រឡប់មកប្រទេសកំណើតវិញក្តី ក៏អ្នកទាំង ៣ មិនបានរស់នៅជុំម្តាយកូននៅភូមិ ក្នុងស្រុកជីក្រែង ខេត្តសៀមរាបដែរ ដោយពួកគេបន្តធ្វើចំណាកស្រុកជីកទូក និងទូ្រ និងឧបករណ៍ផ្សេងៗយកទៅនេសាទនៅខេត្តស្ទឹងត្រែង។ មុខរបរនេសាទអាចធ្វើឲ្យពួកគេរកចំណូលបានប្រមាណពី ២ ម៉ឺន ទៅ ៣ ម៉ឺនរៀល ក្នុង ១ ថ្ងៃ លើកលែងតែថ្ងៃល្អដែលអាចនៅសល់ប្រាក់ប្រមាណ ៧ ម៉ឺនរៀល ក្នុង ១ ថ្ងៃ។ ប៉ុន្តែក្រុមគ្រួសារ

អ្នកស្រី ឈាង អុក ទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាលចំនួន ២២ ម៉ឺនរៀលជារៀងរាល់ខែ ដោយសារអ្នកស្រីមានបណ្ណក្រីក្រ ១ ដែលជាបណ្ណសម្រាប់អ្នកក្រីក្រខ្លាំង។

អ្នកស្រី មាស សុខ អាយុ ៦០ ឆ្នាំ ដែលជាម្ដាយរបស់អ្នកស្រី ឈាង អុន និយាយថា អ្នកស្រែលែងឲ្យកូនទៅធ្វើការនៅក្រៅប្រទេសទៀតហើយ។ អ្នកស្រីថ្លែងថា៖ «ខ្ញុំលែងឲ្យទៅថៃទៀតហើយ ព្រោះទៅអត់មានសល់អីទេ។ សុខចិត្តនៅរកស៊ីនៅនេះ បានប៉ុនណា ស៊ីប៉ុណ្ណឹងទៅ»។

ប៉ុន្តែលោក ផន ចន្ថា គ្រោងត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ នៅពេលស្ថានភាពជំងឺកូវីដធូរស្រាល។ លោកកំពុងសន្សំប្រាក់ដើម្បីធ្វើលិខិតឆ្លងដែនថ្មី ក្រោយពេលលិខិតឆ្លងដែនចាស់បានផុតកំណត់។ ថៅកែរបស់លោកបានទាក់ទងមកលោកតាមទូរស័ព្ទជាញឹកញាប់ឲ្យលោកត្រឡប់ទៅវិញដោយមិនចាំបាច់មានលិខិតឆ្លងដែន ប៉ុន្តែលោកមិនហ៊ានទៅទេនៅពេលដែលជំងឺកូវីដនៅបន្តរាលដាល។

យោងតាមការសិក្សាមួយរបស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងអង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលបានសម្ភាសជាមួយពលករចំណាកស្រុកជាង ១ ០០០ នាក់ដែលត្រឡប់មកកម្ពុជាវិញពលករជាងពាក់កណ្ដាលបានឆ្លើយថា ពួកគេត្រឡប់មកកម្ពុជាវិញ ដោយសារតែការភ័យខ្លាចជំងឺកូវីដ ១៩។ ប៉ុន្តែក៏មានពលករ ២៨ ភាគរយ ត្រឡប់មកវិញដោយសារបាត់បង់ការងារ។ នៅពេលត្រឡប់មកដល់កម្ពុជា ពលករជាទូទៅទទួលបានប្រាក់ចំណូលជាមធ្យមប្រមាណ ១៦៤ ដុល្លារ ក្នុង ១ ខែ។ មានពលករតែ ២១ ភាគរយប៉ុណ្ណោះដែលនិយាយថា ពួកគេមានការងារប្រចាំថ្ងៃ ហើយជាង ១៣ ភាគរយឆ្លើយថា ពួកគេមានមុខជំនួញខ្នាតតូច។ ពលករជាង ៦១ ភាគរយបានឆ្លើយថា ពួកគេនឹងធ្វើចំណាកស្រុកម្ដងទៀតនៅពេលព្រំដែនបើកឲ្យចេញ-ចូលឡើងវិញ ដោយក្នុងនោះ ៩១ ភាគរយ ជ្រើសរើសប្រទេសថៃជាគោលដៅនៃការធ្វើចំណាកស្រុក។ មានតែជាង ៥ ភាគរយប៉ុណ្ណោះដែលឆ្លើយថា ពួកគេនឹងស្នាក់នៅអចិន្ត្រៃយ៍នៅកម្ពុជា។ ក្នុងចំណោមពលករជាង ១ ០០០ នាក់ មានតែជិត ២ ភាគរយប៉ុណ្ណោះ ដែលទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល តាមរយៈបណ្ណសមធម៌ បើទោះបីជាពលករប្រមាណ ៣០ ភាគរយនិយាយថា ពួកគេពុំមានចំណូលសោះ។ បើទោះបីជាពលករភាគច្រើនបង្ហាញក្ដីបារម្ភអំពីការខ្វះចំណូល និងខ្វះការងារធ្វើក៏ដោយ ប៉ុន្តែពួកគេមានតែជិត ៥ ភាគរយប៉ុណ្ណោះដែលធ្លាប់បានទៅស្វែងរកជំនួយដោយបានទៅរកជំនួយតាមរយៈមេភូមិ ក្រុមប្រឹក្សាឃុំ-សង្កាត់ ឬស្វែងរកជំនួយពីអ្នកជិតខាង និងអង្គការ។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ (សង់ត្រាល់) បានថ្លែងថា រដ្ឋាភិបាលគួរបញ្ចូលពលករដែលត្រឡប់ពីក្រៅប្រទេស ជាពិសេសប្រទេសថៃ ចូលក្នុងបញ្ជីបណ្ណសមធម៌ដោយសារតែពលករភាគច្រើនបានខ្ចីប្រាក់គេដើម្បីបានទៅធ្វើការនៅក្រៅប្រទេស ប៉ុន្តែពួកគេបច្ចុប្បន្នកំពុងរងផលប៉ះពាល់ពីកូវីដ ហើយត្រូវត្រឡប់មកកម្ពុជាវិញទាំងគ្មានប្រាក់ និងជំពាក់បំណុលទៀត។ លោកថ្លែងថា៖ «ទាល់តែរដ្ឋលោកបូកបញ្ចូលគាត់ទៅក្នុងប្រព័ន្ធជួយជនក្រីក្រ ដូចជា ការព្យាបាល ពិនិត្យសុខភាពដោយអត់អស់លុយ ហើយប្រសិនបើរដ្ឋចែកជាកញ្ចប់ថវិកាចែកលុយសុទ្ធ ពួកគាត់ក៏គួរតែជាអាទិភាពទី ១ ដែរ ដែលជួយបន្ថយបំណុលរបស់គាត់។ មួយទៀតបង្កើតមុខរបរនៅក្នុងសហគមន៍ ដូចជាវិស័យកសិកម្ម ដែលវាអាចកាត់បន្ថយការប្រថុយប្រថានទៅប្រទេសគេវិញ»។ លោកគាំទ្រដល់ប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជំរុញឲ្យពលករត្រឡប់ពីបរទេស ងាកមកប្រកបរបរក្នុងវិស័យកសិកម្ម។ ប៉ុន្តែលោកសង្កេតឃើញជាក់ស្ដែងថា ការជំរុញនេះហាក់មិនទាន់ឈានដល់មានការអនុវត្តពេញលេញទេ គឺមានដោយអន្លើ។

លោក ថេង បញ្ញាធន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកផែនការនៃក្រសួងផែនការបានឲ្យដឹងថា កាលពីពេលថ្មីៗនេះ បន្ទាប់ពីមានការផ្ទុះឡើងជំងឺកូវីដ១៩ ក្នុងសហគមន៍នៅប្រទេសថៃ មានកិច្ចប្រជុំមួយត្រូវបាន

ធ្វើឡើងដឹកនាំដោយលោក វង្សី វិសុទ្ធ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីការផ្តល់បណ្ណសមធម៌ដល់ពលករចំណាកស្រុកពីប្រទេសថៃដោយមិនប្រកាន់និន្នាការនយោបាយឡើយ។ លោក បញ្ញាធន បញ្ជាក់ដូច្នេះថា៖ «ប្រសិនបើគាត់មានបញ្ហា ឬគាត់ធ្លាក់ខ្លួនក្រីក្រអី គឺគាត់អាចដាក់ពាក្យស្នើសុំ នៅឯឃុំ-សង្កាត់របស់គាត់ដូចប្រជាជនទូទៅអ៊ីចឹង។ អាជ្ញាធរឃុំ-សង្កាត់គាត់នឹងពិនិត្យមើលថាតើការស្នើសុំរបស់ពួកគាត់នោះ ក្រមែន ឬមិនមែន? បើគាត់ក្រមែន គេនឹងផ្តល់បណ្ណឲ្យហើយ។ ប៉ុន្តែយើងមិនធ្វើការផ្តល់បណ្ណសមធម៌ដល់រាល់ពលករចំណាកស្រុកពីថៃដោយស្វ័យប្រវត្តិនោះទេដោយសារតែអ្នកខ្លះក៏មកវិញមិនមែនបាតដៃទទេនោះទេ»៕

## ខេត្តប៉ៃលិន ត្រៀមគ្រែចំនួន២០០ទៀត សម្រាប់ចត្តាឡីស័កពលករមកពីថៃ

https://thmeythmey.com/ 07, Jan 2021 , 3:45 pm ដោយ: អ៊ូ សុខមាន ( OU Sokmean )

អ្នកស្រី បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានត្រៀមគ្រែបន្ថែមចំនួន២០០ទៀត នៅក្នុងមណ្ឌលចត្តាឡីស័កថ្មី(មន្ទីរបក្សខេត្ត) សម្រាប់ឱ្យពលករមកពីប្រទេសថៃ ធ្វើចត្តាឡីស័ក។ អ្នកស្រី បានបញ្ជាក់ថា ការត្រៀមគ្រែបន្ថែមនេះ ព្រោះមិនចង់ឱ្យដឹកជញ្ជូនពលករឆ្លងទៅខេត្តផ្សេងទៀត។ គិតត្រឹមព្រឹកថ្ងៃទី៧ មករា ពលករមកពីប្រទេសថៃចំនួន២៥៣នាក់ កំពុងធ្វើចត្តាឡីស័ក នៅតាមមណ្ឌលចត្តាឡីស័កទាំង៤នៅក្នុងខេត្តប៉ៃលិន។ បើតាមអ្នកស្រី បាន ស្រីមុំ ពលករចត្តាឡីស័កទាំងនោះ គឺមានពលរដ្ឋរស់នៅក្នុងខេត្តប៉ៃលិនផ្ទាល់ ប្រមាណតែ៤០ភាគរយប៉ុណ្ណោះ ក្នុងចំណោមអ្នកទាំងនោះ។ ក្រៅពីនេះ សុទ្ធសឹងជាពលកររស់នៅតាមបណ្តាខេត្តនានា ដែលតម្រូវឱ្យធ្វើសត្តាឡីស័កនៅខេត្តប៉ៃលិន។ «ពលករធ្វើចត្តាឡីស័ក និងមានវិជ្ជមានកូវីដ-១៩ នៅខេត្តប៉ៃលិន គឺមិនមែនសុទ្ធតែជាពលរដ្ឋរស់នៅខេត្តប៉ៃលិនឡើយ។ មានន័យថា ពលកររស់នៅខេត្តផ្សេងៗដែលចេញពីថៃ គឺបានចូលតាមច្រកខេត្តប៉ៃលិនយើង។ មានពលកររស់នៅខេត្តផ្សេងៗដែលមកពីថៃ បានឆ្លងកាត់តាមខេត្តប៉ៃលិនយើង! អ៊ីចឹងទើបខាងកងកម្លាំងយើងសហការជាមួយមន្ត្រីក្រសួងកិបាល បានយកពួកគាត់ធ្វើចត្តាឡីស័ក និងធ្វើតេស្តរកឃើញវិជ្ជមានកូវីដ-១៩មួយចំនួនលើពលករទាំងនោះ»។ នេះជាការលើកឡើងរបស់អ្នកស្រី បាន ស្រីមុំ ថ្លែងប្រាប់សារព័ត៌មានថ្មីៗ។ ក្រៅពីពលរដ្ឋរស់នៅខេត្តប៉ៃលិនផ្ទាល់ គឺមានអ្នករស់នៅបាត់ដំបង និងបន្ទាយមានជ័យជាដើម កំពុងធ្វើចត្តាឡីស័កនៅទីនោះ។ អ្នកស្រីបាន ស្រីមុំ បានបញ្ជាក់ថា ក្នុងមួយថ្ងៃៗ មានពលករខ្មែរដែលធ្វើដំណើរមកពីប្រទេសថៃ ចូលកម្ពុជាតាមច្រកព្រំដែនខេត្តប៉ៃលិន ចន្លោះពី១០ទៅ២០នាក់។

បើតាមរបាយការណ៍លោក កែវ វណ្ណថន អគ្គនាយករង និងជាអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ពលករខ្មែរ៤,៤១៥នាក់ហើយ បានត្រឡប់មកកម្ពុជាវិញ គិតត្រឹមថ្ងៃទី៦ មករា។ ក្រៅពីពលករខ្មែរសម្រុកមកវិញ ក៏មានពលរដ្ឋខ្មែរជិត២៤០នាក់ លួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃដែរ។ នេះបើតាមរបាយការណ៍ពីលោក កែវ វណ្ណថន ដដែល។

សូមជម្រាបថា គិតត្រឹមថ្ងៃទី៧ មករា ក្រសួងសុខាភិបាល រកឃើញពលករខ្មែរ២០នាក់ហើយ ដែលត្រឡប់ពីប្រទេសថៃវិញ មានជំងឺកូវីដ-១៩ ។ ពួកគេទាំងនោះ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅតាមមណ្ឌលសុខភាពនានា ក្នុងខេត្តប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ។ បច្ចុប្បន្នកម្ពុជាមានអ្នកឆ្លងជំងឺកូវីដ-១៩ សរុប ៣៨៥នាក់ ដោយក្នុងនោះ មាន៣៦២នាក់បានជាសះស្បើយ ខណៈថៃ មានអ្នកឆ្លងជាង៩ពាន់នាក់ ជាសះស្បើយជាង៤ពាន់នាក់ និងស្លាប់៦៦នាក់៕

## កិច្ចប្រជុំក្រុមការងារសម្របសម្រួល និងទទួលពលករខ្មែរមកពីប្រទេសថៃ

https://grandnewsasia.com/ 07-01-2021 ម៉ោង 9:14 am

កោះកុង÷ នាថ្ងៃទី៦ ខែមករា ឆ្នាំ២០២១ លោក ទូ សាវុធ អភិបាលរងខេត្តកោះកុង បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារសម្របសម្រួល និងទទួលពលករខ្មែរមកពីប្រទេសថៃ។ ក្នុងឱកាសនោះដែរ លោកអភិបាលរងខេត្ត បានសូមឲ្យសមត្ថកិច្ច និងអង្គភាពពាក់ព័ន្ធ យកចិត្តទុកដាក់សំខាន់លើ ១-ពង្រឹងការត្រួតពិនិត្យ ការចេញចូល របស់ពលករខ្មែរតាមច្រកនានាក្នុងភូមិសាស្ត្រខេត្តកោះកុង ២-ពង្រឹងការទប់ស្កាត់ពលករខ្មែរ ដែលលួចឆ្លងដែនខុសច្បាប់ក្នុងគោលបំណងគេចវេសពីការធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ និង៣-ពិនិត្យស្រាវជ្រាវរកមុខសញ្ញាមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់៕

## ឱកាសការងារក្នុងស្រុកប្រមាណ ២ម៉ឺនកន្លែងត្រៀមឱ្យពលករខ្មែរមកពីថៃ ក្រោយបញ្ចប់ការធ្វើចត្តាឡីស័ក

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 07/01/2021 - 09:00 ដោយ៖ ហេង សុខនី

លោកហៃ ហ៊ុនឡេង ប្រធាននៃទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ បានប្រាប់វិទ្យុបារាំងអន្តរជាតិ RFI នៅថ្ងៃនេះថា ទីភ្នាក់ងារនេះបានដាក់ចេញនូវយន្តការថ្មី ដើម្បីផ្សព្វផ្សាយ នឹងផ្តល់ឱកាសការងារប្រមាណ ២ម៉ឺនកន្លែងសម្រាប់ពលករខ្មែរ ក្រោយពីពួកគេបញ្ចប់ការធ្វើចត្តាឡីស័ក ទៅតាមវិធានសុវត្ថិភាពរបស់ក្រសួងសុខាភិបាល។ វិស័យការងារ ដែលបានត្រៀមសម្រាប់ពលករខ្មែរមាន ឧស្សាហកម្ម និងកម្មន្តសាលសេវាកម្ម សំណង់ និងកសិកម្ម។ ទោះយ៉ាងណា បើតាម លោក ហៃ ហ៊ុនឡេង រហូតមកទល់ពេលនេះ ការងារដែលបានត្រៀមទាំងនោះនៅមិនទាន់ទទួលបានការចាប់អារម្មណ៍ពីពលករខ្មែរនៅឡើយទេ។ គិតមកត្រឹមថ្ងៃនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ ទទួលបានអ្នកស្វែងរកការងារធ្វើចំនួន ២សែន៧ម៉ឺន៦ពាន់៧៨នាក់ក្នុងចំណោមរាជធានី ខេត្តទាំង២៥ទូទាំងប្រទេស។

## អាជ្ញាធរថៃចាប់ពលករខ្មែរឆ្លងដែនខុសច្បាប់៣២នាក់ និងបញ្ជូនត្រឡប់មកវិញជាង១00នាក់

https://www.rfa.org/khmer/ ដោយ៖ អាស៊ីសេរី 2021-01-06

អាជ្ញាធរថៃចាប់ពលករខ្មែរ ៣២នាក់ ក្នុងពេលឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅខេត្តស្រះកែវ (Sra Kao) កាលពីរសៀលថ្ងៃទី៥ មករា ខណៈពលករខ្មែរជាង ១០០នាក់ ឆ្លងជំងឺកូវីដ-១៩ នៅប្រទេសថៃ។ ជាមួយគ្នានេះអាជ្ញាធរថៃបានបញ្ជូនពលករខ្មែរជាង ១០០នាក់ផ្សេងទៀតត្រឡប់ទៅកម្ពុជាវិញតាមច្រកទ្វារព្រំដែនក្នុងខេត្តបន្ទាយមានជ័យ។ មន្ត្រីសង្គមស៊ីវិលយល់ថា ការឆ្លងដែនអំឡុងពេលនេះជារឿងមិនល្អឡើយ ហើយអាចប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត។ ពលករខ្មែរទាំង ៣២នាក់ ដែលត្រូវអាជ្ញាធរថៃចាប់ខ្លួននោះ មានកុមារចំនួន ៦នាក់ បានធ្វើដំណើរជា ២ក្រុមផ្សេងគ្នា ឆ្លងដែនតាមរយៈមេខ្យល់ជនជាតិខ្មែរ ចូលទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់។ សារព័ត៌មានថៃ (77Kaoded) ផ្សាយនៅថ្ងៃទី៦ ធ្នូ ថា ពលករ ១១នាក់ ត្រូវបានចាប់ខ្លួននៅព្រឹកថ្ងៃទី៦ ធ្នូ និង ២១នាក់ទៀត អាជ្ញាធរថៃចាប់ខ្លួនកាលពីរសៀលថ្ងៃទី៥ ធ្នូ ក្នុងពេលពួកគេធ្វើដំណើរទៅស៊ីឈ្នួលកាប់អំពៅនៅតំបន់ព្រំដែនក្នុងខេត្តស្រះកែវ (Sra kao)។ អាជ្ញាធរថៃបានបញ្ជូនពលករទាំងនោះទៅតុលាការខេត្តស្រះកែវ ដើម្បីចាត់វិធានការតាមច្បាប់។ ការចាប់ពលករខ្មែរនេះ គឺបន្ទាប់ពីគណៈរដ្ឋមន្ត្រីថៃបានអនុម័តឱ្យចាត់វិធានការលើមេខ្យល់ និងអាជ្ញាធរថៃទាំងឡាយ ដែលពាក់ព័ន្ធនឹងការនាំពលករបរទេសឆ្លងដែនចូល

ប្រទេសថៃដោយខុសច្បាប់អំឡុងពេលនេះ ដោយមិនមានការលើកលែងឡើយ។ រដ្ឋាភិបាលថៃចេញវិធានការតឹងរ៉ឹងបែបនេះ ដោយសារតែប្រទេសថៃមានការផ្ទុះជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ជាលើកទី២ ដោយអាជ្ញាធរថៃរកឃើញថា ភាគច្រើនឆ្លងតាមរយៈពលករបរទេស។ របាយការណ៍ក្រសួងសុខាភិបាលថៃឱ្យដឹងថា គិតចាប់ពីថ្ងៃទី១៩ ធ្នូ ដល់ថ្ងៃទី៦ មករា មានពលករខ្មែរចំនួន ១០៥នាក់ហើយ ដែលបានឆ្លងជំងឺកូវីដ-១៩ នៅប្រទេសថៃ។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរនៅទីក្រុងបាងកក ដើម្បីសាកសួរអំពីវិធានការក្នុងការជួយដល់ពលករខ្មែរ ដែលឆ្លងជំងឺកូវីដ-១៩ និងពលករ ដែលត្រូវអាជ្ញាធរចាប់ខ្លួននៅខេត្តស្រះកែវនោះបានទេ នៅថ្ងៃទី៦ មករា។

ចំណែកស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី៦ ធ្នូ ថា លោកមិនទាន់ទទួលព័ត៌មានជុំវិញការចាប់ខ្លួនពលករខ្មែរនេះនៅឡើយទេ។ ទោះជាយ៉ាងណាលោកជឿថា អាជ្ញាធរថៃនឹងបញ្ជូនពលករទាំងនោះត្រឡប់មកកម្ពុជាវិញដោយមិនមានការផ្តន្ទាទោសនោះឡើយ៖ *«ខ្លះមកទៅគេចាប់បាន ខ្លះទៅចាប់បាននៅហ្នឹងកន្លែងវាអត់ទៀត។ ខ្ញុំសួរថៃហើយគេអត់ដាក់គុកទេ ទោះបីចាប់បានក៏គេអត់ដាក់ដែរ។ ពិបាកណាស់យើងរាយកម្លាំងពេញទឹកពេញដីហើយនៅតែគាត់លួចចេញ អ្នកភូមិជាប់ព្រំដែនពិបាកណាស់ ផ្ទះគាត់ជាប់ព្រំដែន ហើយផ្លូវក្រោយផ្ទះគាត់ហ្នឹងដើរទៅម៉ោងណាក៏បានដែរ។ បើអ្នកពីចម្ងាយមកបណ្តោយអាហ្នឹងអត់អី បើអត់ស្គាល់ភូមិសាស្ត្រយើងយកបាន បើអ្នកភូមិយកមិនបានទេ»។* មេប៉ូលិសពាក់ផ្កាយ១ រូបនេះឱ្យដឹងថា អាជ្ញាធរថៃក៏បានបញ្ជូនពលករខ្មែរចំនួន ១១០នាក់ប្រគល់ឱ្យអាជ្ញាធរកម្ពុជាវិញតាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យដែរ នៅយប់ថ្ងៃទី៥ មករា។ លោក អ៊ុំ សផល បញ្ជាក់ថា អាជ្ញាធរខ្មែរបានបញ្ជូនពលករទាំងនោះទៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅតំបន់ព្រំដែនខេត្តបន្ទាយមានជ័យអស់ហើយ។

ទាក់ទងរឿងនេះ មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា យល់ថា ពលករខ្មែរឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះ ជាការប្រថុយប្រថាននឹងគ្រោះថ្នាក់ដល់អាយុជីវិត ហើយប្រឈមនឹងអាជ្ញាធរថៃចាប់ដាក់គុក ដោយសារថៃបានដាក់ប្រទេសក្នុងគ្រាអាសន្ន និងមានការត្រួតពិនិត្យតឹងតែងនៅតំបន់ព្រំដែន ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩៖ *«ហានិភ័យស្ទើរថា១០០ដង ទីមួយពួកគាត់ហ្នឹងជួបគេចាប់ ហើយធ្ងន់ធ្ងរជាងសព្វដង ហើយទី២ទាក់ទងទៅលើជំងឺកូវីដហ្នឹង ហើយបើគាត់ទៅយប់ត្រូវបានគេបាញ់ប៉ោះប៉ះពាល់ដល់អាយុជីវិត។ អីចឹងបញ្ហាទាំងអស់ហ្នឹងគួរតែប្រជាពលរដ្ឋទាំងអស់ហ្នឹងចាប់ផ្តើមការគិតពិចារណាថាតើខ្លួនគួរតែប្រថុយប្រថានបន្តទៀត ឬមួយយ៉ាងម៉េច»។* ទោះជាយ៉ាងណាមន្ត្រីសង្គមស៊ីវិលរូបនេះកត់សម្គាល់ថា ការឆ្លងដែនរបស់ពលរដ្ឋនេះគឺដោយសារពួកគេមានជីវភាពក្រីក្រ ហើយនៅផ្ទះអត់ការងារធ្វើ និងគ្មានប្រាក់ដោះស្រាយជីវភាពគ្រួសារ។ លោក ស៊ុំ ច័ន្ទកា យល់ថាដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលគួរតែចុះស្រង់ឈ្មោះពលរដ្ឋក្រីក្រ ដែលអត់ការងារធ្វើរួចផ្តល់ស្បៀងអាហារពួកគាត់ និងជួយរកការងារឱ្យពួកគាត់ធ្វើនៅក្នុងស្រុក ដើម្បីកុំឱ្យពួកគាត់ធ្វើចំណាកស្រុកទាំងប្រថុយប្រថានអំឡុងពេលនេះបន្តទៀត៕

## ពលករខ្មែរ២១នាក់ លួចឆ្លងដែនខុសច្បាប់តាមរយៈមេខ្យល់ត្រូវប៉ូលិសខេត្តស្រះកែវចាប់ឃុំខ្លួន

http://nokorwatnews.com/ 06-01-2021

កាលពីវេលាម៉ោង១៧,០០នាទីល្ងាច ថ្ងៃទី៥ មករា ២០២១ កម្លាំងប៉ូលិសខេត្តស្រះកែវ សហការជាមួយប៉ូលិសស្រុកខៅ ផាក់រ៉ច បានចូលទៅចាប់ខ្លួនស្ត្រីឈ្មោះ យុភីន សៈលៈទ្រី ជនជាតិថៃ អាយុ៤៤ឆ្នាំ នៅបរិវេណចំការអំពៅ ភូមិណង សូន ឃុំណង វ៉ា ស្រុកខៅ ផាក់រ៉ច ខេត្តស្រះកែវ ព្រមទាំងពលករខ្មែរចំនួន២១នាក់ ក្នុងនោះមានប្រុស៩នាក់ ស្រី៨នាក់ ក្មេងប្រុស៣នាក់ និងក្មេងស្រី១នាក់ ក្រោយពីទទួលបានសេចក្តីរាយការណ៍មកថាមានក្រុមពលករខ្មែរលួចចូលមកស៊ីឈ្នួលកាប់អំពៅនៅក្នុងទីតាំងខាងលើ។ សូមជំរាបថា ក្រោយពីសមត្ថកិច្ចសួរ

ចម្លើយទើបដឹងថា ពលករខ្មែរទាំងអស់ធ្វើដំណើរចូលមកតាមច្រករបៀង បរិវេណចម្ការជំឡូងជាប់ព្រំដែនកម្ពុ-ថៃ ក្នុងស្រុកខ្លងហាត ដែលប្រឈមជាមួយស្រុកម៉ាឡៃ របស់កម្ពុជា និងមានរថយន្តរង់ចាំដឹកពលករទៅធ្វើការនៅទឹកដីស្រុក ខៅ ឆាក់រ៉ច ខេត្តស្រះកែវ មានបុរសឈ្មោះចេយ គឿន ជនជាតិខ្មែរ អាយុ៣៥ឆ្នាំ ជាអ្នកទាក់ទងនាំពលករមកស៊ីឈ្នួលកាប់អំពៅជាមួយស្ត្រីថៃឈ្មោះ យុភីន សៈលៈទ្រី ដោយបានធ្វើរោងស្នាក់នៅបណ្ដោះអាសន្ននៅបរិវេណកណ្ដាលចម្ការអំពៅ ចម្ងាយពីផ្ទះរបស់នាង យុភីន ប្រមាណ៥០ម៉ែត្រ ទើបសមត្ថកិច្ចឃាត់ខ្លួនអ្នកទាំងអស់មកសួរចម្លើយ និងរាយការណ៍ឲ្យមន្ត្រីសុខាភិបាលស្រុក ថៅ ឆាក់រ៉ច មកដំណើរការបង្សាំងខ្លួន ពិនិត្យកំដៅ បាញ់ថ្នាំសម្លាប់មេរោគ នៅកន្លែងស្នាក់តែម្ដង និងបញ្ជូនទៅត្រួតពិនិត្យរកវីរុសកូវីដ-១៩ តាមវិធានការតឹងរុឹង។ ក្នុងនោះសមត្ថកិច្ចប៉ូលិសបានចោទប្រកាន់ស្ត្រីឈ្មោះ យុភីន សៈលៈទ្រី ម្ចាស់ចម្ការអំពៅខាងលើពីបទ ជួយសង្គ្រោះលាក់បំពួន ឬជួយដោយប្រការអ្វីក៏ដោយ ដល់ពលករខ្មែរ ដែលចូលមកប្រទេសថៃដោយខុសច្បាប់ឲ្យរួចផុតពីការចាប់ឃុំខ្លួន និងចោទប្រកាន់ពលករខ្មែរទាំងនោះថា ចូលមកប្រទេសថៃដោយខុសច្បាប់ និងបញ្ជូនទៅឲ្យសមត្ថកិច្ចជំនាញស្រុក ខៅ ឆាក់រ៉ច ចាត់ការតាមច្បាប់បន្ត៕

## ពលករចំណាកស្រុកខ្មែរ ឡាវ និងភូមា ត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះធ្វើការស្របច្បាប់២ឆ្នាំនៅប្រទេសថៃ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 06/01/2021 - 12:42 ដោយ៖ញឹម សុផល

ពលករចំណាកស្រុកខុសច្បាប់មកពីប្រទេសកម្ពុជា ឡាវ និងភូមា ត្រូវរដ្ឋាភិបាលថៃចេញច្បាប់អនុញ្ញាតឲ្យធ្វើការ និងស្នាក់នៅដោយស្របច្បាប់រយៈពេល២ឆ្នាំ នៅក្នុងប្រទេសថៃ រួមជាមួយនឹងកូនៗរបស់ពួកគេផងដែរ។ ការសម្រេចចិត្តរបស់អាជ្ញាធរថៃដូច្នេះ គឺជាផ្នែកមួយធ្វើឡើងដើម្បីគ្រប់គ្រង និងតាមដានការរីករាលដាលនៃជំងឺកូវីដ១៩ ដែលពេលនេះ កំពុងផ្ទុះចេញពីក្នុងចំណោមពលករចំណាកស្រុកនៅខេត្តសាមុតសាខន។ ចាប់ពីថ្ងៃទី១៥ ខែមករា រហូតដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ពលករចំណាកស្រុកបរទេសខុសច្បាប់ ទាំង៣សញ្ជាតិ មានកម្ពុជា ឡាវ និងភូមា នឹងត្រូវបានអនុញ្ញាតឲ្យដាក់ពាក្យសុំធ្វើការងារ និងស្នាក់នៅស្របច្បាប់ក្នុងប្រទេសថៃរយៈពេល២ឆ្នាំ តាមរយៈនិយោជករបស់ពួកគេ។

រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchart Chomklin អំឡុងពេលសន្និសីទកាសែតមួយនាដើមសប្ដាហ៍នេះ បានថ្លែងថា ការសម្រេចចិត្តរបស់រដ្ឋាភិបាលថៃ គឺធ្វើឡើងដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ តាមរយៈការធ្វើឲ្យប្រសើរឡើងនៃសុខភាពរបស់ពលករចំណាកស្រុក ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ។ នេះបើតាមការចុះផ្សាយរបស់កាសែតបាងកកប៉ុស្តិ៍កាលពីថ្ងៃម្សិលមិញ។

ទាក់ទងទៅនឹងចំណាត់ការរបស់អាជ្ញាធរថៃដូច្នេះ អ្នកនាំពាក្យក្រសួងការងារកម្ពុជា លោក ហេង សួរ បានប្រាប់វិទ្យុបារាំង RFI នៅថ្ងៃនេះថា ជាយន្តការមួយដែលមានការស្វាគមន៍ និងស្របតាមការស្នើសុំរបស់ក្រសួងការងារកម្ពុជាផងដែរ។

តាមការប្រកាសរបស់អាជ្ញាធរថៃ ពលករត្រូវឆ្លងកាត់ការពិនិត្យសុខភាពរកកូវីដ១៩ ទិញធានារ៉ាប់រងតម្លៃ២ពាន់បាត ក្នុងម្នាក់រយៈពេល១ឆ្នាំ និងត្រូវបង់ថ្លៃចុះឈ្មោះប័ណ្ណការងារជិត២ពាន់បាតទៀត ដែលជាបន្ទុករបស់និយោជក។

សូមបញ្ជាក់ថាប្រទេសកម្ពុជាបានខកខានបញ្ជូនពលករតាមកិច្ចព្រមព្រៀង MOU ចាប់តាំងពីខែកុម្ភៈឆ្នាំ២០២០កន្លងមក នៅពេលដែលប្រទេសថៃបានបិទព្រំដែន ដើម្បីការពារការឆ្លងរាលដាលជំងឺកូវីដ១៩។ ទោះយ៉ាងណា ពលករខុសច្បាប់ខ្មែរ នៅតែអាចចេញចូលបានទៅក្នុងប្រទេសថៃ តាមច្រករបៀងផ្សេងៗជាប់ព្រំដែន

ជាមួយថៃ ដោយពលករខ្លះត្រូវបានថៃចាប់បញ្ជូនមកកម្ពុជាវិញ។ ហើយចុងក្រោយនេះ ពលករខ្មែរជិត២០ បានឆ្លងកូវីដ១៩ ក្រោយការផ្ទុះនៅក្នុងខេត្តសាមុត សាខន ប្រទេសថៃ កាលពីសប្តាហ៍កន្លងទៅ៕

## ថ្ងៃទី១១ ខែ មករា ឆ្នាំ២០២១

### កងកម្លាំងចម្រុះខេត្តបន្ទាយមានជ័យ ចុះល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់ និងការពារឥទ្ធិពលជំងឺកូវីដ-១៩

http://www.freshnewsasia.com/ 2021-01-08 11:19am

**(បន្ទាយមានជ័យ)៖** កងកម្លាំងចម្រុះខេត្តបន្ទាយមានជ័យ ដឹកនាំដោយឧត្តមសេនីយ៍ត្រី សួង សៅ មេបញ្ជាការវរព្រំដែនគោក៨១៥ នាថ្ងៃទី៧ ខែមករា ឆ្នាំ២០២១ បានចុះពិនិត្យល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើម្បីបង្ការទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការពារជំងឺកូវីដ-១៩។ ឧត្តមសេនីយ៍ត្រី សួង សៅ បានលើកឡើងថា ដោយមានការណែនាំពីឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវ ដោយចូលរួមចំណែកអនុវត្តបទបញ្ជា ក៏ដូចអនុសាសន៍សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលលើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ មេបញ្ជាការរូបនេះ បានគូសបញ្ជាក់ថា កងកម្លាំងទាំងអស់នឹងរួមគ្នាបំពេញតួនាទី ភារកិច្ចឱ្យបានល្អ មានសាមគ្គីភាព ឯកភាពផ្ទៃក្នុងឱ្យបានរឹងមាំ ដើម្បីរួមគ្នាទប់ស្កាត់កុំឱ្យជំងឺកូវីដ-១៩ ឆ្លងចូលសហគមន៍ ហើយក្នុងពេលបំពេញភារកិច្ចនេះ ត្រូវរក្សាអនាម័យ ពាក់ម៉ាស លាងដៃនឹងអាល់កុល ដែលអាល់កុលជាប្រចាំ និងមិនត្រូវទៅប៉ះពាល់ ឬប្រាស្រ័យទាក់ទងពលករ ដែលស្ថិតក្នុងការសង្ស័យមានផ្ទុកវីរុសកូវីដ-១៩ នោះឡើយ ត្រូវរាយការណ៍ជាបន្ទាន់មក្រុមការងារ និងគ្រូពេទ្យជំនាញ៕

### រាជរដ្ឋាភិបាល ត្រៀមការងារប្រមាណ ២ម៉ឺនកន្លែង សម្រាប់ពលករខ្មែរ ត្រឡប់មកពីថៃវិញ

https://dap-news.com/national/ ByRC105 Posted on January 10, 2021

ភ្នំពេញ៖ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កលក្ខណៈឲ្យបងប្អូនពលករខ្មែរដែលវិលចូលប្រទេសវិញ បានចុះឈ្មោះ ទទួលព័ត៌មាន ស្វែងរកឱកាសការងារនៅក្នុងស្រុកកាន់តែងាយស្រួល បានជួបជុំ ក្រុមគ្រួសារ និងចៀងវាសធ្វើចំណាកស្រុក ទៅកាន់ប្រទេសថៃវិញ។ យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា ក្នុងន័យនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ បានបង្កើតក្រុមការងារមួយ ដែលមានភារកិច្ច ចុះឈ្មោះ តាមដាន និងឃ្លាំមើល ជាប្រចាំពីស្ថានភាពដំណើរវិលត្រឡប់ របស់បងប្អូនពលករមកពីប្រទេសថៃ ចូលស្រុកកំណើតតាមច្រកព្រំដែនសំខាន់ៗ ដើម្បីក្តាប់ព័ត៌មាន ផ្តល់ការគាំទ្រ និងជួយចុះឈ្មោះស្វែងរកការងារធ្វើក្នុងស្រុក បន្ទាប់ពីធ្វើចត្តាឡីស័ក ក្នុងរយៈពេល១៤ថ្ងៃ ដោយសុវត្ថិភាព។

លោក ហៃ ហ៊ុនឡេង ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ បានអះអាងថា ទីភ្នាក់ងារ NEA បានដាក់ចេញនូវយន្តការ គាំទ្រនិងត្រៀមផ្តល់ ឱកាសការងារប្រមាណ ២ម៉ឺនកន្លែង ជាបឋមសម្រាប់ពលករខ្មែរ ក្រោយពីបញ្ចប់ ការធ្វើចត្តាឡីស័ក ទៅតាមវិធានអនាម័យ សុខភាព និងការបង្ការសុវត្ថិភាពរបស់ក្រសួងសុខាភិបាល។ ការងារដែលបានត្រៀម សម្រាប់ពលករខ្មែរ មានគ្រប់ប្រភេទ នៅក្នុងវិស័យឧស្សាហកម្ម និងកម្មន្តសាល សេវាកម្ម សំណង់ និងកសិកម្ម។ ក្រុមការងារNEA ត្រូវចុះសហការ សម្របសម្រួល ព្រមទាំងបង្កើតជនបង្គោលទំនាក់ទំនងជាមួយអាជ្ញាធររាជធានី ខេត្ត ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ដើម្បីប្រមូលទិន្នន័យបងប្អូនពលករ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ដោយធ្វើបច្ចុប្បន្នភាព និងចងក្រងជាមូលដ្ឋានទិន្នន័យ ដើម្បីងាយស្រួលក្នុងការស្វែងរក

ព័ត៌មានពីការងារ ព្រមទាំងសំដៅឆ្លើយតប ឲ្យបានទាន់ពេលវេលា ក្នុងការផ្តល់សេវាការងារ និងជួយស្វែងរកការងារ ធ្វើគ្រប់ប្រភេទ ជូនដល់បងប្អូនពលករ ទាំងអស់ ដែលចង់បានការងារ ពិតប្រាកដ។ បន្ថែមលើនេះ ក្រុមការងារនេះ ក៏ត្រូវចុះធ្វើការផ្សព្វផ្សាយ អំពីសេវាការងារ និងព័ត៌មានទីផ្សារការងារ ឲ្យបានជ្រួតជ្រាបទូលំទូលាយ ដល់បងប្អូន ពលករ តាមមណ្ឌលចត្តាឡីស័ក នីមួយៗ ដោយធ្វើការចងក្រង ប្រមូល ជ្រើសរើស កម្លាំងពលកម្ម និងតម្រូវការ កម្លាំង ពលកម្មពីគ្រប់ប្រភេទ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយ ព្រមទាំងផ្តល់ការគាំទ្រ សម្របសម្រួលដល់រោង ចក្រ សហគ្រាស និងវិនិយោគិន ដើម្បីងាយស្រួលផ្គូផ្គង និងផ្តល់ឱកាសការងារ ជូនដល់បងប្អូន ពលករ ដោយ ផ្ទាល់ទាន់ពេលវេលា ផងដែរ។

បើក្នុងករណីបងប្អូនពលករ ខកខានមិនទទួលបាន ព័ត៌មាន អំពីឱកាសការងារ ដែលក្រុមការងារNEA បានចុះទៅផ្សព្វផ្សាយ ដល់ទីតាំងមណ្ឌលចត្តាឡីស័កនោះ បងប្អូនអាចធ្វើការទំនាក់ទំនង ដោយផ្ទាល់ក៏បានតាមរ យៈលេខទូរស័ព្ទ របស់មជ្ឈមណ្ឌលការងារទាំង១៣កន្លែងដែលមាននៅតាមបណ្តារាជធានី-ខេត្តមួយចំនួនរួមមាន៖

- មជ្ឈមណ្ឌលការងារខេត្តបន្ទាយមានជ័យ៖
  លេខទូរស័ព្ទ:០១៦ ៣២ ៦៦ ៥៥
- មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង៖
  លេខទូរស័ព្ទ:០១៦ ៩២ ៦៦ ៥៥/០៥៣ ៧៣ ៣១ ១១
- មជ្ឈមណ្ឌលការងារខេត្តសៀមរាប៖
  លេខទូរស័ព្ទ:០១៦ ៥៣ ៦៦ ៥៥/០៦៣ ២១០ ២៧៧
- មជ្ឈមណ្ឌលការងារខេត្តព្រះសីហនុ៖
  លេខទូរស័ព្ទ: ០៨១ ៨៥ ៦៦ ៥៥
- មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ៖
  លេខទូរស័ព្ទ: ០៧៧ ២៣ ២៣ ៧៨/០១៦ ៧៨ ៦៦ ៥៥/០២៣ ៦៣៣ ៦០០២
- មជ្ឈមណ្ឌលការងារខេត្តកំពង់ធំ៖
  លេខទូរស័ព្ទ: ០១៦ ៨៣ ៦៦ ៥៥/០៦២ ២១ ០២ ៧៧
- មជ្ឈមណ្ឌលការងារខេត្តព្រៃវែង៖
  លេខទូរស័ព្ទ: ០៨១ ៧៨ ៦៦ ៥៥/០៤៣ ២១០ ២៧៧
- មជ្ឈមណ្ឌលការងារខេត្តតាកែវ៖
  លេខទូរស័ព្ទ: ០១៦ ៦៧ ៦៦ ៥៥/០៣២ ២១០ ២៧៧
- មជ្ឈមណ្ឌលការងារខេត្តកំពត៖
  លេខទូរស័ព្ទ: ០១៦ ៥០ ៦៦ ៥៥/០៣៣ ២១០ ២៧៧
- មជ្ឈមណ្ឌលការងារខេត្តពោធិ៍សាត់៖
  លេខទូរស័ព្ទ: ០១០ ៧០ ៦៦ ៥៥/០៥២ ៧៤០ ២៧៧
- មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង៖
  លេខទូរស័ព្ទ: ០១៦ ៦៤ ៦៦ ៥៥/០៤៤ ៧១៥ ២៧៧
- មជ្ឈមណ្ឌលការងារខេត្តកំពង់ចាម៖
  លេខទូរស័ព្ទ: ០១៦ ៨៥ ៦៦ ៥៥/០៤២ ២១០ ២៧៧

- មជ្ឈមណ្ឌលការងារខេត្តស្ទឹងត្រែង៖
  លេខទូរស័ព្ទ: ០១០ ៧៤ ៦៦ ៥៥/០៧៤ ២១២ ២៧៧

ឬទំនាក់ទំនងមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារ តាមរយៈលេខទូរស័ព្ទ៖០៧៧ ២៣ ២៣ ៧៨/០១៦ ៧៨ ៦៦ ៥៥ ទំព័រហ្វេសប៊ុក៖ National Employment Agency គេហទំព័រ៖ www.nea.gov.kh៕

## កម្លាំងឈរជើងរបស់អង្គភាពតំបន់ប្រតិបត្តិការសឹករងប៉ៃលិន បន្តសកម្មភាពដើរល្បាតតាមខ្សែបន្ទាត់ព្រំដែន និងពិនិត្យមើលពលករឆ្លងដែនពីប្រទេសថៃ

http://nokorwatnews.com/ 10-01-2021

ខេត្តប៉ៃលិន៖ លោកឧត្តមសេនីយ៍ត្រី កែម អនុជ មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងប៉ៃលិន បានចាត់តាំងកម្លាំង ១២នាក់ចេញសកម្មភាពល្បាតព្រំដែនចាប់ពីបង្គោលសីមាលេខ ៦៥ ដល់បង្គោលសីមាលេខ៦៨ និងសហការជាមួយកម្លាំងវរសេនាតូចនគរបាលលេខ៨២១ ធ្វើការល្បាតត្រួតពិនិត្យតាមខ្សែបន្ទាត់ព្រំដែននៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ កម្លាំងមួយចំនួនត្រៀមតាមគោលដៅ ត្រួតពិនិត្យពលករឆ្លងដែនពីប្រទេសថៃ ទៀតផង។ ជាងនេះទៅទៀត លោកឧត្តមសេនីយ៍ត្រី មេបញ្ជាការ បានដឹកនាំ មេបញ្ជាការរង នាយសេធិការ នាយសេនាធិការរង នាយការិយាល័យ ផ្នែក ចុះចែកអំណោយជូន នាយទាហាន នាយទាហានរង និង ពលទាហាន ដែលឈរជើងនៅតាមអង្គភាព តំបន់គោលដៅ និង ចំណុចឈរជើង ក្នុងភូមិសាស្ត្រខេត្តប៉ៃលិន ។ អំណោយរួមមាន មី ត្រីខ ភេសជ្ជៈ និងថវិកាម្នាក់ៗ ៥០,០០០រៀល៕

## កងការពារព្រំដែនលេខ៥០១ បន្តសកម្មភាពដើរល្បាតតាមខ្សែបន្ទាត់ព្រំដែន និងពិនិត្យមើលពលករឆ្លងដែនពីប្រទេសថៃ

http://nokorwatnews.com/ 10-01-2021

ខេត្តកោះកុង៖ អង្គភាពកងការពារព្រំដែនលេខ៥០១ ក្រោមការចង្អុលបង្ហាញរបស់លោកវរសេនីយ៍ឯក ចាន់ ប៊ុនឌី មេបញ្ជាការកងការពារព្រំដែនលេខ៥០១ បានចាត់តាំងកម្លាំង ចេញសកម្មភាពល្បាតព្រំដែនចាប់ពីអូរជ្រៃដែងព្រំប្រទល់ ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង ដល់ភ្នំធំ ព្រំប្រទល់ ស្រុកសំឡូត ខេត្តបាត់ដំបង និងកម្លាំងមួយចំនួនទៀត សហការជាមួយកម្លាំងវរសេនាតូចនគរបាលលេខ៨២៥ ធ្វើការល្បាតត្រួតពិនិត្យតាមខ្សែបន្ទាត់ព្រំដែននៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២១នេះ។ ដោយឡែកកម្លាំងមួយចំនួនទៀត ត្រៀមត្រួតពិនិត្យពលករឆ្លងដែនពីប្រទេសថៃ។ រីឯការងារកសាងអង្គភាព ទីបញ្ជាការកងការពារព្រំដែន បានចាត់តាំងកម្លាំងចំនួន២៥នាក់ ជួសជុលដំបូលផ្ទះស្នាក់ រៀបចំកន្លែងសម្រាប់លេងកីឡា ១កន្លែង កសាងប៉ាក់សកុងត្រូល ១កន្លែង៕

## គិតត្រឹមថ្ងៃទី៧មករា ខេត្តជាប់ព្រំដែន ទទួលពលករខ្មែរមកពីថៃ ជាង១ម៉ឺន២ពាន់នាក់

https://kampucheathmey.com/ January 10, 2021 By Sorn Phanith

លោកជំទាវ ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលបានឲ្យដឹងថា ចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី៧ ខែមករា ឆ្នាំ២០២១ ខេត្តជាប់ព្រំដែនទទួលបានពលករខ្មែរមកពីថៃ ចំនួន ១២០៨៨នាក់។ បើតាមក្រសួងសុខាភិបាលបានឲ្យដឹងថា គិតត្រឹមម៉ោង៧ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២១នេះ កម្ពុជារកឃើញអ្នកឆ្លងកូវីដ១៩ ចំនួន ៣៩១នាក់ ក្នុងនោះព្យាបាលជាសះស្បើយចំនួន ៣៧១នាក់ និងអ្នកជំងឺ២០នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ក្នុងចំណោមអ្នកជំងឺសរុបចំនួន៣៩១នាក់នោះ មានពលករថៃចំនួន ២៦នាក់ នៅខេត្តបាត់ដំបង៦នាក់ ព្យាបាលជាសះស្បើយ២នាក់ខេត្តប៉ៃលិន១៣នាក់ជាសះស្បើយ៦នាក់ និងខេត្ត

បន្ទាយមានជ័យ៧នាក់។ យ៉ាងណាក៏ដោយ លោកស្រីបានបន្តថា កម្ពុជាបានគ្រប់គ្រងពលករខ្មែរមកពីថៃបានល្អប្រសើរ បើទោះបីជាមានពលករខ្មែរមួយចំនួនតូច គេចវេះមិនព្រមធ្វើចត្តាឡីស័កក៏ដោយ តែអាជ្ញាធរបានរកឃើញវិញបានទាន់ពេលវេលាយកមកដាក់ក្នុងមណ្ឌលឲ្យធ្វើចត្តាឡីស័ក។ លោកជំទាវ បានលើកឡើងថា ការធ្វើចត្តាឡីស័កនេះ គឺជាភារកិច្ចដ៏ចាំបំផុត ក្នុងការបង្ការនិងទប់ស្កាត់ការឆ្លងជំងឺកូវីដ១៩ព្រោះថា បើពលករមានឆ្លងជំងឺនេះហើយ រត់គេចវេះនោះវាមិនត្រឹមតែចម្លងទៅក្រុមគ្រួសារសាច់ញាតិប៉ុណ្ណោះទេ ថែមទាំងចម្លងទៅសហគមន៍ទៀតផង។ លោកជំទាវ បានលើកឡើងពីច្បាប់មកពន្យល់ថា យោងតាមអនុក្រឹត្យចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាល ក្នុងការទប់ស្កាត់ការឆ្លងជាលក្ខណៈអន្តរជាតិតាមច្រកចេញចូលត្រង់ជំពូកទី៥មាត្រា ទី៨ ស្តីពីការដាក់ទោសទណ្ឌបានឲ្យដឹងថា អ្នកដំណើរឬជនណាដែលមិនសហការឬរត់គេចវេះជាមួយមន្ត្រីចត្តាឡីស័កត្រូវពិន័យជាប្រាក់ពី២សែនរៀលទៅ១លានរៀល។ លើសពីនេះ ជនណាក្លែងបន្លំឯកសារពាក់ព័ន្ធសុខភាព ក្នុងគោលបំណងគេចវេះធ្វើចត្តាឡីស័ក ត្រូវមានទោសព្រហ្មទណ្ឌ ដោយមន្ត្រីចត្តាឡីស័កសហការជាមួយអាជ្ញាធរមូលដ្ឋានចេញចូលក្នុងប្រទេសកម្ពុជា។ លោកជំទាវ បានបន្ថែមទៀតថា ពលករខ្មែរមកពីប្រទេសថៃ មានហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺកូវីដ១៩ ខណៈប្រទេសថៃ មានការផ្ទុះរីករាលដាលជំងឺនេះ ព្រោះពេលដែលបងប្អូនធ្វើដំណើរត្រឡប់មកពីប្រទេសថៃ គឺត្រូវការធ្វើដំណើរតាមសេវាសាធារណៈយូរហើយយើងមិនដឹងថា នៅតាមផ្លូវបងប្អូនត្រូវប៉ះពាល់ឬជួបជាមួយអ្នកណានោះទេព្រោះថា ជំងឺកូវីដ១៩នេះ អាចចម្លងបានគ្រប់ពេលវេលាទីកន្លែងនិងគ្រប់កាលៈទេសៈ។ លោកជំទាវ បានអំពាវនាវដល់បងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនិងស្នាក់នៅប្រទេសថៃ សូមកុំចល័តពីកន្លែងមួយទៅកន្លែងមួយបើបើមិនមានការចាំបាច់ទេកុំចេញពីកន្លែងស្នាក់នៅ និងកុំទាន់វិលត្រឡប់មកស្រុកវិញនាកាលៈទេសៈនេះ៕ **អត្ថបទ៖ សំអឿន**

## ចំនួនពលករខ្មែរនៅថៃឆ្លងជំងឺកូវីដ-១៩ កើនឡើងជិតពាក់កណ្ដាល

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2021-01-08

ក្រសួងសុខាភិបាលថៃបានរកឃើញពលករខ្មែរ ឆ្លងជំងឺកូវីដ-១៩ បានកើនឡើងដល់ ១៥៣ គិតត្រឹមព្រឹកថ្ងៃទី៨ ខែ មករា នេះ។ ចំនួននេះ បានកើនឡើងស្ទើរពាក់កណ្ដាល បើប្រៀបធៀបទៅនឹងចំនួនឆ្លងលើពលករចំណាកស្រុកខ្មែរ កាលពីថ្ងៃទី៧ ខែ មករា ដែលមាន ១០៨នាក់។

មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា ថា ពលករខ្មែរដែលឆ្លងជំងឺកូវីដ១៩ នៅប្រទេសថៃទាំងនោះ ប្រឈមនឹងការខ្វះខាតស្បៀងអាហារ ដោយសារពួកគេឆ្លងជំងឺបែបនេះ គឺមិនអាចធ្វើការងារបានឡើយ។ មន្ត្រីសង្គមស៊ីវិលរូបនេះ យល់ថា រដ្ឋាភិបាលខ្មែរគួរតែចុះតាមដានរឿងនេះដល់ទីកន្លែងពលកររស់នៅឱ្យបានជាប់ជាប្រចាំ ដើម្បីតាមដានពីស្ថានភាពជំងឺរបស់ពួកគាត់។ លោក ឌី ថេហូយ៉ា ជឿថា ពលករមួយចំនួនអាចនឹងត្រូវថៅកែបញ្ឈប់ពីការងារដោយសារតែជំងឺនេះទៀតផង។

ប៉ុន្តែប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន ប្រាប់អាស៊ីសេរីថា ពលករទាំងនោះគួរតែទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ដើម្បីឱ្យស្ថានទូតជួយដល់ពួកគេបាន ប្រសិនបើពួកគេត្រូវការជំនួយបន្ទាន់អំឡុងពេលនេះ។ លោកអំពាវនាវដល់ពលករខ្មែរទាំងអស់ ត្រូវអត់ធ្មត់ស្នាក់នៅប្រទេសថៃបន្តទៀត ដោយមិនគួរត្រឡប់មកកម្ពុជាអំឡុងពេលនេះឡើយ៕

## យោធាថៃបញ្ជូនពលករខ្មែរទៅកម្ពុជាវិញ ខណៈកម្ពុជាត្រៀមការងារ ចំនួន២ម៉ឺនកន្លែងជូនពួកគេ

https://www.rfa.org/khmer/ ដោយ ខែ សុណង 2021-01-10

យោធាថៃបញ្ជូនពលករខ្មែរជិត ៥០នាក់ត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញ ស្របពេលរដ្ឋាភិបាលខ្មែរកំពុងត្រៀមការងារចំនួន ២ម៉ឺនកន្លែង សម្រាប់ពលករបញ្ចប់ការធ្វើចត្តាឡីស័ក។ ក្រុមយោធាថៃ បានបញ្ជូនពលករខ្មែរក្មេងចាស់ប្រុសស្រី សរុបចំនួន ៤៨នាក់ ចូលតាមច្រករបៀងចក្រី ស្ថិតក្នុងភូមិទឹកផុស ឃុំអង្គបាន ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីល្ងាចថ្ងៃទី៨ ខែមករា។

កម្លាំងនគរបាលការពារព្រំដែនគោក លេខ៨១៧ និងកម្លាំងយោធាកងពលតូចលេខ ៥០១ បានទទួលយកពលករទាំងនោះទៅធ្វើចត្តាឡីស័ក ១៤ថ្ងៃ នៅក្នុងអនុវិទ្យាល័យកូនភ្នំ៣២ ក្នុងស្រុកសំពៅលូន ដើម្បីការពារនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មុននឹងអនុញ្ញាតឱ្យវិលត្រឡប់ទៅស្រុកកំណើតវិញ។

ទាក់ទងនឹងការបញ្ជូនពលករត្រឡប់ពីប្រទេសថៃនេះ រដ្ឋាភិបាលខ្មែរត្រៀមការងារចំនួន ២ម៉ឺនកន្លែង ដើម្បីជួយឱ្យពលករមានការងារធ្វើ និងដោះស្រាយជីវភាពគ្រួសារជៀសវាងចំណាកស្រុកទៅកាន់ប្រទេសថៃវិញ។ ទីភ្នាក់ងារជាតិមុខរបរ និងការងារខ្មែរ បានឱ្យដឹងថា មានក្រុមការងារចុះឈ្មោះ តាមដាន និងឃ្លាំមើលជាប្រចាំពីស្ថានភាពដំណើរវិលត្រឡប់របស់ពលករមកពីប្រទេសថៃ តាមច្រកព្រំដែនសំខាន់ៗ ដើម្បីក្តាប់ព័ត៌មាន ផ្តល់ការគាំទ្រ និងជួយចុះឈ្មោះស្វែងរកការងារធ្វើក្នុងស្រុក បន្ទាប់ពីពលករធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ដោយសុវត្ថិភាព។

ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ លោក ហៃ ហ៊ុនឡេង ប្រាប់សារព័ត៌មានក្នុងស្រុកថា គម្រោងនេះផ្តល់ការងារប្រមាណ ២ម៉ឺនកន្លែង នឹងផ្តោតលើវិស័យឧស្សាហកម្ម កម្មន្តសាល សេវាកម្ម សំណង់ និងកសិកម្ម៕

# ថ្ងៃទី១២ ខែ មករា ឆ្នាំ២០២១

## អន្តរក្រសួងបានឯកភាពធ្វើការកែប្រែគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 11 January 2021 | 09:59 ICT

**ភ្នំពេញៈ** អន្តរក្រសួងបានឯកភាពកែសម្រួលលក្ខណសម្បត្តិ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដែលបានអនុវត្តរយៈពេល ១០ ឆ្នាំកន្លងមកដោយជោគជ័យទៅជាគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពវិញ ដើម្បីឆ្លើយតបទៅនឹងស្ថានភាព និងបញ្ហាបច្ចុប្បន្ន ខណៈសង្គមស៊ីវិលបានលើកឡើងពីក្តីបារម្ភរបស់ពលរដ្ឋពីការរីករាលដាលគ្រឿងញៀនដល់ទីជនបទ។ ការសម្រេចកំណត់លក្ខណសម្បត្តិ គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពឡើងវិញនេះធ្វើឡើងក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើការកែសម្រួលលក្ខណសម្បត្តិ នៃគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពដឹកនាំដោយលោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ៨ ខែមករា នៅទីស្តីការក្រសួងមហាផ្ទៃ។ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដែលរាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តកាលពីអំឡុងខែសីហា ឆ្នាំ ២០១០ មានលក្ខណសម្បត្តិចំនួន ៥ គឺ ១ គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ ២ គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ៣ គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ ៤ គ្មានក្មេងទំនើង និង ៥ គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

ចំណែកសេចក្តីព្រាងគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពដែលអន្តរក្រសួងទើបកំណត់ឡើងវិញនេះមាន ៨ គឺ ១ គ្មានបទល្មើសគ្រប់ប្រភេទ ពិសេសសកម្មភាពលួច ឆក់ ប្លន់។ ២ គ្មានបទល្មើសគ្រឿងញៀន។ ៣ គ្មានអំពើអានាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ គ្មានក្មេងទំនើង។ ៤

មានអនាម័យមានសោភណភាពល្អ និងបរិស្ថានល្អ។ ៥ ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ ករណីប្រធានស័ក្តិ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព។ ៦ ផ្តល់សេវារដ្ឋបាល និងសេវាសាធារណៈប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។ ៧ ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព និង ៨ គ្មានគ្រោះថ្នាក់ចរាចរណ៍។

លោក ស ខេង ថ្លែងក្នុងពេលដឹកនាំកិច្ចប្រជុំអន្តរក្រសួងថា គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាពត្រូវបានអនុវត្តរយៈពេលប្រមាណ ១០ ឆ្នាំកន្លងមក ទទួលបានការគាំទ្រ និងចូលរួមច្រើនជាពិសេសអនុវត្តបានខ្ជាប់ខ្ជួនពីគ្រប់ក្រសួងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ។ ចំណែកការកែសម្រួលសេចក្តីព្រាងគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពឡើងវិញនេះ គឺជាការធ្វើបច្ចុប្បន្នភាពលើគោលនយោបាយដែលចាំបាច់ឱ្យស្របទៅនឹងបញ្ហាថ្មីៗ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលរួមនឹងផែនការយុទ្ធសាស្ត្ររបស់ក្រសួងស្ថាប័ននីមួយៗ។ លោកថ្លែងថា៖ «ពេលនេះយើងសរសេរគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ហើយការថែមសង្កាត់នេះ គឺដោយសារបណ្តាក្រុង តាមខេត្តក៏មានសង្កាត់ដែរ ម្យ៉ាងនៅរាជធានីភ្នំពេញក៏មានសង្កាត់ដូចគ្នាដែរ។ គោលនយោបាយនេះបានសរសេរច្បាស់ៗ គ្មានពាក្យបង្ការ លុបបំបាត់ ឬកាត់បន្ថយអ្វីទេ»។ លោក ស ខេង ពន្យល់ថា ការដាក់ច្បាស់ៗនូវអ្វីដែលចង់បានក្នុងគោលនយោបាយនេះគឺដើម្បីបញ្ចប់ភាពស្រពេចស្រពិល។ ដូច្នេះគោលនយោបាយកែសម្រួលឡើងវិញនេះបានកំណត់ឱ្យច្បាស់តែម្តង ដូចជាពាក្យ «គ្មានបទល្មើសគ្រប់ប្រភេទ» ជាពិសេសសកម្មភាពលួចឆក់ប្លន់ ឬ «គ្មានបទល្មើសគ្រឿងញៀន» ជាដើមក្នុងគោលនយោបាយនេះក៏មានផ្នែកបន្ទាប់ពន្យល់យ៉ាងលម្អិតដែរ។

លោក អំ សំអាត នាយករងអង្គការលីកាដូបានគាំទ្រគោលនយោបាយនេះ ដោយថ្លែងថា គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលនេះល្អ សម្រាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋានធ្វើឱ្យការរស់នៅប្រកបដោយភាពសុខដុមរមនា សន្តិសុខ សុវត្ថិភាព និងបរិស្ថានល្អ។ ប៉ុន្តែបើមើលទៅលើការអនុវត្តជាក់ស្តែងរបស់មន្ត្រីមូលដ្ឋានមួយចំនួនគឺមិនទាន់ឆ្លើយតបតាមគោលនយោបាយនេះនៅឡើយទេ។ លោកថា៖ «ប្រជាពលរដ្ឋមួយចំនួន នៅតែលើកឡើងពីបញ្ហាមួយចំនួនដូចជា ករណីគ្រឿងញៀនដែលបច្ចុប្បន្នគឺរីករាលដាលដល់ជនបទ ល្បែងស៊ីសងមួយចំនួននៅបន្តកើតមានឡើង ចោរកម្មមួយចំនួននៅតែកើតមានឡើង»។ បើតាមលោក សំអាត សហគមន៍ដីធ្លី និងអង្គការសង្គមស៊ីវិលមួយចំនួនលើកឡើងថា ពេលពួកគេចុះបំពេញការងារ ឬជួបជុំគ្នាដើម្បីការងារសហគមន៍ គឺតែងតែមានអាជ្ញាធរមូលដ្ឋានចុះទៅដល់ និងឃ្លាំមើលសកម្មភាព។ ពួកគេចង់ឱ្យអាជ្ញាធរយកពេលវេលាទាំងនេះទៅយកចិត្តទុកដាក់ដើម្បីការពារផលប្រយោជន៍មូលដ្ឋាន និងការពារសុវត្ថិភាពសន្តិសុខជូនប្រជាពលរដ្ឋវិញដូចជាការបង្ក្រាបបទល្មើសគ្រឿងញៀន និងបទល្មើសដែលកើតក្នុងមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាពតាមគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពវិញទើបជាការល្អ។ លោកបានបញ្ជាក់ថា៖ «ដើម្បីឱ្យគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាពមានប្រសិទ្ធភាពទាល់តែមន្ត្រីមូលដ្ឋានចូលរួមអនុវត្តឱ្យបានពេញលេញ និងមានការចូលរួមពីប្រជាពលរដ្ឋ និងមានទំនុកចិត្តពីពលរដ្ឋ»។

យោងតាមសេចក្តីព្រាងដែល ភ្នំពេញ ប៉ុស្តិ៍ ទទួលបានពីម្សិលមិញ គោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពវិញនេះមានគោលបំណងបន្តកសាង និងពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គមលើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាជន និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតគ្រប់កាលៈទេសៈព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋានផងដែរ។

គ្រប់ចំណុចនៃគោលនយោបាយនេះគឺដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ ព្រមទាំងកសាងបានជាកម្លាំងសរុប វិធានការ

សរុប និងមធ្យោបាយសរុប ដោយបំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ចផ្នែកសាធារណៈផ្នែកឯកជន ផ្នែកពាក់ព័ន្ធ និងប្រជាជនទូទាំងប្រទេស៕

## កិច្ចប្រជុំពិភាក្សាលើផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប ឆ្នាំ២០២១

https://www.facebook.com/deputygovernoryousophear/ 11-01-2021

ខេត្តសៀមរាប៖ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាននៃ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តនៅក្នុងឆ្នាំ២០២១ ដោយមានការអញ្ជើញចូលរួមពីមន្ទីរជំនាញនិងអង្គការដៃគូជាតិអន្តរជាតិសរុបចំនួន១៨នាក់នៅបន្ទប់ប្រជុំសាលាខេត្តសៀមរាប។ ផែនការសម្មភាពសម្រាប់អនុវត្តក្នុងឆ្នាំ២០២១នេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើកផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០១៩-២០២៣) និងផ្តោតទៅលើបញ្ហា និងតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋាន រួមមាន៖

-យុទ្ធសាស្ត្រទី១៖ ពង្រឹងកិច្ចសហប្រតិបតិបត្តិការ ការកសាង និងអនុវត្តច្បាប់គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា

-យុទ្ធសាស្ត្រទី២ ៖ ការលើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ

-យុទ្ធសាស្ត្រទី៣ ៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

-យុទ្ធសាស្ត្រទី៥ ៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

នៅក្នុងកិច្ចពិភាក្សានេះផងដែរ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានជំរុញលើកទឹកចិត្តដល់មន្ទីរអង្គការភាពជំនាញ និងអង្គការដៃគូទាំងអស់ធ្វើការពិនិត្យ និងលើកឡើងនៅជាតុចូលក៏ដូចជាការលើកអំពីសកម្មភាពដែលឆ្លើយតបទៅនឹងបញ្ហាប្រឈម នៅក្នុងក្រុង ស្រុកគោលដៅនីមួយៗ និងបានអនុញ្ញតឱ្យដាក់បញ្ចូលសកម្មភាពនៅក្នុងផែការសកម្មភាពរបស់លេខាធិការដ្ឋានសម្រាប់ឆ្នាំ២០២១។ ការរៀបចំផែនការសកម្មភាព ដើម្បីងាយស្រួលក្នុងការអនុវត្តរួមគ្នា ដោយមានកិច្ចសហការគ្នារវាងស្ថាប័នរដ្ឋ ជាមួយអ្នកពាក់ព័ន្ធ និងអង្គការដៃគូ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនានា ពិសេសការកេងប្រវ័ញ្ចទៅលើស្ត្រី និងកុមារ។

កិច្ចប្រជុំទទួលបានការចូលរួមជាមតិយោបល់សំខាន់ៗ និងការចូលរួមសហការពីអង្គការដៃគូជាតិ អន្តរជាតិ សម្រាប់អនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងខេត្តសៀមរាប ដើម្បីរួមគ្នា ទប់ស្កាត់ បង្ក្រាប ការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស និងរំលោភបំពានទៅលើស្ត្រី និងកុមារតាមគ្រប់រូបភាព។

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១

(សៀមរាប)៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃរបស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃចន្ទ ទី១១ ខែមករា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពល

ករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦និង០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិ ប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥២នាក់ ស្រី ២៤នាក់ ក្នុងនោះ កុមារា ៣នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ សម្រាប់ច្រករបៀងអូរបីជាន់ ចំនួន ២៤នាក់ ស្រី ១០នាក់ កុមារា ១នាក់ កុមារី ១នាក់។ សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៧នាក់ ស្រី ៥នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ សម្រាប់ច្រកអន្តរជាតិអូរស្មាច់ ចំនួន ២១នាក់ ស្រី ៩នាក់ កុមារា ២នាក់ កុមារី ១នាក់។ ច្រកដូង ស្រុកកំរៀង ចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក នៅសាលា និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣១នាក់ និងឧត្តរមានជ័យចំនួន ២១នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## អាជ្ញាធរខេត្តបាត់ដំបង ព្រួយបារម្ភពីបញ្ហាពលករ រត់ចេញពីមណ្ឌលចត្តាឡីស័ក

https://www.cen.com.kh/archives/ January 12, 2021

បាត់ដំប ៖ អាជ្ញាធរខេត្តបាត់ដំបង បានបង្ហាញនូវការព្រួយបារម្ភ ពីបញ្ហាពលករមួយចំនួន ដែលត្រឡប់មកពីប្រទេសថៃ មិនសហការជាមួយអាជ្ញាធរ ក្នុងការងារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ហើយបានរត់គេចពីមណ្ឌលចត្តាឡីស័ក ទៅកាន់ទីកន្លែងផ្សេងៗ ធ្វើឲ្យមានការពិបាកក្នុងការតាមរកមកវិញ ។ ការលើកឡើងនេះ ក្នុងពេលចុះពិនិត្យស្ថានភាព ការវិលត្រឡប់និងការធ្វើចត្តាឡីស័កពលករខ្មែរ តាមមណ្ឌលនានា នៅបណ្តាស្រុកមួយចំនួនជាប់ព្រំដែនថៃ ក្នុងភូមិសាស្រ្តខេត្តបាត់ដំបង អាជ្ញាធរស្រុក បានរាយការណ៍ជូនឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង ពីបញ្ហាពលករខ្មែរមួយចំនួន ដែលបានរត់គេចពីការធ្វើចត្តាឡីស័ក និងត្រូវបានអាជ្ញាធររកឃើញ នាំមកមណ្ឌលឡើងវិញ។

ពាក់ព័ន្ធនឹងបញ្ហានេះ ឯកឧត្តមងួន រតនៈអភិបាលខេត្តបាត់ដំបង បានជំរុញដល់សមត្ថកិច្ចនៅតាមមណ្ឌលចត្តាឡីស័ក ត្រូវរឹតបន្តឹងនូវបញ្ហានេះ ហើយត្រូវតែអនុវត្តឲ្យបានគ្រប់គ្នា ទៅលើពលករខ្មែរ ទើបមកពីប្រទេសថៃ ឲ្យពួកគាត់ធ្វើចត្តាឡីស័កទាំងអស់ តាមកាលកំណត់របស់ក្រសួងសុខាភិបាល មិនត្រូវលើកលែងករណីណាមួយនោះទេ។ពលករខ្មែរ សូមអនុវត្តតាមវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួង ក្នុងការងារទប់ស្កាត់ជំងឺកូវីដ១៩នេះ ព្រោះថាបើត្រឡប់ទៅផ្ទះវិញ ដោយមិនបានធ្វើចត្តាឡីស័កនៅកន្លែងអាជ្ញាធររៀបចំទុកជាស្រេចគឺនៅពេលត្រឡប់ដល់ផ្ទះវិញ ក៏ត្រូវធ្វើចត្តាឡីស័កដូចគ្នា មិនត្រឹមតែប៉ុណ្ណោះនឹងប៉ះពាល់ដល់សមាជិកគ្រួសារថែមទៀត ក្នុងករណីសង្ស័យឬមានឆ្លង ត្រូវធ្វើចត្តាឡីស័កទាំងគ្រួសារ បង្កឲ្យប៉ះពាល់ដល់ការប្រកបរបរទទួលទាន ព្រោះត្រូវធ្វើចត្តាឡីស័កទាំងអស់គ្នានោះ។

សម្រាប់ពលករខ្មែរ បានបញ្ចប់ការធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ តាមការកំណត់របស់ក្រសួង បាននិយាយប្រាប់ថា ពួកគេពេញចិត្តនឹងវិធានការនេះ ព្រោះវានឹងអាចបញ្ចៀសនូវការឆ្លងរីករាលដាលជំងឺកូវីដ១៩នៅក្នុងសហគមន៍របស់ពួកគេ។រាល់ពលករ ខ្មែរឬអ្នកត្រឡប់មកពីក្រៅប្រទេស មិនគួរគេចវេសពីការធ្វើចត្តាឡីស័កនោះឡើយ។

គួរបញ្ជាក់ថា ចាប់តាំងពីមានការផ្ទុះឆ្លងរីករាលដាលក្នុងសហគមន៍នៃជំងឺកូវីដ១៩ នៅក្នុងខេត្តសាមុទសាខន ប្រទេសថៃ មានពលករខ្មែរឆ្លងដែនពីថៃតាមច្រកនានា ជាប់ខេត្តបាត់ដំបង មានចំនួនជាង ២ ៣០០នាក់ ត្រូវ

បានធ្វើសំណាកជាង ២ ០០០នាក់ និងអ្នកបញ្ចប់ការធ្វើចត្តាឡីស័ក ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញចំនួនជិត ១ពាន់នាក់ ខណៈការរកឃើញពលករឆ្លងជំងឺកូវីដ១៩ មានជាបន្តបន្ទាប់៕ **រក្សាសិទ្ធិដោយៈអ៊ឹងសារុំ**

## ក្រសួងការងារប្រកាសរកការងារឱ្យពលករមកពីថៃ អាចស្វែងរកការងារបាន

https://www.rasmeinews.com/ 11 January, 2021

**ដោយ: ពៅនិមល/ភ្នំពេញ:** *ដោយសារវិបត្តិនៃជំងឺឆ្លងកូវីដ១៩ រដ្ឋាភិបាលកម្ពុជាតាមរយៈ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រកាសថា បានត្រៀមការងារចំនួន២ម៉ឺនកន្លែង ដល់បងប្អូនពលករខ្មែរដែលធ្វើត្រឡប់ មកពីប្រទេសថៃវិញ ដោយអាចស្វែងរកការងារបាន ក្រោយចប់ការធ្វើចត្តាឡីស័ក (ដាច់ដោយឡែក១៤ថ្ងៃ) ដើម្បីជួយដោះស្រាយបញ្ហាសេដ្ឋកិច្ចក្នុងគ្រួសារ។*

មានប្រសាសន៍ប្រាប់រស្មីកម្ពុជានៅព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២១នេះ លោក ហៃ ហ៊ុនឡេង ប្រធាន NEA បានលើកឡើងថា ការងារប្រមាណ២ម៉ឺនកន្លែងនេះ រួមមានក្នុង វិស័យឧស្សាហកម្ម សេវាកម្ម សំណង់ និងកសិកម្មជាដើម។ លោកបន្តថា "ដោយសារខាង យើងខ្ញុំធ្វើការប្រមូលចងក្រងព័ត៌មានអំពីតម្រូវការការងារ ដូច្នេះហើយមិនថាតែបងប្អូន ដែលជាអ្នកវិលត្រឡប់មកពីប្រទេសថៃ ឬអ្នកកំពុងស្វែងរកការងារក្នុងស្រុកទេ គឺថាឱកាសទាំងអស់នេះ គឺបើកចំហរជាទូទៅសម្រាប់សាធារណជន និងអ្នកចង់ស្វែងរកការងារ ញ៉ឹងអត់ប្រកាន់លក្ខខណ្ឌណាទេ) យើងបូកសរុបចូលទៅជាបឋមឥឡូវនេះដែលអាចទំនេរ ទទួលយកបានភ្លាមៗគឺថាយ៉ាងហោចណាស់ ២ម៉ឺនឱកាសការងារ គឺអាចបង្ករលក្ខណៈឱ្យ បងប្អូនយើងអាចដាក់ពាក្យស្វែងរកការងារ ឬក៏ចង់ជ្រើសរើសការងារណាមួយដែល សមស្របទៅតាមលក្ខខណ្ឌនិងជំនាញ និងចំណង់ចំណូលចិត្តរបស់គាត់អាចធ្វើការចុះ ឈ្មោះហើយទំនាក់ទំនងមកខាងទីភ្នាក់ងារជាតិមុខរបរនិងការងារ"។

លោកបញ្ជាក់ទៀតថា ជាចំណុចចាប់ផ្តើមនៃការពិចារណាអំពីការងារ ខ្ញុំចង់អំពាវនាវឱ្យ បងប្អូនយើងដែលគាត់អញ្ជើញត្រឡប់មកមាតុប្រទេសហើយប្រសិនបានធ្វើចត្តាឡីស័កទៅហើយ ឃើញថាមានសុខភាពល្អ ហើយអាចចេញមកនៅក្នុងសហគម ឬក្នុងសង្គមជាតិ យើងជាធម្មតានោះ គឺថាអាចទំនាក់ទំនងធ្វើការចុះឈ្មោះស្វែងរកឱកាសការងារណាមួយ ដែលសមស្របជាមួយគាត់ប្រសិនបើគាត់មានបំណងចង់ធ្វើការនៅក្នុងស្រុកហើយយើង ក៏រំពឹងទុកដែរ ឱកាសការងារដែលបើកជូនតាមរយៈការណែនាំ ឬក៏ការចង្អុលបង្ហាញ របស់រាជរដ្ឋាភិបាលក្នុងការលើកទឹកចិត្តឱ្យបងប្អូនយើងស្វែងរកការងារក្នុងស្រុក គឺខាង យើងខ្ញុំនឹងខិតខំធ្វើយ៉ាងណាជំរុញការប្រមូលផ្តុំឱកាសការងារឱ្យកាន់តែទូលំទូលាយ ហើយបងប្អូនធ្វើការជ្រើសរើសនិងសម្រេចចិត្តកាន់តែបានល្អប្រសើរទៅតាមលក្ខខណ្ឌសមប្រកបរបស់ពួកគាត់។

ជុំវិញបញ្ហាខាងលើនេះ NEA បានសហការ និងសម្របសម្រួល ព្រមទាំងបង្កើតជនបង្គោល ទាក់ទងជាមួយអាជ្ញាធរគ្រប់មូលដ្ឋាន ដើម្បីប្រមូលទិន្នន័យពលករដែលបាន វិលត្រឡប់ មកពីប្រទេសថៃ ដោយធ្វើបច្ចុប្បន្នភាព និងចងក្រងជាមូលដ្ឋានទិន្នន័យ ដើម្បីងាយស្រួល ក្នុងការស្វែងរកព័ត៌មានពីការងារ ព្រមទាំងសំដៅឆ្លើយតបឲ្យទាន់ពេលវេលាក្នុងការផ្តល់ សេវាការងារ និងជួយស្វែងរកការងារធ្វើគ្រប់ប្រភេទជូនដល់ពលករដែលចង់បានការងារ ពិតប្រាកដ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី៧ ខែមករា ឆ្នាំ២០២១ ចំនួនពលករខ្មែរដែល ត្រឡប់មកពីប្រទេសថៃ មកមាតុភូមិកម្ពុជាវិញសរុបចំនួនប្រមាណជាង១២,០០០នាក់៕/PC

# ថ្ងៃទី១៣ ខែ មករា ឆ្នាំ២០២១

## ក្រសួងមហាផ្ទៃ៖ គិតត្រឹមថ្ងៃទី១២ ខែមករា ពលករខ្មែរចាកចេញពីថៃចូលមកកម្ពុជាវិញ មានជាង១៣ម៉ឺននាក់

http://www.freshnewsasia.com/ 2021-01-12 04:05pm

**(ភ្នំពេញ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គិតត្រឹមថ្ងៃទី១២ ខែមករា ឆ្នាំ២០២១នេះ ពលករខ្មែរដែលបានចាកចេញពីប្រទេសថៃ ចូលមកកម្ពុជាវិញ គឺមានប្រហែលជាង១៣ម៉ឺននាក់ ប៉ុន្តែពួកគេក៏ត្រូវបានអាជ្ញាធរកម្ពុ ធ្វើការឃាត់ខ្លួនឲ្យធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ ស្របទៅតាមការណែនាំរបស់រាជរដ្ឋាភិបាលក៏ដូចក្រសួងសុខាភិបាលកម្ពុជាផងដែរ។

លោកស្រី ជូ ប៊ុនអេង បានសម្តែងការព្រួយបារម្ភ ចំពោះការជួញដូរមនុស្សលើពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃជាងមួយលាននាក់ ទាំងស្របច្បាប់ និងមិនស្របច្បាប់ ខណៈប្រទេសភូមិផងរបងតែមួយនេះ កំពុងផ្ទុះរីករាលដាលខ្លាំងនូវជំងឺរាតត្បាតមេរោគកូវីដ-១៩នោះ។ ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាន ក្នុងឱកាសបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីរបាយការណ៍សូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍ (MGI) និងកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ (GCM) នៅព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០២១នេះ លោកស្រី ជូ ប៊ុនអេង បានលើកឡើងថា វាជាការព្រួយបារម្ភចំពោះរាជរដ្ឋាភិបាលលើពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃនោះ ដោយសារពួកគេអាចបន្តប្រឈម នឹងការចាញ់បោកមេខ្យល់មួយចំនួនតូច បោកពួកគេតាមរូបភាពផ្សេងៗ ក្នុងអំឡុងដែលពួកគាត់មិនអាចដើរចល័តរកការងារ ធ្វើបាននៅប្រទេសថៃនោះ។ យ៉ាងណាក៏ដោយ លោកស្រី ជូ ប៊ុនអេង ក៏បានអះអាងជាថ្មីទៀតផងដែរថា នាពេលបច្ចុប្បន្ននេះ អាជ្ញាធរកម្ពុជា បានសហការគ្នាជាមួយសមត្ថកិច្ចថៃ កំពុងបន្តស្រាវជ្រាវស្វែងរកចាប់មេខ្យល់ ដែលបោកប្រជាពលរដ្ឋខ្មែរឲ្យផ្សងគ្រោះថ្នាក់ ឆ្លងកាត់ព្រំដែនប្រទេសកម្ពុជា និងប្រទេសថៃ ខណៈដែលប្រទេសថៃ បានរឹតត្បិតការដើរចល័តរបស់ពលករបរទេសនោះ។

សូមបញ្ជាក់ផងដែរថា រហូតមកដល់ថ្ងៃទី១២ ខែមករានេះ ពលករខ្មែរដែលបានចាកចេញពីប្រទេសថៃមកកម្ពុជាវិញ ត្រូវបានរកឃើញឆ្លងមេរោគកូវីដ-១៩ ចំនួន២៧នាក់ ខណៈរាប់រយនាក់ទៀតកំពុងបន្តធ្វើចត្តាឡីស័កនោះ៕

## ពលករខ្មែរ ធ្វើការនៅថៃ អាចប្រឈម នឹងការជួញដូរ ខណៈជំងឺកូវីដ១៩កំពុងផ្ទុះខ្លាំងនៅប្រទេសនេះ

https://dap-news.com/ BySS107 Posted on January 12, 2021

ភ្នំពេញ៖ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកស្រី ជូ ប៊ុនអេង បានសម្តែងការព្រួយបារម្ភ ចំពោះការជួញដូរមនុស្សលើពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃ ជាងមួយលាននាក់ទាំងស្របច្បាប់ និងមិនស្របច្បាប់ ខណៈប្រទេសភូមិផងរបងតែមួយនេះកំពុងផ្ទុះរីករាលដាលខ្លាំងនូវជំងឺរាតត្បាតមេរោគកូវីដ១៩នោះ។ នេះបើយោងតាមអគ្គស្នងការនគរបាលជាតិ ។

ថ្លែងប្រាប់អ្នកយកព័ត៌មាន ក្រោយពីបើកកម្មវិធីសិក្ខាសាលា ពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីរបាយការណ៍សូចនាករ អភិបាលកិច្ចទេសន្តរប្រវេសន៍ (MGI) និងកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ (GCM) នៅសណ្ឋាគារ Raffles រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០២១នេះ លោកស្រី ជូ ប៊ុនអេង បានលើកឡើងថា វាជាការព្រួយបារម្ភចំពោះ រាជរដ្ឋាភិបាលលើពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃនោះ ដោយសារពួកគេអាចនឹងបន្តប្រឈមនឹង ការចាញ់បោកពួកអគតិមួយចំនួន

តូច (មេខ្យល់) បោកបញ្ឆោតពួកគេតាមរូបភាពផ្សេងៗ ក្នុងអំឡុងដែលពួកគាត់មិនអាចដើរ ចល័តរកការងារធ្វើបាននៅប្រទេសថៃនោះ។ យ៉ាងណាក៏ដោយលោកស្រី ជូ ប៊ុនអេង ក៏បានអះអាងជាថ្មីទៀតផងដែរថា នាពេលបច្ចុប្បន្ននេះអាជ្ញាធរកម្ពុជា បានសហការគ្នាជាមួយសមត្ថកិច្ចថៃ កំពុងបន្តស្រាវជ្រាវស្វែងរកចាប់មេខ្យល់ ដែលបោកប្រជាពលរដ្ឋខ្មែរឲ្យផ្សងគ្រោះថ្នាក់ ឆ្លងកាត់ព្រំដែនប្រទេសកម្ពុជា និងប្រទេសថៃ ខណៈដែលប្រទេសថៃបានរឹតត្បិតការដើរ ចល័តរបស់ពលករបរទេសនោះ។ នៅក្នុងកិច្ចសម្ភាសន៍នោះដែរ លោកស្រី ជូ ប៊ុនអេង ក៏បានឲ្យដឹងផងដែរថា រហូតមកដល់ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១នេះ ពលករខ្មែរដែលបានចាកចេញពី ប្រទេសថៃចូលមកកម្ពុជាវិញ គឺមានប្រហែលជាង ១៣ម៉ឺននាក់ ប៉ុន្តែពួកគេក៏ត្រូវបានអាជ្ញាធរកម្ពុជា ធ្វើការឃាត់ខ្លួនឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ស្របទៅតាមការណែនាំរបស់រាជរដ្ឋាភិបាល ក៏ដូចក្រសួងសុខាភិបាលកម្ពុជាផងដែរ។

សូមបញ្ជាក់ផងដែរថា រហូតមកដល់ថ្ងៃទី១២ ខែមករានេះ ពលករខ្មែរដែលបានចាក់ចេញពី ប្រទេសថៃមកកម្ពុជាវិញ ត្រូវបានរកឃើញឆ្លងមេរោគកូវីដ១៩ចំនួន ២៧នាក់ ខណៈរាប់រយនាក់ទៀត កំពុងបន្តធ្វើចត្តាឡីស័កនោះ ៕

## សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍របស់កម្ពុជា

https://www.cen.com.kh/ January 12, 2021

ភ្នំពេញ៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានធ្វើសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍របស់កម្ពុជា និងការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ នេះ ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងប្រាប់ក្រុមអ្នកកាសែតថា កិច្ចប្រជុំនេះ គឺជាសិក្ខាសាលាថ្នាក់ជាតិ ដើម្បីទៅលើរបាយការណ៍មួយ ដែលហៅថា របាយការណ៍ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍កម្ពុជា និងការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ ហើយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានសហការជាមួយអង្គការ IOM ធ្វើរបាយការណ៍បឋម ដោយក្នុងរបាយការណ៍នោះបានដកស្រង់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលជាចំណុចខ្លាំង និងក៏មានរំលេចចំណុចខ្វះចន្លោះ ចំណុចប្រឈម ដើម្បីធ្វើការកែលំអរ និងដាក់ទិសដៅបន្តថា តើត្រូវធ្វើអ្វីទៀត? ដើម្បីធានាថាទេសន្តរប្រវេសន៍កម្ពុជាមានសុវត្ថិភាពរៀបរយ និងស្របច្បាប់។

លោកស្រីបានបញ្ជាក់ថា "ក្នុងចំនួនដ៏ច្រើននៃពលករដែលចេញធ្វើការងារនៅក្រៅប្រទេស និយាយដោយឡែកតែពលករកម្ពុជា គឺមួយចំនួនបានចេញទៅតាមអនុស្សារណៈ (MOU) ស្របច្បាប់ ដោយមានការរៀបចំឯកសារត្រឹមត្រូវពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទន្ទឹមនឹងនោះក៏មានពលករយើងមួយចំនួនដែលបានប្រថុយប្រថានចេញទៅដោយគ្មានច្បាប់ និងមានពលករមួយចំនួនទៀតអស់សុពលភាពច្បាប់។ ហើយជាពិសេសនៅក្នុងដំណាក់កាលការឆ្លងរាលដាល នៃជំងឺកូវីដ១៩ នៅតាមបណ្តាប្រទេសក៏ដូចជាប្រទេសកម្ពុជា ក៏ដូចជាប្រទេសគោលដៅបាននឹងកំពុងប្រឈមជាមួយនិងការបាត់បង់នូវការងារមួយចំនួនរបស់កម្មករ កម្មការិនី ក៏ដូចជាពលករ ពលការិនី ហើយគាត់ប្រឈមជាមួយនិងជីវភាព ការវិលត្រឡប់មានការលំបាកដោយសារតែមានការបិទព្រំដែន ឬមួយក៏មានការរឹតបន្តឹងនៅតាមប្រទេសគោលដៅមួយចំនួន ជាពិសេសដូចជានៅប្រទេសថៃជាដើមដោយស្នើសុំកុំឲ្យពលករចលាច័តចុះឡើង"។

លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ទៀតថា ទោះបីជាយ៉ាងណាក៏ដោយក៏រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងក្នុងការជួយឧបត្ថម្ភគាំទ្រទៅដល់ប្រជាពលរដ្ឋទូទៅ ដោយមិនគិតថា តែប្រជាពលរដ្ឋនៅក្នុងប្រទេស ឬពលករដែលទើបតែវិលត្រឡប់ទេ ដោយបញ្ចូលនៅក្នុងបញ្ជីប្រជាពលរដ្ឋក្រីក្រ៕ **រក្សាសិទ្ធិដោយៈ ចេស្តារ**

## ក្រសួងកិច្ចការនារីបណ្តុះបណ្តាលគ្រូបង្គោលមូលដ្ឋាន ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស ក្នុងបរិបទកូវីដ១៩

http://btv.com.kh/ 12/01/2021

ឧត្តរមានជ័យ៖ គ្រូបង្គោលថ្នាក់តំបន់ ក្នុងខេត្តឧត្តរមានជ័យ ត្រូវបានបណ្តុះបណ្តាល ស្តីពីសកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់នូវរាល់អំពើជួញដូរស្ត្រី និងកុមារ និងរាល់ទម្រង់ នៃការកេងប្រវ័ញ្ចផ្លូវភេទនៅកម្ពុជា ក្នុងបរិបទកូវីដ–១៩នេះ។

ក្នុងវគ្គបណ្តុះបណ្តាល កាលពីម្សិលមិញ លោកជំទាវ ទេស ច័ន្ទសារឿន អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី បានលើកឡើងថា វគ្គបណ្តុះបណ្តាលគ្រូបង្គោលសំរាប់ថ្នាក់តំបន់ ស្តីពីការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ និងការកេងប្រវ័ញ្ចនាពេលនេះ គឺធ្វើឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពគ្រូបង្គោល ដែលជាសិក្ខាកាមគ្រប់រូបមកពីបណ្តាលខេត្តផ្សេងៗជាប់ព្រំដែន ឱ្យខិតខំធ្វើការផ្សព្វផ្សាយបន្តបន្ថែមទៀត ដល់ពលរដ្ឋនៅតាមបណ្តាលមូលដ្ឋានរបស់ខ្លួន ឱ្យបានទំលំទូលាយពីខ្លឹមសារនានានូវរាល់ការទប់ស្កាត់នូវទង្វើ ជួញដូរស្ត្រី និងកុមារ រួមទាំងអំពើហិង្សាក្នុងគ្រួសារផងដែរ។ លោកជំទាវ បានបញ្ជាក់ថា អ្វីដែលសំខាន់ជាងគេនោះ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងស្ថិតក្នុងបរិបទជំងឺកូវីដ–១៩ ដូច្នេះហើយសម្រាប់ការជួញដូរមនុស្សឆ្លងដែន ពីសំណាក់ជនខិលខូចមួយចំនួនតូចនោះ នៅបន្តមាន នៅតាមព្រំដែន ដែលកត្តាទាំងអស់នេះជាបញ្ហាប្រឈមមួយគួរឱ្យបារម្ភយ៉ាងខ្លាំង ដែល ត្រូវពន្យល់ណែនាំដល់ពលរដ្ឋ កុំឱ្យមានការជឿជាក់លើការលួងលោមបោកបញ្ឆោតរបស់ក្រុមមេខ្យល់ នាំទៅធ្វើការនៅឯប្រទេសជិតខាង។

លោកស្រី មុំ ពុទ្ធីតា អភិបាលរងខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ឧត្តរមានជ័យ គឺជាខេត្តមួយដែលមានព្រំប្រទល់ជាប់ប្រទេសថៃ ដែលពីពេលកន្លងមក តែងតែមានពលរដ្ឋឆ្លងដែនទៅរកការងារនៅ ប្រទេសថៃ តាមច្រកព្រំដែនខេត្តនេះ ហើយក៏ធ្លាប់មានពលករខ្មែរ ចាញ់បោកក្រុមមេខ្យល់ ដែលបានលួងលោមពលរដ្ឋធ្វើចំណាកស្រុកដោយខុសច្បាប់ ដែលជាទង្វើជួញដូរមនុស្ស។ ប៉ុន្តែ សកម្មភាពទាំងនេះ កន្លងមក អាជ្ញាធរខេត្ត តែងតែបានទប់ស្កាត់បានមួយចំនួនធំ៕ អត្ថបទ៖ ឃិន សារិទ្ធ

## រដ្ឋបាលខេត្តសៀមរាប បង្ហាញយុទ្ធសាស្ត្រចំនួន៤ចំនុច ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ឆ្នាំ២០២១ !

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១

(សៀមរាប)៖ កាលពីរសៀលថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានដឹកនាំកិច្ចប្រជុំពិនិត្យ ពិភាក្សាលើផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តនៅក្នុងឆ្នាំ២០២១ ដើម្បីធ្វើការផ្លាស់ប្តូរមតិយោបល់សំខាន់ៗ និងការចូលរួមសហការពីអង្គការដៃគូជាតិ អន្តរជាតិ ក្នុងការរួមគ្នាទប់ស្កាត់ បង្ក្រាប ការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស និងរំលោភបំពានទៅលើស្ត្រី និងកុមារតាមគ្រប់រូបភាព ដោយពិធីនេះមានការអញ្ជើញចូលរួមពីមន្ទីរជំនាញ អង្គការដៃគូជាតិ និងអន្តរជាតិចំនួនចំនួនផងដែរ។

ក្នុងឱកាសនោះ លោកស្រី យូ សុភា បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៤ចំនុច ដែលជាផែនការសម្មភាព សម្រាប់អនុវត្តក្នុងឆ្នាំ២០២១ ដោយផ្អែកលើកផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០១៩-២០២៣) និងផ្តោតទៅលើ បញ្ហាតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋាន ក្នុងនោះរួមមាន៖ទី១.ពង្រឹងកិច្ចសហប្រតិបតិបត្តិការ ការកសាង និងអនុវត្តច្បាប់គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា,ទី២.ការលើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ,ទី៣.ការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទី៤ គឺការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

លោកស្រីអភិបាលរងខេត្ត ក៏បានជំរុញលើកទឹកចិត្តដល់មន្ទីរ អង្គភាពជំនាញ និងអង្គការដៃគូទាំងអស់ធ្វើការពិនិត្យ និងលើកឡើងនូវធាតុចូលក៏ដូចជាការលើកអំពីសកម្មភាពដែលឆ្លើយតបទៅនឹងបញ្ហាប្រឈម នៅក្នុងក្រុង ស្រុកគោលដៅនីមួយៗ និងបានអនុញ្ញតឱ្យដាក់បញ្ចូលសកម្មភាព នៅក្នុងផែការសកម្មភាពរបស់លេខាធិការដ្ឋានសម្រាប់ឆ្នាំ២០២១។ ការរៀបចំផែនការសកម្មភាព ដើម្បីងាយស្រួលក្នុងការអនុវត្តរួមគ្នា ដោយមានកិច្ចសហការគ្នារវាងស្ថាប័នរដ្ឋ ជាមួយអ្នកពាក់ព័ន្ធ និងអង្គការដៃគូ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនានា ពិសេសការកេងប្រវ័ញ្ចទៅលើស្ត្រី និងកុមារ។៕ ដោយៈ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយៈ ធូ កុសល

## នគរបាលការពារព្រំដែនគោក៨១៥ ទទួលពលករខ្មែរ២៧នាក់ ទើបត្រឡប់ពីថៃ និងបញ្ជូនទៅធ្វើចត្តាឡីស័ក

http://www.freshnewsasia.com/ 2021-01-12 12:14pm

**(បន្ទាយមានជ័យ)៖** ក្នុងកំឡុងពេលប្រទេសថៃ កំពុងមានសន្ទុះកើនឡើង នៃការឆ្លងជំងឺកូវីដ១៩ ក្នុងសហគមន៍ ដែលបង្កឱ្យមានការភ័យខ្លាចនោះ ធ្វើឱ្យពលករខ្មែរជាច្រើនត្រូវបង្ខំចិត្តត្រឡប់មកស្រុកកំណើតវិញ កម្លាំងនគរបាលការពារព្រំដែនគោកវរលេខ៨១៥ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ឈរជើងនៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ បានរៀបចំទទួលពលករខ្មែរចំនួន២៧នាក់បន្ថែមទៀត រួចបញ្ជូនទៅធ្វើចត្តាឡីស័ក តាមវិធានសុខាភិបាលនៅស្រុកម៉ាឡៃ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានឱ្យដឹងថា ដោយមានការយកចិត្តទុកដាក់ពីសំណាក់ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្ត លោកបានចាត់ឱ្យកម្លាំងក្រោមឱវាទរៀបចំចាត់ចែងតាមភារកិច្ចរៀងៗខ្លួន ដើម្បីនាំពលករខ្មែរទាំងអស់ដែលវិលត្រឡប់មកពីប្រទេសថៃវិញ ដើម្បីបញ្ជូនទៅកាន់មណ្ឌលធ្វើចត្តាឡីស័ក តាមវិធានសុខាភិបាលឱ្យបានខ្ជាប់ខ្ជួន។ លោកវរសេនីយ៍ឯក សួង សៅ បានបន្តថា កម្លាំងនគរបាលជំនាញ បានរៀបចំ និងត្រៀមកម្លាំងតាមខ្សែបន្ទាត់ព្រំដែន ដោយរង់ចាំទទួលពលករខ្មែរ ដែលបានប្រាប់មុខស្រុកកំណើតវិញ ក្នុងនោះកម្លាំងឈរជើង នៅចំណុចនគរបាល ការពារព្រំដែនប៉ុស្តិ៍ចំបក់ ក្នុងភូមិបឹងបេង ឃុំបឹងបេង ស្រុកម៉ាឡៃ។ លោកថា លោកអនុសេនីយ៍ឯក ប៉ុន គុណ នាយប៉ុស្តិ៍វរសេនាតូការពារព្រំដែនគោកលេខ៨១៥, លោកវរសេនីយ៍ត្រី មាស ម៉េងហ៊ួង មេបញ្ជាការរងនគការពារព្រំដែនគោក៨១៥, លោកអនុសេនីយ៍ឯក អ៊ុន វណ្ណៈ នាយប៉ុស្តិ៍រដ្ឋបាលឃុំបឹងបេង និងផ្នែកយោធាសឹងរងស្រុកម៉ាឡៃ បានសហការគ្នា កាលពីយប់ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ទទួលពលករខ្មែរ ដែលអាជ្ញាធរថៃចាប់បញ្ជូនពួកគាត់មកតាមច្រករបៀង របស់ប៉ុស្តិ៍ចំបក់នគបាលការពារព្រំដែនគោកវរសេនាតូច៨១៥។

បើតាមរបាយការណ៍របស់សមត្ថកិច្ច បានឱ្យដឹងថា ពលករខ្មែរចំនួន ២៧នាក់ ក្នុងនោះមានស្ត្រី១០នាក់ និងកុមារ៤នាក់។ សមត្ថកិច្ចបានឱ្យដឹងទៀតថា បន្ទាប់ពីបានទទួលពលករខ្មែររួចមក លោកអនុសេនីយ៍ឯក ប៉ុន គុណ បានអប់រំណែនាំពួកគាត់ចំពោះបញ្ហាជំងឺកូវីដ១៩ ដែលកំពុងមានសន្ទុះឆ្លងរីករាលដាលក្នុងសហគមន៍ នៅ

ប្រទេសថៃ និងសូមប្រជាពលរដ្ឋអនុវត្តន៍តាមការណែនាំរបស់រដ្ឋាភិបាល ក៏ដូចជាក្រសួងសុខាភិបាល។ បន្ទាប់ពីធ្វើការអប់រំណែនាំរួច ពលករខ្មែរទាំង២៧នាក់ ត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ក្នុងស្រុកម៉ាឡៃ តាមការណែនាំរបស់ក្រសួងសុខាភិបាល៕

## ពលរដ្ឋខ្មែរត្រូវថៃដោះលែងចេញពីពន្ធនាគារហើយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ម៉ោង ១៣:២១ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អាជ្ញាធរថៃបានដោះលែងពលរដ្ឋខ្មែរចំនួន១៣នាក់ឱ្យមានសេរីភាពវិញ ក្រោយពីចាប់ខ្លួនដាក់ពន្ធនាគារ និងបាននាំមកប្រគល់ឱ្យអាជ្ញាធរកម្ពុជាវិញតាមច្រកទ្វារអន្តរជាតិជាំ ស្ថិតក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង កាលពីរសៀលថ្ងៃទី៩ ខែមករាឆ្នាំ២០២១ ។ ពលរដ្ឋខ្មែរទាំង១៣នាក់នេះ មាន ៖

១-ឈ្មោះ រឿន រិត ភេទប្រុស អាយុ៣៤ឆ្នាំ

២-ឈ្មោះ វ៉េត គីម ភេទប្រុស អាយុ៥២ឆ្នាំ

៣-ឈ្មោះ សី តុលា ភេទប្រុស អាយុ៣០ឆ្នាំ

៤-ឈ្មោះ ប៉ាន់ វណ្ណា ភេទប្រុស អាយុ៣៣ឆ្នាំ

៥-ឈ្មោះ បូ ផាន់ណា ភេទប្រុស អាយុ៤៦ឆ្នាំ

៦-ឈ្មោះ ញ៉ែម ទិត្យ ភេទប្រុស អាយុ៣០ឆ្នាំ។

អ្នកទាំង៦នាក់ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

៧-ឈ្មោះ លី ឌី ភេទប្រុស អាយុ៣៨ឆ្នាំ រស់នៅភូមិត្រពាំងបី ឃុំព្រះប្រឡាយ

៨-ឈ្មោះ ស៊ីម សំអាត ភេទប្រុស អាយុ៥២ឆ្នាំ នៅភូមិត្រាំប៉ោង ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ

៩-ឈ្មោះ ទិន តុល ភេទប្រុស អាយុ៥៥ឆ្នាំ នៅភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ

១០-ឈ្មោះ ម៉េត វុទ្ធា ភេទប្រុស អាយុ២៧ឆ្នាំ រស់នៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ

១១-ឈ្មោះ លួត លេន ភេទប្រុស អាយុ២៤ឆ្នាំ រស់នៅភូមិកន្ទួត ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

១២-ឈ្មោះ ស៊ឹង គង់ ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិ៣ ឃុំល្វា ស្រុកចំការលើ ខេត្តកំពង់ចាម និង

១៣-ឈ្មោះ វុត រ៉េត ភេទប្រុស អាយុ៥៦ឆ្នាំ រស់នៅភូមិកន្ទួត ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។

អ្នកទាំង៧នាក់ក្រោយនេះ ត្រូវទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ។ពលរដ្ឋខ្មែរទាំង១៣នាក់ ជាប់ចោទពីបទឆ្លងដែនទៅកាប់គ្រញូង ចូលតាមច្រកអូរស្វាយ និងត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារនៅស្រុកខាន់ថាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ ។

ពួកគាត់ទាំង១៣នាក់និយាយថា ដោយសារក្រុមគ្រួសារមានជីវភាពក្រីក្រពេកនិងស្វែងរកការងារធ្វើពុំបានផង ទើបសម្រេចចិត្តធ្វើដំណើរទាំងប្រថុយប្រថានចាកចេញពីផ្ទះ ធ្វើចំណាកស្រុកឆ្លងដែនចូលទៅប្រទេសថៃរុករកកាប់គ្រញូងក្នុងដីថៃហើយស្ពាយចូលដីខ្មែរ យកមកលក់បានកម្រៃចិញ្ចឹមជីវិត។ ប៉ុន្តែជាអកុសល ត្រូវក្រុមទាហានថៃចាប់ខ្លួននាំទៅដាក់ពន្ធនាគារខេត្តស៊ីសាកេតដែលអ្នកខ្លះជាប់១ទៅ២ឆ្នាំនិងទើបបានដោះលែងវិញនៅពេលនេះ ។

មន្ត្រីបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំ បានឱ្យដឹងថា ពលរដ្ឋខ្មែរដែលអាជ្ញាធរថៃចោទពីបទឆ្លងដែនទៅកាប់គ្រញូង និងបានដោះលែងនាំមកប្រគល់ឱ្យអាជ្ញាធរកម្ពុជាវិញនេះ គឺសមត្ថកិច្ចកម្ពុជាបានធ្វើការណែនាំ និងឱ្យធ្វើកិច្ចសន្យាបញ្ឈប់ការឆ្លងដែនដោយខុសច្បាប់តទៅទៀត ។ បន្ទាប់មក សមត្ថកិច្ចបានប្រគល់ពួកគាត់ទាំង១៣

នាក់ ទៅឲ្យគ្រូពេទ្យនាំទៅធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក ក្នុងស្រុកអន្លង់វែង មុនពេលអនុញ្ញាតឱ្យត្រឡប់ទៅជួបជុំគ្រួសារវិញ ដែលនេះជាវិធានការសុខាភិបាល ៕

## វេទិការស្តីពី ចំណាកស្រុកប្រកបដោយសុវត្ថិភាព ខេត្តព្រះវិហារ

https://m.facebook.com/pg/CentralCambodiaOrg/ 12-01-2021 ម៉ោង 10:01 AM

ក្នុងរយះពេល៣ថ្ងៃ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) បានរៀបចំវេទិការស្តីអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដោយចាប់ពីថ្ងៃទី ០៩ ដល់១១ ខែមករា ឆ្នាំ២០២១នេះ ចំនួន២ឃុំ គឺឃុំត្នំពេញ និងឃុំត្បែង២ ស្រុកគូលែន ខេត្តព្រះវិហារ ដោយមានអ្នកចូលរួមចំនួន ២៧៩នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ២១៦នាក់ ក្រោមកិច្ចសហការជាមួយអង្គការ CARITAS Cambodia ប្រចាំខេត្តព្រះវិហារ ព្រមទាំងអាជ្ញាធរភូមិឃុំត្នំពេញ និងឃុំត្បែង២ របស់ស្រុកគូលែន ខេត្តព្រះវិហារផងដែល។ ក្រៅពីការរៀបចំនូវវេទិការនេះ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) ក៏បានផ្តល់នូវចំណេះដឹងបែបស៊ីជម្រៅក្នុងធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ក្រុមគ្រូបង្គោលក៏ដូជាមន្ត្រីអាជ្ញាធរ នៅក្នុងឃុំទាំង២ ខាងលើនេះប្រមាណជា ១០នាក់ផងដែល ក្នុងគោលបំណងពង្រឹងចំណេះដឹង ដល់ពួកគាត់ក្នុងចុះអប់រំបន្តដល់មូលដ្ឋានដទៃទៀត។

## ថ្ងៃទី១៤ ខែ មករា ឆ្នាំ២០២១

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ និងលើកទិសដៅបន្តឆ្នាំ២០២១ របស់រដ្ឋបាលស្រុកក្រឡាញ់

https://www.facebook.com/deputygovernoryousophear/ 13-01-2021

នៅព្រឹកថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២១ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅបន្តឆ្នាំ២០២១ ដែលរៀបចំដោយក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃរដ្ឋបាលស្រុកក្រឡាញ់ ដែលដឹកដោយ លោកស្រី ម៉ននី រង្សី អភិបាល នៃគណៈអភិបាលស្រុក និងជាប្រធានក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកក្រឡាញ់ ព្រមទាំងមានការអញ្ជើញចូលរួមពីលោកស្រីអភិបាលរងស្រុក ប្រធានក្រុមប្រឹក្សាឃុំ ប្រធានការិយាល័យជុំវិញស្រុក និងអង្គការដៃគូ សរុប ២៨នាក់ ស្រី ០៦នាក់ នៅសាលប្រជុំសាលាស្រុកក្រឡាញ់។

លោកស្រី ម៉ននី រង្សី អភិបាល នៃគណៈអភិបាលស្រុក និងជាប្រធានក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកក្រឡាញ់ បានធ្វើការត្រួតពិនិត្យការងាររយៈពេលពេញមួយឆ្នាំ២០២០ ដែលក្រុមការងារនៃរដ្ឋបាលស្រុកព្រមទាំងរដ្ឋបាលឃុំទាំង១០ និងអង្គការដៃគូទាំងអស់ ដែលបានអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ បន្ថែមពីនោះលោកស្រី អភិបាលស្រុក បានដាក់ទិសដៅជា ផែនការសកម្មភាពសម្រាប់អនុវត្តបន្តនៅក្នុងឆ្នាំ២០២១ រួមមាន៖ ១.ការរៀបចំកិច្ចប្រជុំជាទៀងទាត់សម្រាប់ធ្វើការត្រួតពិនិត្យ ពិភាក្សារកដំណោះស្រាយលើបញ្ហាពាក់ព័ន្ធ ២. ពង្រឹងកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ ក្នុងការបង្ការទប់ស្កាត់ តាមរយៈការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយស្របច្បាប់ ផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ច្បាប់ពាក់ព័ន្ធនិងការឱកាសការងារក្នុងស្រុក និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ៣. ពង្រឹងការគ្រប់គ្រង ចំណាក និងចំណូលស្រុក ពង្រឹងការធ្វើចត្តាឡីស័ក និងការផ្តល់សេវាសមស្របជូនបងប្អូនប្រជាពលរដ្ឋរងគ្រោះ និងងាយរងគ្រោះ។

មានប្រសាសន៍នៅក្នុងកិច្ចប្រជុំបូកសរុបនេះផងដែរ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានថ្នាក់ខេត្ត បានជំរុញ និងលើកទឹកចិត្ត ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ ស្រុក និងថ្នាក់ឃុំ លើការរៀបចំផែនការសកម្មភាព និងផែនការថវិកា ដើម្បីស្វែងរកការគាំទ្របន្ថែមពីអង្គការដៃគូពាក់ព័ន្ធ សម្រាប់អនុវត្តសកម្មភាពដែលជាតម្រូវការចំបាច់ ដើម្បីឆ្លើយតបទៅបញ្ហាប្រឈមនៅក្នុងមូលដ្ឋាន និងជំរុញឱ្យរៀបចំកិច្ចប្រជុំជាទៀងទាត់ ដើម្បីធ្វើការតាមដាន និងមានដំណោះស្រាយជាប្រចាំរាល់បញ្ហាទាក់ទងនឹងអំពើជួញដូរមនុស្ស ឬ ការរំលោភបំពាននានាលើស្ត្រី និងកុមារ។

## អាជ្ញាធរខេត្ត ព្រមានដល់មេខ្យល់ នាំពលករខ្មែរ ឆ្លងតាមច្រករបៀង នៅព្រំដែន នឹងមិនលើកលែង បើនៅតែបន្ត

https://www.rasmeinews.com/ 13 January, 2021

**ដោយៈ អូរស្មាច់ / ឧត្តរមានជ័យៈ** *លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានព្រមាន ជាសាធារណៈ ដល់មេខ្យល់ដែលនៅបន្តធ្វើសកម្មភាព លបលួចនាំពលករខ្មែរ ធ្វើចំណាកស្រុក ឆ្លងព្រំដែនតាមច្រករបៀង ចូលទៅស្វែងរកការងារធ្វើ ក្នុងស្រុកថៃ នឹងគ្មានការលើកលែង បើអាជ្ញាធរ សមត្ថកិច្ច ក្នុងតំបន់រកឃើញ។* លោកអភិបាលខេត្ត បានលើកឡើងបែបនេះ នាពេលថ្មីៗនេះ ក្រោយពីលោកទទួលបាននូវព័ត៌មាន ពីអាជ្ញាធរ សមត្ថកិច្ច កងកម្លាំងយោធា ប៉ូលិស ដែលកំពុងឈរជើងការពារ តាមតំបន់ច្រករបៀង នៅព្រំដែន និងបានឃាត់ខ្លួន រួចអប់រំពលរដ្ឋទាំងនោះ ឲ្យត្រឡប់ទៅលំនៅឋានវិញ ជាច្រើននាក់។ លោកបានបន្តថាៈ បច្ចុប្បន្ន បញ្ហាជំងឺកូវីដ-១៩ នៅលើពិភពលោក មិនទាន់មានសភាព ធូរស្បើយនៅឡើយ ពោលគឺប្រទេសថៃ រវាងខេត្ត និងខេត្ត ជាប់ព្រំដែនកម្ពុជា កំពុងតែមានការប្រឈមខ្ពស់ នូវជំងឺកូវីដ.១៩ ហើយប្រជាពលរដ្ឋ ដែលតែងតែមានបំណង ចង់ចំណាកស្រុក ទៅធ្វើការងារ នៅឯប្រទេសថៃ មិនត្រូវចាញ់បោក តាមការលួងលោម អូសទាញ តាមរយៈក្រុមមេខ្យល់នោះឡើយ។

លោក ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាល ខេត្តឧត្តរមានជ័យ បានឱ្យដឹងថាៈ ពលករខ្មែរ ឆ្លងដែនចេញពីថៃ ចូលមកកម្ពុជា ចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ដល់ពេលនេះ មានចំនួនប្រមាណជាង ២.០០០ នាក់ បានចូលធ្វើចត្តាឡីស័ក រយៈពេល ១៤ ថ្ងៃ តាមការណែនាំរបស់ ក្រសួងសុខាភិបាល នៅតាមមណ្ឌលវិទ្យាល័យ ដែលបានត្រៀមទុក តាមស្រុក ក្រុង ក្នុងខេត្ត។ បច្ចុប្បន្ន ចំនួនភាគច្រើន បានធ្វើចត្តាឡីស័ក គ្រប់ចំនួនថ្ងៃបា នចេញជាបន្តបន្ទាប់។

លោក ប៊ុច រតនា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តឧត្តរមានជ័យ បានឲ្យដឹងថាៈ គ្រឹះស្ថានសិក្សា រួមមាន វិទ្យាល័យ អនុវិទ្យាល័យ និងបឋមសិក្សា ដើម្បីបានធ្វើជាមណ្ឌលចត្តាឡីស័ក សម្រាប់ពលករខ្មែរ ស្នាក់នៅបណ្តោះអាសន្ន មានចំនួន ១៣ សាលា ទទួលមនុស្សសរុប ២.០៨៤ នាក់ គិតមកដល់ពេលនេះ៕/V

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២១

(សៀមរាប)៖ នៅថ្ងៃពុធ ទី១៣ ខែមករា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រក

ដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៧នាក់ ស្រី ១៨នាក់ ក្នុងនោះកុមារា ៥នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់

-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៧នាក់ ស្រី ៦នាក់ កុមារា ២នាក់ កុមារី ០០នាក់

-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៩នាក់ ស្រី ៧នាក់ កុមារា ៣នាក់ កុមារី ១នាក់

-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១១នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់

-ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣៦នាក់, ឧត្តរមានជ័យចំនួន ១១នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## លោកស្រីវេជ្ជបណ្ឌិត ឱ វណ្ណឌីន ៖ សូមបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ក្នុងការធ្វើចត្តាឡីស័កពលករខ្មែរ ត្រឡប់ពីប្រទេសថៃ

https://grandnewsasia.com/ 13-01-2021

ប៉ៃលិន៖ លោកស្រីវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល បានជំរុញដល់អាជ្ញាធរខេត្តប៉ៃលិន និងមន្ត្រីសុខាភិបាល នៃមន្ទីរសុខាភិបាលខេត្តទាំងអស់ ត្រូវយកចិត្តទុកដាក់ខ្ពស់ លើការធ្វើចត្តាឡីស័កដល់ប្រជាពលរដ្ឋខ្មែរដែលមានការសង្ស័យ ឱ្យបានត្រឹមត្រូវច្បាស់លាស់ ជាពិសេសពលករដែលទើបត្រឡប់មកពីប្រទេសថៃវិញ ដើម្បីការពារពីជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍។ លោកស្រីបានមានប្រសាសន៍បែបនេះ ក្នុងឱកាសអញ្ជើញដឹកនាំប្រតិភូ និងតំណាងអង្គការ សុខភាព ពិភពលោកនៅកម្ពុជា ជួបសំណេះសំណាល និងពិភាក្សាការងារ ជាមួយអាជ្ញាធរខេត្តប៉ៃលិន និងថ្នាក់ដឹកនាំមន្ទីរសុខាភិបាលខេត្ត ដែលដឹកនាំដោយលោកស្រីបាន ស្រីមុំ អភិបាលខេត្ត នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ នៅសាលប្រជុំសាលាខេត្ត ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីរួមទប់ស្កាត់ការចម្លងរីករាលដាលជម្ងឺកូវីដ-១៩។

លោកស្រីវេជ្ជបណ្ឌិត ឱ វណ្ណឌីន បានមានប្រសាសន៍លើកឡើងថា៖ បញ្ហាជំងឺកូវីដ-១៩ គឺកំពុងតែក្តៅគគុកចំពោះពលករដែលឆ្លងដែនពីប្រទេសថៃចូលមកកម្ពុជា ជាពិសេសខេត្តប៉ៃលិន ដែលកំពុងមានអ្នកជម្ងឺកូវីត-១៩ ជាបន្តបន្ទាប់ ដូច្នេះទាមទារអោយអាជ្ញាធរខេត្ត និងមន្ទីរសុខាភិបាលខេត្ត យកចិត្តទុកដាក់ខ្ពស់ ក្នុងចូលរួមទប់ស្កាត់ការចម្លងរីករាលដាលជម្ងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ដោយពលករឆ្លងដែនពីប្រទេសថៃ គឺត្រូវពិនិត្យសុខភាពឱ្យបានម៉ត់ចត់ត្រឹមត្រូវ និងធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃសិន មុននឹងឱ្យពួកគាត់ ត្រឡប់ទៅគេហដ្ឋានវិញ។

នៅក្នុងឱកាសនោះផងដែរ លោកស្រីវេជ្ជបណ្ឌិត រដ្ឋលេខាធិការ បានមានប្រសាសន៍កោតសសើរ ចំពោះការខិតខំប្រឹងប្រែងរបស់អាជ្ញាធរខេត្តប៉ៃលិន និងស្ថាប័នពាក់ព័ន្ធ ដែលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការចូលរួមប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ព្រមទាំងកិច្ចការងារផ្សេងៗទៀត ដែលក្រសួងសុខាភិបាលបានជូនដំណឹងជាបន្តបន្ទាប់នាពេលកន្លងមក ស្របតាមយន្តការស្តង់ដាសុខភាពពិភពលោក ក្នុងនោះឃើញថាខេត្តប៉ៃលិនបានអនុវត្តន៍ប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុត ជាពិសេសសូមលើកទឹកចិត្តដល់ក្រុមគ្រូពេទ្យជំនាញទាំងអស់ ដែលកំពុងបំពេញបេសកកម្មដ៏ថ្លៃថ្លានេះ សម្រាប់ប្រទេសជាតិ និងប្រជាជន ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈគ្រូពេទ្យ និងការទទួលខុសត្រូវខ្ពស់។

លោកស្រី បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍ឱ្យដឹងថា៖ បន្ទាប់ពីទទួលបានបទ បញ្ជាពីរាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីណែនាំនានា របស់ក្រសួងសុខាភិបាល អាជ្ញាធរខេត្តប៉ៃលិន បានដាក់ កម្លាំងចម្រុះ

ប្រចាំការ២៤ម៉ោ/២៤ម៉ោ នៅតាមព្រំដែនជាមួយប្រទេសថៃ និងតាមច្រកធម្មជាតិ ចំនួន ២៥គោលដៅ ដើម្បីត្រួតពិនិត្យពលករដែលឆ្លងដែន ព្រមទាំងបានត្រៀមមណ្ឌលចត្តាឡីស័កកម្រិត១ និងកម្រិត២ សរុប ៥កន្លែង ក្នុងនោះកម្រិត១ ចំនួន៤កន្លែង និងកម្រិត ២ចំនួន ១កន្លែង ព្រមទាំងបានផ្តល់នូវថវិកាលើកទឹកចិត្ត ដល់មន្ត្រី ប្រចាំការ និងក្រុមគ្រូពេទ្យផងដែរ។

សូមបញ្ជាក់ថា៖ ខេត្តប៉ៃលិនគិតដល់ពេលនេះ បានរកឃើញពលករដែលឆ្លងដែន មកពីប្រទេសថៃ ចំនួន ១៣នាក់ វិជ្ជមានជម្ងឺកូវីត-១៩ ក្នុងនោះបានព្យាបាលជាសះស្បើយចំនួន ០៦នាក់ និងចំនួន ០៧នាក់ទៀត កំពុងសម្រាកព្យាបាល នៅក្នុងមណ្ឌលផ្ទះសំណាក់គ្រូបង្រៀនខេត្ត៕

## នាយឧត្តមសេនីយ៍ អ៊ី ឈាន ៖ ពង្រឹងសមត្ថកិច្ចកងទ័ពនៅតាមព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩

https://grandnewsasia.com/ 13-01-2021

ប៉ៃលិន៖ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ នាយឧត្តមសេនីយ៍ អ៊ី ឈាន ប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាចុះមូលដ្ឋានខេត្តប៉ៃលិន និងជារដ្ឋលេខាធិការ ក្រសួងការពារជាតិ និងលោក សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន ព្រមទាំងក្រុមការងា បានអញ្ជើញចុះជួបសំណេះ សំណាលសាកសួរសុខទុក្ខ និងបាននាំយកគ្រឿងឧបភោគបរិភោគ ទៅឧបត្ថម្ភដល់កងកម្លាំងចម្រុះ ដែលកំពុងបំពេញបេសកកម្ម ការពារតាមគោលដៅ ខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដើម្បីត្រួតពិនិត្យការឆ្លងដែនរបស់ពលករខ្មែរ មកពីប្រទេសថៃចូលមកខេត្តប៉ៃលិន តាមច្រកធម្មជាតិនានា ហើយបញ្ជូនមកធ្វើចត្តាឡីស័ក ក្រោមការពិនិត្យ និងតាមដានសុខភាព ដោយការយកចិត្តទុកដាក់ខ្ពស់ពីក្រុមគ្រូពេទ្យជំនាញ ក្នុងការបង្ការ និងទប់ស្កាត់ការចម្លងរីករាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍។ នាយឧត្តមសេនីយ៍ អ៊ី ឈាន ប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាចុះមូលដ្ឋានខេត្តប៉ៃលិន បានមានប្រសាសន៍លើកឡើងថា៖ ការពង្រឹងសមត្ថកិច្ចតាមព្រំដែន គឺជាការអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ឱ្យបណ្តាខេត្តដែលមានព្រំដែន ជាប់នឹងប្រទេសជិតខាង ត្រូវមានការយកចិត្តទុកដាក់ឱ្យបានខ្ពស់ នូវការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ជាពិសេសព្រំដែនកម្ពុជា-ថៃ ដែលមានហានិភ័យខ្ពស់ ចំពោះពលករខ្មែរចំណាកស្រុក ហើយខេត្តប៉ៃលិនគិតដល់ពេលនេះ បានរកឃើញពលករដែលឆ្លងដែន មកពីប្រទេសថៃ ចំនួន ១៣នាក់ វិជ្ជមានជម្ងឺកូវីត-១៩ ក្នុងនោះបានព្យាបាលជាសះស្បើយចំនួន ០៦នាក់ និងចំនួន ០៧នាក់ទៀត កំពុងសម្រាកព្យាបាល នៅក្នុងមណ្ឌលផ្ទះសំណាក់គ្រូបង្រៀនខេត្ត។

លោកប្រធានក្រុមការងារ ក៏បានមានប្រសាសន៍ជំរុញដល់កម្លាំងចម្រុះទាំងអស់ និងមន្ត្រីប្រចាំការនៅតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ត្រូវធ្វើយ៉ាងណាខិតខំតាមដានរាល់សភាពការណ៍ នៃការឆ្លងដែនរបស់ពលករខ្មែរ និងត្រូវប្រចាំការ ២៤ម៉ោ/២៤ម៉ោ តាមគោលដៅដែលខ្លួនទទួលខុសត្រូវ ក្រែងសមត្ថកិច្ចថៃបញ្ជូនពលករខ្មែរត្រឡប់មកវិញ ហើយប្រសិនបើមានមែន មន្ត្រីជំនាញសុខាភិបាលត្រូវពិនិត្យសុខភាព និងធ្វើចត្តាឡីស័ក ១៤ថ្ងៃសិន ដើម្បីទប់ស្កាត់ការចម្លងរីករាលដាលជម្ងឺកូវីដ-១៩ ចូលក្នុងសហគមន៍។ នៅក្នុងឱកាសនោះផងដែរ នាយឧត្តមសេនីយ៍ អ៊ី ឈាន បានមានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះកងម្លាំងចម្រុះ ដែលកំពុងឈរជើងការពារនៅតាមបន្ទាត់ព្រំដែន និងនៅតាមគោលដៅទាំងអស់ ដែលបានខិតខំបំពេញការងារទាំងកំលាំងកាយទាំងកំលាំងចិត្ត ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការរួមគ្នាប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការចម្លងរីករាលដាលជំងឺកូវីដ-១៩ ជាពិសេសសូមលើកទឹកចិត្តដល់ក្រុមគ្រូពេទ្យជំនាញទាំងអស់ ដែលកំពុងបំពេញបេសកកម្មដ៏ថ្លៃថ្លានេះ សម្រាប់ប្រទេសជាតិ។

សូមបញ្ជាក់ថា៖ អំណោយដែលលោក អ៊ី ឈាន ឧបត្ថម្ភជូនដល់កងកម្លាំង ដែលកំពុងប្រចាំការ ទាំង ២៥ គោលដៅ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា+ថៃ ដោយក្នុង ១គោលដៅៗ ទទួលបានរួមមាន៖ អង្ករ ១០០គីឡូក្រាម មី ៣កេះ ត្រីខ ២យួ ទឹកស៊ីអ៊ីវ ១យួ ទឹកសុទ្ធ ៤យួ, ទឹកក្រូច ២កេះ ស្មើនឹង៣ឡូ ម៉ាស់ ៤ប្រអប់ ដែល ១ដុំ ស្មើនឹង ១២ដបតូច ផ្អក ២កែវ ពងទា ២ដុង និងកងកម្លាំង ក្នុងម្នាក់ៗ ទទួលបានថវិកាចំនួន ៣ម៉ឺនរៀលផងដែរ៕

## ថ្ងៃទី១៥ ខែ មករា ឆ្នាំ២០២១

### គិតមកដល់ពេលនេះ សម្រាប់ខេត្តឧត្តរមានជ័យមានពលករធ្វើចត្តាឡីស័កចំនួន២២៨០ នាក់ ដោយចំណាយថវិកាជិត១ម៉ឺនដុល្លារក្នុងមួយថ្ងៃ

http://www.freshnewsasia.com/ 2021-01-14 12:55pm

(ឧត្តរមានជ័យ)៖ លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានថ្លែងថា មកដល់ម៉ោងនេះ បងប្អូនពលករដែលកំពុងធ្វើចត្តាឡីស័កក្នុងខេត្តមានចំនួន២២៨០នាក់ ដោយផ្តល់ការហូបចុកក្នុងមួយថ្ងៃ ៣ពេល ក្នុងនោះចំណាយថវិកាប្រមាណ១០០០០ដុល្លារក្នុងមួយថ្ងៃ។ ការថ្លែងរបស់លោកអភិបាលខេត្តឧត្តរមានជ័យ ក្នុងឱកាសដែលលោកចូលរួមក្នុងពិធីតែងតាំងមន្ត្រីគ្រប់គ្រង នាយក នាយករងវិទ្យាល័យ អនុវិទ្យាល័យនិងបឋមសិក្សាក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការជាច្រើនរូបទៀត នៅព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១នេះ។ លោក ប៉ែន កុសល្យ បានថ្លែងថា ខេត្តតាមបណ្តោយព្រំដែនរួមមាន៖ ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ កំពុងប្រឈមជំងឺកូវីដ១៩ ហើយខេត្តខ្លះមានពលករខ្លះមកពីប្រទេសថៃ មានផ្ទុកមេរោគកូវីដ១៩ ចំណែកខេត្តឧត្តរមានជ័យមានភព្វ័វាសនា មិនមានពលករណាម្នាក់មានផ្ទុកជំងឺកូវីដ១៩នោះទេ។ លោកអភិបាលខេត្ត បានថ្លែងការគោរពដ៏ខ្ពង់ខ្ពស់ចំពោះសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដែលបានផ្តល់ថវិកា និងឃីតសម្រាប់ឧបត្ថម្ភពលករដែលកំពុងធ្វើចត្តាឡីស័កនៅក្នុងខេត្ត។

ករណីនេះអភិបាលខេត្តក៏បានថ្លែងអំពាវនាវឲ្យបងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនប្រជាពលរដ្ឋ ដែលមានបងប្អូនមកពីក្រៅប្រទេស ត្រូវធ្វើការណែនាំឲ្យទៅធ្វើចត្តាឡីស័ក ចៀសវាងគេចវេសសម្ងំនៅក្នុងផ្ទះ ដែលបណ្តាលឲ្យពាក់ព័ន្ធដល់យើង ក្រុមគ្រួសារយើង និងសហគមន៍របស់យើង។ លោកអភិបាលបញ្ជាក់ថា ក្នុងភូមិមួយបើមានបងប្អូនកើតជំងឺកូវីដ១៩ហើយមិនបានទៅពិនិត្យព្យាលឲ្យបានត្រឹមត្រូវទេនោះភូមិនោះអាចប្រឈមការបិទតែម្តង។ លោក ប៉ែន កុសល្យ ក៏បានថ្លែងណែនាំដល់លោកនាយក នាយករង ដែលទទួលបានការតែងតាំងនៅពេលនេះ ត្រូវខិតខំបំពេញភារកិច្ចឲ្យអស់ពីលទ្ធភាព និងសមត្ថភាព ដើម្បីជំនះការលំបាកនានា ពិសេសត្រូវពង្រឹងការ សាមគ្គីភាពគ្នាឲ្យបានល្អជាមួយថ្នាក់ដកនាំ និងមន្ត្រីក្រោមឱវាទដើម្បីធ្វើឲ្យអង្គភាពកាន់តែមានការប្រែប្រួលមុខមាត់ថ្មីថែមទៀត៕

### ពលករ លួចឆ្លងដែនម្នាក់ អស់ជិត ១ពាន់បាត តែត្រូវតម្រួតថៃចាប់!

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២១ ម៉ោង ១៩:០៤ ប៊ុន ធឿន

បន្ទាយមានជ័យ៖ ពលករខ្មែរប្រុសស្រី ចំនួន ៨នាក់ ដែលលួចឆ្លងដែនខុសច្បាប់ តាមរយៈមេខ្យល់ ត្រូវបានតម្រួតថៃ ចាប់នៅចម្ងាយពីព្រំដែនជិត ១គីឡូម៉ែត្រ ក្នុងទឹកដីថៃ កាលពីវេលាម៉ោង ៥ជិតភ្លឺ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ស្ថិតក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ។

មន្ត្រីការងារព្រំដែន បានអោយដឹងថា ប្រជាពលរដ្ឋខ្មែរ ទាំង ៨នាក់នោះ មានស្រី ៥នាក់ និងកុមារ ៣នាក់ បានជិះក្នុងរថយន្តថៃ ដឹកចេញពីព្រំដែន ត្រូវបានតម្រួតថៃ ស្ទាក់ចាប់បាន នៅចម្ងាយជិត ១គីឡូម៉ែត្រ ពីព្រំដែនថៃ-កម្ពុជា ហើយត្រូវបាននាំយក ទៅដាក់ប៉ុស្តិ៍តម្រួតយោធា នៅស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ។ មន្ត្រីដដែល បានបញ្ជាក់ថា នៅពេលដែលតម្រួតថៃឃាត់រថយន្ត ១គ្រឿង ដែលដឹកពលករខ្មែរឆ្លងដែនដោយខុសច្បាប់ ហើយ បានសាកសួរ ពលករខ្មែរទាំងនោះប្រាប់ថា ពួកគាត់ត្រូវថៅកែថៃ ណាត់អោយចូលទៅធ្វើការងារ តាមបន្ទាត់ព្រំដែន កាប់អំពៅ និងដកជំឡូងមីរឺច្រូតស្រូវ ហើយឆ្លងដែន ត្រូវបានមេខ្យល់ នាំឆ្លងដែនម្នាក់ អស់ជិត ១ពាន់បាត។ ឆ្លង ដែនហើយ រថយន្តថៃ ចាំទទួលដឹកដល់កន្លែង។ តែពេលដឹកចេញពីព្រំដែន ត្រូវតម្រួតថៃ ចាប់បាន ហើយធ្វើចត្តា ឡីស័ក ក្នុងប្រទេសថៃតែម្តង។

គួរបញ្ជាក់ថា ភាគីថៃ បានរឹតបណ្តឹងតាមបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ ដើម្បី ទប់ស្កាត់កូវីដ១៩ ហើយកម្ពុជា ក៏កំពុងមានវិធានការទប់ស្កាត់កូវីដ១៩ ដូចគ្នា ដោយដាក់ពង្រាយកម្លាំងឈរជើង តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ផងដែរ។

ពលករខ្មែរ ត្រឡប់ពីប្រទេសថៃ រាល់ថ្ងៃ នៅច្រកអូរបីជាន់ ស្រុកអូរជ្រៅ ក្នុង ១ថ្ងៃ មិនជាង២០០នាក់ទេ។ ពលករទាំងនោះ ត្រូវបានពិនិត្យនៅច្រកព្រំដែន ហើយដឹកទៅធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ នៅមណ្ឌលចត្តាឡី ស័ក ក្នុងខេត្តបន្ទាយមានជ័យ៕ ដោយៈ ប៊ុន ធឿន

## កូវីដ១៩៖ ខេត្តបន្ទាយមានជ័យប្រឈមនឹងការខ្វះមណ្ឌលធ្វើចត្តាឡីស័ក ខណៈពល ករខ្មែរវិលមកពីថៃកាន់តែច្រើនឡើង

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 14/01/2021 - 08:29

គិតមកដល់ពេលនេះករណីឆ្លងជំងឺកូវីដ១៩ ទៅលើពលករខ្មែរមានការកើនឡើងជាបន្តបន្ទាប់ ក្រោយ តែពីពលករខ្មែរបានត្រលប់ចូលប្រទេសវិញ បន្ទាប់ពីមានការផ្ទុះជំងឺកូវីដ១៩ជាសហគមន៍នៅឯប្រទេសថៃកាល ពីខែធ្នូកន្លងទៅ។ នៅចំពោះមុខការរាលដាលជាបន្តបន្ទាប់ អាជ្ញាធរខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ គឺខេត្ត បន្ទាយមានជ័យ បានប្រាប់ឲ្យដឹង នៅថ្ងៃនេះថា ខេត្តបន្ទាយមានជ័យបាននឹងកំពុងអនុវត្តវិធានការសុខាភិបាល យ៉ាងខ្ជាប់ខ្ជួន តែអ្វីដែលគួរឲ្យបារម្ភ គឺខេត្តកំពុងប្រឈមនឹងការខ្វះមណ្ឌលសម្រាប់ឲ្យពលករធ្វើចត្តាឡីស័ក។

លោក លី សារី អ្នកនាំពាក្យខេត្តបន្ទាយមានជ័យ បានប្រាប់វិទ្យុបារាំងអន្តរជាតិនៅថ្ងៃនេះថា ស្ថាន ការណ៍កូវីដ១៩បច្ចុប្បន្ននៅឯខេត្តបន្ទាយមានជ័យ គឺកំពុងស្ថិតនៅក្នុងការគ្រប់គ្រងរបស់អាជ្ញាធរ។ បើតាមការ បញ្ជាក់របស់អ្នកនាំពាក្យ វិធានការសុវត្ថិភាព ដើម្បីបង្ការការរាលដាលជំងឺកូវីដ១៩ ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង ក្នុងអំឡុងពេលដែលខេត្តនៅជាប់ព្រំដែនជាមួយប្រទេសថៃនេះ កំពុងទទួលពលករខ្មែរត្រលប់មកពីប្រទេសថៃ វិញជាបន្តបន្ទាប់។ ក៏ប៉ុន្តែ បើតាមលោក លី សារី មណ្ឌលចត្តាឡីស័កនៅក្នុងខេត្តកំពុងចង្អៀតណែន ដោយសារ តែមានពលករច្រើនត្រូវធ្វើចត្តាឡីស័ក ហើយបច្ចុប្បន្នខេត្តក៏កំពុងយកវិទ្យាល័យសម្តេចឪមួយទៀត ធ្វើជាទីតាំង ចត្តាឡីស័កបន្ថែម។ សរុបមកទល់ពេលនេះ ខេត្តបន្ទាយមានជ័យជាខេត្តដែលមានពលករខ្មែរវិជ្ជមានកូវីដ១៩ ច្រើនជាងគេ ដោយក្នុងចំណោមពលករដែលរកឃើញមានជំងឺកូវីដ១៩ ទាំង៤១នាក់ ខេត្តបន្ទាយមានជ័យមាន ២០នាក់។

រាប់ចាប់តាំងពីថ្ងៃទី៣១ធ្នូ ដែលកម្ពុជារកឃើញពលករខ្មែរមកពីប្រទេសថៃ មានវិជ្ជមានជំងឺកូវីដ១៩ ចំនួន២នាក់មក មកដល់ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១នេះ ករណីរកឃើញវិជ្ជមានជំងឺកូវីដ១៩លើពលករខ្មែរ បានកើនឡើងដល់ទៅ៤១នាក់។ រីឯថ្ងៃទី១៤មករានេះ ក្រសួងសុខាភិបាលបានរកឃើញអ្នកឆ្លងជាពលករខ្មែរ

ចំនួន៨នាក់ ដោយក្នុងនោះ មានស្ត្រី៤នាក់និងបុរសម្នាក់មកពីខេត្តបន្ទាយមានជ័យ ស្ត្រី២នាក់មកពីខេត្តសៀមរាប និងពលករជាស្ត្រីម្នាក់ពីខេត្តបាត់ដំបង។ នេះបើតាមសេចក្តីប្រកាសព័ត៌មានក្រសួងសុខាភិបាលនៅថ្ងៃទី១៤មករា២០២១នេះ។

គួរជម្រាបជូនថា តួលេខចុងក្រោយនៃចំនួនអ្នកឆ្លងជំងឺកូវីដ១៩នៅកម្ពុជា ដល់ពេលនេះ មានចំនួន ៤១១នាក់ ដោយក្នុងនោះមានអ្នកជាសះស្បើយ៣៧៧នាក់ និងអ្នកកំពុងព្យាបាល៣៤នាក់។ នេះបើតាមក្រសួងសុខាភិបាល៕

## រដ្ឋាភិបាល នឹងផ្តល់ជំនួយដល់ពលករនៅប្រទេសម៉ាឡេស៊ីដែលនៅក្រោមភាពអាសន្ន

https://www.khmertimeskh.com/ តាំង រីនិត្យ / Khmer Times

រដ្ឋាភិបាលនឹងផ្តល់ជំនួយដល់ពលករចំណាកស្រុកកម្ពុជាដែលត្រូវការជំនួយក្នុងពេលប្រទេសម៉ាឡេស៊ីស្ថិតក្នុងគ្រាអាសន្ន ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសបាននិយាយកាលពីម្សិលមិញថា«នៅពេលពលករចំណាកស្រុករបស់យើងត្រូវការជំនួយ យើងនឹងជួយពួកគេ»។ ទោះយ៉ាងណា លោកមិនបានផ្តល់ព័ត៌មានជាក់លាក់ទេ។ ការអត្ថាធិប្បាយរបស់លោកធ្វើឡើងនៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាបានជំរុញឲ្យរដ្ឋាភិបាលផ្តល់ជំនួយដល់ពលករចំណាកស្រុកកម្ពុជា បន្ទាប់ពីប្រទេសម៉ាឡេស៊ីប្រកាសអំពីការដាក់ប្រទេសក្នុងគ្រាអាសន្នកាលពីម្សិលមិញ។

ការប្រកាសរបស់ព្រះមហាក្សត្រ Sultan Abdullah Sultan Ahmad Shah ស្តីពីការដាក់ប្រទេសក្នុងគ្រាអាសន្នកាលពីព្រឹកម្សិលមិញបានកើតឡើងអំឡុងពេល ដែលមានការកើនឡើងចំនួនករណីវិជ្ជមាននៃជំងឺកូវីដ-១៩ គួរឲ្យព្រួយបារម្ភ ដែលកាលពីម្សិលមិញឃើញថាចំនួនករណីវិជ្ជមានបានកើនឡើងដល់ ១៣ ០០០ នាក់និងករណីស្លាប់មានចំនួន ៥៥៥ នាក់ជាមួយនិងប្រព័ន្ធសុខាភិបាលរបស់ខ្លួន។ មុនមួយថ្ងៃ រដ្ឋាភិបាលម៉ាឡេស៊ីបានប្រកាសរឹតបន្តឹងការរឹតត្បឹតជំងឺកូវីដ-១៩ ដាក់រដ្ឋចំនួន ៥ និងទឹកដីសហព័ន្ធចំនួន ៣ ក្រោមបទបញ្ជាត្រួតពិនិត្យការធ្វើដំណើរ (MCO) ម្តងទៀតក្នុងរយៈពេល ២សប្តាហ៍។ ហើយក៏ត្រូវបានគេរាយការណ៍ផងដែរថាការដាក់ប្រទេសក្នុងគ្រាអាសន្ននេះនឹងមានរយៈពេលរហូតដល់ខែសីហា ឬមុន អាស្រ័យលើស្ថានភាពនៃជំងឺកូវីដ-១៩នៅក្នុងប្រទេស។

នៅក្នុងបទសម្ភាសន៍ជាមួយកាសែតខ្មែរថាមស៍លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សបាននិយាយថា នេះគឺជាពេលវេលាដ៏សំខាន់បំផុតសម្រាប់ពលករចំណាកស្រុកនៅប្រទេសម៉ាឡេស៊ីដែលអស់រយៈពេលជាច្រើនខែមកហើយដែលបានទទួលរងផលប៉ះពាល់ពីការកើនឡើងនៃជំងឺកូវីដ-១៩។ លោកបន្តថា៖ «ពលករកម្ពុជាភាគច្រើននៅប្រទេសម៉ាឡេស៊ីបានទទួលរងនូវបញ្ហាហិរញ្ញវត្ថុ ដោយសារនិយោជករបស់ពួកគេបានបញ្ឈប់ការងារដោយសារវិបត្តិសេដ្ឋកិច្ច»។ លោកបន្ថែមថាពលករមួយចំនួនថែមទាំងបានចាប់ផ្តើមរស់នៅតាមចិញ្ចើមផ្លូវដោយសារពួកគេមិនមានលទ្ធភាពជួលកន្លែងស្នាក់នៅ ហើយមិនត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងកន្លែងដែលផ្តល់ដោយអតីតនិយោជករបស់ពួកគេ។ លោកនិយាយថា៖ «ឥឡូវនេះ រដ្ឋាភិបាលម៉ាឡេស៊ីបានដាក់ប្រទេសស្ថិតក្នុងគ្រាអាសន្ន វានឹងកាន់តែអាក្រក់ទៅៗសម្រាប់ពលកររបស់យើង ជាពិសេសដោយសារពួកគេមិនអាចវិលត្រឡប់មកផ្ទះវិញដោយសារការហាមឃាត់របស់រដ្ឋាភិបាលកម្ពុជាលើជើងហោះហើរមកពីប្រទេសម៉ាឡេស៊ី»។

យោងតាមក្រសួងការងារ បច្ចុប្បន្នមានប្រជាជនកម្ពុជា ២៥ ១៤៩ នាក់កំពុងរស់នៅនិងធ្វើការនៅប្រទេសម៉ាឡេស៊ី។ នៅពេលក្រុមហ៊ុនកាត់បន្ថយប្រាក់ខែ និងការងារ ដើម្បីដោះស្រាយវិបត្តិសេដ្ឋកិច្ចដោយសារជំងឺរាតត្បាត ពលកររាប់ពាន់នាក់ដែលទទួលបានប្រាក់ឈ្នួលទាប និងមានជំនាញទាបនៅក្នុងប្រទេសម៉ាឡេស៊ីគឺជា

អ្នកដែលងាយរងគ្រោះជាងគេ។ អង្គការពលកម្មអន្តរជាតិ (ILO) បាននិយាយនៅក្នុងរបាយការណ៍មួយថាមានករណីពលករចំណាកស្រុកត្រូវបានបញ្ឈប់ដោយអយុត្តិធម៌ ឬមិនទទួលបានប្រាក់ឈ្នួលនៅពេលដែលមានការបិទប្រទេសលើកដំបូងដោយសារការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នៅទូទាំងប្រទេសនៅក្នុងខែមីនា។ ILO ក៏បាននិយាយផងដែរថា វិធានការណ៍គាំទ្ររបស់រដ្ឋាភិបាលម៉ាឡេស៊ីភាគច្រើនមិនបានជួយដល់ពលករចំណាកស្រុកទេ ហើយសហជីព និងអង្គការដទៃទៀតបានចូលរួមជួយដល់ពលករចំណាកស្រុករួមទាំងការចែកចាយអាហារ និងការផ្តល់កន្លែងស្នាក់នៅដល់ពួកគេផងដែរ។ ទន្ទឹមនឹងនេះ ជើងហោះហើរដែលចេញពីប្រទេសម៉ាឡេស៊ីត្រូវបានហាមឃាត់មិនឲ្យចុះចតនៅប្រទេសកម្ពុជាចាប់តាំងពីខែកក្កដាឆ្នាំ ២០២០ ។

លោក មឿន តុលា បានស្នើរដ្ឋាភិបាលឲ្យផ្តល់ជំនួយបន្ទាន់ដល់ពលករចំណាកស្រុកកម្ពុជា ដើម្បីឲ្យពួកគេអាចរស់បានក្នុងពេលលំបាកនេះ។ លោកបាននិយាយថា៖ «ជាបឋម រដ្ឋាភិបាលកម្ពុជា តាមរយៈស្ថានទូតរបស់ខ្លួននៅប្រទេសម៉ាឡេស៊ីគួរតែផ្តល់នូវស្បៀងអាហារ និងសម្ភារៈចាំបាច់ផ្សេងៗដល់ពលករចំណាកស្រុកកម្ពុជាដែលគ្មានការងារធ្វើ។ ទីពីរ ស្ថានទូតគួរតែជួយកម្មករចរចាជាមួយម្ចាស់ដីរបស់ពួកគេដើម្បីបញ្ចុះថ្លៃឈ្នួលសម្រាប់ការស្នាក់នៅរបស់ពួកគេដែលមានសារៈសំខាន់ណាស់នៅពេលនេះ»។ លោកបន្ថែមថាទោះបីជាការរៀបចំសម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់ពលករចំណាកស្រុកកម្ពុជាដែលគ្មានការងារធ្វើអាចជាដំណោះស្រាយដ៏ល្អបំផុតក៏ដោយ ក៏វាមិនអាចកើតឡើងបានដែរនៅពេលនេះដោយសារតែការរឹតត្បិតការធ្វើដំណើរដែលបានកំណត់ដោយប្រទេសកម្ពុជា និងម៉ាឡេស៊ី។ លោកបន្ថែមថា៖ «ជម្រើសល្អបំផុតគឺស្ថានទូតកម្ពុជាស្នើរដ្ឋាភិបាលម៉ាឡេស៊ីបញ្ចូលពលករចំណាកស្រុកទៅក្នុងកម្មវិធីកញ្ចប់ជំនួយជំរុញសេដ្ឋកិច្ចរបស់រដ្ឋាភិបាលម៉ាឡេស៊ី»។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបាននិយាយថាសម្រាប់ពេលនេះ រដ្ឋាភិបាលមិនមានគម្រោងធ្វើមាតុភូមិនិវត្តន៍ពលករចំណាកស្រុកកម្ពុជាពីប្រទេសម៉ាឡេស៊ីទេ។ លោកបន្តថា៖ «យើងមានគោលការណ៍ច្បាស់លាស់ព្រោះស្ថានភាពរាតត្បាតនៅដំណាក់កាលនេះមិនអំណោយផលសម្រាប់យើងទេ។ ដូច្នេះខ្ញុំសូមស្នើដល់ប្រជាជនកម្ពុជារបស់យើងឲ្យមានភាពអត់ធ្មត់ រក្សាភាពស្ងប់ស្ងៀម អនុវត្តអនាម័យឲ្យបានល្អ និងអនុវត្តតាមវិធានការបង្ការដែលបានដាក់ចេញដោយរដ្ឋាភិបាលម៉ាឡេស៊ី»។ នៅពេលសួរអំពីអ្វីដែលស្ថានទូតកម្ពុជាអាចធ្វើបានដើម្បីជួយដល់ពលករចំណាកស្រុកនៅប្រទេសម៉ាឡេស៊ី លោកបានបង្វែរសំណួរនេះទៅក្រសួងការបរទេស។

ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីមិនអាចទាក់ទងសុំការអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ៕

*ប្រែសម្រួលដោយ សៀវ គួយអ៊ី*

## អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរ៦នាក់ក្នុងពេលចល័តទីតាំងធ្វើការខុសបម្រាមរបស់ថៃ

https://www.rfa.org/khmer/ ដោយ មាន ឫទ្ធិ 2021-01-14

អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរ ៦នាក់ ក្នុងពេលដែលពួកគេធ្វើដំណើរជាមួយថៅកែ ដើម្បីទៅធ្វើការងារនៅខេត្តភាគឦសានរបស់ប្រទេសថៃ កាលពីថ្ងៃទី១២ មករា។ អាជ្ញាធរថៃបានបញ្ជូនពលករទាំងនោះទៅឃុំខ្លួន ដើម្បីរង់ចាំការដោះស្រាយតាមច្បាប់។ មន្ត្រីសង្គមស៊ីវិលយល់ថា ករណីនេះប្រសិនបើអាជ្ញាធរខ្មែរមិនជួយពលករទាំងនោះទេ គឺពួកគេអាចប្រឈមនឹងការជាប់ពន្ធនាគារ២ឆ្នាំ។ ពលករខ្មែរទាំង៦នាក់នោះ មានមនុស្សពេញវ័យ ៥នាក់ និងកុមារម្នាក់។ ពួកគេបានឆ្លងដែនចូលមកប្រទេសថៃតាមច្រករបៀងព្រំដែនក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី៨ មករា។

សារព័ត៌មានរបស់ថៃ (Thai Reference) ចុះផ្សាយនៅរសៀលថ្ងៃទី១២ មករាថា អាជ្ញាធរថៃចាប់ពលករទាំងនោះក្នុងពេលពួកគេធ្វើដំណើរជាមួយថៅកែជនជាតិថៃពីរនាក់ប្តីប្រពន្ធ នៅខេត្តសាកុនណាក់ខនSakunnakorn នៅភាគឦសាន ដែលមានចម្ងាយប្រមាណ ៦០០គីឡូម៉ែត្រពីក្រុងបាងកក។ អាជ្ញាធរថៃបានបញ្ជូនពលករទាំងនោះទៅ

តុលាការដើម្បីចាត់វិធានការតាមច្បាប់ បន្ទាប់ពីសាកសួរពួកគេកាលពីរសៀលថ្ងៃទី១២ មករា។ អាជ្ញាធរថៃបានចោទប្រកាន់ពួកគាត់ពីបទឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ និងល្មើសបម្រាមរបស់ថៃ ដែលហាមឃាត់ចល័តទីតាំងពីខេត្តមួយទៅខេត្តមួយ អំឡុងការរាតត្បាតការរាតត្បាតជំងឺកូវីដ១៩។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក និងអ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ នៅថ្ងៃទី១៣ មករា ដោយទូរស័ព្ទចូលជាច្រើនដង តែពុំមានអ្នកទទួល។

អ្នកបកប្រែ និងធ្វើការងារផ្នែកការពារសិទ្ធិពលករខ្មែរនៅប្រទេសថៃ លោក ប្រាក់ ភក្រា ថ្លែងថា នេះជាលើកទី១ហើយ ដែលអាជ្ញាធរថៃចាប់ពលករខ្មែរពេលពួកគេធ្វើដំណើរចល័តខុសទីតាំង អំឡុងពេលការរាតត្បាតជំងឺកូវីដ ១៩ ជាលើកទី២នៅប្រទេសថៃ។ លោកបារម្ភថា ពលករទាំងនោះប្រឈមនឹងជាប់ពន្ធនាគារប្រមាណ ២ឆ្នាំ ប្រសិនបើអាជ្ញាធរខ្មែរមិនបានជួយអន្តរាគមន៍ដល់ពួកគាត់ទាន់ពេលវេលានោះ៖ «ហើយភាគច្រើននោះគឺ តុលាការកាត់ក្តីឱ្យជាប់ឃុំរយៈពេល២ឆ្នាំអីចឹងទៅ។ អានេះខ្ញុំគិតវា ហានិភ័យណាស់សម្រាប់ពលករដែលអត់ដឹងរឿង ហើយថៅកែនាំឆ្លងខេត្តឆ្លងអីនៅពេលដែលគេចាប់ទៅ ទោសគឺធ្ងន់នឹងថៅកែធ្ងន់ទាំងពលករ ហើយអត់មានការសម្របសម្រួលទេ។ ព្រោះថា នេះជាទោសមួយដែលបំពានច្បាប់ការដាក់ប្រទេសក្នុងគ្រាមានអាសន្ន»។ លោក ប្រាក់ ភក្ត្រា បន្ថែមថា មានពលករខ្មែរជាច្រើននាក់កំពុងអត់ការងារធ្វើ ហើយប្រឈមនឹងដាច់ស្បៀងអាហារនៅពេលដ៏ខ្លីខាងមុខ ដោយសារវិបត្តិជំងឺកូវីដ១៩ផ្ទុះឡើងជាលើកទី២នៅប្រទេសថៃ។

ចំណែកមន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា វិញ លោកមានប្រសាសន៍ថា អាជ្ញាធរថៃបានដាក់ប្រទេសក្នុងគ្រាអាសន្ន ដោយបានហាមឃាត់ពលករបរទេសមិនឱ្យចល័តចេញពីខេត្តមួយទៅខេត្តមួយនោះឡើយ។ លោកថា ពលករចល័តទីលំនៅអំឡុងពេលនេះប្រឈមនឹងទោសធ្ងន់ធ្ងរ បើអាជ្ញាធរថៃចាប់ពួកគេបញ្ជូនទៅតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ៖ «អ៊ីចឹងកុំចាត់ទុកគាត់ជាជនល្មើស គាត់ជាជនរងគ្រោះពីអំពើជួញដូរអំពើកេងប្រវ័ញ្ចអ៊ីចឹង។ ជាការស្នើសុំរបស់ខ្ញុំមួយទៀត រដ្ឋាភិបាលប្រទេសទទួលក៏គួរតែយោគយល់ក្នុងកាលៈទេសៈហ្នឹងដែរ។ ពិសេសទៀតស្ថានទូតខ្មែរ គួរតែចាត់វិធានការយ៉ាងណាដើម្បីឆ្លើយតបចំពោះបញ្ហាទាំងអស់នេះកុំឱ្យពលរដ្ឋខ្មែររងគ្រោះទ្វេដង។ រងគ្រោះទី១ចាញ់បោកមេខ្យល់ រងគ្រោះទី២ត្រូវបានគេចាប់ដាក់ពន្ធនាគារ»។ លោកបន្ថែមថា ពលករខ្មែរមិនគួរឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះឡើយ ព្រោះប្រឈមនឹងអាជ្ញាធរថៃចាប់ពួកគេដាក់ពន្ធនាគារផង និងអាចឆ្លងជំងឺកូវីដ១៩ផង។

រដ្ឋាភិបាលថៃបានបន្តដាក់ប្រទេសក្នុងគ្រាអាសន្នរហូតដល់ថ្ងៃទី២៨ កុម្ភៈ ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩។ ច្បាប់នេះហាមឃាត់ប្រជាពលរដ្ឋប្រមូលផ្តុំគ្នាជាច្រើននាក់ និងរៀបចំពិធីដែលមានមនុស្សច្រើនជាដើម។ អំឡុងពេលដាក់ប្រទេសក្នុងគ្រាអាសន្ននេះ រដ្ឋាភិបាលថៃបានបង្កើនការត្រួតពិនិត្យតឹងតែងនៅខេត្តជាប់ព្រំដែនកម្ពុជា និងជាប់ទីក្រុងបាងកក ដោយហាមឃាត់មិនឱ្យមានការចល័តពលករបរទេសឡើយ។ អ្នកល្មើសច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់គុក ២ឆ្នាំ និងពិន័យជាប្រាក់ ៤ម៉ឺនបាត ឬប្រមាណ ១ពាន់ ៣០០ដុល្លារអាមេរិក។

របាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរស្របច្បាប់ និងមិនស្របច្បាប់ ប្រមាណពី ១លាន ៨សែននាក់ ទៅ២លាននាក់ ធ្វើការនៅប្រទេសថៃ៕

# ខេត្តឧត្តរមានជ័យ និងបាត់ដំបង ទទួលបានថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងពលករមកពីថៃ

https://thmeythmey.com/ 14, Jan 2021 , 11:29 pm ដោយ: សៅ សុខអេង

សម្តេចនាយករដ្ឋមន្ត្រីកម្ពុជាបានផ្តល់ថវិកាចំនួន៨០០លានរៀលដល់អភិបាលខេត្តឧត្តរមានជ័យ និងចំនួន ២០០លានរៀលទៀតដល់អភិបាលខេត្តបាត់ដំបង។ នេះបើតាមលោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលដែលបានបញ្ជាក់ប្រាប់អ្នកសារព័ត៌មានថ្មីៗតាមទូរសព្ទ ដោយបន្ថែមថា ថវិកាទាំងនេះគឺសម្រាប់ឲ្យខេត្តទាំងពីរនេះផ្គត់ផ្គង់ដល់ពលករខ្មែរដែលមកពីប្រទេសថៃ។ លោកស្រី ឱ វណ្ណឌីន រដ្ឋលេខាធិការនៃក្រសួងសុខាភិបាល និងជាអ្នកនាំពាក្យនៃក្រសួងសុខាភិបាលបានបញ្ជាក់ថា ទំហំថវិកាទាំងនោះគឺរដ្ឋាភិបាលកម្ពុជាបានប្រគល់ឲ្យទៅតាមតម្រូវការរបស់អភិបាលខេត្តនីមួយៗ ដើម្បីគ្រប់គ្រងលើពលករខ្មែរមកពីប្រទេសថៃដែលមានសន្ទុះកើនឡើង។ «ធម្មតាគាត់ប្រគល់ជូនអ៊ីចឹងហើយ គាត់នឹងយកទៅចាត់ចែងយកទៅប្រើប្រាស់។ បើសិនគាត់ប្រើប្រាស់ទៅ វាខ្វះខាតនូវចំណុចណា កន្លែងណា គាត់នឹងបន្ថែមឲ្យទៀតហើយ។ គាត់(រដ្ឋាភិបាល)ធ្លាប់បានផ្តល់ថវិកាឲ្យពីមុន ប៉ុន្តែវាអត់គ្រប់ ពីព្រោះពលករយើងមានកំណើន»។ នេះជាការលើកឡើងរបស់លោកស្រី ឱ វណ្ណឌីន។

លោក លី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យបានបញ្ជាក់ប្រាប់អ្នកសារព័ត៌មានថ្មីៗតាមទូរសព្ទថា ថវិកាដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រគល់ឲ្យខេត្តឧត្តរមានជ័យនេះ ខាងអភិបាលខេត្តនឹងយកទៅចាត់ចែងទិញម្ហូបអាហារដល់ពលករចំនួនជាង២២០០នាក់ ដែលមកពីប្រទេសថៃ ដោយបច្ចុប្បន្នពួកគេកំពុងតែធ្វើចត្តាឡីស័កនៅកន្លែងចត្តាឡីស័កចំនួន១១។ បើតាមលោក លី រ៉ាដូ គិតត្រឹមថ្ងៃទី១៤ ខែមករានេះមានពលករចំនួន២៥០០នាក់ហើយដែលបានធ្វើដំណើរមកពីប្រទេសថៃ ហើយចូលមកខេត្តឧត្តរមានជ័យ។

លោក ងួត រតនៈ អភិបាលខេត្តបាត់ដំបងបានបញ្ជាក់ប្រាប់អ្នកសារព័ត៌មានថ្មីៗតាមទូរសព្ទថា ថវិកាដែលខេត្តរបស់លោកទទួលបានពីរាជរដ្ឋាភិបាលនោះ អាជ្ញាធរខេត្តនឹងយកទៅចាត់ចែងលើការស្នាក់នៅ និងទិញម្ហូបអាហារឲ្យពលករមកពីប្រទេសថៃដែលកំពុងធ្វើចត្តាឡីស័ក។ «ថវិកានោះគឺសម្រាប់ទិញអាហារ៣ពេល ជូនគាត់ពេលដែលគាត់ស្នាក់នៅ១៤ថ្ងៃក្នុងម្នាក់២ម៉ឺនរៀល។» នេះជាការលើកឡើងរបស់លោកអភិបាលខេត្តបាត់ដំបងដោយបញ្ជាក់ថា ខេត្តបាត់ដំបងបច្ចុប្បន្នមានពលករចំនួន២៥០០០នាក់ ហើយដែលបានវិលត្រឡប់ពីប្រទេសថៃ ដោយក្នុងនោះមានចំនួន១៤០០នាក់ ដែលកំពុងធ្វើចត្តាឡីស័ក។

កន្លងមកសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់ថវិកាសរុប៣៥០លានរៀល ដល់ខេត្តជាប់ប្រទេសថៃចំនួន៧ ដើម្បីចាត់ចែងការងារចំពោះមុខរួមមាន ការរឹតបន្តឹងការធ្វើចត្តាឡីស័កជាដើម ក្នុងន័យទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ពីប្រទេសថៃ។ ខេត្តទាំង៧រួមមាន ខេត្តព្រះវិហារ ឧត្តរមានជ័យ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ពោធិ៍សាត់ និងខេត្តកោះកុង ដោយខេត្តនីមួយៗទទួលបាន ៥០លានរៀល។ កាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០២០ សម្តេចនាយករដ្ឋមន្ត្រីក៏បានផ្តល់ថវិកាបន្ថែមចំនួន៧០០លានរៀលទៀតដល់ខេត្តចំនួន៤ ដែលនៅជាប់ព្រំដែនប្រទេសថៃ។ ក្នុងនោះខេត្តប៉ៃលិនចំនួន២០០លានរៀល ខេត្តបាត់ដំបង២០០លានរៀល ខេត្តបន្ទាយមានជ័យចំនួន២០០លានរៀល និងខេត្តឧត្តរមានជ័យ១០០លានរៀល។ កាលពីថ្ងៃទី១២ ខែមករា សម្តេចក៏បានផ្តល់ថវិកាចំនួន៥០០លានរៀលទៀតដល់ខេត្តបន្ទាយមានជ័យ។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាល មិនទាន់មានតួលេខពលករសរុបដែលមកពីប្រទេសថៃមកកម្ពុជាសម្រាប់គិតត្រឹមថ្ងៃទី១៤ ខែមករានេះនៅឡើយទេ។ ប៉ុន្តែលោកស្រី មានតែតួលេខពលករសរុបដែលគិតត្រឹមថ្ងៃទី៧ ខែមករា មានចំនួន១២០៨៨ម៉ឺននាក់ ក្នុងនោះមានស្រីចំនួនជាង៥៣ពាន់នាក់។

បច្ចុប្បន្នអ្នកកើតកូវីដ-១៩ នៅកម្ពុជាឡើងដល់៤១១នាក់ ក្នុងនោះ៣៥នាក់ ជាពលករមកពីថៃ។ អ្នកសះស្បើយឡើងដល់៣៧៧នាក់។ អ្នកកំពុងសម្រាកព្យាបាល៣៤នាក់ មាន២០នាក់នៅពេទ្យបង្អែកបន្ទាយមានជ័យ ៦នាក់នៅប៉ៃលិន ២នាក់នៅបាត់ដំបង និង៦នាក់នៅមណ្ឌលកំចាត់ជំងឺរបេងរាជធានីភ្នំពេញ៕

## ថ្ងៃទី១៨ ខែ មករា ឆ្នាំ២០២១

## រាជរដ្ឋាភិបាលកម្ពុជាអំពាវនាវពលករដែលធ្វើការនៅថៃឱ្យបន្តស្នាក់ នៅតាមកន្លែងរៀងៗខ្លួនសិន ដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 15/01/2021

ភ្នំពេញ ៖ រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃនេះបានអំពាវនាវដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមស្នាក់នៅ ក្នុងប្រទេសថៃបន្តទៀត ចៀសសវាងការចល័តពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីរួមគ្នាបង្ការ ទប់ស្កាត់ ការពារការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ដែលកំពុងផ្ទុះឡើងនៅទូទាំងប្រទេសថៃ។ សូមជម្រាបថា ការអំពាវនាវនាវនេះធ្វើឡើងខណៈពេលដែលគេសង្កេតឃើញមានការឆ្លងកូវីដ១៩ក្នុងអំឡុងពេលដែលបងប្អូនពលករនៅប្រទេសថៃធ្វើដំណើរត្រឡប់មកវិញដោយលួចលាក់ និងខុសពីបំរាមអាជ្ញាធរថៃ ។

ទន្ទឹមនោះ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ក៏បានបញ្ជាក់ ដែរថា ក្នុងពេលមានការរាតត្បាតជំងឺកូវីដ-១៩ នៅប្រទេសថៃនោះ អាជ្ញាធរថៃនឹងមិនមានវិធានការច្បាប់ប្រឆាំងនឹង និយោជក ក៏ដូចជាពលករបរទេសដែលកំពុងធ្វើការ និងស្នាក់នៅមួយកន្លែងនោះឡើយ។ ផ្ទុយទៅវិញ ប្រសិនបើពលករ បរទេសដែលចល័តពីកន្លែងមួយទៅកន្លែងមួយទៀត ឬមានបំណងចង់វិលត្រលប់ទៅស្រុកកំណើតវិញនោះ នឹងត្រូវអាជ្ញាធរ មានសមត្ថកិច្ចថៃចាប់ឃាត់ខ្លួន ហើយក៏អាចប្រឈមនឹងការឆ្លងជំងឺកូវីដ-១៩ ថែមទៀតដែរ។ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមអំពាវនាវយ៉ាង ទទូចដល់ពលករកម្ពុជាទាំងឡាយដែលកំពុងស្នាក់នៅប្រទេសថៃស្រាប់ សូមរក្សាភាពនឹងនរ និងបន្តស្នាក់នៅមួយ កន្លែងសិន ដោយកុំទាន់ឆ្លងដែនចូលមកប្រទេសកម្ពុជាវិញឱ្យសោះ ហើយសូមជឿទុកចិត្តលើសមត្ថភាព និងលទ្ធភាព ទប់ស្កាត់ ការព្យាបាលជំងឺកូវីដ-១៩ របស់អាជ្ញាធរថៃ។

សូមជម្រាបថា នៅថ្ងៃនេះពលករខ្មែរមកពីថៃចំនួន១៥នាក់ទៀតឆ្លងកូវីដ-១៩ ត្រូវបានរកឃើញវិជ្ជមានកូវីដ-១៩ ដែលធ្វើឲ្យចំនួនសរុបក្នុងចំណោពលករមកពីប្រទេសថៃឡើងដល់៥៦នាក់ ៕

## ពលករខ្មែរសម្រុកមកពីថៃច្រើនពេក អាជ្ញាធរខេត្តបន្ទាយមានជ័យ សម្រេចធ្វើរឿងមួយ

https://kampucheathmey.com/ January 15, 2021 By Sokhom Khon

លោក លី សារី អ្នកនាំពាក្យខេត្តបន្ទាយមានជ័យ បានមានប្រសាសន៍នៅព្រឹកថ្ងៃទី១៥ ខែមករានេះថា រដ្ឋបាលខេត្ត បានសម្រេចយកវិទ្យាល័យសម្តេចឪ មួយទៀតធ្វើជាទីតាំងមណ្ឌលចត្តាឡីស័ក ដែលអាចដាក់គ្រែពី៣០០ទៅ៤០០ សម្រាប់ដាក់ពលករខ្មែរមកពីប្រទេសថៃ។ លោក លី សារី បានបន្តថា ការបន្ថែមមណ្ឌលចត្តាឡីស័កមួយកន្លែងទៀតនេះ ដោយសារពលករខ្មែរវិលត្រឡប់មកពីថៃ មានចំនួនកាន់តែច្រើនឡើងៗ។ លោកបានបន្តទៀតថា បច្ចុប្បន្ននេះ មានពលករខ្មែរកំពុងធ្វើចត្តាឡីស័ក នៅតាមមណ្ឌលចត្តាឡីស័ក ទាំង១៨កន្លែង រួមទាំងមណ្ឌលចត្តាឡីស័ក វិទ្យាល័យសម្តេចឪ ប្រមាណជាង៣០០០នាក់ និងបានបញ្ជូនពលករដែលបានធ្វើតេស្តអវិជ្ជមានលើកទី១ លើកទី២ ទៅស្រុកកំណើតវិញ ប្រមាណជាង៤០០នាក់ផងដែរ។ លោកបានឲ្យដឹងទៀតថា មុននឹងបញ្ជូនពលករទៅស្រុកកំណើតវិញ អាជ្ញាធរបានធ្វើការអប់រំពីវិធានការ ការពារសុខភាពនិងចេញបណ្ណសុខភាព

ជូនពួកគាត់ថា មិនមានឆ្លងជំងឺកូវីដ-១៩ ដើម្បីឲ្យអាជ្ញាធរនៅតាមស្រុករបស់គាត់បានដឹង និងងាយស្រួលក្នុងការគ្រប់គ្រងបន្តទៀត។ យ៉ាងណាក៏ដោយ លោក លី សារី បានបន្ថែមថា ស្ថានការណ៍កូវីដ១៩ បច្ចុប្បន្ននៅឯខេត្តបន្ទាយមានជ័យ កំពុងស្ថិតនៅក្នុងការគ្រប់គ្រងរបស់អាជ្ញាធរ ទោះបីជាខេត្តមានពលករខ្មែរមកពីថៃ មានឆ្លងច្រើនជាងគេ រហូតដល់ចំនួន២៥នាក់ ក្នុងចំណោមពលករឆ្លងសរុប៥៦នាក់។

ក្រសួងសុខាភិបាល បានឲ្យដឹងថា គិតត្រឹមម៉ោង៧ព្រឹក ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១នេះ កម្ពុជារកឃើញអ្នកជំងឺកូវីដ-១៩ សរុបចំនួន៤២៦នាក់ ក្នុងនោះមានអ្នកជាសះស្បើយ ចំនួន៣៨១នាក់ និងអ្នកកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យចំនួន៤៥នាក់ ក្នុងនោះពលករខ្មែរ ចំនួន៣៩នាក់ ដោយនៅខេត្តបន្ទាយមានជ័យ ២៥នាក់ ប៉ៃលិន២នាក់ បាត់ដំបង១១នាក់ និងខេត្តឧត្តរមានជ័យម្នាក់៕ **អត្ថបទ ៖ សំអឿន**

## ពលរដ្ឋស្រុកអង្គរជុំជាង៣ពាន់នាក់វិលត្រឡប់ពីថៃ ក្រោយផ្ទុះជំងឺកូវីដ១៩តាមសហគមន៍

https://thmeythmey.com/m/ 15, Jan 2021 , 10:59 pm ដោយ: អ៊ីសា រ៉ហានី ( Isa Rohany )

សៀមរាប៖ គិតត្រឹមពាក់កណ្ដាលខែ មករា ប្រជាពលរដ្ឋស្រុកអង្គរជុំប្រមាណជាង៣ពាន់នាក់ហើយ ដែលបានវិលត្រឡប់ពីប្រទេសថៃ បន្ទាប់ពីប្រទេសជិតខាងនេះ ផ្ទុះជំងឺកូវីដ១៩ជាសហគមន៍។ តួលេខនេះ ហាក់មានចំនួនច្រើន តែអាជ្ញាធរថា បានទប់ស្កាត់ត្រឹមត្រូវ ដោយធានាថា ពលរដ្ឋទាំងនោះ ត្រូវធ្វើចត្តាឡីស័កគ្រប់ៗគ្នា។

អភិបាលស្រុកអង្គរជុំ លោក លុក ផុស បានឱ្យដឹងថា ពលរដ្ឋស្រុកអង្គរជុំដែលចេញទៅធ្វើការនៅប្រទេសថៃ សរុបជាង៧ពាន់នាក់ ក្នុងនោះជាង៣ពាន់នាក់ហើយ ដែលបានវិលត្រឡប់មកស្រុកវិញ បន្ទាប់ពីផ្ទុះជំងឺកូវីដ១៩ និងក្រោយផ្ទុះជាសហគមន៍ក្នុងប្រទេសថៃ។ លោកបន្ថែមថា អាជ្ញាធរបានរៀបចំទៅទទួល និងនាំពួកគេទៅធ្វើចត្តាឡីស័កបានត្រឹមត្រូវ នៅសាលាគរុកោសល្យ និងវិក្រឹត្យការខេត្តសៀមរាប មុននឹងអនុញ្ញាតឱ្យពលរដ្ឋទាំងអស់ចូលក្នុងភូមិបាន។

ក្នុងកាលៈទេសៈនេះ នៅពេលដែលប្រទេសថៃមិនទាន់ស្ងប់ស្ងាត់ពីជំងឺកូវីដ១៩ ពលរដ្ឋស្រុកអង្គរជុំខ្លះបានងាកទៅធ្វើចម្ការដំឡូក ខ្លះធ្វើកសិកម្មផ្សេងៗ ចិញ្ចឹមសត្វ និងខ្លះទៀតចេញធ្វើការសំណង់នៅក្នុងស្រុក និងទីក្រុងជាដើម៕

## ពលករខ្មែរមកពីប្រទេសថៃ២១នាក់ ចូលតាមច្រកព្រំដែនក្នុងខេត្តកោះកុង បានត្រូវអនុញ្ញាតឲ្យវិលត្រឡប់ទៅផ្ទះវិញ ក្រោយធ្វើចត្តាឡីស័ក និងទទួលលទ្ធផលអវិជ្ជមានកូវីដ

http://www.freshnewsasia.com/index.php/ 2021-01-17 12:58pm

**(កោះកុង)៖** ពលករខ្មែរ ធ្វើដំណើរមកពីប្រទេសថៃចំនួន២១នាក់ ត្រូវបានអនុញ្ញាតវិលត្រឡប់ទៅស្រុកកំណើត ជួបជុំក្រុមគ្រួសារសាច់ញាតិ ក្រោយពីធ្វើចត្តាឡីស័កតាមការកំណត់ និងធ្វើតេស្តអវិជ្ជមានវីរុសកូវីដ១៩។

ការជូនដំណើរពលករទាំង២១នាក់នេះ ធ្វើឡើងក្រោមវត្តមានលោកស្រី មិថុនា ភូថង អភិបាលខេត្តកោះកុង លោក ឈេង សុវណ្ណដា អភិបាលក្រុងខេមរភូមិន្ទ មន្ត្រីមន្ទីរសុខាភិបាលខេត្ត នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២១នេះ។ លោកស្រី មិថុនា ភូថង បានថ្លែងឲ្យដឹងថា លោកស្រីមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានដឹងថាពលករចំនួន២១នាក់ ធ្វើតេស្តរយៈពេល១៤ថ្ងៃ ក្រោយពីទទួលលទ្ធផលអវិជ្ជមាន ពីមន្ទីរពិសោធន៍ក្រសួងសុខាភិបាល ហើយតម្រូវឲ្យបងប្អូនបានវិលត្រឡប់ ទៅស្រុកកំណើតវិញដោយសុវត្ថិភាព។ លោកស្រីណែនាំសូមបងប្អូនថែរក្សាសុខភាពដោយខ្លួនឯង និងត្រូវអនុវត្តន៍ទៅតាមការផ្សព្វផ្សាយ របស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល ថែរក្សាអនាម័យបរិស្ថានជុំវិញខ្លួនឯង ហើយត្រូវអនុវត្តន៍ឲ្យបាននូវពាក្យ «៣ការពារ ៣កុំ» ពាក្យនេះ ដែលបងប្អូនគួរពិចារណាហើយ អនុវត្តន៍ជាប់ជានិច្ច ដើម្បីការពារការរីកដាលការឆ្លងជំងឺកូវីដ១៩ ចូលក្នុងសហគមន៍។

លោកស្រីបានថ្លែងបន្តថា ដើម្បីសុវត្ថិភាពនៃការរីករាលដំងឺឆ្លងកូវីដ១៩ ចូលក្នុងសហគមន៍បងប្អូនត្រូវរួមគ្នាផ្សព្វផ្សាយបន្ត បើបងប្អូនពលករនៅប្រទេសថៃ ចង់វិលចូលប្រទេស ឬស្រុកកំណើតវិញ សូមឲ្យណែនាំឲ្យពួកគាត់ចូលតាមច្រកទ្វារអន្តរជាតិ ចាំយាម មកកុំលួចឆ្លងដែនតាច្រកធម្មជាតិ និងផ្ទៃសមុទ្រឲ្យសោះ ព្រោះវាគ្រោះថ្នាក់ណាស់ ក្នុងធ្វើដំណើរតាមច្រកធម្មជាតិ និងផ្ទៃសមុទ្រ។ ក្នុងឱកាសនោះលោកស្រីអភិបាលខេត្ត បានផ្តល់នៅសម្ភារការពារសុវត្ថិភាព នៃការចម្លងកូវីដ១៩ និងថវិកាមួយចំនួនផងដែរ ដើម្បីសម្រួលក្នុងការធ្វើដំណើរ៕

## ដោយសារតែបញ្ហាក្រពះសំខាន់ ប៉ុន្តែគួរយល់ដឹងពីកាលៈទេសៈផង

https://kohsantepheapdaily.com.kh/ ១៧ ខែ មករា ឆ្នាំ ២០២១ ម៉ោង ១៨:៣៥

បន្ទាយមានជ័យ ៖ ដ្បិតមួយរយៈចុងក្រោយបន្ទាត់ព្រំដែនកម្ពុជាថៃត្រូវបានរឹតបណ្តឹង ដើម្បីការពារអ្នកឆ្លងដែនខុសច្បាប់ពេល គឺដើម្បីទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩ចូលសហគមន៍ក៏ដោយក៏មានពលករខ្មែរមួយចំនួន នៅតែបន្តលួចឆ្លងដែនខុសច្បាប់ទាំងប្រថុយប្រថានដដែល ។ ជាក់ស្តែងពលករខ្មែរ៦នាក់ត្រូវបានសមត្ថកិច្ចចម្រុះថៃចាប់ក្នុងស្រុកអារញ្ញ និងស្រុកខ្លងហាតខេត្តស្រះកែវ កាលពីថ្ងៃទី១៥ មករា ២០២១ ។ ពលករទាំងនេះមិនត្រូវបានគេស្គាល់អត្តសញ្ញាណនៅឡើយទេ ប៉ុន្តែ៤នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួននៅក្នុងស្រុកអារញ្ញ និង២នាក់ចាប់នៅស្រុកខ្លងហាត ក្រោយលួចឆ្លងដែនចេញពីកម្ពុជា នេះបើយោងតាមការចុះផ្សាយរបស់គេហទំព័រនិងកាសែតក្នុងស្រុករបស់ថៃ១ ។ ក្រោយសាកសួរពលករទាំងនេះ ប្រាប់សមត្ថកិច្ចថៃថា បំរុងទៅរកការងារធ្វើលើទឹកដីថៃព្រោះនៅស្រុកកំណើតគ្មានការងារធ្វើ។ ក្រោយពិនិត្យសុខភាពពលករទាំងនេះគេប្រគល់ឲ្យសមត្ថកិច្ចជំនាញដើម្បីចាត់ការបន្តតាមនិតិវិធី៕

## អភិបាលខេត្តប៉ៃលិនជូនដំណើរពលករជាង១០នាក់ជាសះស្បើយពីកូវីដឱ្យត្រឡប់ទៅផ្ទះវិញ

https://kohsantepheapdaily.com.kh/ ១៦ ខែ មករា ឆ្នាំ ២០២១ ម៉ោង ២០:២១

ខេត្តប៉ៃលិន ៖ នៅរសៀលថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ លោកជំទាវ បាន ស្រីមុំ អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិននិងឯកឧត្តម សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិនបានអញ្ជើញជួបសំណេះសំណាលនិងជូនដំណើរពលករឡើងរថយន្តធ្វើដំណើរទៅលំនៅឋានរៀងៗខ្លួនវិញ ក្រោយពីឆ្លងវីរុសកូវីដ-១៩ ហើយទទួលបានការយកចិត្តទុកដាក់ពីក្រុមគ្រូពេទ្យជំនាញក្នុងការព្យាបាលរហូតទទួលបានការជាសះស្បើយពីជម្ងឺទាំងស្រុង ។

លោកជំទាវអភិបាលខេត្ត ក៏បាននាំមកនូវការអបអរសាទររបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជូនបងប្អូននាពេលនេះផងដែរ ។ ក្នុងនាម លោកជំទាវផ្ទាល់ ក៏សូមសំដែងនូវទឹកចិត្តត្រេកអរជាមួយប្អូនៗ និងបានផ្តាំផ្ញើទៅប្អូនៗថា ទោះបីពេលនេះប្អូនៗទទួលបានជាសះស្បើយក្តី តែពេលត្រឡប់ទៅផ្ទះវិញក៏ត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃទៀត ដើម្បីជាការបង្ការបន្ថែម ហើយបើមានអាការៈប្រែប្រួលណាមួយ សូមប្រញាប់ទំនាក់ទំនងមកក្រុមគ្រូពេទ្យ និងកុំភ្លេចញ៉ាំថ្នាំអោយបានទៀងទាត់តាមការណែនាំរបស់គ្រូពេទ្យផងដែរ ។ លោកជំទាវក៏បានបញ្ជាក់បន្ថែមជូនប្អូនៗទាំង១២នាក់ថា ក្នុងដំណាក់កាលព្យាបាល និងការស្នាក់នៅហូបចុក គឺជាការយកចិត្តទុកដាក់របស់សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រានី ហ៊ុន សែន ដោយមិនទុកអោយបងប្អូនពលករខ្មែរយើងណាម្នាក់ ជួបទុក្ខលំបាកដោយសារវីរុសកូវីដ-១៩ ដោយលោកមិនបានដឹង និងមិនបានដោះស្រាយនោះឡើយ ។

លោកក៏បានចាត់ឱ្យក្រសួងសុខាភិបាល និងក្រុមគ្រូពេទ្យជំនាញ ដើម្បីធ្វើការងារនេះជាសមរភូមិមុខ បន្ទាប់មកកងកម្លាំង និងអាជ្ញាធរមូលដ្ឋាន ក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ ការរីករាលដាលនៃវីរុសកំណាចនេះចូល

ក្នុងមូលដ្ឋាន ។ លោកជំទាវក៏បានស្នើអោយប្អូនៗទាំងអស់ បើមានសាច់ញាតិដែលត្រូវត្រឡប់មកស្រុកកំណើតវិញ សូមមកតាមសម្រួល និងត្រូវផ្តល់ព័ត៌មានពិត ជូនកងកម្លាំងការពារ និងក្រុមគ្រូពេទ្យជំនាញ រួចស្ម័គ្រចិត្តចូលខ្លួនធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ៕

## កិច្ចប្រជុំបន្ទាន់ ស្តីពីការគ្រប់គ្រងពលករ ហូរចូលមកពីប្រទេសថៃ មានការកើនឡើង

https://www.rasmeinews.com/ 15 January, 2021

**ដោយៈ គ្រញូង/បាត់ដំបងៈ** *នៅព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ នៅក្នុងវិទ្យាល័យ កំរៀង ស្រុកកំរៀង លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានដឹកនាំកិច្ចប្រជុំបន្ទាន់ស្តីពីការ គ្រប់គ្រងពលករ មានការកើនឡើង នៃការផ្ទុះជំងឺកូវីដ ១៩ ចំពោះពលករទើបត្រឡប់មក ពីប្រទេសថៃ នៅស្រុកជាយដែន ខេត្តបាត់ដំបង ជាប់ព្រំប្រទល់ប្រទេសថៃនិងក្លាប់សភាព ការណ៍ថ្មីៗ នៅតាមបន្ទាត់ព្រំដែន ក្នុងស្រុកកំរៀង ភ្នំព្រឹក និងស្រុកសំពៅលូន ខេត្តបាត់ដំបង។*

បន្ទាប់ពីបានស្តាប់នូវ សេចក្តីរាយការណ៍ របស់លោកអភិបាល ស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន បានឱ្យដឹងថា តាមរយៈទាហាន ទំនាក់ទំនង កម្ពុជា-ថៃ និងការផ្តល់ព័ត៌មានពីភាគីថៃ គឺថាមានករណីសង្ស័យពលករមួយចំនួន ដែលវិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ មានមួយចំនួន ផ្ទុកជំងឺកូវីដ ១៩ ដោយត្រូវមានការប្រុងប្រយ័ត្នខ្ពស់ និងរៀបចំពួកគាត់ឲ្យរស់នៅសម្រាក ធ្វើចត្តាឡីស័ក ដាច់ដោយឡែក ពីពលករផ្សេងៗទៀត។

លោក ងួន រតនៈ បានមានប្រសាសន៍ ណែនាំជម្រុញ ដល់រដ្ឋបាលស្រុក ត្រូវរៀបចំបន្ទប់ ទឹកបន្ថែម និងរៀបចំផ្លូវឱ្យពួកគាត់សម្រាប់ប្រើប្រាស់ ដើម្បីជៀសវាងការប្រើប្រាស់ជាមួយពលករផ្សេងទៀត និងពង្រឹងបន្ថែមកម្លាំងយាមកាម ឱ្យបានហ្មត់ចត់ និងច្បាស់ លាស់ នៅតាមបន្ទាត់ព្រំដែន និងបន្តដាក់កម្លាំងត្រួតពិនិត្យរថយន្តតាក់ស៊ីនៅតាមដងផ្លូវបន្ថែម ជៀសវៀងកុំឲ្យពួកគាត់ចូលទៅដល់មូលដ្ឋានដែលជាកន្លែងរស់នៅរបស់ពួកគាត់ ដើម្បីបង្ការ ការពារកុំឲ្យជំងឺកូវីដ-១៩ ចូលក្នុងទៅក្នុងសហគមន៍ដែលនាំឲ្យឆ្លង រីករាលដាល ពេញមូលដ្ឋាន ដែលពួកគាត់រស់នៅ៕/V-PC

## អាជ្ញាធរខេត្តឧត្តរមានជ័យ ត្រៀមបង្កើនទីតាំងចត្តាឡីស័ក ខណៈពលករខ្មែរកាន់តែច្រើន វិលមកពីថៃវិញ

http://btv.com.kh/ 15/01/2021

ឧត្តរមានជ័យ ៖ អាជ្ញាធរខេត្តឧត្តរមានជ័យ ត្រៀមបង្កើនទីតាំងចត្តាឡីស័ក បន្ទាប់ពីមើលឃើញថា ពលករខ្មែរកាន់ តែច្រើន បានសម្រុកចេញមកពីប្រទេសថៃ ចូលស្រុកកំណើតវិញ តាមច្រកព្រំដែនខេត្តនេះ ដោយសារបញ្ហាកូវីដ–១៩ ដែលកំពុងតែរាតត្បាតនៅក្នុងសហគមន៍ប្រទេសថៃនោះ។ អាជ្ញាធរខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ជារៀងរាល់ថ្ងៃ មានពលករខ្មែរ ចំនួនចាប់ពី១០០នាក់ ឡើងទៅ បានវិលត្រឡប់មកពីប្រទេសថៃ ចូលប្រទេសកំណើតខ្លួន តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ និងច្រកជាំសាងាំ ដោយសារការអត់ការងារធ្វើ ដែលបង្កឡើងដោយវិបត្តិកូវីដ–១៩។ អាជ្ញាធរខេត្តនេះ បានបញ្ជាក់ថា ប្រទេសថៃកំពុងតែរងការរាតត្បាតនៃមេរោគកូវីដ–១៩ ក្នុងសហគមន៍ ដែលស្ថានភាពបែបនេះ បានធ្វើឱ្យពលករខ្មែរ ដែលកំពុងធ្វើការនៅក្នុងប្រទេសនេះ មានការភ័យ ខ្លាចចំពោះការឆ្លងមេរោគនេះ ទើបនាំគ្នាចាកចេញពីប្រទេសថៃ ចូលមកប្រទេសកំណើតវិញ។

ឯកឧត្តម ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ពលករដែលបានវិលមកពីថៃ ត្រូវបានមន្ត្រីសុខាភិបាល ពិនិត្យសុខាភាពដោយយកចិត្តទុកដាក់ និងតម្រូវឱ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃសិន ហើយក្រោយពេលលទ្ធផលធ្វើតេស្តបង្ហាញថា ពួកគេ អវិជ្ជមានមេរោគកូវី-១៩ ទើបអនុញ្ញាតឱ្យទៅផ្ទះ។ នៅក្នុងខេត្តឧត្តរមានជ័យ បច្ចុប្បន្ន អាជ្ញាធរ បានប្រើប្រាស់សាលារៀនចំនួន១៣កន្លែង ធ្វើជា មណ្ឌលចត្តាឡីស័ក ហើយគ្រោងនឹងបើកពីរទីតាំងបន្ថែមទៀត ប្រសិនបើពលករខ្មែរ នៅតែបន្តចូលមក៕ អត្ថបទ៖ ឃិន សារិទ្ធ

## អាជ្ញាធរថៃឃាត់ខ្លួនពលករចំណាកស្រុក ១១នាក់ មកពីប្រទេសម៉ាឡេស៊ី

https://www.rfa.org/khmer/ ដោយ ម៉ៅ សុធានី 2021-01-16

ប៉ូលិសថៃ បានឃុំខ្លួនពលករចំណាកស្រុកខ្មែរ១១នាក់ នៅខេត្តណារ៉ាធីវ៉ាត (Narathiwat) នៅតំបន់ភាគខាងត្បូងប្រទេសថៃ ក្រោយពួកគេ កំពុងលាក់ខ្លួនក្នុងផ្ទះមួយ បន្ទាប់ពីមេខ្យល់បាននាំពួកគេ មកពីប្រទេសម៉ាឡេស៊ី (Malaysia)។ សារព័ត៌មានអនឡាញ បឺណាញូវ (BenarNews) ឱ្យដឹងថា ពលករចំណាកស្រុកទាំង ១១ នាក់នោះ រួមមានបុរស៧នាក់ ស្ត្រី២នាក់ និងក្មេងស្រី២នាក់។ អាជ្ញាធរថៃ បានធ្វើតេស្តរកមេរោគកូវីដ១៩ និងបានដាក់ពួកគេឱ្យធ្វើចត្តាឡីស័ក ចំនួន១៤ថ្ងៃ មុននឹងបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ។ ពលករចំណាកស្រុកទាំងនេះ បានប្រាប់ប៉ូលិសថៃថា ពួកគេធ្វើដំណើរពីតំបន់យ៉ូហូ (Johor) ផ្នែកខាងត្បូងនៃប្រទេសម៉ាឡេស៊ី តាមរថយន្តមកដល់ព្រំដែនថៃ ក៏បានជួបពលរដ្ឋថៃ ២នាក់ជាមេខ្យល់ ដែលបានដឹកពួកគេម្តង ២នាក់តាមម៉ូតូ យកមកលាក់ទុកក្នុងផ្ទះមួយ នៅតាមព្រំដែន។ ពលករខ្មែរទាំងនោះ មានបំណងធ្វើដំណើរត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីបាត់បង់ការងារ ក្រោយដែលរដ្ឋាភិបាលម៉ាឡេស៊ី ប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន ចាប់ពីថ្ងៃទី១៣ ខែមករា រហូតដល់ថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ ខាងមុខ ដើម្បីទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ១៩។

សមត្ថកិច្ចថៃប្រកាសផ្តល់រង្វាន់ចំនួនទឹកប្រាក់ ១ម៉ឺនបាត ឬស្មើជាង៣៣០ដុល្លារ ចំពោះការផ្តល់ព័ត៌មានដល់ជនណាដែលរត់ពន្ធមនុស្សខុសច្បាប់ ចូលទឹកដីប្រទេសថៃ។ ពលករចំណាកស្រុកទាំងនោះប្រាប់ប៉ូលិសថាពួកគេបានបង់ប្រាក់ក្នុងម្នាក់ៗ ចំនួន ៤០០ដុល្លារ សម្រាប់មេខ្យល់ ដើម្បីនាំពួកគេឆ្លងដែនចូលក្នុងទឹកដីថៃ៕

## ប៉ូលិសថៃស្ថិតនៅក្នុងការសង្ស័យ នាំមនុស្សឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 17-01-2021

ប្រព័ន្ធផ្សព្វផ្សាយថៃបានផ្សាយថា នៅថ្ងៃទី១៦ ខែមករា ស្នងការរងនៃកម្លាំងប៉ូលិសថៃ លោក Damsongsak Kittprapas បានបញ្ជាក់ថា មានប៉ូលិស ២០នាក់ជាប់ពាក់ព័ន្ធនឹងការដឹកជញ្ជូនមនុស្សឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃ ពីប្រទេសមីយ៉ាន់ម៉ា។ តាមការលើកឡើងរបស់ស្នងការរងប៉ូលិសថៃបានឲ្យដឹងទៀតថា ប៉ូលិសកំពុងតែស្វែងរកចាប់ខ្លួន មនុស្ស៨នាក់ជាប់ពាក់ព័ន្ធការនាំមនុស្ស ពីប្រទេសមីយ៉ាន់ម៉ាចូលក្នុងខេត្ត Samut Sakhon ។ ខេត្ត នេះជាតំបន់ដែលមានករណីឆ្លងកូវីដ-១៩ ច្រើនបំផុត ហើយមូលហេតុគឺមកពីពលករចូលមកខុសច្បាប់ពីប្រទេសជិតខាង។ តាមការស្រាវជ្រាវ មានប៉ូលិស ២០នាក់ ក្នុងនោះមានទាំងមន្ត្រីប៉ូលិសជាន់ខ្ពស់ផងដែរ។ លើសពីនេះទៅទៀត ក៏មានមន្ត្រីរដ្ឋាភិបាល៣រូប រងការសង្ស័យជាប់ពាក់ព័ន្ធបណ្តាញជួញដូរមនុស្សឆ្លងដែនខុសច្បាប់។

តាមសារព័ត៌មាន Bangkok Post បានផ្សាយថា នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១នេះ ប្រទេសថៃ បានរាយការណ៍ពីការរកឃើញករណីឆ្លង COVID-19 ថ្មីៗចំនួន២៣០ករណីបន្ថែមទៀត និងករណីស្លាប់ម្នាក់ផងដែរ។ អ្នកនាំពាក្យមជ្ឈមណ្ឌលគ្រប់គ្រង COVID-19 របស់ប្រទេសថៃ លោក Taweesilp Visanuyothin បានលើកឡើង

ថា អ្នកស្លាប់គឺបុរសវ័យ៦៧ឆ្នាំដែលបានស្លាប់នោះបានទៅកន្លែងកម្សាន្តចំនួន២ដង គឺនៅថ្ងៃទី២១ និងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០កន្លងទៅនេះ។ លោក Taweesilp Visanuyothin បន្តទៀតថា ក្នុងចំណោមករណីឆ្លងថ្មីៗទាំង ២៣០ករណីខាងលើ ក្នុងនោះរួមមាន៨៣ករណី ជាក្រុមអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមអ្នកជំងឺដែល បានឆ្លងពីមុន ឬជាក្រុមអ្នកដែលបានធ្វើដំណើរទៅកាន់ តំបន់ដែលមានហានិភ័យខ្ពស់ ខណៈ ១២៦ករណីទៀត បានធ្វើតេស្តវិជ្ជមានអំឡុងពេលកំពុងស្វែងរកករណីសកម្មនៅក្នុងសហគមន៍។ មកទល់ពេលនេះមានករណីឆ្លង COVID-19 សរុបនៅទូទាំងប្រទេស មាន ១១,៦៨០ករណីក្នុងនោះមានអ្នកស្លាប់ ៧០នាក់ និងអ្នកជាសះស្បើយ ៨,៩០៦នាក់៕

## ថ្ងៃទី១៩ ខែ មករា ឆ្នាំ២០២១

## លោកជំទាវ ជូ ប៊ុនអេង ៖ កម្ពុជា-ថៃ សន្យាពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ក្នុងការទប់ស្កាត់ការជួញដូរមនុស្ស

https://www.cen.com.kh/ January 18, 2021

ភ្នំពេញ ៖ រាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលនៃប្រទេសថៃ បានសន្យានឹងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតក្នុងកិច្ចការទប់ស្កាត់ការជួញដូរមនុស្ស ខណៈភាគីទាំងពីរ ក៏បានបញ្ចប់នូវសេចក្តីព្រាងច្បាប់ចុងក្រោយរបស់ផងខ្លួន ស្តីពី សហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ទាក់ទងនឹងបញ្ហាការជួញដូរមនុស្សដែរនោះ។

ថ្លែងប្រាប់អ្នកយកព័ត៌មានក្រោយពីកិច្ចប្រជុំ នាព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១នេះ តាមរយៈវីដេអូខុនហ្វឺរ៉ែន លើសេចក្តីព្រាងចុងក្រោយ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ រវាងកម្ពុជា និងថៃ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានលើកឡើងថា ការធ្វើសេចក្តីព្រាងច្បាប់នេះ គឺដើម្បីធ្វើយ៉ាងណាឲ្យកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសភូមិផងរបងតែមួយនេះ មានប្រសិទ្ធភាពបន្ថែមទៀតក្នុងការបង្ក្រាបការជួញដូរមនុស្ស ឬក៏ឧក្រិដ្ឋកម្មឆ្លងដែនជាដើមនោះ។ លោកជំទាវរដ្ឋលេខាធិការក៏បានលើកឡើងផងដែរថា មិនមែនតែរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ដែលមានការព្រួយបារម្ភចំពោះពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃ ដោយខ្លាចក្រែងពួកគេរងការជួញដូរមនុស្សនេះ រដ្ឋាភិបាលថៃក៏បានគិតគួរដែរ ដោយរហូតមានការឯកភាពគ្នាធ្វើសេចក្តីព្រាងច្បាប់នេះឡើង ដើម្បីបង្ការពួកគាត់កុំឲ្យជួបបញ្ហាទាំងនេះ ខណៈពួកគេស្ថិតនៅមានហានិភ័យកាន់តែខ្លាំងពីពួកឱកាសនិយម ក្នុងការដែលប្រទេសទាំងពីរកំពុងជួបវិបត្តិនៃការរាតត្បាតនូវមេរោគកូវីដ១៩នោះ។

សូមបញ្ជាក់ថា សេចក្តីព្រាងច្បាប់ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ រវាងកម្ពុជា និងថៃត្រូវបានមន្ត្រីអន្តរក្រសួងនៃប្រទេសទាំងពីរ សម្រេចព្រមព្រៀងគ្នារួចជាស្ថាពរហើយ ដោយរង់ចាំឆ្លងមតិ បន្ថែមនៃថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរតែប៉ុណ្ណោះ៕ **រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ**

## កម្ពុជា-ថៃ ប្តេជ្ញារួមគ្នា ទប់ស្កាត់ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនឲ្យកាន់តែមានប្រសិទ្ធភាព

https://kampucheathmey.com/ on January 18, 2021 By Sorn Phanith

ខណៈពេលដែលសេក្តីព្រាងច្បាប់ ស្តីពីសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ទាក់ទងនឹងបញ្ហាការជួញដូរមនុស្សជិតបញ្ចប់នោះរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសថៃ បានសន្យានឹងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការទប់ស្កាត់ការជួញដូរមនុស្សនិងឧក្រិដ្ឋកម្មឆ្លងឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

ថ្លែងប្រាប់អ្នកយកព័ត៌មាន ក្រោយពីកិច្ចប្រជុំតាមរយៈវីដេអូខុនហ្វឺរ៉ែនលើសេចក្ដីព្រាងចុងក្រោយនៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ រវាងកម្ពុជា និងថៃនាព្រឹកថ្ងៃទី១៨ មករា នេះ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានមានប្រសាសន៍ថា ការធ្វើសេចក្ដីព្រាងច្បាប់នេះ គឺដើម្បីធ្វើយ៉ាងណាឲ្យកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសកម្ពុជានិងថៃ បង្ក្រាបការជួញដូរមនុស្ស ឬក៏ឧក្រិដ្ឋកម្មឆ្លងដែនឲ្យមានប្រសិទ្ធភាពបន្ថែមទៀត។ លោកស្រីបានបន្តថា សេចក្ដីព្រាងច្បាប់ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ រវាងកម្ពុជា និងថៃ ត្រូវបានមន្ត្រីអន្តរក្រសួងនៃប្រទេសទាំងពីរ សម្រេចព្រមព្រៀងគ្នារួចជាស្ថាពរហើយ ដោយរង់ចាំឆ្លងមតិ បន្ថែមពីថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរតែប៉ុណ្ណោះ។ លោកស្រីបន្តទៀតថា« មិនមែនតែរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ដែលមានការព្រួយបារម្ភចំពោះពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃ ដោយខ្លាចក្រែងពួកគេរងការជួញដូរមនុស្សនេះ រដ្ឋាភិបាលថៃក៏បានគិតគូរដែរ ដោយរហូតមានការឯកភាពគ្នាធ្វើសេចក្ដីព្រាងច្បាប់នេះឡើង ដើម្បីបង្ការពួកគាត់កុំឲ្យជួបបញ្ហាទាំងនេះ ខណៈពួកគេស្ថិតនៅមានហានិភ័យកាន់តែខ្លាំងពីពួកឱកាសនិយម ក្នុងការដែលប្រទេសទាំងពីរកំពុងជួបវិបត្តិនៃការរាតត្បាតនូវមេរោគកូវីដ១៩នោះ»៕ **អត្ថបទ៖ សំអឿន**

## ជិត ១ ខែ បានរកឃើញវិជ្ជមានកូវីដលើពលករខ្មែរមកពីថៃ ៦៩ នាក់

https://www.postkhmer.com/ មុំ គន្ធា | Publication date 18 January 2021 | 09:59 ICT

**ភ្នំពេញៈ** ត្រឹមរយៈពេលជិត ១ ខែប៉ុណ្ណោះចាប់ពីថ្ងៃទី ២០ ធ្នូ ដល់ថ្ងៃទី ១៧ មករា ពលករខ្មែរដែលបានវិលត្រឡប់មកពីប្រទេសថៃតាមច្រកនៃបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន ៦៩ នាក់ត្រូវបានរកឃើញវិជ្ជមានកូវីដ ១៩ ដោយក្នុងនោះពលករដែលបានព្យាបាលជាសះស្បើយ ២១ នាក់។ ចំនួននៃអ្នកឆ្លងវីរុសកូវីដ ១៩ នៅតែបន្តកើតមានឡើង ដែលជាហេតុធ្វើឱ្យក្រសួងសុខាភិបាល និងក្រសួងការងារបន្តអំពាវនាវដល់ពលករ និងពលរដ្ឋទាំងអស់ត្រូវបន្តការប្រុងប្រយ័ត្ន និងអនុវត្តនូវវិធានការរបស់ក្រសួងសុខាភិបាលជាប់ជាប្រចាំ។

ដោយសង្កេតឃើញមានការឆ្លងកូវីដ ១៩ អំឡុងពេលពលករខ្មែរនៅប្រទេសថៃធ្វើដំណើរវិលត្រឡប់មកវិញដោយលួចលាក់ និងខុសពីបម្រាមអាជ្ញាធរថៃនោះលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងជាប្រធានគណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ អំពាវនាវជាថ្មីដល់ពលករកម្ពុជាកំពុងស្នាក់នៅ និងធ្វើការ នៅប្រទេសថៃ សុំបន្តស្នាក់នៅទីនោះបន្តទៀត និងចៀសវាងការចល័តពី ១ កន្លែងទៅ ១ កន្លែង។ លោកថ្លែងថា៖ «សូមបងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមេត្តារក្សាភាពនឹងនរ និងបន្តស្នាក់នៅ ១ កន្លែងដោយពុំទាន់ចាំបាច់ឆ្លងដែនវិលត្រឡប់មកស្រុកកំណើតវិញនោះទេ។ សូមជឿទុកចិត្តលើសមត្ថភាព និងលទ្ធភាពទប់ស្កាត់ និងព្យាបាល ជំងឺកូវីដ ១៩ របស់អាជ្ញាធរថៃ»។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលឱ្យដឹងពីថ្ងៃទី ១៥ មករា តាមរយៈសារជាសំឡេងថា បច្ចុប្បន្នថ្វីដ្បិតប្រទេសកម្ពុជាបានបញ្ចប់នូវព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា ក៏ពិតមែន ប៉ុន្តែបញ្ហាការចម្លងក៏ដូចជាការរាតត្បាតនៃជំងឺកូវីដ ១៩ គឺនៅតែជាបញ្ហាសុខភាពសាធារណៈដែលទាំងអស់គ្នាត្រូវតែប្រុងប្រយ័ត្នខ្ពស់។ លោកស្រីថ្លែងដូចនេះ បន្ទាប់ពីកាលពីថ្ងៃទី ១៥ ខែមករា ក្រសួងសុខាភិបាលបានរកឃើញពលករខ្មែរចំនួន ១៥ នាក់បានឆ្លងវីរុសកូវីដ១៩ក្នុងរយៈពេលតែ ១ ថ្ងៃ។ លោកស្រីថា៖ «នេះជាចំនួនច្រើន ដែលយើងបានគិតទុកជាមុនរួចទៅហើយថានឹងអាចមានការកើនឡើងនូវចំនួនអ្នកឆ្លងវីរុសកូវីដ១៩ជាបន្តបន្ទាប់ទៀត។ ដូច្នេះសុំឱ្យបងប្អូនយើង កុំមានការធ្វេសប្រហែសឱ្យសោះ»។ អ្នកនាំពាក្យរូបនេះបន្តថា៖ «ខ្ញុំក៏ធ្លាប់បានជម្រាបជូន ក៏ដូចជាធ្វើការណែនាំសាធារណជនទាំងអស់ជារឿយៗរួចមកហើយថា យើងងាយស្រួលក្នុងការបំភ្លេចវីរុសកូវីដ១៩ដោយយើង

គិតថា ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា បានបិទបញ្ចប់ហើយ។ ដូច្នេះហាក់ដូចជា មិនមានបញ្ហាអីដែលជាការព្រួយបារម្ភទៀតទេចំពោះបញ្ហាវីរុសកូវីដ ១៩។ កាលណាគិតបែបនេះ គឺជាការមើលងាយខ្លួនយើង។ យើងបានដាក់ខ្លួនយើងបើកចំហទូលំទូលាយណាស់សម្រាប់ឱ្យវីរុសកូវីដ១៩ វាយលុកចូលមកក្នុងសរីរាង្គកាយរបស់យើងងាយស្រួលបំផុត»។លោកស្រីថា ពលរដ្ឋទាំងអស់ត្រូវបន្តការរស់នៅតាមធម្មតាបែបគន្លងថ្មីដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនវិធានការការពារ។

តាមរបាយការណ៍ក្រសួងសុខាភិបាលគិតត្រឹមថ្ងៃទី ១៧ មករា កម្ពុជាមានអ្នកជំងឺកូវីដ ១៩ ចំនួន ៤៣៩ នាក់ ក្នុងនោះពលករខ្មែរមកពីប្រទេសថៃ ៦៩ នាក់។ រីឯអ្នកព្យាបាលជាសះស្បើយ ៣៨៥ នាក់។ ឯអ្នកជំងឺកូវីដ ១៩ កំពុងសម្រាកព្យាបាលមានចំនួន ៥៤ នាក់៕

## ពលករខ្មែរនៅថៃខាង ៣សែននាក់បារម្ភរឿងបន្តសុពលភាពទិដ្ឋាការមិនបាន នឹងក្លាយជាពលករខុសច្បាប់នៅពេលខាងមុខ

https://www.rfa.org/khmer/ ដោយ សុជីវី 2021-01-18

ពលករខ្មែរធ្វើការងារនៅប្រទេសថៃជាច្រើននាក់ព្រួយបារម្ភខ្លាចតសុពលភាពទិដ្ឋាការមិនបាន ហើយនឹងក្លាយទៅជាពលករខុសច្បាប់នៅពេលខាងមុខនេះ។ ក្ដីបារម្ភនេះ ដោយសារតែលិខិតឆ្លងដែនរបស់ពួកគាត់នៅសល់តែជាង ២ខែទៀតនឹងអស់សុពលភាពទិដ្ឋាការ ដោយអាជ្ញាធរថៃមិនទាន់បើកឱ្យធ្វើទិដ្ឋាការថ្មីជូនដល់ពលករបរទេសនៅឡើយ។ មន្ត្រីអង្គការសង្គមស៊ីវិលលើកឡើងថា រឿងនេះ ប្រសិនបើរដ្ឋាភិបាលកម្ពុជា និងថៃមិនធាប់ដោះស្រាយជូនពួកគាត់ទេ នោះពលករខ្មែររាប់សែននាក់នឹងក្លាយទៅជាពលករខុសច្បាប់។

ពលករមានស្រុកកំណើតនៅបន្ទាយមានជ័យ លោក ទេព កាន រៀបរាប់ប្រាប់អាស៊ីសេរីថា ទិដ្ឋាការរបស់លោកអស់សុពលភាពនៅចុងខែមីនាខាងមុខនេះហើយ គឺថៅកែថៃមិនទាន់នាំលោកទៅស្នើសុំធ្វើទិដ្ឋាការថ្មីនៅឡើយទេ។ ពលកររូបនេះបន្ថែមថា លោកព្រួយបារម្ភខ្លាចអស់សុពលភាពទិដ្ឋាការនឹងក្លាយទៅជាពលករខុសច្បាប់ដែលត្រូវអាជ្ញាធរថៃចាប់ខ្លួនបញ្ជូនទៅកម្ពុជាវិញ។ លោកបន្តថា មួយរយៈនេះលោកធ្វើការបានប្រាក់បន្តិចបន្តួចសម្រាប់ទិញស្បៀងអាហារហូបចុកម្នាក់ឯងប៉ុណ្ណោះ ដោយមិនមានប្រាក់ផ្ញើទៅឪពុកម្ដាយនៅស្រុកកំណើតឡើយ។ លោកនិយាយថា លោកមិនចង់ត្រឡប់ទៅកម្ពុជាវិញអំឡុងពេលនេះទេ ព្រោះនៅផ្ទះគ្មានការងារធ្វើ។ ដូច្នេះ លោកសុខចិត្តខំស្នៅនៅប្រទេសថៃបន្តទៀត ក្រែងលោស្ថានការណ៍ជំងឺកូវីដ១៩ បានធូរស្រាលនឹងមានការងារធ្វើជាប់លាប់ឡើងវិញ៖ «និយាយរួមទៅខ្ញុំព្រួយបារម្ភសព្វបែបយ៉ាងណាមួយពេលនេះ ការងារអត់សូវមានធ្វើទេ ហើយមានជំងឺកូវីដទៀត។ មួយវិញទៀត ជិតដល់ខែតលិខិតឆ្លងដែន ហើយអត់មានលុយកាត់ទេ។ បើសិនបើយើងធ្វើខុសច្បាប់ ពិបាកដល់ពេលប៉ូលិសចូលមក អីចឹងគេចាប់យើង។ បើមានវីសាទៅយើងចង់ទៅធ្វើនៅកន្លែងណាក៏បានដែរ តែឥឡូវជិតដល់ថ្ងៃតវីសាហើយការងារអត់មានធ្វើទៀត»។

ស្របជៀងគ្នានេះ ពលករខ្មែរធ្វើការសំណង់នៅទីក្រុងបាងកក លោក អាត់ ខាន់ណា ថ្លែងថា មួយរយៈនេះលោកគិតច្រើនគេងមិនសូវលក់នោះឡើយ ដោយបារម្ភខ្លាចគ្មានប្រាក់ធ្វើទិដ្ឋាការថ្មីមិនបានផង និងខ្លាចដាច់ស្បៀងអាហារផង។ ពលករវ័យ ៣៩ឆ្នាំរូបនេះប្រាប់ថា សព្វថ្ងៃលោកធ្វើការបានប្រាក់ប្រមាណ ៥ពាន់ (៥.០០០) បាត ឬស្មើនឹង ១៦០ដុល្លារអាមេរិកក្នុងមួយខែ ស្របពេលដែលលោកត្រូវចិញ្ចឹមប្រពន្ធទើបមានកូនខ្ចីបាន ១០ខែ។ ដូច្នេះប្រាក់នេះគ្រប់សម្រាប់តែទិញអង្ករច្រកផ្ទាំងប៉ុណ្ណោះ។ លោកបន្តថា ប្រសិនបើលិខិតឆ្លងដែនរបស់លោក និងប្រពន្ធអស់សុពលភាពទិដ្ឋាការ គឺគ្រួសាររបស់លោកនឹងជួបការលំបាកកាន់តែខ្លាំង៖ «សព្វថ្ងៃខ្ញុំពិបាកចិត្តខ្លាំងណាស់គិតច្រើន មួយរឿងលិខិតឆ្លងដែន ខ្លាចយើងដាច់ទៅនៅប្រទេសគេមិនបាន ហើយបើយើងត្រឡប់ទៅខ្មែរយើងមិនមាន

ការធ្វើទេ។ មួយវិញទៀត ខ្ញុំខ្ចីប្រាក់ពីធនាគារច្រើនអត់មានប្រាក់សងគេទៀត សព្វថ្ងៃនេះពិបាកចិត្តណាស់ ការងារក៏មិនសូវមានធ្វើទៀត។ យើងព្រួយបារម្ភ ព្រោះវីសាយើងជិតដាច់ហើយ ណាមួយបើយើងមិនមានលុយគេក៏មិនធ្វើឱ្យយើង ហើយយើងមិនដឹងទៅពឹងអ្នកណាបាន ខ្ញុំព្រួយបារម្ភខ្លាំងណាស់»។ ពលកររូបនេះឱ្យដឹងទៀតថា កន្លែងធ្វើការរបស់លោកមានពលករខ្មែរធ្វើការ ប្រមាណ ៤០នាក់ ហើយពួកគាត់មានជីវភាពខ្វះខាត ដោយសារគ្មានការងារធ្វើ បណ្ដាលមកពីការរាតត្បាតជំងឺកូវីដ១៩ នៅក្នុងប្រទេសថៃ។ លោក អាត់ ខាន់ណា ប្រាប់ថា ពលករទាំងនោះអស់សុពលភាពទិដ្ឋាការនៅចុងខែមីនាទាំងអស់គ្នា ហើយពួកគាត់បារម្ភខ្លាចធ្វើទិដ្ឋាការមិនទាន់ នឹងក្លាយទៅជាពលករខុសច្បាប់ ដែលត្រូវអាជ្ញាធរថៃចាប់ដាក់គុក ឬចាប់បញ្ជូនត្រឡប់ទៅកម្ពុជាវិញ បានគ្រប់ពេល។

អាស៊ីសេរីថា មិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ និងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ដើម្បីសុំអត្ថាធិប្បាយជុំវិញពីក្ដីកង្វល់របស់ពលករនេះបានទេនៅថ្ងៃទី១៧ មករា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

ប៉ុន្តែរដ្ឋមន្ត្រីក្រសួងការងារថៃ លោក សុឆាត ឈុំក្លិន (Suchhat Chomklin) បានប្រាប់ទទួលប៉ុស្តិ៍លេខ៣របស់ថៃកាលពីថ្ងៃទី១៥ មករាថា ក្រសួងពាក់ព័ន្ធរបស់ថៃគ្រោងប្រជុំដោះស្រាយបញ្ហានេះនៅថ្ងៃទី២០ មករាខាងមុខ។ លោកបញ្ជាក់ថា ក្រសួងគ្រោងស្នើសុំពន្យារពេលសុពលភាពទិដ្ឋាការរបស់ពលករបរទេសរយៈពេល ៦ខែទៅមុខទៀត ដោយមិនមានការចាប់ចងពីសំណាក់អាជ្ញាធរថៃឡើយ៖ «ក៏បានជជែកគ្នាហើយថា រឿងលិខិតឆ្លងដែនដែលគាត់អស់សុពលភាព ដែលត្រូវតសុពលភាពនោះ ខាងក្រសួងការបរទេសរបស់ប្រទេសដើមកំណើតនឹងធ្វើយ៉ាងណា។ គេក៏បានគិតគូរថា នឹងចូលមកបោះទីតាំងធ្វើឱ្យពលរដ្ឋរបស់គេនៅក្នុងប្រទេសថៃ។ ប៉ុន្តែទាំងនេះអាស្រ័យលើនីតិវិធីរបស់ក្រសួងការបរទេសដើមកំណើត និងប្រទេសថៃ។ តែខ្ញុំគិតថា ស្ថានការណ៍រាតត្បាតជំងឺកូវីដ១៩ លើកទី២ វាមិនមែនជាពេលវេលាដែលយកមនុស្សជាច្រើននាក់មកប្រមូលផ្ដុំគ្នាកកកុញនៅមន្ទីរពេទ្យបានទេ»។ របាយការណ៍ក្រសួងការងារថៃឱ្យដឹងថា ពលករកម្ពុជា ឡាវ (Lao) និងភូមា (Myanmar) សរុបប្រមាណ ១លាន ៥សែននាក់ (១.៥០០.០០០) នឹងអស់សុពលភាពទិដ្ឋាការនៅចុងខែមីនាខាងមុខ។

អ្នកបកប្រែភាសាថៃ និងអ្នកការពារសិទ្ធិពលករខ្មែរនៅប្រទេសថៃ លោក ប្រាក់ ភត្រា ប្រាប់អាស៊ីសេរីថា ក្នុងចំណោមនោះមានពលករខ្មែរជាង ៣សែន (៣០០.០០០) ដែលនឹងអស់សុពលភាពទិដ្ឋាការធ្វើការងារនៅប្រទេសថៃ។ លោកបន្ថែមថា ពលករទាំងនោះនឹងក្លាយទៅជាពលករធ្វើការងារខុសច្បាប់ ប្រសិនបើពួកគាត់មិនអាចធ្វើទិដ្ឋាការថ្មីធ្វើការងារឱ្យទាន់ពេលវេលា។ លោកបញ្ជាក់ថា អំឡុងពេលនេះពលករមិនអាចធ្វើឯកសារបញ្ជាក់លិខិតស្នាម ដើម្បីសុំសិទ្ធិធ្វើការងារស្របច្បាប់បានឡើយ ដោយសារវិបត្តិជំងឺកូវីដ១៩។ លោកប្រាប់ថា ពលករខ្មែរជាច្រើននាក់កំពុងជ្រួលច្របល់បញ្ហានេះ ដោយពួកគាត់បានទាក់ទងមកលោកឱ្យជួយពួកគាត់ជាបន្តបន្ទាប់៖ «បច្ចុប្បន្ននេះគាត់ពិបាកហ្នឹងស្ថានភាពការងារគាត់មិនសូវមានហើយ គាត់ត្រូវចំណាយចាយវាយខ្ពស់លើការពន្យារទិដ្ឋាការស្នាក់នៅ ការសុំទិដ្ឋាការទៅមុខទៀត។ ខ្ញុំគិតថា វាជារឿងធំមួយដែលគួរឱ្យបារម្ភ ព្រោះថាបើសិនជាស្ថាប័នមិនបានរិធានការជួយសម្របសម្រួលដល់ពលករទេ គាត់អាចនឹងក្លាយជាពលករខុសច្បាប់ ដែលធ្វើឱ្យពួកគាត់ហ្នឹងរងគ្រោះដោយអាជ្ញាធរថៃចាប់ដំណើរការតាមច្បាប់»។

ចំណែកមន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហ្វយ៉ា វិញ លោកយល់ថា រឿងនេះជាទុក្ខលំបាកដ៏ធំរបស់ពលករ ដែលអាជ្ញាធរកម្ពុជា និងថៃគួរតែដោះស្រាយជាបន្ទាន់។ មន្ត្រីសង្គមស៊ីវិលរូបនេះជឿថា ប្រសិនអាជ្ញាធរប្រទេសទាំង២ មិនចេញមុខដោះស្រាយបញ្ហានេះទេ គឺពលករខ្មែររាប់សែននោះ នឹងក្លាយជាពលករខុសច្បាប់។ លោកប្រាប់ថា នៅពេលនោះពលករអាចនឹងត្រូវថៅកែកេងប្រវ័ញ្ចកម្លាំងពីពួកគាត់ ហើយបាត់បង់អត្ថប្រយោជន៍ការងារផ្សេងៗ ជាច្រើនទៀត៖ «អីចឹងបានជាប្រសិនបើមនុស្សរាប់សែននាក់នោះ ឬ

ដល់លាននាក់ត្រឡប់មកខ្មែរ អាហ្នឹងបញ្ហាកាន់តែធំហើយ។អីចឹងរដ្ឋាភិបាលកម្ពុជាគួរតែគិតពិចារណា ហើយចាត់វិធានការណ៍ឱ្យឆ្លើយតបនឹងបញ្ហានេះ។ មួយទៀត ពលករត្រូវបង្ហាញអំពីទុក្ខកង្វល់របស់ខ្លួន ដែលជួបបញ្ហា ដើម្បីឱ្យរដ្ឋាភិបាលប្រទេសទាំងពីរ ជាពិសេសរដ្ឋាភិបាលកម្ពុជា ឱ្យបានដឹងបញ្ហារបស់ខ្លួន ហើយយើងចូលរួមធ្វើការទាំងអស់គ្នាជាមួយអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យហ្នឹង»។ លោកបន្តថា ពលករទាំងនោះធ្វើទិដ្ឋាការធ្វើការងារស្របច្បាប់នៅក្នុងប្រទេសថៃរយៈ ២ឆ្នាំម្តង ហើយទិដ្ឋាការការងាររបស់ពួកគាត់នឹងអស់សុពលភាពនៅចុងខែមីនាខាងមុខ។ មន្ត្រីសង្គមស៊ីវិលរូបនេះ ព្រួយបារម្ភថា ពួកគាត់អាចនឹងបំពេញបែបបទធ្វើការងារមិនទាន់នោះទេ ព្រោះអំឡុងពេលនេះអាជ្ញាធរថៃបានត្រួតពិនិត្យតឹងតែងលើពលករបរទេស ដោយមិនឱ្យពួកគាត់ចល័តទីតាំងធ្វើការងារនោះឡើយ។ លោកថា ប្រសិនបើពលករទាំងនោះក្លាយពលករខុសច្បាប់ ពួកគាត់អាចនឹងត្រូវអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់ទៅកម្ពុជាវិញ ឬចាប់ដាក់ពន្ធនាគារបានគ្រប់ពេល។ លោក ឌី ថេហូយ៉ាង ឱ្យដឹងថា បច្ចុប្បន្នពលករខ្មែរធ្វើការងារស្របច្បាប់ និងមិនស្របច្បាប់មានប្រហែលពី ១លាន ៨សែនទៅ ២លាននាក់ (២.០០០.០០០) ធ្វើការងារនៅប្រទេសថៃ៕

## លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុ បានអញ្ជើញដឹកនាំកិច្ចប្រជុំជំនាញដល់ផែនការងារប្រឆាំងបទល្មើសគ្រឿងញៀន ផែនការងារប្រឆាំងការជួញដូរ និងផែនការងារប្រឆាំងបទល្មើសសេដ្ឋកិច្ច

https://gdlf-kh.com/ 2021/01/18/ Kao sophy ខេត្តព្រះសីហនុ

ខេត្តព្រះសីហនុ៖ នៅព្រឹកថ្ងៃច័ន្ទ ៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១នេះ លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុ បានអញ្ជើញដឹកនាំកិច្ចប្រជុំជំនាញដល់ផែនការងារប្រឆាំងបទល្មើសគ្រឿងញៀន ផែនការងារប្រឆាំងការជួញដូរ និងផែនការងារប្រឆាំបទល្មើសសេដ្ឋកិច្ច នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។ ក្នុងកិច្ចប្រជុំនោះផងដែរ លោកឧត្តមសេនីយ៍ទោស្នងការបានមានប្រសាសន៍ថា វិធានការទាំងបីគឺ អប់រំផ្សព្វផ្សាយ វិធានការជំនាញ និងវិធានការច្បាប់ត្រូវដើរព្រមគ្នា ហើយហាមជាដាច់ខាតចំពោះមន្ត្រីអនុវត្តច្បាប់ណាទៅកាង ឬនៅពីក្រោយបទល្មើស ៕

## គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកំពង់ចាម បើកកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារប្រចាំ ឆ្នាំ២០២០

https://www.pdikampongcham.info/ ១៨ ខែមករា ២០២១ *អត្ថបទ៖ ទឹម សំណាង*

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ បើកកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារប្រចាំ ឆ្នាំ២០២០ ក្រោមអធិបតីភាព លោកជំទាវ ប៉ាង ដានី អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកំពង់ចាម កិច្ចប្រជុំនេះ ក៏មានការអញ្ជើញចូលរួមពី លោក លោកស្រី ជាប្រធាន អនុប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ និង លោក លោកស្រី ជាអភិបាលរងក្រុង ស្រុក ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាច្រើនរូបទៀត ផងដែរ ។

នាឱកាសនោះ លោកជំទាវ ប៉ាង ដានី បានលើកឡើងថា នាបច្ចុប្បន្នប្រព័ន្ធអប់រំផ្សព្វផ្សាយ បានផ្សព្វផ្សាយថា ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងបរិបទសង្គម ដែលកំពុងតែមានវិបត្តិជម្ងឺកូវីដ ១៩ ក៏មានជនទុច្ចរិត ឆ្លៀតក្នុងឱកាស ធ្វើសកម្មភាពជួញដូរមនុស្ស ។ អញ្ចឹងទេ យើងជាគណៈកម្មាការខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវតែរួបរួមគ្នា ខិតខំធ្វើការងារនេះ ឲ្យបានជោគជ័យ ។ លោកជំទាវ បានរំលឹក ដល់អង្គប្រជុំផងដែរ

ថា ប្រជាពលរដ្ឋ ដែលបានធ្វើចំណាកស្រុក ទៅកាន់ប្រទេសជិតខាមានចំនួនសរុបទាំងអស់ ១៣.៥៨២នាក់ ប៉ុន្តែចំនួនប្រជាពលរដ្ឋ ដែលស្របច្បាប់មានចំនួន ១០.៦៨០នាក់ ប៉ុណ្ណោះ និងបានធ្វើចំណូលស្រុកត្រឡប់មកវិញ គិតត្រឹមថ្ងៃទី១៧ ខែមករា ឆ្នាំ២០២១នេះ មានចំនួនសរុប ៦.១១៣នាក់ ។

នេះជាចំនួនដ៏ច្រើន ដែលត្រូវត្រឡប់មកវិញក្នុងនោះ ប្រជាពលរដ្ឋចំណាកស្រុកច្រើនជាងគេ គឺនៅ ៖ ១.ស្រុកស្ទឹងត្រង់ ដែលមានប្រមាណជា ២.៥៩៣នាក់ ក្នុងនោះ មានស្ត្រី១.៣៣៣នាក់។ ទី២.ស្រុកព្រៃឈរ ២.០៥៣នាក់ ។ ទី៣.ស្រុកកងមាស និងតិចជាងគេ គឺនៅក្នុងក្រុងកំពង់ចាម មាន ៥៧៣នាក់ ។ ដោយឡែកចំពោះ អ្នកចំណូលស្រុកវិញ គិតត្រឹមថ្ងៃ១៨ ខែមករា ឆ្នាំ២០២១ នេះ ស្រុកដែលច្រើនជាងគេ គឺ ៖ ១.ស្រុកចំការលើ មានចំនួន ១.២៣៣នាក់ ។ ទី២.ស្រុកព្រៃឈរ មានចំនួន ៨.២០១នាក់ ។ ៣.ស្រុកកំពង់សៀម មានចំនួន ៨០៩នាក់ និងស្រុកដែលតិចជាងគេគឺស្រុកស្រីសន្ធរ ។ ប៉ុន្តែ ចំណូលស្រុក របស់ក្រុងកំពង់ចាម មានចំនួន ៨៩៣នាក់ ខណៈដែលអ្នកចាកចេញស្របច្បាប់ មានចំនួន ៥៧៣នាក់ តែដល់ពេលចំណូលស្រុកវិញ មានចំនួន ៥៩៣នាក់ ។ ជាមួយគ្នានោះដែរ លោកជំទាវ ក៏បានថ្លែងនូវការកោតសរសើរ ចំពោះ ក្រុមការងារទាំងអស់ ដែលបានខិតខំបំពេញភារកិច្ច កន្លងមក ។ ប៉ុន្តែ នៅឆ្នាំបន្ទាប់នេះ យើងទាំងអស់គ្នា ត្រូវតែមានផែនការ សកម្មភាព មានរបាយការណ៍ច្បាស់លាស់ ដើម្បី បញ្ជាក់ពីសកម្មភាពការងារ ដែលយើងទាំងអស់គ្នា បាន យកចិត្តទុកដាក់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់បណ្ដាគោលដៅ ផងដែរ ៕

## ពលករខ្មែរម្នាក់ស្លាប់ និងម្នាក់ទៀតរងរបួសធ្ងន់នៅប្រទេសថៃ

https://kampucheathmey.com/ on January 18, 2021 By Sokhom Khon

ពលករខ្មែរម្នាក់បានស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ ចំណែកម្នាក់ទៀតរងរបួសធ្ងន់ ត្រូវបានអាជ្ញាធរនៃប្រទេសថៃ បញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍មួយ នាខេត្តប្រាជីនបុរី ។

តាមការផ្សព្វផ្សាយព័ត៌មានក្នុងស្រុកថៃ បានបញ្ជាក់ថា ករណីគ្រោះថ្នាក់ចរាចរណ៍នេះ បានកើតឡើងកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១២និង៤៩ នាទីថ្ងៃត្រង់ ក្នុងភូមិសាស្ត្រភូមិ២ ឃុំបានណា ស្រុកកាបិនបុរី ខេត្ត ប្រាជីនបុរី ប្រទេសថៃ។ នៅកន្លែងកើតហេតុ គេសង្កេតឃើញថា ម៉ូតូដែលបង្កឡើងដោយខ្លួនឯងនោះ ម៉ាកហុងដា វេវ ធុនC110 ពណ៌ ស ខ្មៅពាក់ស្លាកលេខ ស្រះកែវ ២៩៤៤ បើកបរដោយឈ្មោះ សាន់ ម៉េងហន ភេទប្រុស អាយុ៣៥ ឆ្នាំ និងអ្នករួមដំណើរ គឺជាជនជាតិខ្មែរដូចគ្នា។

តាមការអះអាងពីសមត្ថកិច្ចថៃ បានបញ្ជាក់ថា មូលហេតុគឺដោយសារតែការបើកបរមានល្បឿនលឿន លុះដល់ត្រង់ចំណុចផ្លូវកោង មិនអាចយកចង្កូតមកវិញបាន ក៏ជ្រុលទៅបុកនឹងបង្គោលភ្លើង បណ្ដាលអោយបាក់ ក ស្លាប់ម្នាក់តែម្ដង ដោយ បច្ចុប្បន្នសមត្ថកិច្ចបានបញ្ជូនទាំងអ្នករងរបួស ក៏ដូចជាសព ជនរងគ្រោះទៅកាន់មន្ទីរពេទ្យស្រុកកាបិនបុរីហើយ ដើម្បីចាត់ចែងតាមនីតិវិធី៕ **អត្ថបទ ៖ សោ និយមរ័ត្ន**

## កូវីដ១៩៖ អាជ្ញាធរថៃអំពាវនាវឲ្យពលករទាំងអស់ចុះឈ្មោះធ្វើប័ណ្ណស្នាក់នៅស្របច្បាប់ក្នុងប្រទេសថៃ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 18/01/2021 - 08:06

អាជ្ញាធរថៃបានអំពាវនាវឲ្យពលករទាំងអស់ រួមទាំងពលករកម្ពុជាផង ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ទៅចុះឈ្មោះធ្វើប័ណ្ណស្នាក់នៅស្របច្បាប់នៅក្នុងប្រទេសថៃ ដើម្បីជៀសវាងការដាក់ទោសពីអាជ្ញាធរថៃ។ ការចេញមកអំពាវនាវជាថ្មីម្ដងទៀតនេះ គឺធ្វើឡើងដើម្បីទប់ស្កាត់ការចម្លងបន្តនូវជំងឺកូវីដ១៩នៅក្នុងប្រទេសថៃ និងដើម្បីឲ្យ

អាជ្ញាធរមានភាពងាយស្រួលក្នុងការតាមដានសុខភាពពលករទាំងនោះ។ នេះបើយោងតាមកាសែត បាងកកប៉ុស្តិ៍ ចុះផ្សាយនៅថ្ងៃចន្ទទី១៨មករានេះ។

លោក Taweesilp Visanuyothin អ្នកនាំពាក្យមជ្ឈមណ្ឌលសម្រាប់ស្ថានភាពកូវីដ១៩ថៃ កាលពីម្សិលមិញបានចេញមកអំពាវនាវឲ្យពលករទាំងអស់ ដែលកំពុងស្ថិតនៅប្រទេសថៃ ទៅចុះឈ្មោះស្នើសុំប័ណ្ណស្របច្បាប់ពីក្រសួងការងារថៃ។ បើតាមអ្នកនាំពាក្យ ការធ្វើបែបនេះ គឺដើម្បីបង្ការការឆ្លងជំងឺកូវីដ១៩ជាបន្តដោយមិនដឹងប្រភព ព្រោះថាបើតាមការសន្និដ្ឋានមានពលករកំពុងធ្វើការនៅប្រទេសថៃ ប្រមាណជាង៥ម៉ឺននាក់ ជាពលករខុសច្បាប់ ដែលជាបញ្ហាបារម្ភរបស់អាជ្ញាធរថៃ ក្នុងការតាមដានពួកគេ។ ក្នុងចំណោមពលករខុសច្បាប់ទាំងអស់ រួមមានពលករមកពីប្រទេសកម្ពុជា ពលករមកពីប្រទេសភូមា និងប្រទេសឡាវ ត្រូវទៅធ្វើការចុះឈ្មោះសុំប័ណ្ណស្របច្បាប់ ចាប់ពីដើមខែមករាដល់ថ្ងៃទី១៣កុម្ភៈ ហើយអាជ្ញាធរនឹងមិនពិន័យ ឬដាក់ទោសទណ្ឌលើពួកគេនោះឡើយនៅក្នុងស្ថានការណ៍នៃជំងឺកូវីដ១៩។ បើតាមអ្នកនាំពាក្យដដែរ វិធានការបែបនេះ គឺដើម្បីគ្រប់គ្រងស្ថានការណ៍ឆ្លងនៃជំងឺកូវី១៩ឲ្យបានល្អប្រសើរ និងធ្វើឲ្យអាជ្ញាធរមានភាពងាយស្រួលនៅក្នុងការតាមដានសុខភាពពួកគេ។ ទន្ទឹមនេះដែរ ក្រោយពីការចុះឈ្មោះសុំភាពស្របច្បាប់រួច ពលករទាំងអស់នឹងអាចស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃដោយស្របច្បាប់ចំនួន២ឆ្នាំ។ នេះបើតាមការបញ្ជាក់របស់លោក Taweesilp Visanuyothin។

គិតមកទល់ពេលនេះ ក្រសួងសុខាភិបាលថៃ បានរកឃើញករណីវិជ្ជមានជំងឺកូវីដ១៩ មានរហូតដល់ ១២ ០៥៤នាក់ ស្លាប់៧០នាក់ និងកាលពីថ្ងៃទី១៧ ខែមករា ម្សិលមិញ អាជ្ញាធរថៃបានរកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ ចំនួន ៣៧៤នាក់។ រាប់ចាប់តាំងពីមានការផ្ទុះរាលដាលជំងឺកូវីដ១៩ជាសហគមន៍នៅខេត្តសាមុត សាខន កាលពីខែធ្នូកន្លងទៅ ពេលនេះខេត្តចំនួន៦១ទៀត ក៏ត្រូវបានរកឃើញថាមានអ្នកវិជ្ជមានជំងឺកូវី១៩ដែរ លើកលែងតែខេត្តចំនួន១៦ប៉ុណ្ណោះ មិនទាន់មានការរកឃើញ។ ជាមួយគ្នានេះ ពលករចំណាកស្រុកកម្ពុជា ក៏ត្រូវបានរកឃើញវិជ្ជមានកូវីដ១៩ផងដែរ ទាំងនៅក្នុងប្រទេសថៃ និងពលករដែលត្រលប់ចូលមកកម្ពុជាវិញ។ អាជ្ញាធរកម្ពុជា បានរកឃើញពលករខ្មែរចំនួន៦៩នាក់ បានឆ្លងជំងឺកូវីដ១៩ ក្រោយត្រលប់មកពីប្រទេសថៃ ចាប់តាំងពីមានការផ្ទុះកូវីដ១៩ជាសហគមន៍ នៅខេត្តសាមុត សាខន កន្លងមក៕

## ថ្ងៃទី២០ ខែ មករា ឆ្នាំ២០២១

### សម្តេចក្រឡាហោម ស ខេង៖ ការលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារ មិនត្រូវបានដកចេញពីគោលនយោបាយភូមិឃុំ មានសុវត្ថិភាពឡើយ

http://www.freshnewsasia.com/ 2021-01-19 11:21am

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១នេះ បានលើកឡើងថា កម្មវិធីមួយចំនួនត្រូវបានដកចេញ និងកែសម្រួលក្នុងគោលនយោបាយភូមិឃុំ មានសុវត្ថិភាព ដើម្បីឲ្យត្រូវបានស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ខណៈកម្មវិធីមួយចំនួនមិនសូវជាកង្វល់ទៀតឡើយ។ សម្តេចក្រឡាហោម ស ខេង បានអះអាងថា សម្រាប់បញ្ហាគ្រឿងញៀន និងការលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារ មិនត្រូវបានដកចេញពីគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាពនោះទេ។ រហូតមកដល់ពេលនេះ ការកែសម្រួលថ្មី នៃគោលនយោបាយភូមិឃុំ មានសុវត្ថិភាព កំពុងរៀបចំជិតរួចរាល់ហើយ ដើម្បីត្រៀមស្នើសុំការសម្រេចពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា។ ក្នុងឱកាសអញ្ជើញជាអធិបតី ប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ «**ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣**» សម្តេចក្រឡាហោម ស ខេង បានថ្លែងយ៉ាងដូច្នេះថា «**បញ្ហាខ្លះយើងអាចដកចេញ ពីគោលនយោបាយ**

ភូមិឃុំមានសុវត្ថិភាព ដើម្បីយើងបញ្ចូលបញ្ហាបច្ចុប្បន្នភាព បញ្ហាដែលមានសារៈសំខាន់សម្រាប់បច្ចុប្បន្នភាពចូលវិញ [...] ក្នុងនោះបញ្ហាដែលទាក់ទងនឹងការជួញដូរស្ត្រី អំពើហិង្សា គឺមិនត្រូវបានដកចេញនោះទេ ពោលបញ្ហានៅដដែល តែយើងថែមបញ្ហាសំខាន់ៗ»។

សម្តេចក្រឡាហោម ស ខេង បានសង្កត់ធ្ងន់ថា បញ្ហាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បញ្ហាគ្រឿងញៀន នៅតែជាកង្វល់ចំពោះមុខរបស់យើងនៅឡើយ។ បញ្ហាទាំងអស់នេះទាមទារឲ្យទាំងអស់គ្នា បន្តយកចិត្តទុកដាក់ខិតខំប្រឹងប្រែង ពុះពារជំនះ និងដោះស្រាយប្រកបដោយយុត្តិធម៌និងកាន់តែមានប្រសិទ្ធភាពថែមទៀត ដើម្បីឲ្យប្រជាជន ជាពិសេសស្ត្រីកម្ពុជាដែលមានចំនួនរហូតដល់ ៥២ភាគរយ នៃប្រជាជនសរុបរស់នៅប្រកបដោយការគោរពសិទ្ធិ សេចក្តីសុខ និងសុវត្ថិភាពក្នុងជីវិត និងភាពសុខដុមរមនាក្នុងសង្គម។ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអះអាងថា រាជរដ្ឋាភិបាលកម្ពុជា ក៏បាននិងកំពុងបន្តបោះជំហានទៅមុខលើទិសដៅដ៏ត្រឹមត្រូវ និងប្រកបដោយយុទ្ធសាស្រ្ត ក្នុងការពង្រឹងស្ថាប័ន និងកិច្ចការពារដល់ប្រជាពលរដ្ឋ ជាពិសេស គឺផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើស្ត្រី និងកុមារនៅកម្រិតសហគមន៍ដើម្បីធានានូវសិទ្ធិស្មើភាពគ្នារវាងស្ត្រី និងបុរស។

ដោយឡែក ពាក់ព័ន្ធគោលភូមិឃុំ មានសុវត្ថិភាពនេះ សម្តេចក្រឡាហោម ស ខេង បានគូសបញ្ជាក់ទៀតថា កន្លងទៅតាមរយៈការអនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាព យើងបានឃើញថា យើងទាំងអស់គ្នា បានខិតខំប្រឹងប្រែងដើម្បីអនុវត្តនូវគោលនយោបាយនេះ ហើយមានវឌ្ឍនភាពយ៉ាងល្អ។ ក្នុងរយៈពេល១០ឆ្នាំ តាំងពីឆ្នាំ ២០១០-២០២០ គឺលទ្ធផលនៃការអនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាពនេះ គឺទទួលបានជោគជ័យធំណាស់។ បើតាមសម្តេចក្រឡាហោម ស ខេង បើទោះបីអនុវត្តបានល្អយ៉ាងក្តី ក៏នៅមានបញ្ហាខ្លះដែលនៅតែជាបញ្ហា ហើយអាចធំជាងមុនថែមទៀត។ ឧទាហរណ៍បញ្ហាគ្រឿងញៀន ស្ថិតក្នុងកម្មវិធីមួយ នៃគោលនយោបាយភូមិឃុំមានសុវត្ថិភាព ក្នុងការអនុវត្តកន្លងទៅ ស្ថាប័នពាក់ព័ន្ធខិតខំប្រឹងប្រែងច្រើន ប៉ុន្តែដោយសារទីផ្សារគ្រឿងញៀនវារីករាលដាលកាន់តែធំ ចឹងហើយចំនួនចាប់ជនប្រព្រឹត្តបទល្មើស ឬក៏វត្ថុតាងគ្រឿងញៀន មកផ្តន្ទាទោសកាន់តែច្រើន តែវាមិនទាន់ធូរស្រាល។ សម្តេចក្រឡាហោម ស ខេង បានអះអាងថា សម្តេចបានស្នើទៅសម្តេចតេជោនាយករដ្ឋមន្ត្រី ដើម្បីលើកកម្ពស់កម្រិត នៃគោលនយោបាយភូមិឃុំ មានសុវត្ថិភាព មានន័យថា ពីមុនគ្រាន់តែជារបស់ក្រសួងមហាផ្ទៃតែមួយទេ ប៉ុន្តែពេលនេះ ត្រូវលើកកម្រិតថា មិនមែនជារបស់ក្រសួងណាមួយទៀតទេ គឺជារបស់រាជរដ្ឋាភិបាល ហើយយើងបានពង្រីកខ្លឹមសាររបស់វា ឲ្យកាន់តែទូលំទូលាយបន្ថែមទៀត ហើយនឹងដកចេញនូវចំណុចមួយចំនួន៕

## រដ្ឋមន្ត្រីមហាផ្ទៃ ៖ បញ្ហាអំពើហិង្សា ផ្លូវភេទ គ្រប់ទម្រង់ នៅតែជាក្តីកង្វល់ ដែលត្រូវដោះស្រាយជាចំបាច់

https://dap-news.com/national/ ByPH104 Posted on January 19, 2021

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ថា បញ្ហាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទលើស្ត្រី និងកុមារ ព្រមទាំងបញ្ហាគ្រឿងញៀន នៅតែជាក្តីកង្វល់ចំពោះមុខ ដែលទាមទារឲ្យភាគីពាក់ព័ន្ធ ត្រូវដោះស្រាយ ប្រកបដោយយុត្តិធម៌ និងត្រឹមត្រូវបំផុត ។ សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍បែបនេះ ក្នុងកម្មវិធីប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ នាព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា។ សម្តេចក្រឡាហោម បានបញ្ជាក់យ៉ាង

ដូច្នេះថា «បញ្ហាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ព្រមទាំងបញ្ហាគ្រឿងញៀន នៅតែជាកង្វល់ចំពោះមុខ របស់យើងនៅឡើយ ។ បញ្ហាទាំងអស់នេះទាមទារឱ្យយើងទាំងអស់គ្នា ជាអ្នកពាក់ព័ន្ធ បន្តយកចិត្តទុកដាក់ខិតខំប្រឹងប្រែងពុះពារជំនះ និងដោះស្រាយប្រកបដោយយុត្តិធម៌ និងកាន់តែមានប្រសិទ្ធភាពថែមទៀត ដើម្បីឱ្យប្រជាជនយើង ជាពិសេសស្ត្រីកម្ពុជាដែលមានចំនួនរហូតដល់៥២ភាគរយ នៃប្រជាជនសរុបរស់នៅប្រកបដោយការគោរពសិទ្ធិ សេចក្តីសុខ និងសុវត្ថិភាពក្នុងជីវិត និងភាពសុខដុមរមនាក្នុងសង្គម»។

សម្តេចក្រឡាហោម បន្តថា ដើម្បីសម្រេចបានគោលបំណងនេះ រាជរដ្ឋាភិបាលបាននឹងកំពុងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី១ ទី២ ទី៣ និងទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គោលនយោបាយ និងកម្មវិធីតាមវិស័យ ជាពិសេស ការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដែលលក្ខណៈសម្បត្តិទី៣ចែងថា «គ្មានអំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ » ព្រមទាំង បានបង្កើតយន្តការ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងផែនការសកម្មភាពជាតិនានា ដើម្បីឆ្លើយតប ចំពោះអំពើហិង្សាគ្រប់ទម្រង់លើស្ត្រី និងក្មេងស្រី និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់ សេវាជាពហុវិស័យជួយស្ត្រីរងគ្រោះដោយអំពើហិង្សាឱ្យបានទាន់ពេលវេលា។ សម្តេចក្រឡាហោមបន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា ក៏បាននឹងកំពុងបន្តបោះជំហានទៅមុខ លើទិសដៅ ដ៏ត្រឹមត្រូវ និងប្រកបដោយយុទ្ធសាស្ត្រ ក្នុងការពង្រឹងស្ថាប័ន និងកិច្ចការពារដល់ប្រជាពលរដ្ឋ ជាពិសេសគឺផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើស្ត្រី និងកុមារនៅកម្រិតសហគមន៍ ដើម្បីធានានូវសិទ្ធិស្មើភាពគ្នា រវាងស្ត្រីនិងបុរស។ ជាងនេះទៅទៀត សម្តេចក្រឡាហោម ស ខេង ក៏បានលើកឡើងថា «យើងជឿជាក់ថា ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣នេះ នឹងក្លាយជាផែនទី តម្រង់ទិសដ៏ស័ក្តិសិទ្ធិ មួយ ដែលនឹងជួយជំរុញបន្ថែមទៀត ក្នុងការអនុវត្តការងារទប់ស្កាត់ និងលុបបំបាត់អំពើហិង្សា លើស្ត្រីគ្រប់ទម្រង់ឱ្យកាន់តែសម្រេច បានឆាប់រហ័សតាមការរំពឹងទុក » ៕

## សមត្ថកិច្ចឃាត់ខ្លួនមេខ្យល់ម្នាក់ដែលរត់ពន្ធពលករទៅប្រទេសថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 19/01/2021

បន្ទាយមានជ័យ ៖ កម្លាំងយោធា និងនគរបាលកម្លាំងខេត្តបន្ទាយមានជ័យ បានសហការឃាត់ខ្លួនមេខ្យល់ម្នាក់ ពាក់ព័ន្ធរត់ពន្ធ ជួញដូរមនុស្សឆ្លងដែន ពីកម្ពុជាទៅថៃ ហើយបានបញ្ជូនសំណុំរឿងទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១នេះ។ ជនសង្ស័យឈ្មោះ ប៊ិក ឧត ឬ ប៊ិក ដួត ភេទប្រុស អាយុ៣៦ឆ្នាំ នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

សមត្ថកិច្ចបានឲ្យដឹងថា ជនសង្ស័យខាងលើនេះ ត្រូវបានកម្លាំងយោធាកងការពារព្រំដែន៥០៣ នៃយោធភូមិភាគតី៥ ល្បាតឃើញមុខសញ្ញា៣នាក់ នេះកំពុងជូនពលករខ្មែរប្រុស ស្រីចំនួន១១នាក់ ក្នុងនោះក្មេងតូចអាយុ០៣ខែ០១នាក់ លួចរត់ពន្ធមនុស្សដែនពីកម្ពុជា ទៅថៃ នៅចំណុចចំការស្វាយ ស្ថិតក្នុងភូមិចំការគ ឃុំ ស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យកាលពីម៉ោង១០យប់ថ្ងៃទី១៦ខែមករាឆ្នាំ២០២១ ។ ក្រោយការឃាត់ខ្លួនក៏បានបញ្ជូនជនសង្ស័យនេះ អោយជំនាញនៃអធិការដ្ឋាននគរបាលស្រុកស្វាយចេក ដើម្បីសាកសួរ ។ ចំណែកពលករប្រុស ស្រីទាំង១១នាក់ ក្នុងនោះក្មេងប្រុសតូច០១នាក់ នាំទៅធ្វើចត្តាឡីស័ក នៅមណ្ឌលសំចតឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

តាមចម្លើយសារភាពរបស់ជនសង្ស័យឈ្មោះ ប៊ិក ឧតឬប៊ិក ដួត បានបញ្ជាក់ថា ខ្លួននិងបក្សពួកចំនួន០២នាក់ទៀត ។ តែពួកគេឈ្មោះ ឡុំ ភេទប្រុសនិងឈ្មោះថា ភេទប្រុស បានធ្វើសកម្មភាពនាំមនុស្សទៅថៃចំនួន១១នាក់ ពិតប្រាកដមែនដោយយកកម្រៃជូនឆ្លងដែនថ្លៃ១០០បាត/ម្នាក់។ ពេលពួកខ្លួននាំពលករដើរទៅដល់ចំណុចខ័ណ្ឌនៃព្រំដែន ត្រូវបានកម្លាំងយោធាខ្មែរឃាត់ខ្លួនតែម្តង ។ កម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានរៀបចំសំណុំរឿងបញ្ជូនជនសង្ស័យទៅសាលាដំបូងខេត្ត ដើម្បីចាត់ការតាមនីតិវិធី៕

## អាជ្ញាធរខេត្តត្បូងឃ្មុំ បានអប់រំដោយផ្ទាល់ ពីវិធីបង្ការជំងឺឆ្លងកូវីដ១៩ ដល់ពលករខ្មែរ មកពីក្រៅប្រទេសជិត ៦ពាន់នាក់

https://dap-news.com/ ByVNT108 Posted on January 19, 2021

ភ្នំពេញ៖ លោក ស៊ាក ឡេង ប្រធានក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ បានលើកឡើងថា គិតត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ អាជ្ញាធរខេត្តត្បូងឃ្មុំ បានអប់រំដោយផ្ទាល់ពីវិធីបង្ការជំងឺឆ្លងកូវីដ១៩ ដល់ពលករដែលវិលត្រឡប់ មកពីក្រៅប្រទេសចំនួន ៥៨១៥ នាក់ ក្នុងនោះស្រី ២៣២១នាក់ ។ ថ្លែងក្នុងសន្និសីទសារព័ត៌មានស្តីពី «វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តខេត្តត្បូងឃ្មុំ» នាព្រឹកថ្ងៃទី១៩ មករានេះ លោក ស៊ាក ឡេង បានមានប្រសាសន៍ថា ចំពោះការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ គឺអាជ្ញាធរខេត្តបានជម្រុញ គណៈបញ្ជាការឯកភាពក្រុង-ស្រុក ធ្វើការផ្សព្វផ្សាយទៅដល់ឃុំ-សង្កាត់ និងទីតាំងសំខាន់ៗ តាមចំនួនដែលបានកំណត់ ដោយធ្វើការផ្សព្វផ្សាយ តាមរយៈការចាក់ផ្សាយតាម ទូរទស្សន៍ Online ចាក់ផ្សាយតាមវិទ្យុជាតិត្បូងឃ្មុំ តាមវេបសាយមន្ទីរព័ត៌មានខេត្ត ការចាក់ឧឃោសនស័ព្ទ ការផ្សព្វផ្សាយតាមបណ្តាញសង្គម បិទផ្សាយផ្ទាំងរូបភាព នៅគ្រប់បណ្តាឃុំ-សង្កាត់ទាំង៦៤ និងភូមិចំនួន ៨៧៣ភូមិ។ ប្រធានក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ បញ្ជាក់ថា «គិតត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ បានអប់រំដោយផ្ទាល់ពីវិធីបង្ការជំងឺឆ្លង ជូនពលករដែលបានវិលត្រឡប់ មកពីក្រៅប្រទេសសរុបចំនួន ៥៨១៥ នាក់ ស្រី ២៣២១ នាក់ ក្នុងនោះមកពីប្រទេសថៃចំនួន ៤៥៤៥ នាក់ ស្រី ១៨៤២នាក់ និងប្រទេសផ្សេងៗ ចំនួន ១២៧០ នាក់ ស្រី ៤៧៩នាក់» ។

លោកបន្ថែមថា ដោយឡែកមូលនិធិរដ្ឋបាលខេត្ត ដើម្បីយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ បានទទួលថវិកាពីក្រសួងស្ថាប័នពាក់ព័ន្ធ សប្បុរសជន ក្រុមហ៊ុន និងអង្គការដៃគូនានា សរុបចំនួន ៧៦ ៥៥៧ ០០០រៀល និងប្រាក់ដុល្លា ៩ ៧១២ដុល្លា និងសម្ភារៈរួមមាន ម៉ាស់ចំនួន ២២២ ០០០ ម៉ាស់ ម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគ ចំនួន ៣៥គ្រឿង ទឹកថ្នាំសម្លាប់មេរោគ ៤ធុង អាល់កុល ៥៩កាន ដែលលាងដៃ ៧៧៦ដប សាប៊ូលាងដៃ ២១កេស ស្មើនឹង ១ ៥២១ដុំ និងខិតប័ណ្ណសម្រាប់ផ្សព្វផ្សាយចំនួន ១ ០០០សន្លឹក។ លោកបន្តថា ចំពោះថវិកាសម្រាប់ ចូលរួមទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនរាជរដ្ឋាភិបាលកម្ពុជា សរុបចំនួន ២២១ ២៤០ ០០០រៀល និងចំនួន ១៤ ៤៩០ដុល្លារ ។

ក្រៅពីការងារប្រយុទ្ធប្រឆាំងកូវីដ១៩ ប្រធានក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ គូសបញ្ជាក់ថា ការងារគ្រប់គ្រងរដ្ឋបាល ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការងារកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ច ការងារផ្តល់សេវាសាធារណៈ ការងារគ្រប់គ្រងព្រំដែន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការអភិវឌ្ឍសមត្ថភាព ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ការអភិវឌ្ឍវិស័យឯកជន វិស័យការងារ និងវិស័យបណ្តុះបណ្តាល ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងគ្រោះមហន្តរាយ ការគ្រប់គ្រងដីសាធារណៈរបស់រដ្ឋ ការដោះស្រាយទំនាស់ដីធ្លី ក៏កំពុងត្រូវបានជានា និងមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ ដែលបានរួមចំណែកយ៉ាងសំខាន់ ដល់ខេត្តទាំងមូល មានការប្រែ

មុខមាត់ថ្មី ព្រមទាំងបានលើកកម្ពស់ស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មានភាពប្រសើរឡើង ពីមួយឆ្នាំទៅមួយឆ្នាំ ។

សូមរំលឹកថា គិតត្រឹមព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១នេះ កម្ពុជាបានរកឃើញអ្នកឆ្លងជំងឺកូវីដ១៩ សរុបចំនួន៤៣៩នាក់ ក្នុងនោះអ្នកព្យាបាលជាសះស្បើយចំនួន ៣៨៦ និងអ្នកកំពុងសម្រាក នៅមន្ទីរពេទ្យចំនួន ៥៣ នាក់ ៕

## រដ្ឋបាលខណ្ឌដូនពេញ ចុះប្រមូលស្ត្រីរកស៊ីផ្លូវភេទ ដែលឈរនៅតាមរបង និង ក្រោមដើមឈើ រួមទាំងអ្នកគកដេរ(អ្នកចាប់ម៉ូយ) ជុំវិញវត្តភ្នំ

https://khmernote.com.kh/ ព័ត៌មានជាតិ January 19, 2021 Khmernote Media

ភ្នំពេញ៖ រដ្ឋបាលខណ្ឌដូនពេញ ចុះប្រមូលស្ត្រីរកស៊ីផ្លូវភេទ ដែលឈរនៅតាមរបង និង ក្រោមដើមឈើ រួមទាំងអ្នកគកដេរ(អ្នកចាប់ម៉ូយ) ជុំវិញរមណីយដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ និង សួនច្បារមិត្តភាពកម្ពុជា-ថៃ ។ ដោយអនុវត្តតាមបទបញ្ជាដ៏មុឺងម៉ាត់របស់លោក សុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ នៅយប់ថ្ងៃច័ន្ទ ៥ កើត ខែមាឃ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩:០០ នាទីយប់ លោក យស យុទ្ធី អភិបាលរងខណ្ឌដូនពេញ បានដឹកនាំកម្លាំងប្រជាការពារខណ្ឌ បើកប្រតិបត្តិការចុះប្រមូលស្ត្រី រកស៊ីផ្លូវភេទ រួមទាំងអ្នកគកដេរ(អ្នកចាប់ម៉ូយ) នៅ ជុំវិញរមណីយដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ និង សួនច្បារមិត្តភាពកម្ពុជា-ថៃ។ ជាលទ្ធផល នៃការបង្ក្រាបនេះ កម្លាំងប្រជាការពារខណ្ឌ បានធ្វើការប្រមូលស្ត្រីរកស៊ីផ្លូវភេទរួមទាំងអ្នកគួកដេរ(អ្នកចាប់ម៉ូយ)សរុបចំនួន១៣នាក់ (ស្រី១១នាក់) បញ្ជូនមកសាលាខណ្ឌដូនពេញ ដើម្បីរៀបចំឯកសារ បញ្ជូនបន្តទៅ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ៕

## ថ្ងៃទី២២ ខែ មករា ឆ្នាំ២០២១

## សម្តេចតេជោ ហ៊ុន សែន ផ្តល់ជំនួយថវិកាបន្ថែមដល់ខេត្តប៉ៃលិន ១០០លានរៀល និង កោះកុង ៣០លានរៀល ដើម្បីរៀបចំធ្វើចត្តាឡីស័កដល់ពលករ

http://www.freshnewsasia.com/ 2021-01-21 04:26pm

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១នេះ បានផ្តល់ជំនួយថវិកាបន្ថែមដល់ខេត្តប៉ៃលិន ចំនួន១០០លានរៀល និងខេត្តកោះកុង៣០លានរៀលទៀត ដើម្បីរៀបចំសម្រួលដល់ការធ្វើចត្តាឡីស័ករបស់ពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃ។ នេះបើតាម លោកស្រី យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាល បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News នៅរសៀលនេះ។ លោកស្រី យក់ សម្បត្តិ បានបញ្ជាក់បន្ថែមថា ថវិកាទាំងនេះ ត្រូវបានរៀបចំចាត់ចែងប្រគល់ជូនអភិបាល នៃគណៈអភិបាលខេត្តទាំងពីរផងដែរ។ ការផ្តល់ជំនួយដល់បណ្តាខេត្តកម្ពុជា ដែលនៅជាប់ព្រំដែនថៃ បានធ្វើឡើងជាបន្តបន្ទាប់ ដើម្បីរៀបចំការធ្វើចត្តាឡីស័កសម្រាប់ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ក្រោយពេលប្រទេសថៃ បានផ្ទុះឡើងនូវការឆ្លងជំងឺកូវីដ១៩ ក្នុងសហគមន៍យ៉ាងខ្លាំងក្លា ដែលផ្តើមចេញពីខេត្តសាមុតសាខន ប្រទេសថៃ។

កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ កន្លងទៅ សម្តេចតេជោ ហ៊ុន សែន ទើបតែផ្តល់ថវិកា ៨០០លានរៀលទៀត សម្រាប់ខេត្តឧត្តរមានជ័យ និង២០០លានរៀលថែមទៀត សម្រាប់ខេត្តបាត់ដំបង ដើម្បីរៀបចំទីតាំងសម្រាប់ធ្វើចត្តាឡីស័កជូនពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃនេះផងដែរ។

បើតាមក្រសួងសុខាភិបាល, រហូតដល់ពេលនេះ មានពលករខ្មែរមិនតិចជាង១,២ម៉ឺននាក់ បានត្រឡប់ពីប្រទេសថៃ ហើយត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក នៅខេត្តជាប់ព្រំដែន ក្នុងប្រទេសកម្ពុជា៕

# ពលករខ្មែរមកពីថៃឆ្លងកូវីដកើនឡើងដល់៨១នាក់ ក្នុងនោះមានស្ត្រីដល់ទៅ៦២នាក់

https://kohsantepheapdaily.com.kh/ ២១ ខែ មករា ឆ្នាំ ២០២១ ម៉ោង ១០:៣៦

រាជធានីភ្នំពេញ ៖ គិតត្រឹមព្រឹកថ្ងៃទី ២១ ខែមករានេះ កម្ពុជាបានរកឃើញមានអ្នកឆ្លងកូវីដ១៩ថ្មី ចំនួន ៥ នាក់ទៀត ដែលក្នុងនោះ ៤នាក់ ជាពលករខ្មែរ មកពីប្រទេសថៃ ដែលនាំឲ្យចំនួនពលករខ្មែរធ្វើដំណើរវិលត្រឡប់មកកម្ពុជាវិញកើតជំងឺកូវីដ១៩ កើនឡើងដល់ ៨១នាក់ ក្នុងនោះស្ត្រីគឺមានចំនួនដល់ទៅ ៦២ នាក់ ។ នេះបើយោងតាមសេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលចុះថ្ងៃទី២១ ខែមករា ។

ប្រភពដដែលបានឲ្យដឹងថា ករណីវិជ្ជមានវីរុសកូវីដ១៩ថ្មី ចំនួន ៥នាក់ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ ២០២១ គឺមានមនុស្ស ៤នាក់ ជាពលករធ្វើដំណើរមកពីប្រទេសថៃ ដែលក្នុងនោះ៣នាក់គឺមកដល់ខ្មែរតាំងពីថ្ងៃទី ៦ ខែមករា ឆ្នាំ២០២១ និងម្នាក់ទៀត មកដល់កម្ពុជា កាលពីថ្ងៃទី១៩ ខែមករា ខណៈអ្នករកឃើញវិជ្ជមានអ្នកទី ៥ មិនមែនជាពលករមកពីថៃ គឺជា ជាស្ត្រីជនជាតិខ្មែរ ធ្វើដំណើរមកពីអាមេរិក មកដល់កម្ពុជា កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២១។ យ៉ាងណាមិញ ក្រសួងសុខាភិបាល ក៏បានប្រកាសពីករណីជាសះស្បើយកូវីដ១៩ ចំនួន ៤នាក់ ដែលជាពលករខ្មែរធ្វើដំណើរមកពីប្រទេសថៃ ។

សូមបញ្ជាក់ថា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា កាលដើមខែមករា ឆ្នាំ២០២១ នេះ បានបញ្ជាឲ្យកម្លាំងទាំងអស់ចាត់វិធានការតឹងរឹងនៅតាមព្រំដែន ដើម្បីធានាឲ្យបានថា ពលករខ្មែរទាំងអស់ដែលវិលត្រឡប់ពីថៃចូលកម្ពុជា នឹងត្រូវបានយកសំណាកទៅធ្វើតេស្តរកជំងឺកូវីដ១៩ ហើយក៏មានការបញ្ជូនកម្លាំងទៅព្រំដែនសហការជាមួយនឹងមន្ត្រីសុខាភិបាល ក៏ដូចជាការបង្កើតមណ្ឌលចត្តាឡីស័កនៅតាមខេត្តតាមបណ្តោយព្រំដែនថៃផងដែរ ៕

# តំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ បន្តសហការជាមួយ កម្លាំងចម្រុះ មន្ត្រីជំនាញ អាជ្ញាធរមូលដ្ឋាន និងការពារទីតាំងបរិវេណមណ្ឌលចត្តាឡីស័កពលករខ្មែរ

http://nokorwatnews.com/archives/ 21-01-2021

ខេត្តឧត្តរមានជ័យ៖ លោកឧត្តមសេនីយ៍ទោ តន់ ញាន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ម្សិលមិញ បានចាត់តាំងកម្លាំងកងទ័ពប្រមាណជាង៥០នាក់ បន្តចុះសហការជាមួយផ្នែកទំនាក់ទំនងព្រំដែនកម្ពុជាប្រចាំច្រកអូរស្មាច់ និងកងពលតូចជីកជញ្ជូនលេខ៩៩ ព្រមទាំងកម្លាំងចម្រុះ និងអាជ្ញាធរមូលដ្ឋាន ក្នុងការចុះការពារ និងរៀបចំសម្អាតទីតាំងថ្មី សម្រាប់ធ្វើចត្តាឡីស័ក ដល់បងប្អូនប្រជាពលករត្រឡប់មកពីប្រទេសថៃ។ ជាមួយគ្នានេះដែរ កម្លាំងមួយផ្នែករបស់តំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ បានសហការជាមួយនឹងកងពលតូចជីកជញ្ជូនលេខ៩៩ ធ្វើការដឹកជញ្ជូនប្រជាពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ មកកាន់ទីតាំងធ្វើចត្តាឡីស័ក ក្នុងខេត្តឧត្តរមានជ័យ និងមួយផ្នែក សហការជាមួយផ្នែកទំនាក់ទំនងព្រំដែនកម្ពុជា ប្រចាំការការពារនៅច្រកថ្មដូន និងច្រកជប់គគីរ ការពារក្រែងមានករណីបងប្អូនពលករលួចឆ្លងដែនដោយខុសច្បាប់ ឬមិនព្រមចូលរួមធ្វើចត្តាឡីស័ក។ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ ក៏បានដាក់បទបញ្ជាឲ្យកម្លាំងទ័ព២៧នាក់ ប្រចាំការ ការពារនៅជុំវិញទីតាំងមណ្ឌល ដើម្បីបង្កើនសុវត្ថិភាព និងរបៀបរៀបរយ ចំពោះមណ្ឌលចត្តាឡីស័កពលករខ្មែរ។

គួរបញ្ជាក់ថា ចាប់តាំងពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ មានបងប្អូនប្រជាពលរដ្ឋសរុបចំនួន៤,៧០៨នាក់ ក្នុងនោះស្រីចំនួន២,០៩៥នាក់ ដែលបានឆ្លងដែនពីប្រទេសថៃមកដល់ទឹកដីកម្ពុជា តាមច្រកអន្តរជាតិអូរស្មាច់ ហើយកងកម្លាំងទាំង៣ប្រភេទ និងក្រុមការងារពាក់ព័ន្ធទាំងអស់ បានសម្រប

សម្រួល ដោយដឹកជញ្ជូនពួកគាត់មកកាន់ទីតាំងធ្វើចត្តាឡីស័កទាំង៧ ដែលបានកំណត់ទុក។ ដោយឡែក មានបងប្អូនពលករចំនួន៤៦៨នាក់ ស្រីចំនួន២០៥នាក់ បានធ្វើចត្តាឡីស័កចប់ នៅមណ្ឌលចត្តាឡីស័កខេត្តឧត្តរមានជ័យ និងបានឲ្យត្រឡប់ទៅមូលដ្ឋានវិញ៕

## មនុស្សប្រុសស្រី២នាក់ សង្ស័យជាមេខ្យល់នាំចេញពលករប្រុសស្រី៣៦នាក់ទៅប្រទេសថៃ ដោយខុសច្បាប់ត្រូវសមត្ថកិច្ចឃាត់ខ្លួន

http://cambodiapolice.com/policekh/ 8:03 pm 20 មករា 2021 80

បាត់ដំបង៖ មនុស្សប្រុសស្រី២នាក់ ដែលជាប់ពាក់ព័ន្ធករណីនាំចេញពលករទៅប្រទេសថៃខុសច្បាប់៣៦នាក់ ហើយក្នុងនោះក៏មានក្មេងស្រីម្នាក់ផងដែរ ត្រូវបានកម្លាំងសមត្ថកិច្ចនគរបាលចាប់ខ្លួនកាលពីវេលាម៉ោង២និង២០នាទីរំលងអាធ្រាត្រយប់ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២១។ សមត្ថកិច្ចបានឲ្យដឹងថា ជនសង្ស័យមានឈ្មោះ ប៉ាត ម៉ៅ ភេទប្រុស អាយុ៤៥ឆ្នាំ រស់នៅភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

លោកវរសេនីយ៍ឯក គឹម ពន្លក អធិការនគរបាលស្រុកកំរៀងបានរាយការណ៍អោយដឹងថា ក្រោយពីទទួលបានជនសង្ស័យពីនគរបាលការពារព្រំដែនគោកលេខ៨១៩ រួចមកនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ វេលាម៉ោង១៦និង០០នាទី សមត្ថកិច្ចបានធ្វើការសាកសួរលើឈ្មោះ ប៉ាត ម៉ៅ ភេទប្រុស អាយុ៤៥ឆ្នាំ បានឆ្លើយសារភាព ថាកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១វេលាម៉ោង២២ និង០០នាទី ដោយមានឈ្មោះ ប៉ែន សាម៉ន ហៅម៉ៅ ភេទស្រី អាយុ៤១ឆ្នាំ រស់នៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀងបានខលមកខ្លួន ដោយប្រាប់ថាចាំជួយជូនពលករខ្មែរចេញទៅប្រទេសថៃផង តែមិនបានប្រាប់ចំនួននោះទេដោយអោយថ្លៃឈ្នួលក្នុងម្នាក់ ១០.០០០រៀល (មួយម៉ឺនរៀល) និយាយរួចខ្លួនដើរទៅចាំនៅចំណុចច្រក ស៊ុន សេន ស្ពានបីភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង រហូតដល់ម៉ោង២២និង៣០នាទី ក៏ឃើញរថយន្តពីរគ្រឿងមិនចាំម៉ាកបើកទៅដល់ហើយដាក់ពលករចុះមានប្រុសមានស្រី តែខ្លួនមិនបានរាប់ចំនួនទេ រួចក៏នាំពលករដើរចូលទៅទឹកដីថៃ រហូតដល់ម៉ោង០២និង២០នាទីរំលងអធ្រាត នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ទាហ៊ានថៃចាប់ឃាត់ខ្លួននិងពលករយកមកប្រគល់ជូនសមត្ថកិច្ចកម្ពុជា។

ពេលសាកសួរឈ្មោះប៉ាត ម៉ៅ ភេទប្រុស អាយុ៤៥ឆ្នាំ បានឆ្លើយសារភាពថាខ្លួនពិតជាបានស៊ីឈ្នួលពីឈ្មោះ ប៉ែន សាម៉ន ហៅ ម៉ៅ ភេទស្រី អាយុ៤១ឆ្នាំ នាំពលករខ្មែរលួចឆ្លងដែនចេញទៅប្រទេសថៃដោយខុសច្បាប់ពិតប្រាកដមែន។ ឆ្លងតាមការស្តាប់ចម្លើយឈ្មោះ ប៉ែន សាម៉ន ហៅ ម៉ៅ ភេទស្រី អាយុ៤១ឆ្នាំ រស់នៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង បានឆ្លើយថាខ្លួនមិនដែលបានស្គាល់ឈ្មោះ ប៉ាត ម៉ៅ ភេទប្រុស ឬក៏ជួលអោយនាំពលករខ្មែរចេញទៅប្រទេសថៃនោះទេ ចំណែកឯលេខទូរស័ព្ទដែលខលទៅគឺជាលេខរបស់ខ្លួន បានដាក់បំរើទូរស័ព្ទសាធារណៈពិតប្រាកដមែន។

ករណីនេះ កម្លាំងនគរបាលស្រុកកំរៀងបានឃាត់ខ្លួនជនសង្ស័យទាំងពីរនាក់ តាមបញ្ជារបស់ឯកឧត្តម គឹ ប៊ុណ្ណារ៉ា ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ដើម្បីកសាងសំណុំរឿងបញ្ជូនទៅការិយាល័យចាត់ការតាមនីតិវិធីបន្ត។ ចំណែកឯពលករទាំង៣៦នាក់នោះត្រូវនគរបាលការពារព្រំគោកលេខ៨១៩ ធ្វើការអប់រំអោយត្រលប់ទៅលំនៅដ្ឋានវិញរៀងៗខ្លួន៕

## ជនប្រុស-ស្រី ២ នាក់ ត្រូវបានបញ្ជូនទៅតុលាការពាក់ព័ន្ធនាំពលករទៅប្រទេសថៃ

https://www.postkhmer.com/ គីម សារុំ | Publication date 21 January 2021 | 17:30 ICT

ជនប្រុស-ស្រី ២ នាក់ ត្រូវបានចាប់បញ្ជូនទៅសាលាដំបូងខេត្តបាត់ដំបង នៅថ្ងៃរសៀលនេះ ក្រោយពីឃាត់ខ្លួនកាលពីថ្ងៃទី ១៩ ខែមករា នៅឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ពាក់ព័ន្ធនឹងការនាំពលករ ប្រមាណជាង ៣០ នាក់ទៅធ្វើការនៅប្រទេសថៃ។

លោក ប៊ិន វ៉ាន់ដារ៉ា នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបាត់ដំបងឲ្យដឹងនាថ្ងៃនេះថា ជនសង្ស័យមានឈ្មោះ ប៉ាត ម៉ៅ ភេទប្រុស អាយុ ៤៥ ឆ្នាំ និងឈ្មោះ ប៉ែន សាម៉ន ភេទស្រី អាយុ ៤១ ឆ្នាំ ត្រូវបានសមត្ថកិច្ចលោកបញ្ជូនបន្តទៅសាលាដំបូងខេត្តបាត់ដំបង នៅរសៀលនេះហើយ។ ពួកគេជាប់ពាក់ព័ន្ធនាំពលករខ្មែរប្រុសស្រីទៅប្រទេសថៃ។ លោកបន្តថា ករណីនេះជនសង្ស័យឈ្មោះ ប៉ាត ម៉ៅ បានឆ្លើយសារភាព ប៉ុន្តែស្ត្រីឈ្មោះ ប៉ែន សាម៉ន ឆ្លើយថា គាត់មិនបាននាំពលករទៅប្រទេសថៃទេ ប៉ុន្តែលេខទូរស័ព្ទរបស់គាត់ គឺពិតជាបានទាក់ទងទៅពលករទាំងនោះប្រាកដមែន។ តែទោះយ៉ាងណាលោកទុកសមត្ថកិច្ចនេះជូនតុលាការសាកសួរពួកគេបន្តទៀត។ លោក ដារ៉ា ថ្លែងថា៖ «នៅនគរបាលមូលដ្ឋានឆ្លើយម្នាក់អត់ម្នាក់។ លុះមកដល់ការិយាល័យខ្ញុំ ក៏អ៊ីចឹងទៀត តែខ្ញុំបញ្ជូនពួកគេទៅតុលាការឲ្យសាកសួរបន្តទៀត»។

បើតាមលោក គីម ពន្លក អធិការនគរបាលស្រុកកំរៀងប្រាប់នៅថ្ងៃនេះថា ជនសង្ស័យទាំង២នាក់ ត្រូវបានសមត្ថកិច្ចលោកទទួលបន្តពីនគរបាលការពារព្រំដែនគោកលេខ ៨១៩ ឈរជើងនៅស្រុកកំរៀង។ ក្រោយមកនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២១ សមត្ថកិច្ចបានសាកសួរឈ្មោះ ប៉ាត ម៉ៅ ហើយបុរសនេះបានឆ្លើយសារភាពថា កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ វេលាម៉ោង ២២ និង ០០ នាទី ដោយមានឈ្មោះ ប៉ែន សាម៉ន ហៅ ម៉ៅ ភេទស្រី រស់នៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀងបានទូរស័ព្ទប្រាប់គាត់ឲ្យចាំជួយជូនពលករខ្មែរចេញទៅប្រទេសថៃ ប៉ុន្តែមិនបានប្រាប់ចំនួននោះទេ។រីឯថ្លៃឈ្នួលគឺឈ្មោះ ប៉ែន សាម៉ន ប្រាប់ថាពលករម្នាក់គេឲ្យ១ម៉ឺនរៀលថ្លៃនាំឆ្លងដែន។ លោកអធិការបន្តតាមសម្ដីជនសង្ស័យឈ្មោះ ប៉ាត ម៉ៅ ថា បន្ទាប់ពីបាននិយាយស្រុះស្រួលគ្នាមកគាត់បានដើរទៅចាំនៅចំណុចច្រក ស៊ុន សេន ស្ពានបីស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង រហូតដល់ម៉ោង ១២ កន្លះរំលងអាធ្រាត្រឈានចូលថ្ងៃទី ១៩ ខែមករា ក៏ឃើញរថយន្ត ២ គ្រឿង ដឹកមនុស្សពេញរថយន្ត ហើយដាក់ពលករប្រុសស្រីចុះពីរថយន្ត។ បន្ទាប់មកគាត់បាននាំពលករដើរចូលទៅទឹកដីថៃ ហើយក៏ត្រូវទាហ៊ានថៃចាប់ខ្លួន និងពលករយកមកប្រគល់ជូនសមត្ថកិច្ចកម្ពុជាតែម្ដង។

បើតាមលោកអធិការ ចំពោះចម្លើយរបស់ស្ត្រីឈ្មោះ ប៉ែន សាម៉ន ហៅ ម៉ៅ បានឆ្លើយថាខ្លួនមិនដែលបានស្គាល់ឈ្មោះ ប៉ាត ម៉ៅ ទេ ចំណែកឯលេខទូរស័ព្ទដែលគេទៅ គឺជាលេខរបស់ខ្លួនពិតប្រាកដមែន។ ចំណែកឯពលករប្រុសស្រី ចំនួន ៣៦ នាក់ ត្រូវបាននគរបាលការពារព្រំដែនគោកលេខ ៨១៩ ធ្វើការអប់រំឲ្យត្រឡប់ទៅលំនៅឋានវិញរៀងៗខ្លួន៕

## សង្គមស៊ីវិលខ្មែរ៖ វិធានការឃ្លាំមើលពលករពីអាជ្ញាធរថៃ ជាវិធានការល្អ តែគួរមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 20/01/2021 - 08:11 ដោយ៖ ជួប នរក្សា

ក្រសួងសុខាភិបាលថៃនៅថ្ងៃពុធ ទី២០ មករានេះ បានចេញមកកំណត់ចង្អុលអំពីខេត្តដែលកំពុងរងការយាយីខ្លាំងពីការចម្លងនៃជំងឺកូវីដ១៩ រួមមានទាំងខេត្តសាមុតសាខនផងដែរ។ បើតាមអាជ្ញាធរថៃ ខេត្តសាមុតសាខន នឹងត្រូវដាក់ការឃ្លាំមើលយ៉ាងតឹងរ៉ឹងបន្ថែមទៀតទៅលើពលករ ដែលកំពុងធ្វើការនៅទីនោះ ដើម្បី

គ្រប់គ្រងស្ថានការណ៍កូវី១៩ ឲ្យបានប្រសើរ។ ក៏ប៉ុន្តែ មន្ត្រីផ្នែកពលករនៅអង្គការសង់ត្រាល់កម្ពុជា ថា អាជ្ញាធរគួរមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយ បន្ថែមលើវិធានការនេះ។

លោក ឌី ថេហូយ៉ា មន្ត្រីទទួលបន្ទុកផ្នែកពលករទេសន្តប្រវេសន៍នៃអង្គការសង់ត្រាល់ បានប្រាប់វិទ្យុបារាំងអន្តរជាតិ RFI នៅថ្ងៃនេះថា វិធានការតាមដានឃ្លាំមើលរបស់មន្ត្រីសុខាភិបាលថៃ ទៅលើពលករដែលកំពុងធ្វើការនៅក្នុងខេត្តសាមុតសាខននៅពេលនេះ ជាវិធានការមួយល្អ ព្រោះថា នៅក្នុងខេត្តសាមុតសាខនមានពលករខ្មែរកំពុងធ្វើការប្រមាណជាង២០ម៉ឺននាក់ក្នុងចំណោមពលករខ្មែរសរុបជាង២លាននាក់ ដែលកំពុងធ្វើការនិងស្នាក់នៅប្រទេសថៃបច្ចុប្បន្ន។ វិធានការនេះនឹងអាចទប់ស្កាត់ការឆ្លងជំងឺកូវីដ១៩បានរហ័ស នៅស្ថានភាពនៃការរាលដាលជំងឺកូវីដ១៩ចូលសហគមន៍នៅប្រទេសថៃនេះ។ នេះបើតាមលោក ឌី ថេហូយ៉ា។

លោក Taweesilp Visanuyothin អ្នកនាំពាក្យនៃមជ្ឈមណ្ឌលស្ថានភាពកូវី១៩ថៃ បានលើកឡើងថា ស្ថានភាពកូវីដ១៩ នៅតែគួរឱ្យព្រួយបារម្ភនៅក្នុងប្រទេសថៃ។ បើតាមអ្នកនាំពាក្យ អាជ្ញាធរថៃនឹងដាក់វិធានការចាត់តាំងមន្ត្រីសុខាភិបាលចុះឃ្លាំមើលនិងតាមដានសុខភាពពលករជាប្រចាំនៅខេត្តសាមុតសាខន។ វិធានការនេះ គឺមន្ត្រីសុខាភិបាលថៃនឹងចុះត្រួតពិនិត្យ និងតាមដានរោងចក្រដែលពលករខ្មែរ និងពលករផ្សេងទៀតធ្វើការចំនួន៦០០រោងចក្រ ជាប្រចាំថ្ងៃ ក្នុងចំណោមរោងចក្រសរុបចំនួន ១២០០០រោងចក្រនៅក្នុងខេត្តសាមុតសាខន។ ក៏ប៉ុន្តែបើតាមមន្ត្រីផ្នែកពលកររូបនេះ ថា អាជ្ញាធរថៃគួរណាបន្ថែមការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដើម្បីឲ្យពលករទាំងអស់អាចចូលរួមបានដោយមិនមានការភិតភ័យ និងជាពិសេសអាជ្ញាធរថៃត្រូវធានាបាននូវសុពលភាពស្របច្បាប់ដល់បណ្តាពលករខ្មែរ ដែលកំពុងធ្វើការនៅទីនោះ ដើម្បីធ្វើយ៉ាងណា កុំឲ្យពួកគេមានការកង្វល់ ក៏ដូចជាការប្រឈមមុខនឹងបញ្ហាច្បាប់ណាមួយ។

សូមរំលឹកជូនថា គុល្យការចុងក្រោយ ករណីវិជ្ជមានកូវី១៩ នៅថៃបានកើតមានសរុបចំនួន ១២៥៩៤ និងករណីវិជ្ជមានកូវីដ១៩ក្រោយព្រឹត្តិការណ៍សហគមន៍នៅផ្សារបង្ការ ខេត្តសាមុតសាខន មានចំនួន ៨៣៧៥។ នេះបើតាមការបញ្ជាក់របស់អ្នកនាំពាក្យមជ្ឈមណ្ឌលស្ថានភាពកូវីដ១៩ថៃ កាលពីអង្គារទី១៩ម្សិលមិញ។ ទន្ទឹមនឹងការផ្ទុះនៅប្រទេសថៃនេះដែរ ក្រសួងសុខាភិបាលកម្ពុជា ក៏បានរកឃើញអ្នកវិជ្ជមានកូវីដ១៩ជាពលករ ចំនួន ៧៧នាក់ ក្នុងចំណោមពលករប្រមាណជាង៧០០០នាក់ក្រោយត្រលប់មកពីប្រទេសថៃវិញ៕

## ការផ្ទុះឡើងជំងឺកូវីដ-១៩មិនមែនជាមូលហេតុតែមួយដែលធ្វើឲ្យពលករចំណាកស្រុកកម្ពុជាសម្រុកត្រលប់មកពីថៃ

https://www.khmertimeskh.com/ 21-01-2021

ពលករចំណាកស្រុកកម្ពុជាដែលរស់ប្រទេសថៃត្រូវបានរដ្ឋាភិបាលថៃ និងកម្ពុជាណែនាំឲ្យនៅមួយកន្លែងរងចាំការប្រកាសព័ត៌មានបន្ថែម តែប្រជាជនមួយចំនួនហាក់ដូចមិនស្តាប់ការអំពាវនាវនោះទេ។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) បាននិយាយថា ការលំបាកផ្នែកហិរញ្ញវត្ថុ និងការភ័យខ្លាច នៃការដាក់ទណ្ឌកម្មចំពោះការកាន់ឯកសារមិនមានសុពលភាព ឬផុតកំណត់គឺជាមូលហេតុចំបង ដែលធ្វើឲ្យពលករចំណាកស្រុកកម្ពុជានៅតែបន្តវិលត្រឡប់មកផ្ទះវិញជារៀងរាល់ថ្ងៃ។ លោកបន្តថា៖ «ពួកគេភាគច្រើនមិនមែនត្រលប់មកវិញដោយសារជំងឺកូវីដ-១៩ នោះទេប៉ុន្តែដោយសារពួកគេគ្មានការងារធ្វើ គ្មានថវិកា ដើម្បីផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃ ហើយឯកសារស្របច្បាប់របស់ពួកគេនឹងមិនមានសុពលភាពក្នុងពេលឆាប់ៗនេះ»។

ប្រទេសថៃធ្លាប់បានប្រកាសថាពលករចំណាកស្រុក ទោះបីជាពលករខុសច្បាប់ក៏អាចស្នាក់នៅ និងធ្វើការនៅប្រទេសថៃបានរយៈពេល ២ ឆ្នាំដែរ ទោះបីមានលក្ខខណ្ឌច្រើនក៏ដោយ។ ពលករដែលគ្មានឯកសារចាំបាច់ត្រូវស្វែងរកនិយោជិក ហើយនិយោជកត្រូវទិញគម្រោងធានារ៉ាប់រងសុខភាពរយៈពេលពីរឆ្នាំសម្រាប់និយោជិករបស់ពួកគេក្នុងចំណោមលក្ខខណ្ឌផ្សេងទៀត។

លោកថា និយោជកខ្លះសុខចិត្តជ្រើសរើសការបញ្ចប់កិច្ចសន្យាពលកររបស់ពួកគេជាជាងគោរពតាមបទប្បញ្ញត្តិ។ លោកក៏បានបន្តថាដំណើរការចុះឈ្មោះ និងការបន្តឯកសាររបស់ពួកគេមានលក្ខណៈស្មុគស្មាញ ជាពិសេសសម្រាប់ប្រជាជនកម្ពុជាដែលកាន់លិខិតឆ្លងដែនដែលត្រូវផុតកំណត់។ លោកបន្ថែមថា៖ «ស្ថានភាពទូទៅនៃពលករចំណាកស្រុកកម្ពុជាគឺពួកគេមានការលំបាកជាមួយនឹងសុពលភាពនៃឯកសារស្របច្បាប់។ ខ្ញុំគិតថាលិខិតឆ្លងដែនប្រជាជនកម្ពុជារាប់សែននាក់នឹងផុតសុពលភាពក្នុងពេលឆាប់ៗនេះនៅថ្ងៃទី ៣១ ខែមីនាហើយពួកគេទាំងអស់ខ្លាចវិធានការរបស់រដ្ឋាភិបាលថៃ»។ លោកបន្តថាវាអាចចំណាយពេលដល់ទៅ ៥ ខែដើម្បីបន្តលិខិតឆ្លងដែន។ លោកក៏បានបញ្ជាក់ផងដែរថាលោកបានឮពីមនុស្សដែលបានដឹងអំពីស្ថានភាពថាពលករបានទទួលបានការមើលការខុសត្រូវប្រសើរជាងមុនចាប់តាំងពីត្រឡប់មកកម្ពុជា។ យោងតាមលោក ថេហ្វយ៉ា ខណៈពេលដែលមនុស្សជាច្រើនស្ថិតក្នុងការធ្វើចត្តាឡីស័កនៅក្នុងសាលារៀន ពួកគេត្រូវបានផ្តល់ឲ្យនូវសេវាកម្មជាមូលដ្ឋាន និងអាហារបីពេលក្នុងមួយថ្ងៃ ដែលរដ្ឋាភិបាលត្រូវចំណាយចំនួន ៥ ដុល្លារក្នុងមួយថ្ងៃ។

ពលករចំណាកស្រុកកម្ពុជាម្នាក់ដែលកំពុងធ្វើចត្តាឡីស័កនៅជិតព្រំដែន បាននិយាយថា នាងបានត្រឡប់មកពីប្រទេសថៃបន្ទាប់ពីធ្វើការជាកសិកររយៈពេលមួយឆ្នាំនៅខេត្តកូរ៉ាត។ ខណៈពេលដែលជំងឺកូវីដ-១៩ ជាបញ្ហាតិចតួចក្នុងការវិលត្រលប់នេះ ដែលមូលហេតុចំបងនោះគឺនាងត្រូវចូលរួមពិធីមង្គលការរបស់គ្រួសារ។ កញ្ញាបន្តថា៖ «នៅមណ្ឌលចត្តាឡីស័ក ខ្ញុំទទួលបានអាហារគ្រប់គ្រាន់ និងមានទីកន្លែងល្អសម្រាប់ស្នាក់នៅ»។ សៀវ គួយអ៊ី

## មានពលករខ្មែរ៦នាក់ រងគ្រោះក្នុងហេតុការណ៍ឆេះរោងចក្រផលិតប៉ារ៉ែតជ័រ នៅប្រទេសកូរ៉េខាងត្បូង

http://www.freshnewsasia.com/ 2021-01-20 04:26pm

**(កូរ៉េខាងត្បូង)៖** យ៉ាងហោចណាស់មានពលករខ្មែរ៦នាក់ បានរងគ្រោះឆេះកន្លែងស្នាក់នៅ សម្ភារប្រើប្រាស់ និងខោអាវគ្មានសល់ ក្នុងហេតុការណ៍គ្រោះអគ្គីភ័យឆាបឆេះក្នុងរោងចក្រ ផលិតប៉ារ៉ែតជ័រ នៅខេត្តឈុនប៊ុក ប្រទេសកូរ៉េខាងត្បូង នារសៀលថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១។ នេះបើយោងតាមលោក ឡុង ឌីម៉ង់ អគ្គរាជទូតកម្ពុជាប្រចាំនៅកូរ៉េខាងត្បូង ថ្លែងប្រាប់ភ្នាក់ងារសារព័ត៌មាន Fresh News នៅរសៀលថ្ងៃទី២០ ខែមករា ឆ្នាំ ២០២១នេះ។

លោក ឡុង ឌីម៉ង់ បានឱ្យដឹងទៀតថា រោងចក្រដែលបានឆេះនេះមានពលករប្រមាណ ៨០នាក់ ដោយក្នុងនោះមានពលករខ្មែរចំនួន៦នាក់។ ទ្រព្យសម្បត្តិដែលបាត់បង់របស់ពលករខ្មែរ គឺសម្ភារប្រើប្រាស់ និងខោអាវរបស់ពួកគាត់ ដោយឡែកសម្រាប់ ID card លិខិតឆ្លងដែន ឯកសារផ្សេងៗ មិនមានការបាត់បង់ទេ។ សម្រាប់ស្ថានភាពពលករខ្មែរ ទាំង៦នាក់បច្ចុប្បន្ននេះ គឺថៅកែមានកន្លែងស្នាក់នៅបណ្តោះអាសន្ន និងរៀបចំម្ហូបអាហារជូនពលករដោយយកចិត្តទុកដាក់។ លោកអគ្គរាជទូត បានបញ្ជាក់បន្ថែមថា បើតាមពលករខ្មែរដែលរងគ្រោះឈ្មោះ សោភ័ណ្ឌ បានបញ្ជាក់ដែរថា នៅថ្ងៃស្អែកនេះ ថៅកែពួកគេនឹងនាំទៅដាក់ ពាក្យស្វែងរកការងារថ្មីផងដែរ។ លោក ឡុង ឌីម៉ង់ បានបញ្ជាក់ទៀតថា ក្រុមអនុព័ន្ធការងារនឹងនៅរក្សាទំនាក់ទំនងជាមួយពួកគាត់ និងជួយសម្របសម្រួលរាល់បញ្ហា

ផ្សេងៗ បើសិនជាមាន ការស្នើសុំអ្វីមួយពីពលករខាងលើ។ ជាពិសេសក្រុមការងារ នឹងចុះទៅសួរសុខទុក្ខ ហើយយកសម្ភារៈនិងថវិកាមួយចំនួនជូនពួកគាត់ផងដងដែរ៕

## សម្តេចតេជោ ហ៊ុន សែន ផ្តល់ជំនួយថវិកាបន្ថែម ៥០០លានរៀលទៀតដល់ខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ ដើម្បីរៀបចំធ្វើចត្តាឡីស័កសម្រាប់ពលករ

http://www.freshnewsasia.com/ 2021-01-22 09:22am

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១នេះ បានសម្រេចផ្តល់ថវិកាបន្ថែមចំនួន ៥០០លានរៀលថែមទៀត ដល់ខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ ដើម្បីរៀបចំទប់ស្កាត់ជំងឺកូវីដ១៩ និងធ្វើចត្តាឡីស័ក សម្រាប់ពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃ។ នេះបើតាម លោកស្រី យក់ សម្បត្តិ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។

លោកស្រី យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាល បានបញ្ជាក់ឲ្យដឹងថា ក្នុងចំណោមជំនួយថវិកា ៥០០លានរៀលរបស់សម្តេចតេជោថ្មីនេះ គឺខេត្តបន្ទាយមានជ័យទទួលបាន ៣០០លានរៀល និងខេត្តឧត្តរមានជ័យ ទទួលបាន២០០លានរៀល បូករួមទឹកសុទ្ធ៣០០០កេសថែមទៀត។ លោកស្រីបានបញ្ជាក់ទៀតថា ថវិកាទាំងនេះរួមទាំងសម្ភារៈ ត្រូវបានក្រសួងសុខាភិបាល រៀបចំចាត់ចែងប្រគល់ដល់ជូន អភិបាលនៃគណៈអភិបាលខេត្តទាំងពីរផងដែរ។ ចាប់តាំងពីប្រទេសថៃ មានការផ្ទុះជំងឺកូវីដ១៩ នៅក្នុងសហគមន៍យ៉ាងខ្លាំងក្លា ក្នុងខេត្តសមុទ្រសាខន ដែលជាប់ព្រំដែនជាមួយគ្នា កម្ពុជាបានរកឃើញមានពលករជាបន្តបន្ទាប់មានផ្ទុកជំងឺកូវីដ១៩ ក្រោយពេលត្រឡប់មកពីប្រទេសថៃ។

ឆ្លើយតបនឹងស្ថានភាពនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានផ្តល់ជំនួយថវិកាជាបន្តបន្ទាប់ដល់ខេត្តជាប់ព្រំដែនថៃទាំង ៧ ដើម្បីរៀបចំធ្វើចត្តាឡីស័កដល់ពលករដែលត្រឡប់មកពីប្រទេសថៃ។

បើតាមក្រសួងសុខាភិបាល, រហូតដល់ពេលនេះ មានពលករខ្មែរមិនតិចជាង១,២ម៉ឺននាក់ បានត្រឡប់ពីប្រទេសថៃ ហើយត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក នៅខេត្តជាប់ព្រំដែន ក្នុងប្រទេសកម្ពុជា៕

# ថ្ងៃទី២៥ ខែ មករា ឆ្នាំ២០២១

## ក្រសួងមហាផ្ទៃ-ប្រតិភូទូតរដ្ឋអាមេរិក បើកកិច្ចប្រជុំត្រួតពិនិត្យនិងពិភាក្សា ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://www.cen.com.kh/ January 22, 2021

ភ្នំពេញៈ ក្រសួងមហាផ្ទៃ និងប្រតិភូទូតសហរដ្ឋអាមេរិក បានបើកកិច្ចប្រជុំត្រួតពិនិត្យនិងពិភាក្សាស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅរសៀលថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ នេះ នៅទីស្តីការក្រសួងមហាផ្ទៃនេះនៅទីស្តីការក្រសួងមហាផ្ទៃ។ ភាគីកម្ពុជាដឹកនាំដោយលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងភាគីអាមេរិកដោយលើកប៉ាទ្រីក មូហ្វី អគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា។

លោកស្រី ជូ ប៊ុនអេង បានមានប្រសាសន៍បន្ទាប់ពីចប់កិច្ចប្រជុំថា កិច្ចប្រជុំនេះ គឺជាកិច្ចប្រជុំលើកទី២ ដើម្បីពិភាក្សាអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលរៀងរាល់ឆ្នាំ គឺសហរដ្ឋអាមេរិកតែងតែធ្វើការវាយតម្លៃទៅលើប្រទេសនានាក្នុងពិភពលោកនៅក្នុងកម្រិតនៃការឆ្លើយតបទៅនិងអំពើជួញដូរមនុស្ស។ ហើយជាការសោកស្តាយដោយសារពីរឆ្នាំកន្លងមក គឺកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់លេខ២ នៅក្នុងការឃ្លាំមើល ដែលចំណាត់ថ្នាក់នេះ គឺជាចំណាត់ថ្នាក់ដែលទាបជិតចុងក្រោយ ហើយជាគោល

ករណ៍បើកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ២ នៅក្នុងការឃ្លាំមើលជាប់គ្នាពីរឆ្នាំ ហើយមិនមានការរីកចំរើនទេ នោះកម្ពុជានឹងធ្លាក់ទៅលេខ៣ ដោយស្វ័យប្រវត្តិ។

លោកស្រីបន្តថា កម្ពុជាបានខិតខំធ្វើនៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងតែងតែសង្ឃឹមថា លទ្ធផលដែលបានមកគឺជាលទ្ធផលដែលល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែហេតុអ្វីបានជាការវាយតម្លៃមានការធ្លាក់ចុះ បើតាមការសិក្សាមើល គឺកម្ពុជាមិនទាន់ឆ្លើយតបទៅនិងអ្វីដែលគេចង់បាន ហើយអ្វីដែលគេចង់បាននោះគឺមានចំណុចខ្លះដែលអាចនិយាយបានថា នៅពាក់ព័ន្ធជាមួយបញ្ហាច្បាប់តាមប្រទេស ក៏ដូចជាគោលនយោបាយនានា និងរបៀបរបបការងារដែលវាមិនដូចគ្នាទាំងស្រុង។ ប៉ុន្តែនៅពេលដែលក្រសួងមហាផ្ទៃ និងប្រតិភូទូតសហរដ្ឋអាមេរិកបានជួបគ្នា គឺធ្វើឲ្យភាគីទាំងពីរយល់គ្នាបានច្រើន ហើយអ្វីដែលកម្ពុជាបានធ្វើគឺមានការរីកចំរើនច្រើន។ អាចនិយាយបានថា នៅឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជារដ្ឋាភិបាលនៅទូទាំងពិភពលោក គឺបានប្រឈមជាមួយបញ្ហាធំៗ ទាំងបញ្ហាសេដ្ឋកិច្ច កូវីដ១៩ គ្រោះធម្មជាតិ ការបាត់បង់ការងាររបស់កម្មករ...។ ហើយជាលទ្ធផលមានការប្រែប្រួលខ្លាំងនៅក្នុងដំណាក់កាលនេះ៕ **រក្សាសិទ្ធិដោយៈ ចេស្តារ**

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ៖ អាមេរិកនៅតែប្តេជ្ញាចិត្តជួយកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2021-01-22 06:54pm

**(ភ្នំពេញ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បានថ្លែងថា សហរដ្ឋអាមេរិកនៅតែប្តេជ្ញាចិត្តក្នុងការជួយកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ លោកស្រីថ្លែងបែបនេះក្នុងឱកាសតំណាងសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជួបប្រជុំពិនិត្យ និងពិភាក្សា ជាមួយលោក ផាទ្រីក មើហ្វី ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅរសៀលថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ នាទីស្តីការក្រសួងមហាផ្ទៃ។ ក្នុងឱកាសនោះ លោកស្រី ជូ ប៊ុនអេង បានលើកឡើងថា អំឡុងពេលមានវិបត្តិកូវីដ១៩នេះ អំពើជួញដូរមនុស្សចាប់ផ្តើមកម្រើកឡើងមិនថា នៅប្រទេសណានោះទេ ក្នុងនោះកម្ពុជាក៏មានបញ្ហានេះកើតឡើងផងដែរ។ លោកស្រីថា នៅកម្ពុជាសកម្មភាពសម្តែងអំពើជួញដូរមនុស្សអំឡុងពេលវិបត្តិកូវីដ១៩នេះ មាន២មុខសញ្ញា គឺទី១៖ ការនាំមនុស្សចេញឆ្លងដែនដោយខុសច្បាប់ ដោយមានគោលដៅ និងធ្វើការកេងប្រវ័ញ្ច និងទី២គឺ៖ ការនាំមនុស្សទៅរៀបអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ។

បើតាមលោកស្រី ជូ ប៊ុនអេង, ឯកអគ្គរដ្ឋទូតអាមេរិក បានសម្តែងការកោតសរសើរលើការខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងមហាផ្ទៃ ដែលធ្វើឲ្យសហរដ្ឋអាមេរិកនៅតែប្តេជ្ញាចិត្តជួយគាំទ្រកម្ពុជា ក្នុងការធ្វើសកម្មភាពនេះបន្ថែមទៀត។ លោកស្រីបន្តថា ជាទូទៅជំនួយលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាមេរិកមកកម្ពុជា ធ្វើឡើងតាមរយៈអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែលោកស្រីចាត់ទុកថា ជំនួយនេះក៏បានរួមចំណែកដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សឲ្យកាន់តែល្អទៀតផង។ លោកស្រីបញ្ជាក់យ៉ាងដូច្នេះថា៖ «**លោក មើហ្វី បានបញ្ជាក់បន្ថែមថា សហរដ្ឋអាមេរិកនៅតែប្តេជ្ញាចិត្តនៅក្នុងការចំណាយថវិកាសម្រាប់ការគាំទ្រ ទៅដល់ប្រទេសនានា (មានកម្ពុជាផងនោះ) ដែលប្តេជ្ញាចិត្តនៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ គ្រាន់តែថាអ្វីដែលជាជំនួយរបស់គាត់ឲ្យផ្ទាល់ទៅអង្គការដៃគូ**»។

គួរជម្រាបថា យោងតាមរបាយការណ៍របស់ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលប្រមូលបានពីមន្ត្រីជំនាញរបស់នាយកដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត ទូទាំងប្រទេសបានបង្ហាញអំពីលទ្ធផល នៃការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវ

ភេទថា មានភាពល្អប្រសើរជាងមុន នៅឆ្នាំ២០១៩ បើធៀបនឹងរយៈពេលដូចគ្នា នៅក្នុងឆ្នាំ២០១៨។ សម្រាប់ការបង្ក្រាប និងសង្គ្រោះជនរងគ្រោះ អគ្គស្នងការនគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត ចំនួន២២ បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបបានចំនួន១៦៩ លើ១៣៤ករណី មានការកើនឡើង ៣៥ករណី ស្មើនឹង ២៦.១១ភាគរយ ឃាត់ខ្លួនបានជនសង្ស័យចំនួន ២២៩ លើ២២៤នាក់ ក្នុងនោះមានស្ត្រី ៧២នាក់ ក្នុងនោះជនសង្ស័យជាអនីតិជន ចំនួន ១១នាក់ និងជនបរទេសចំនួន ៤០នាក់ មាន៧សញ្ជាតិ។ សង្គ្រោះជនរងគ្រោះបានចំនួន ៤៥៦ លើ២៣០នាក់ ក្នុងនោះ អាយុក្រោម១៥ឆ្នាំ ១៤១នាក់អាយុ ១៥ ដល់១៧ឆ្នាំ មាន៥៥នាក់ និងអាយុ ១៨ឆ្នាំឡើងទៅ ២៦០នាក់ (ប្រគល់ជូនមន្ទីរសង្គមកិច្ចចំនួន ១៦៥នាក់ និងប្រគល់ឲ្យគ្រួសារវិញចំនួន ២៩១នាក់)៕

## អាមេរិកប្រកាស បន្តផ្តល់ថវិកាដល់កម្ពុជា សម្រាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://dap-news.com/national/ ByTR110 Posted on January 23, 2021

**ភ្នំពេញ ៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា អាមេរិកនៅតែប្តេជ្ញាចិត្ត ក្នុងការចំណាយថវិកាសម្រាប់ប្រយុទ្ធប្រឆាំ ងនឹងអំពើជួញដូរមនុស្ស នៅប្រទេសកម្ពុជា។

ក្រោយបញ្ចប់ ជំនួបពិភាក្សាការងារ ជាមួយលោក ផាទ្រីក មើហ្វី (W. Patrick Murphy) ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំក ម្ពុជា កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១នៅទីស្តីការក្រសួង លោកស្រី ជូ ប៊ុនអេង បានប្រាប់ក្រុមអ្នកសារព័ត៌មានថា ឯកអគ្គរដ្ឋទូតអាមេរិក កោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងការខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ មនុស្ស។ លោកស្រីបញ្ជាក់ថា «ស្ថានទូតសហរដ្ឋអាមេរិក លោក មើហ្វី លោកបានបញ្ជាក់បន្ថែមថា សហរដ្ឋអាមេរិកនៅតែប្តេជ្ញា ចិត្ត នៅក្នុងការចំណាយថវិកាសម្រាប់ការគាំទ្រ ទៅដល់ប្រទេសនានា (មានកម្ពុជា) ដែលប្តេជ្ញាចិត្តនៅក្នុងការប្រយុទ្ធ ប្រឆាំងនឹងអំពើជួញដូរមនុស្ស។ គ្រាន់តែថាអ្វីដែលជាជំនួយរបស់គាត់ឲ្យផ្ទាល់ទៅអង្គការដៃគូ គឺមិនឲ្យរាជរដ្ឋាភិបាល ផ្ទាល់ទេ ទោះបីយ៉ាងណាក៏ដោយនេះជាការបំពេញបន្ថែម ដើម្បីធ្វើឲ្យការប្តេជ្ញាចិត្តក៏ដូចជា គោលការណ៍របស់យើង បានអនុវត្តទៅដែរ»។

បន្ថែមពីនេះ លោកស្រីរដ្ឋលេខាធិការ ក៏បានលើកឡើងថា អំឡុងពេលជំងឺកូវីដ-១៩ អំពើជួញដូរមនុស្សចាប់ផ្តើម កម្រើកឡើង នៅតាមបណ្តាប្រទេសមួយចំនួន ក្នុងនោះ ក៏មានកម្ពុជាផងដែរ។លោកស្រីថា នៅកម្ពុជាសកម្មភាពអំពើ ជួញដូរមនុស្សអំឡុងពេលជំងឺកូវីដ-១៩ រួមមាន ៖ នាំមនុស្សចេញឆ្លងដែនដោយខុសច្បាប់ និងនាំមនុស្សទៅរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ ជាដើម។ ជាងនេះទៅទៀត លោកស្រីក៏បានបញ្ជាក់ថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានធ្វើការងារយ៉ាងច្រើន ដើម្បីប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្សនៅកម្ពុជាបើទោះបីជាកម្ពុជាកំពុងជួប ទៅនឹងវិបត្តិនៃការរីករាល ដាលជំងឺកូវីដ-១៩ និងគ្រោះទឹកជំនន់យ៉ាងណាក៏ដោយ៕

## ពលករ១៣៥ បានត្រឡប់ទៅគេហដ្ឋានវិញ ក្រោយធ្វើចត្តាឡីស័ករួច

https://www.kampucheathmey.com/ on January 22, 2021By Sorn Phanith

ពលករចំនួន១៣៥នាក់ ក្រោយបញ្ចប់ការធ្វើចត្តាឡីស័ក១៤ថ្ងៃហើយ រដ្ឋបាលខេត្តបានឲ្យវិលត្រឡប់ទៅគេហដ្ឋានវិញអស់ហើយនៅព្រឹកនេះ ក្នុងមណ្ឌលចត្តាឡីស័កកងវ៉ា នៅផ្លូវជាតិលេខ៥៦ ភូមិកងវ៉ាសង្កាត់ កំពុងស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានបញ្ជាក់ឲ្យដឹងថា នេះជាជោគជ័យមួយយ៉ាងធំសម្រាប់ខេត្តបន្ទាយមានជ័យ ដែលមានក្រុមគ្រូពេទ្យ ស្ម័គ្រចិត្ត គ្រូពេទ្យជាប់កិច្ចសន្យា និងក្រុមគ្រូពេទ្យក្របខ័ណ្ឌ និងអង្គ

ភាពទាំង ៣មាន កម្លាំងអាវុធហត្ថ នគរបាល និង ទាហាន ខិតខំប្រឹងប្រែង មើលការខុសត្រូវទាំងថ្ងៃទាំងយប់ មិនឲ្យពលករទាំងអស់ចេញដើររហេតរហូត គឺនៅក្នុងបន្ទប់ចំនួន១៤ថ្ងៃ រហូតដល់ពលករទាំង១៣៥នាក់ សំងំរស់នៅក្នុងបន្ទប់បានដល់ទៅ១៤ថ្ងៃ ដែលត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅគេហដ្ឋានវិញ។ ក្នុងនោះលោក អ៊ុំ រាត្រី បានធ្វើការផ្តាំផ្ញើដល់បងប្អូនទាំងអស់ ពេលត្រឡប់ទៅផ្ទះវិញ ត្រូវបន្តធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃបន្តទៀត និងត្រូវតាមដានសុខភាពរបស់ខ្លួនជាប្រចាំ ហើយបើមានអាការៈមិនស្រួល ត្រូវទាក់ទងទៅកាន់ក្រុមគ្រូពេទ្យជាបន្ទាន់។ ជាមួយគ្នានេះ អភិបាលខេត្តបន្ទាយមានជ័យ និងលោកស្រី រស់ សុផានី អភិបាលរងខេត្ត ព្រមទាំងក្រុមការងារ កងកម្លាំងចម្រុះខេត្ត ក៏បានធ្វើការត្រួតពិនិត្យ និងរៀបចំចាត់ចែងដឹកជញ្ជូនបងប្អូនពលករឲ្យបានត្រឡប់ទៅកាន់ លំនៅឋានតាមបណ្តាខេត្ត ស្រុកនានាតាមរយៈរថយន្តដឹកជញ្ជូនកងទ័ព ផងដែរ ៕

## អាជ្ញាធរខេត្តបន្ទាយមានជ័យថាពលករខ្មែរនៅតែបន្តវិលមកកម្ពុជាវិញ ខណៈនៅថៃអស់ការងារធ្វើ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 24/01/2021 - 06:07

ពលករខ្មែរដែលទៅរកការងារធ្វើនៅប្រទេសថៃនៅតែបន្តវិលចូលប្រទេសកម្ពុជានៅប៉ុន្មានថ្ងៃចុងក្រោយនេះ ដែលមានចំនួនច្រើនឡើង ខណៈប្រទេសជិតខាងមួយនេះ កំពុងរីករាលដាលកូវីដ១៩ ធ្វើឲ្យពលករខ្មែរត្រូវបាត់បង់ការងារ។ តាំងពីប្រទេសថៃផ្ទុះកូវីដ១៩ទៅក្នុងសហគមន៍នៅខេត្តសាមុតសាខនមក គឺមានពលករខ្មែរជាង ១ម៉ឺននាក់ហើយបានវិលមកកម្ពុជាវិញជាបន្តបន្ទាប់។

លោក លី សារី អ្នកនាំពាក្យសាលាខេត្តបន្ទាយមានជ័យប្រាប់វិទ្យុបារាំងអន្តរជាតិRFIនៅថ្ងៃអាទិត្យនេះថា រយៈពេល២ថ្ងៃចុងក្រោយនេះ ពលករខ្មែរដែលមកពីថៃបានកើនឡើងដល់ជិត ១០០នាក់ បន្ថែមទៀតដោយសារតែនៅប្រទេសថៃអស់ការងារធ្វើ។ ដូច្នេះមណ្ឌលចត្តាឡីស័កនៅតាមសាលារៀនកន្លងមកគឺនៅបន្តប្រើប្រាស់បន្តទៀត ដែលធ្វើឲ្យការសិក្សារបស់សិស្សនៅខេត្តជាប់ព្រំដែនមួយនេះ ត្រូវបន្តពន្យារពេល។ នេះបើតាមអ្នកនាំពាក្យដដែល។ លោក លី សារី បានឲ្យដឹងថា តាំងពីប្រទេសថៃផ្ទុះកូវីដ១៩ទៅក្នុងសហគមន៍នៅខេត្តសាមុតសាខននោះ គឺមានពលករខ្មែរដែលមកពីថៃវិញឆ្លងកាត់ខេត្តបន្ទាយមានជ័យ មានជាង ១ម៉ឺននាក់ ក្នុងនោះប្រមាណ៣ពាន់នាក់ ត្រូវធ្វើចត្តាឡីស័កនៅតាមទីតាំងមួយចំនួនក្នុងបន្ទាយមានជ័យ។

សូមជម្រាបថា ពេលនេះអាជ្ញាធរខេត្តបន្ទាយមានជ័យ កំពុងតែស្វែងរកបុរសម្នាក់ជាពលករខ្មែរ ដែលបានលួចរត់ចេញពីមណ្ឌលធ្វើចត្តាឡីស័កនៅវិទ្យាល័យមង្គលបូរី កាលពីយប់ថ្ងៃ២២ ខែមករា ឆ្នាំ២០២១។ លោក លី សារី បានអះអាងថា ការរត់ចេញរបស់ពលកររូបនោះ មិនមែនមកពីពិបាករស់នៅក្នុងមណ្ឌលចត្តាឡីស័កនោះទេ តែលោកជឿថា មកពីពលកររូបនេះខ្លាចម្ចាស់បំណុលតាមទារលុយ ទើបរូបគេរត់គេចខ្លួន រួមទាំងប្រពន្ធដែលនៅឯផ្ទះផងដែរ។ យ៉ាងណាក៏ដោយពលកររូបនេះបានធ្វើតេស្តកូវីដ១៩ជាលើកទី១ គឺអវិជ្ជមាន តែតម្រូវឲ្យធ្វើតេស្តចំនួន២លើកទៀត៕

## បុរសលួចចេញពីមណ្ឌលចត្តាឡីស័កវិទ្យាល័យមង្គលបុរី បានឆ្លងដែនទៅថៃវិញ

https://thmeythmey.com/ 24, Jan 2021 , 3:18 pm

ពលករខ្មែរម្នាក់ដែលលួចចេញពីមណ្ឌលចត្តាឡីស័កវិទ្យាល័យមង្គលបុរី ខេត្តបន្ទាយមានជ័យ បានឆ្លងដែនវិលត្រឡប់ទៅថៃ ជាមួយភរិយារបស់ខ្លួនវិញ។ នេះបើតាមការអះអាងរបស់ លោក ជា ទី មេឃុំសឿ។

បើតាមលោក ជា ទី ពលករឈ្មោះ ខា រិន ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កនៅវិទ្យាល័យមង្គលបុរី កាលពីថៃទី២១ ខែមករា ហើយលទ្ធផលសំណាកលើកទី១ បង្ហាញថា គាត់អវិជ្ជមានកូវីដ-១៩ ។ បីថ្ងៃក្រោយមកពលកររូបនេះ បានលួចរត់ទៅថៃវិញជាមួយភរិយា។ អភិបាលស្រុកមង្គលបុរី លោក វ័ត្ន ជាស៊ីណង់ បានបញ្ជាក់ថា នេះជាលើកទី២ ដែលមានករណីរត់គេចចេញពីមណ្ឌលចត្តាឡីស័កវិទ្យាល័យមង្គលបុរីនេះ ដោយករណីទីមួយត្រូវបានឃាត់ខ្លួន ហើយយកត្រឡប់មកធ្វើចត្តាឡីស័កវិញ។ លោកបន្ថែមថា៖ «អ្នកដែលលួចរត់ចេញពីមណ្ឌលចត្តាឡីស័ក ខុសពីគោលការណ៍ណែនាំ គឺអាជ្ញាធរពុំមានផាកពិន័យ អ្វីនោះទេ គឺគ្រាន់យកខ្លួនគាត់មកធ្វើចត្តាឡីស័ក ហើយរាប់ចាប់ពីថ្ងៃទីមួយ ឡើងវិញប៉ុណ្ណោះ»។

បើតាមអភិបាលស្រុកមង្គលបុរី គិតត្រឹមថ្ងៃទី២៤ ខែមករានេះ មណ្ឌលចត្តាឡីស័កវិទ្យាល័យមង្គលបុរីទទួលពលករខ្មែរពីថៃ មកធ្វើចត្តាឡីស័កចំនួន ៦២៨នាក់ ក្នុងនោះមាន៤នាក់វិជ្ជមាន ខណៈអ្នកមួយចំនួនទៀតបានវិលត្រឡប់ទៅផ្ទះវិញ ក្រោយផុតអំឡុងពេលនៃចត្តាឡីស័ក។ គិតត្រឹមថ្ងៃទី២៤នេះ កម្ពុជាមានអ្នកកើតកូវីដ-១៩ ចំនួន៤៥៨ករណី ដោយ ៤០៥ករណីជាសះស្បើយ ក្នុងនោះ មានពលករខ្មែរមកពីថៃចំនួន ៨២នាក់ និងជាសះស្បើយ ៤០នាក់។ រីឯអ្នកជំងឺកំពុងសម្រាកព្យាបាល មានចំនួន ៥៣នាក់ ក្នុងនោះ ៩នាក់ក្នុងមជ្ឈមណ្ឌលកំចាត់ជំងឺរបេង និង ហង់សិន, ១នាក់ក្នុងពេទ្យមិត្តភាពខ្មែរ-សូវៀត, ១នាក់ក្នុងមណ្ឌលសុខភាពចាក់អង្រែ។ ចំណែកឯពលករពីថៃព្យាបាលនៅតាមបណ្តាមន្ទីរពេទ្យខេត្ត ក្នុងនោះ ៣០នាក់នៅក្នុងបន្ទាយមានជ័យ, ៩នាក់នៅបាត់ដំបង ២នាក់នៅឧត្តរមានជ័យ និង ១នាក់នៅប៉ៃលិន៕

## មេខ្យល់ ឈ្មោះយាត. មករា ហៅពាក់មី នាំ ពលករ ចំនួន១៤នាក់ ប្រុងឆ្លងដែនទៅប្រទេសថៃត្រូវបាន ឃាត់ខ្លួន

https://www.facebook.com/Khmer-People-News ថ្ងៃទី មករា 23 នៅម៉ោង 1:19 PM ·

ខេត្តបាត់ដំបង÷ ក្រោយពីសមត្ថកិច្ចធ្វើការឃាត់ខ្លួនមេខ្យល់ម្នាក់ រួមនឹងពលករផ្សេងទៀតសរុបទាំងអស់ចំនួន១៤នាក់ ចំពោះមុខសមត្ថកិច្ចត្រូវបានអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលជាមុនសិនបន្ទាប់ពីធ្វើការសាកសួរទៅលើអ្នកទាំង១៤នាក់។ ប្រភពដដែលបន្តថា ការឃាត់ខ្លួនអ្នកទាំង១៤នាក់បានធ្វើឡើងកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១កន្លងមកនេះ។ នេះបើយោងតាមការឲ្យដឹងពី លោកអនុសេនីយ៍ឯក ង៉ែត.វណ្ណា មន្ត្រីនគរបាលស្រុកកំរៀង។

កិច្ចប្រតបត្តិការខាងលើកម្លាំងរបស់អធិការនគរបាលស្រុកកំរៀង សហការជាមួយនគរបាលការពារព្រំដែនគោកលេខ៨១៩ បានបើកការស្រាវជ្រាវបង្ក្រាប និងឃាត់ខ្លួនមេខ្យល់ម្នាក់រួមទាំងពលករប្រុសស្រីចំនួន១៣នាក់ផ្សេងទៀតនូវគ្រាដែលពួកគេបានប្រមូលផ្តុំគ្នាប្រុងឆ្លងដែនចូលក្នុងប្រទេសថៃ ត្រង់ចំណុចភូមិស្វាយឃុំបឹងរាំងស្រុកកំរៀងខេត្តបាត់ដំបង។ មេខ្យល់ដែលត្រូវសមត្ថកិច្ចឃាត់ខ្លួននេះមានឈ្មោះ យាត.មករា ហៅ ពាក់មី ភេទប្រុស អាយុ៣៦ឆ្នាំ ស្នាក់នៅបន្ទប់ជួលនៅក្នុងស្រុកកំរៀង ដើម្បីធ្វើសកម្មភាព។ ប្រភពបន្តថាជនសង្ស័យខាងលើនេះបានសារភាពថា÷នៅថ្ងៃកើតហេតុកាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ខ្លួននិងបក្សពួកចំនួន២នាក់ទៀតបានប្រមូលផ្តុំពលករខ្មែរសរុបចំនួន១៣នាក់ក្នុងនោះស្ត្រីចំនួន៧នាក់ផងដែរ ដែលមកពីបណ្តាខេត្តផ្សេងៗឲ្យមកស្នាក់នៅក្បែរតំបន់ព្រំដែនងាយស្រួលដើបនៅវេលារំលងអាធ្រាត ដើម្បីឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដោយមានវថយន្តរបស់ជនជាតិថៃមកចាំទទួលតែម្តង។ លុះដល់ម៉ោង១២:០០នាទីកណ្តាលអាធ្រាតនាថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បំរុងនិងធ្វើសកម្មភាពក៏ត្រូវបានសមត្ថកិច្ចចុះបង្ក្រាបនិងឃាត់ខ្លួនតែម្តង។

ចំពោះមុខសត្ថកិច្ចមេខ្យល់បានសារភាពថា ថ្លៃឈ្នួលជូនពលករទៅដល់គោលដៅ គឺត្រូវលោកមេខ្យល់ប្រមូលយកមុនក្នុងម្នាក់តម្លៃប្រហាក់ប្រហែល៤០ម៉ឺនរៀលស្មើប្រាក់ថៃចំនួន៣៥០០បាត។ សមត្ថកិច្ចបញ្ជាក់បន្ថែមថា÷ក្រោយពីធ្វើការសាកសួរអ្នកទាំង១៤នាក់ ជនសង្ស័យឈ្មោះ យាត.មករា ត្រូវកម្លាំងអធិការកសាងសំណុំរឿងបញ្ជូនបន្តទៅកាន់ការិយាល័យជំនាញ នៃស្នងការខេត្តបាត់ដំបង ដើម្បីបន្តអនុវត្តតាមនីតិវិធី។ ចំណែកមេខ្យល់អ្នកពាក់ព័ន្ធចំនួន២នាក់ទៀតដឹងខ្លួនមុនបានគេចខ្លួនបាត់ចំណែកពលករសរុបទាំង១៣នាក់ បានបញ្ជូនទៅពិនិត្យសុខភាពនិងដាក់ឲ្យធ្វើចត្តាឡីស័កនៅអនុវិទ្យាល័យបឹងរាំងស្រុកកំរៀង។ ក្រោយពីសមត្ថកិច្ចនៃអធិការស្រុកកំរៀងបានបញ្ជូនមេខ្យល់ម្នាក់ខាងលើមកស្នងការខេត្តកាលពីថ្ងៃទី២២ ខែមករាបច្ចុប្បន្នសមត្ថកិច្ចការិយាល័យជំនាញ នៃស្នងការខេត្តបានកំពុងរៀបចំសំណុំរឿងត្រៀមបញ្ជូនទៅជនសង្ស័យទៅតុលាការដើម្បីផ្តន្ទាទោសតាមផ្លូវច្បាប់៕

## ពលករខ្មែរ៧នាក់រងរបួសធ្ងន់ស្រាលក្នុងហេតុការណ៍បាក់ស្ពានបេតុងនៅប្រទេសថៃ

https://www.rfa.org/khmer/ ដោយ ខែ សុណង 2021-01-24

ពលករខ្មែរចំនួន៧នាក់រងរបួសធ្ងន់ស្រាលក្នុងហេតុការណ៍បាក់ស្ពានបេតុង នៅខេត្តណាខនរាជស៊ីមា (Nakhon Ratchasima) នៅភូមិភាគខាងកើតនៃប្រទេសថៃ នៅរសៀលថ្ងៃទី២៣ មករា។

អ្នកបកប្រែ និងធ្វើការងារផ្នែកការពារសិទ្ធិពលករខ្មែរនៅប្រទេសថៃ លោក ប្រាក់ ភត្រា ឱ្យដឹងថា ករណីបាក់ស្ពានកំពុងសាងសង់សង្កត់លើកម្មករនោះ មានពលករខ្មែរ ៧នាក់ និងកម្មករជនជាតិមីយ៉ាន់ម៉ា ឬភូមាម្នាក់ (Myanmar) និង (Thai) ម្នាក់ដែរ ប៉ុន្តែលោកថា ចំនួនអ្នករបួសអាចមានច្រើនជាងនេះ៖ «ស្ពានទើបសាងសង់ស្ពានធ្វើដើម្បីវៀងចេញទៅក្រៅខេត្តដើម្បីឆ្លងទៅខេត្តមួយទៀតកុំឱ្យស្ទះឡាន។ កំពុងសាងសង់វាស្រុតដែកដែលគេចាក់បេតុងវាស្រុតទៅកម្មករយើងកំពុងតែធ្វើការចាក់ស៊ីម៉ង់វាស្រុតទៅវាសង្កត់ធ្លាក់មកលើពលករ ដែលកំពុងធ្វើការនៅហ្នឹងរងរបួស»។ លោក ប្រាក់ ភត្រា ឱ្យដឹងទៀតថា កម្មករដែលរបួសធ្ងន់ស្រាលទាំងនេះ ភាគច្រើនបាក់ដៃបាក់ជើង ត្រូវបានគេជួយសង្គ្រោះនៅមន្ទីរពេទ្យចំនួន៣នៅក្នុងខេត្តនេះ។ លោកបន្តថា អាជ្ញាធរថៃកំពុងធ្វើការស្រាវជ្រាវរកមូលហេតុដែលបណ្តាលឱ្យបាក់ស្ពានបេតុងនេះ ថាតើបណ្តាលមកពីសំណង់មិនរឹងមាំ ឬជាកំហុសរបស់វិស្វករ៕

## សមត្ថកិច្ចថៃ ឃាត់ខ្លួនឃាតកបានហើយ ករណីឃាតកម្មលើពលករខ្មែរដូចគ្នា

https://www.kampucheathmey.com/ January 24, 2021By Sonya

**បាត់ដំបង៖** ករណីឃាតកម្មរវាងពលករខ្មែរនឹងខ្មែរ បង្កឲ្យបាត់បង់ជីវិតម្នាក់ សមត្ថកិច្ចថៃបានចុះស្រាវជ្រាវហេតុឃាត់ខ្លួនជនជាឃាតកបានហើយ នៅល្ងាចថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ ត្រង់បន្ទប់ស្នាក់នៅរបស់កម្មករបើតក្នុងក្រុងប៊ួងខេត្តឈុនបុរី ប្រទេសថៃ។ មកទល់ពេលនេះ ទាំងជនរងគ្រោះនិងទាំងជនដៃដល់នៅមិនទាន់ស្គាល់អត្តសញ្ញាណនៅឡើយទេ ប៉ុន្តែតាមប្រភពពីពលករនៅថៃបញ្ជាក់ថា ពួកគេជាពលករខ្មែរដូចគ្នា ដោយផ្តើមឡើងចេញពីការផឹកស៊ីជាមួយគ្នាក៏បង្កជាជម្លោះពាក្យសម្តី រហូតជនដៃដល់បានទាញពូថៅកាប់ត្រង់កញ្ចឹងកជនរងគ្រោះបណ្តាលឲ្យស្លាប់តែម្តង។ ប្រភពដដែលបន្ថែមថា ឃាតកម្មដែលបង្កឡើងរវាងពលករដូចគ្នាបានកើតឡើងកាលពីយប់ថ្ងៃទី២២ ខែមករាឆ្នាំ២០២១ ត្រង់ចំណុចភូមិ២ន ឃុំណងឆាក ស្រុកបានប៊ឹង ខេត្តឈុនបុ រីក្នុងក្រុមហ៊ុន សេនសាន់សេតអ៊ិនដាតទ្រី ចំកាត់ ក្នុងបន្ទប់ស្នាក់នៅរបស់កម្មករ។ ក្រោយបង្កហេតុយតុជនដៃដល់ធ្វើសកម្មភាពបានរត់គេចខ្លួនបាត់រំលងបានមួយថ្ងៃ ទើបសមត្ថកិច្ចថៃកំណត់មុខសញ្ញាឃាត់ខ្លួនបានតែម្តង។ បច្ចុប្បន្នជនសង្ស័យកំពុងត្រូវបានតម្រួតថៃបន្តការសាកសួរនិងគ្រោងបញ្ជូនទៅតុលាការអនុវត្តតាមនីតិវិធី៕ **អត្ថបទ៖ សៅ សារិទ្ធ**

# ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០២១

## សម្តេចតេជោ ហ៊ុន សែន ផ្តល់ជំនួយ៣០០លានរៀលបន្ថែមទៀត ដល់ខេត្តឧត្តរមានជ័យ និង ប៉ៃលិន ដើម្បីសម្រួលដល់ការធ្វើចត្តាឡីស័ករបស់ពលករ

http://www.freshnewsasia.com/ 2021-01-26 07:23am

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១នេះ បានសម្រេចផ្តល់ជំនួយបន្ថែមចំនួន ៣០០លានរៀលទៀត ដល់ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន ដើម្បីរៀបចំសម្រួលដល់ការធ្វើចត្តាឡីស័ករបស់ពលករខ្មែរមកពីប្រទេសថៃ។ នេះបើតាម លោកស្រី យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាល បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។

លោកស្រី យក់ សម្បត្តិ បានបញ្ជាក់បន្ថែមថា ក្នុងចំណោមថវិកាចំនួន៣០០លានរៀលនោះ មានខេត្តឧត្តរមានជ័យ ទទួលបាន២០០លានរៀល និងខេត្តប៉ៃលិន ទទួលបាន១០០លានរៀល។ ថវិកាទាំងនេះ ត្រូវបានក្រសួងសុខាភិបាលរៀបចំផ្ទេរជូនរដ្ឋបាលខេត្តទាំងពីរភ្លាមៗផងដែរ។ ចាប់តាំងពីប្រទេសថៃ មានការផ្ទុះជំងឺកូវីដ១៩ នៅក្នុងសហគមន៍យ៉ាងខ្លាំងក្លា ក្នុងខេត្តសមុទ្រសាខន ដែលជាប់ព្រំដែនជាមួយគ្នា កម្ពុជាបានរកឃើញមានពលករជាបន្តបន្ទាប់មានផ្ទុកជំងឺកូវីដ១៩ ក្រោយពេលត្រឡប់មកពីប្រទេសថៃ។

ឆ្លើយតបនឹងស្ថានភាពនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានផ្តល់ជំនួយថវិកាជាបន្តបន្ទាប់ដល់ខេត្តជាប់ព្រំដែនថៃទាំង ៧ ដើម្បីរៀបចំធ្វើចត្តាឡីស័កដល់ពលករដែលត្រឡប់មកពីប្រទេសថៃ។

បើតាមក្រសួងសុខាភិបាល, គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ មានពលករខ្មែរចំនួនជិត២ម៉ឺននាក់បានត្រឡប់ពីប្រទេសថៃ ហើយត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក នៅខេត្តជាប់ព្រំដែន ក្នុងប្រទេសកម្ពុជា៕

## ក្រសួងមហាផ្ទៃ៖ ការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សបានរីកចម្រើននៅឆ្នាំ ២០២០

https://www.khmertimeskh.com/ សែន ដេវីត / Khmer Times

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) បាននិយាយថាទោះបីមានវិបត្តិជំងឺកូវីដ-១៩ ក៏ដោយក៏គណៈកម្មាធិការបានខិតខំយ៉ាងខ្លាំងដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅកម្ពុជា។

កាលពីថ្ងៃសុក្រលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានជួបជាមួយលោក Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក។ លោកស្រីបាននិយាយថា ជំនួបនេះសង្កត់ធ្ងន់លើកិច្ចពិភាក្សាអំពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ លោកស្រីបន្តថាក្រុមការងារអន្តរក្រសួងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានធ្វើការរួមគ្នាដើម្បីឆ្លើយតបនឹងការជួញដូរមនុស្ស ហើយលទ្ធផល មានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ លោកស្រីបន្ថែមថា ក្រុមការងារបានធ្វើការងារជាច្រើន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សក្នុងឆ្នាំ ២០២០ ដូចជាក្រសួងអប់រំបង្កើតសៀវភៅសិក្សាសម្រាប់បឋមសិក្សា និងមធ្យមសិក្សា ដើម្បីបណ្តុះបណ្តាលសិស្សានុសិស្សអំពីការការពារការជួញដូរមនុស្ស ក្រសួងសុខាភិបាលកំពុងបង្កើតគោលនយោបាយទាក់ទងនឹងសុខភាពពលករចំណាកស្រុក និងក្រសួងការងារកំពុងបង្កើតការងារជាង ២ ម៉ឺនកន្លែងសម្រាប់ពលករដែលវិលត្រឡប់មកពីប្រទេសថៃ។ លោកស្រីនិយាយថា៖ «យើងក៏ធ្វើការជាមួយអង្គការសហប្រជាជាតិផងដែរក្នុងការបង្កើតការងារសម្រាប់ពលករដែលវិលត្រឡប់មកស្រុកវិញដែលអាចដាំដំណាំដើម្បីទ្រទ្រង់ជីវភាពរបស់ពួកគេ ហើយគណៈកម្មាធិការបានធ្វើចំណាត់ការល្អនៅឆ្នាំ ២០២០ ទោះបីមានជំងឺរាតត្បាតកូវីដ-១៩ ក៏ដោយ»។

កាលពីខែធ្នូ លោកស្រីបាននិយាយថាជំងឺកូវីដ-១៩ និងការបិទព្រំដែនបណ្តាលឲ្យមានការកើនឡើងនៃការជួញដូរស្ត្រីចេញពីប្រទេសកម្ពុជា។ ពួកគេត្រូវបានជួញដូរខុសច្បាប់ដោយ មេខ្យល់ ដែលសន្យាថានិងជួយឲ្យពួកគេបានរៀបការនៅបរទេស។

ទោះជាយ៉ាងណា យោងតាមរបាយការណ៍របស់ស្ថានទូតសហរដ្ឋអាមេរិក ស្តីពីរបាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០២០ នៅប្រទេសកម្ពុជា រដ្ឋាភិបាលមិនបានបំពេញតាមបទដ្ឋានអប្បបរមាសម្រាប់ការលុបបំបាត់ការជួញដូរទេ ប៉ុន្តែកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីធ្វើដូច្នោះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមមានការបន្តចោទប្រកាន់ និងផ្តន្ទាទោសអ្នកជួញដូរ ការបង្កើតផែនការសកម្មភាពថ្មីរយៈពេល ៥ ឆ្នាំដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ ការអភិវឌ្ឍ និងការប្រើប្រាស់អត្តសញ្ញាណជនរងគ្រោះនិងបច្ចេកវិទ្យាប្រមូលទិន្នន័យថ្មីៗ៕ *ប្រែសម្រួលដោយ សៀវ គួយអ៊ី*

## ក្រសួងសង្គមកិច្ច កំពុងរៀបចំកែសម្រួលលើគោលនយោបាយការពារសិទ្ធិជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2021-01-25 11:04am

**(ភ្នំពេញ)៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១នេះ បានរៀបចំបើកសិក្ខាសាលាពិគ្រោះយោបល់ និងកែសម្រួលលើគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅភោជនីយដ្ឋានទន្លេបាសាក់២ ក្រោមអធិបតីភាពលោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច។

នាឱកាសនោះ លោក ញឹក វណ្ណារ៉ា បានឱ្យដឹងថា អំពើជួញដូរមនុស្សបាននិងកំពុងកើតឡើងគ្រប់ទីកន្លែងក្នុងរូបភាពភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន និងក្នុងប្រទេស ដែលមានអង្គការចាត់តាំង ហើយឧក្រិដ្ឋកម្មនេះបានជះឥទ្ធិពលជាអវិជ្ជមានដល់បុគ្គល គ្រួសារ និងសហគមន៍ ជាពិសេសទាំងនៅថ្នាក់ជាតិ តំបន់និងពិភពលោក។

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងខិតខំប្រឹងប្រែងបង្កើត រៀបចំ ចងក្រង ផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងយន្តការនានាសំដៅប្រយុទ្ធប្រឆាំង និងកាត់បន្ថយឱ្យបានជាអតិបរមានូវអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ អនុតំបន់ តំបន់ និងលើពិភពលោក។ ដោយឡែក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានទទួលអាណត្តិពីរាជរដ្ឋាភិបាល ក្នុងការការពារ និងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ ក្រសួងបានបំពេញការងារយ៉ាងសកម្ម និងសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការងារកសាងគោលនយោបាយ ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការបង្កើនភាពជាដៃគូ។ លោកបានបន្តថា ទោះបីក្រសួងសម្រេចបានសមិទ្ធផលជាច្រើនយ៉ាងណាក៏ដោយ ក៏កិច្ចការពារ និងការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅមិនទាន់ឆ្លើយតបបានទាំងស្រុងនៅឡើយទេ ជាពិសេសការផ្តល់សេវាគាំទ្រសម្រាប់ជនរងគ្រោះនៅមានកម្រិតនៅឡើយ។

បន្ទាប់ពីក្រសួងសង្គមកិច្ចបានដាក់ចេញនូវគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅឆ្នាំ២០០៩ ក្រសួងបានធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលជាច្រើនវគ្គសម្រាប់អនុវត្តទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ សំដៅពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីទទួលបន្ទុកការងារសង្គមកិច្ចពាក់ព័ន្ធនានា ទាំងស្ថាប័នរដ្ឋាភិបាល និងអង្គការដៃគូអភិវឌ្ឍក្នុងការការពារ និងគាំទ្រដល់ជនរងគ្រោះប្រកបដោយសុវត្ថិភាព ពិសេសធានាបាននូវជនរងគ្រោះទទួលបានផលប្រយោជន៍ពីលិខិតូបករណ៍ជាតិ

ច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងទទួលបានសិទ្ធិអំណាច និងមានលទ្ធភាពធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ដោយជោគជ័យជាស្ថាពរ ទទួលបានការឧបត្ថម្ភទាំងផ្នែកសម្ភារៈ និងស្មារតី ពិសេសសេវាសុខភាព សេវាអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទទួលបាននូវកិច្ចការពារយ៉ាងល្អប្រសើរ ឆ្លងផុតពីភាពរងគ្រោះសាជាថ្មី និងការរើសអើង។ ដោយក្រសួងសង្គមកិច្ចបានយល់ឃើញថា គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានដាក់ឱ្យអនុវត្តអស់រយៈពេលជាង ១០ ឆ្នាំរួចមក ក្រសួងបានសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) និងអង្គការដៃគូពាក់ព័ន្ធក្នុងការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព ឯកសារនេះ ដើម្បីឱ្យឯកសារនេះមានសង្គតភាព និងឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន។

លោករដ្ឋលេខាធិការបានបន្តទៀតថា ដើម្បីពង្រឹងប្រសិទ្ធភាពថែមទៀតនៃកិច្ចការពារសិទ្ធិ និងការគាំទ្រដល់ជនរងគ្រោះ កម្ពុជាត្រូវពិនិត្យឡើងវិញនូវគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលបានដាក់ឱ្យប្រើប្រាស់ចាប់តាំងពីឆ្នាំ២០០៩ ហេតុនេះ ក្រសួងត្រូវការមតិ និងយោបល់ដែលមានលក្ខណៈចូលរួម មានន័យថា ការកែសម្រួលឯកសារនេះត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ដោយរួមមាន ក្រសួង ស្ថាប័ន អង្គការជាតិ-អន្តរជាតិ និងភ្នាក់ងារអង្គការសហប្រជាជាតិ នៅគ្រប់ដំណាក់កាលនៃការកែសម្រួល។

សូមជម្រាបថា សិក្ខាសាលាពិគ្រោះយោបល់ និងកែសម្រួលលើគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិនិត្យឡើងវិញនូវលទ្ធផលនៃការវាយតម្លៃទៅលើការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សរបស់អង្គការដៃគូអភិវឌ្ឍ និងប្រមូលយោបល់ និងធាតុចូលសម្រាប់កែសម្រួលលើគោលនយោបាយ និងបទដ្ឋានអប្បបរមានេះ៕

## ស្ត្រីជាប់ពន្ធនាគារ ស្នើតុលាការកំពូលឱ្យដោះលែងខ្លួន ករណីសញ្ជារកម្ម

https://www.postkhmer.com/ គឹម សារុំ | Publication date 25 January 2021 | 17:05 ICT

**ភ្នំពេញៈ** ស្ត្រីជាប់ចោទម្នាក់បានស្នើសុំឱ្យតុលាការកំពូលដោះលែងខ្លួនពីពន្ធនាគារ ក្នុងពេលកំពុងសវនាការនៅថ្ងៃទី ២៥ មករានេះ បន្ទាប់ពីត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់ពន្ធនាគារ ៧ ឆ្នាំក្នុងសំណុំរឿងសញ្ជារកម្មករណីឲ្យកូនឈ្នួលមិនទាន់គ្រប់អាយុ ៣ នាក់ ក្នុងចំណោម ៤ នាក់ រួមភេទជាមួយភ្ញៀវ ប្រព្រឹត្តនៅសង្កាត់ស្ទឹងមានជ័យ កាលពីឆ្នាំ ២០១៧។

នៅក្នុងបន្ទប់សវនាការតុលាការកំពូលនេះស្ត្រីជាប់ចោទឈ្មោះ សុខា សុថារី បានប្រាប់ចៅក្រមថា គាត់ពិតជាអនុញ្ញាតឲ្យជនរងគ្រោះទាំង ៣ នាក់ ឲ្យចូលធ្វើការក្នុងហាងកាត់សក់សាឡនរបស់គាត់មែន។ ប៉ុន្តែគាត់មិនបានពិនិត្យមើលអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនពួកគេទេ។ ចំពោះការរួមភេទរវាងពួកគេជាមួយភ្ញៀវ គឺគាត់មិនបានដឹងទេតែទទួលស្គាល់ថា គាត់បានយកលុយពីពួកគេម្នាក់ ៥ ដុល្លារ ពីកម្រៃសេវាកាត់សក់ឲ្យភ្ញៀវ។ ស្ត្រីជាប់ចោទថា៖ «ខ្ញុំសូមឲ្យតុលាការកំពូលដោះលែងខ្ញុំវិញផង ព្រោះខ្ញុំបានជាប់ឃុំក្នុងពន្ធនាគារជាង ៣ ឆ្នាំហើយ។ កាលនោះខ្ញុំមិនបានយល់ពីច្បាប់ និងគិតមិនបានវែងឆ្ងាយ»។

លោក អ៊ុក គឹមសិទ្ធិ តំណាងមហាអយ្យការសន្និដ្ឋានថា តាមរបាយកាណ៍សំយោគរបស់នគរបាលប្រឆាំងការជួញដូរមនុស្សបង្ហាញថា ក្នុងរឿងនេះមានក្មេងស្រីអាយុ ១៥ ឆ្នាំ, ១៦ ឆ្នាំ, ១៧ ឆ្នាំ អាយុ ២១ ឆ្នាំ ហើយស្ត្រីជាប់ចោទបានយកកម្រៃពីជនរងគ្រោះម្នាក់ ៥ ដុល្លារ ក្នុងតម្លៃរួមភេទម្តង ៣០ ដុល្លារ។ ផ្អែកតាមភស្តុតាងស្រោមអនាម័យដែលសមត្ថកិច្ចរកឃើញ ក្នុងផ្ទះរបស់ស្ត្រីជាប់ចោទ គឺគ្រប់គ្រាន់ក្នុងការចោទប្រកាន់។ លោកថ្លែងថា៖«ខ្ញុំ

យល់ឃើញថាសាលដីការបស់សាលាឧទ្ធរណ៍ដែលតម្កល់តាមសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញគឺត្រឹមត្រូវតាមច្បាប់ហើយ។ខ្ញុំសូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ»។

លោក សុគន្ធ ពិដោរ មេធាវីការពារសិទ្ធិឲ្យស្ត្រីជាប់ចោទបានសន្និដ្ឋានថា កូនក្តីលោកពិតជាបានបើកកន្លែងកាត់សក់ និងសាឡននោះមែន។ តែកូនក្តីលោកមិនបានយកកម្រៃពីការរួមភេទរបស់នារីរងគ្រោះទេ។តាមចម្លើយក្មេងស្រី ឈ្មោះដ.ម អាយុ ១៥ ឆ្នាំ ក្នុងចំណោម ៤ នាក់ នៅដំណាក់កាលសមត្ថកិច្ចថា នាងបានលួចរួមភេទជាមួយភ្ញៀវបានថ្លៃ ៣០ ដុល្លារ ហើយដក ៥ ដុល្លារ ឲ្យកូនក្តីលោកជាថ្លៃម៉ាស្សា។ តែកូនក្តីលោកពិតជាមិនបានដឹងថាពួកគេរួមភេទជាមួយភ្ញៀវទេ។ លោកថា៖ «ប៉ុន្តែដោយសារភាពល្ងង់របស់កូនក្តីខ្ញុំសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាដោះលែងគាត់ឲ្យមានសេរីភាពវិញផង»។

តាមកំណត់ហេតុនគរបាលប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញបង្ហាញថា ស្ត្រីជាប់ចោទឈ្មោះ សុខា សុថារី អាយុ ៣៨ ឆ្នាំ បានបើកហាងកាត់សក់បុរស និងកន្លែងម៉ាស្សាតាមបណ្តោយផ្លូវវេងស្រេង ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យរាជធានីភ្នំពេញ។ ស្ត្រីជាប់ចោទត្រូវបានសមត្ថកិច្ចចាប់ខ្លួននៅថ្ងៃទី ១៩ កក្កដា ឆ្នាំ ២០១៧ ជាមួយនឹងក្មេងស្រីមិនទាន់គ្រប់អាយុ ៣ នាក់ និងស្ត្រីពេញវ័យម្នាក់។ តាមកំណត់ហេតុដដែល ការបង្ក្រាបនេះសមត្ថកិច្ចបានរកឃើញស្រោមអនាម័យប្រើរួច និងមិនទាន់ប្រើបានមួយចំនួន និងរំដោះក្មេងស្រីអាយុ ១៥ ឆ្នាំ, ១៦ ឆ្នាំ, ១៧ ឆ្នាំ និងនារីអាយុ ២១ ឆ្នាំម្នាក់។ កាលពីថ្ងៃឃាត់ខ្លួនពួកគេទាំង ៤ នាក់ បានឆ្លើយប្រាប់សមត្ថកិច្ចស្រដៀងគ្នាថា ពួកគេពិតជាបានរួមភេទជាមួយភ្ញៀវមែនដោយម្តងៗយកកម្រៃពីភ្ញៀវម្នាក់ ៣០ ដុល្លារ ប៉ុន្តែបានដក់ឱ្យស្ត្រីម្ចាស់ហាង ៥ ដុល្លារ។

សំណុំរឿងនេះត្រូវសាលាដំបូងរាជធានីភ្នំពេញប្រកាសសាលក្រមនៅថ្ងៃទី ២២ មិថុនា ឆ្នាំ ២០១៨ ផ្តន្ទាទោសស្ត្រីជាប់ចោទ ៧ ឆ្នាំ ដោយចោទបទសញ្ជារកម្មមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២៨៤,២៨៨ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែដោយមិនសុខចិត្តនឹងសាលក្រមនេះស្ត្រីជាប់ចោទបានប្តឹងឧទ្ធរណ៍តែត្រូវឧទ្ធរណ៍ប្រកាសសាលដីកានៅថ្ងៃទី ១២ សីហា ឆ្នាំ ២០២០ ដោយតម្កល់ទោស ៧ ឆ្នាំដដែល។ ក្រោយមកស្ត្រីជាប់ចោទបានប្តឹងសារទុក្ខទៅតុលាការកំពូលទៀត។

យ៉ាងណាក្តី ក្រោយជំនុំជម្រះ លោកចៅក្រម ឃឹម ប៉ុណ្ណ ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការកំពូលបានថ្លែងថាសាកដីកានៃសំណុំរឿងនេះនឹងប្រកាសថ្ងៃទី ១ កុម្ភៈ ខាងមុខនេះ៕

## មន្ត្រីសង់ត្រាល់៖ ពលករខ្មែរដែលរងគ្រោះដោយបាក់ស្ពានអាកាសនៅថៃកំពុងត្រូវបានយកចិត្តទុកដាក់

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 25/01/2021 - 08:10 ដោយ៖ អ៊ឹង ប៊ុនថន

មន្ត្រីអង្គការសង់ត្រាល់ប្រចាំប្រទេសថៃបានឲ្យដឹងថា ករណីពលករខ្មែរចំនួន៧ នាក់ នៅក្នុងចំណោមជនរងគ្រោះសរុប៩ នាក់ដែលបានរងរបួសយ៉ាងធ្ងន់ធ្ងរ ដោយសារតែការបាក់ស្ពានអាកាសកំពុងសាងសង់នៅខេត្តនគររាជសីមានោះ គឺត្រូវបានអ្នកទទួលខុសត្រូវយកចិត្តទុកដាក់។ តែនៅមិនទាន់ដឹងថា ក្រុមហ៊ុនម៉ៅការរបស់ថៃដែលជាម្ចាស់គម្រោងស្ពានអាកាសជិត១៥គីឡូម៉ែត្រនេះផ្តល់សំណងប៉ុន្មាននៅឡើយ។

លោក លឹង សុផុន មន្ត្រីគម្រោងនៃអង្គការសង់ត្រាល់ ប្រចាំប្រទេសថៃ ប្រាប់វិទ្យុបារាំងអន្តរជាតិRFI នៅព្រឹកថ្ងៃចន្ទនេះថា ក្រោយពីជួបឧបទ្ទហេតុបាក់ស្ពានអាកាស ដែលកំពុងសាងសង់ក្នុងស្រុកមឿង ខេត្តនគររាជសីមានោះ ខាងក្រសួងសាធារការរបស់ថៃ ដាក់កំហិតឲ្យក្រុមហ៊ុនម៉ៅការសំណង់ជាអ្នកទទួលខុសត្រូវទាំងស្រុងលើជនរងគ្រោះ។ នៅក្នុងដំណាក់កាលសង្គ្រោះបឋមនេះ ជនរងគ្រោះទាំងអស់ចំនួន៩ គឺខ្មែរ៧នាក់

ភូមា ១នាក់ និងថៃ១នាក់ ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ខណៈជនរងគ្រោះខ្លះបាក់ដៃ និងបាក់ជើង ដោយសារតែជន្ទល់សំណង់បានបាក់ស្រុតនៅពេលកំពុងចាក់បេតុង។ បើតាមមន្ត្រីសង្គមស៊ីវិលរូបនេះ ករណីបាក់ស្ពានអាកាសនេះ គឺជាគ្រោះថ្នាក់ការងារ ដែលតាមច្បាប់របស់ថៃ គឺថៅកែម៉ៅការសំណង់ជាអ្នកទទួលខុសត្រូវ ទាំងថ្លៃព្យាបាល ការធានារ៉ាប់រងចាយវាយអំឡុងពេលព្យាបាល និងប្រាក់សំណងការខូចខាត។ ប៉ុន្តែនៅពេលនេះ លោកថា ក្រុមហ៊ុនម៉ៅការសំណង់នោះមិនទាន់ផ្តល់សំណងការខូចខាតលើជនរងគ្រោះនៅឡើយ ខណៈដែលមន្ត្រីទូតកម្ពុជាប្រចាំប្រទេសថៃកំពុងទៅជួបជនរងគ្រោះនៅមន្ទីរពេទ្យ។

យោងតាមកាសែតបាងកកប៉ុស្ដិ៍ ការបាក់សំណង់ស្ពានអាកាសនៅប្រទេសថៃនេះ បានកើតឡើងនៅថ្ងៃទី២៣មករា២០២១។ គឺជាផ្នែកមួយនៃគម្រោងផ្លូវក្រវ៉ាត់ក្រុងប្រវែង ១៤,៥ គីឡូម៉ែត្រនៅភាគខាងជើងនៃទីប្រជុំជនស្រុកមឿង ខេត្តនគររាជសីមា។ សំណង់នេះត្រូវបានសាងសង់ក្រោមការត្រួតពិនិត្យរបស់នាយកដ្ឋានផ្លូវល្បឿនលឿនដោយមានថវិកាចំនួន ១,៤ ពាន់លានបាត។ ឧបទ្ទវហេតុនេះបានធ្វើឲ្យកម្មករចំណាកស្រុកចំនួន ៩នាក់ រងរបួស គឺមកពីកម្ពុជា៧នាក់ មីយ៉ាន់ម៉ាម្នាក់និងថៃម្នាក់ ហើយត្រូវបានបញ្ជូនទៅព្យាបាលនៅទីក្រុងបាងកក។ ការបាក់រលំសំណង់មួយនេះ ត្រូវបានគេបន្ទោសទៅលើកំហុសបច្ចេកទេស ដែលប្រើជើងទម្រមិនអាចទ្រនឹងទំងន់នៃបេតុងដែលកំពុងចាក់៕

## ស្ថានទូតខ្មែរ ប្រចាំប្រទេសថៃ បញ្ជាក់ថា មានពលករខ្មែរ៧នាក់ រងរបួស ក្នុងករណីបាក់ស្រុតស្ពាន អាកាស នៅខេត្តនគររាជសីមា

https://dap-news.com/national/ ByPH104 Posted on January 25, 2021

ភ្នំពេញ៖ស្ថានទូតខ្មែរប្រចាំប្រទេសថៃបានឲ្យដឹងថាមានក្នុងករណីបាក់ស្រុតស្ពានអាកាស នៅខេត្តនគររាជសីមា មានពលករខ្មែរ៧នាក់ រងគ្រោះតែមិនដល់ថ្នាក់បាត់បង់ជីវិតទេ ហើយកំពុងទទួលបានការព្យាបាល ។

នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ តំណាងស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសថៃ បានចុះមកមន្ទីរពេទ្យមហារាជ និងការដ្ឋានសាងសង់ផ្លូវ នៅខេត្តនគររាជសីមា ដើម្បីសួរសុខទុក្ខបងប្អូនពលករខ្មែរចំនួន៧រូប ប្រុស៤នាក់ និងស្រី៣នាក់ ដែលបានជួបគ្រោះថ្នាក់ស្ពានអាកាស បាក់ស្រុត ចុះខណៈកំពុងសាងសង់ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៤៖១៨នាទី ស្ថិតនៅបរិវេណផ្លូវសុរៈណារ៉ាយ ឃុំឃោកស៊ូង ស្រុកមឿងនគររាជសីមា ខេត្តនគររាជសីមា ប្រទេសថៃ ។

បញ្ជាក់គ្រោះថ្នាក់ខាងលើ មិនមែនករណីរងគ្រោះ ដល់ស្លាប់បាត់បង់ជីវិតនោះទេ ។ បច្ចុប្បន្នពលករ៣នាក់ បានចេញពីមន្ទីរពេទ្យហើយ ចំណែកពលករ៤នាក់ ទៀត កំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យ ក្នុងនោះ ១នាក់ ជាស្ត្រី រងរបួសបាក់ជើងស្តាំ ១នាក់ទៀត នឹងចេញពីមន្ទីរពេទ្យប៉ុន្មាន ថ្ងៃខាងមុខទៀត និងពលករ២នាក់ទៀត នឹងចេញពីមន្ទីរពេទ្យ នាល្ងាចថ្ងៃនេះ ។ ការចំណាយលើការព្យាបាល នៅមន្ទីរពេទ្យរបស់ពលករខ្មែរទាំងអស់ គឺខាងនិយោជក និងធានារ៉ាប់រងសង្គម ជាអ្នកទទួលខុសត្រូវ ចំណែកពលករ ដែលកំពុងសម្រាកព្យាបាល និងមិនអាចទាន់ចូលធ្វើការវិញបាន នឹងទទួលបានប្រាក់ឈ្នួល ទៅតាមច្បាប់ ។ ជាមួយគ្នានេះផងដែរ តំណាងស្ថានទូតបានពាំនាំថវិកា និងគ្រឿងឧបភោគបរិភោគមួយចំនួន ជូនដល់ប្អូនប្អូនពលករ ដែលកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យ និងសម្រាកនៅកន្លែងស្នាក់នៅ របស់ពួកគាត់ព្រមទាំងផ្តាំផ្ញើការសួរសុខទុក្ខ ពីរាជរដ្ឋាភិបាលកម្ពុជា ដែលមានការព្រួយបារម្ភ ពីសុខទុក្ខរបស់បងប្អូន ពលករខ្មែរផងដែរ៕

## ថ្ងៃទី២៧ ខែ មករា ឆ្នាំ២០២១

## កិច្ចប្រជុំត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 26-01-2021

នៅរសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំប្រចាំខែមករា ឆ្នាំ២០២១ ក្រោមកិច្ចដឹកនាំរបស់ លោកជំទាវ យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប ព្រមទាំងមានការអញ្ជើញចូលរួមពីលោក លោកស្រី សមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ ពីមន្ទីរអង្គភាពពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធ សរុប៥៥ នាក់ ស្រី៣៤នាក់ ។ កិច្ចប្រជុំនេះ ទទួលបានការគាំទ្រពីរដ្ឋបាលសាខេត្ត និងអង្គកាបន្ទាយស្រី។

នៅក្នុងកិច្ចប្រជុំនេះផងដែរ ក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នាសម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬការរំលោភបំពានផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ដោយកិច្ចប្រជុំបានធ្វើការពិនិត្យពិភាក្សា និងត្រួតពិនិត្យលើបញ្ហាប្រឈម និងទិសដៅ ដែលបានដាក់ចេញកាលពីកិច្ចប្រជុំប្រចាំឆ្នាំ ២០២០ និងពិនិត្យលើរបាយការណ៍ប្រចាំខែមករា ឆ្នាំ២០២១ នៃសកម្មភាពរបស់លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ក្រុមការងារបច្ចេកទេសទាំង៦ (ក្រុមការងារបង្ការទប់ស្កាត់ ក្រុមការងារការពារជនរងគ្រោះ ក្រុមការងារកិច្ចការអនុវត្តច្បាប់ ក្រុមការងារកិច្ចការយុត្តិធម៌ ក្រុមការងារកិច្ចសហប្រតិបត្តិការ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍) រដ្ឋបាលក្រុង ស្រុក និងអង្គការដៃគូជាតិ អន្តរជាតិ ដើម្បីពិភាក្សារកដំណោះស្រាយលើបញ្ហាក្នុងពេលអនុវត្តការងារ ដែលអង្គប្រជុំបានលើកឡើង។

ក្រោយពីការលើកឡើងអំពីបញ្ហាប្រឈម និងការពិភាក្សារកដំណោះស្រាយ នៅក្នុងអង្គប្រជុំ លោកជំទាវ យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានផ្តល់ជាអនុសាសន៍សម្រាប់អនុវត្តបន្ត ផងដែរ។

## ចំណាយថវិកា ៤០ លានរៀល ក្នុង១ថ្ងៃ លើមណ្ឌលចត្តាឡីស័ក ១៥ ទីតាំង

https://www.rasmeinews.com/ 26 January, 20210

**ដោយៈ អូរស្មាច់ / ឧត្តរមានជ័យៈ** *អភិបាលខេត្តឧត្តរមានជ័យ លោក ប៉ែន កុសល្យ បានបញ្ជាក់ពីការចំណាយថវិកា ក្នុងមួយថ្ងៃៗ អស់ចំនួន ៤០ លានរៀល លើមណ្ឌលធ្វើចត្តាឡីស័ក ចំនួន ១៥ ទីតាំង នៅក្នុងខេត្តឧត្តរមានជ័យ ក្នុងការផ្គត់ផ្គង់ អាហារហូបចុក ប្រចាំថ្ងៃ ដល់ពលករកម្ពុជា វិលត្រឡប់ពីស្រុកថៃ ដែលកំពុងស្នាក់នៅ ក្នុងអំឡុងពេលបរិបទកូវីដ-១៩ នេះ។* លោក ប៉ែន កុសល្យ បានបន្តថាៈ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា បានខិតខំយកទុកដាក់ខ្ពស់ ចំពោះពលករខ្មែរគ្រប់រូប ដែលបានធ្វើដំណើរឆ្លងដែន មកពីប្រទេសថៃ ចូលមកកម្ពុជាតាមច្រកព្រំដែនសំខាន់ៗ ក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ ក្នុងអំឡុងពេល បរិបទជំងឺកូវីដ ១៩នេះ ដោយតម្រូវឲ្យពលករ ទាំងអស់ ត្រូវស្នាក់នៅធ្វើចត្តាឡីស័ក ចំនួន ១៤ ថ្ងៃ ដើម្បីកមេរោគកូវីដ-១៩ នៅពេលប្រទេសថៃ កំពុងតែផ្ទុះជំងឺនេះ ចូលដល់ក្នុងសហគមន៍ ហើយក៏ជាបញ្ហាប្រឈមមួយ យ៉ាងខ្លាំងចំពោះ បងប្អូនពលករខ្មែរ ដែលបានធ្វើការនៅឯប្រទេសថៃ មានការបារម្ភ និងភ័យខ្លាចបំផុតនោះ។ លោកបានបន្ថែមថាៈ ក្នុងកាលៈទេសៈបែបនេះ រាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរខេត្ត ដែលជាសេនាធិការ ថ្នាក់ក្រោមជាតិ ក៏កំពុងតែបានយកចិត្តទុកដាក់ខ្ពស់ដែរ ក្នុង

ការមើលថែសុខភាព ដល់ពលករខ្មែរគ្រប់រូប ដែលកំពុងធ្វើចត្តាឡីស័ក ស្នាក់នៅរយៈពេល ១៤ ថ្ងៃ ត្រូវផ្គត់ផ្គង់ជាសម្ភារប្រើប្រាស់ និងការហូបចុកអាហារ ជូនដល់ពួកគាត់ បានគ្រប់គ្រាន់ប្រចាំថ្ងៃ។

លោក ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាល ខេត្តឧត្តរមានជ័យ បានឱ្យដឹងថាៈ ពលករខ្មែរ ឆ្លងមកពីថៃ ចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ មកដល់ពេលនេះ មានចំនួនប្រមាណជាង ២.០០០ នាក់ បានចូលធ្វើចត្តាឡីស័ក រយៈពេល ១៤ ថ្ងៃ តាមការណែនាំរបស់ក្រសួងសុខាភិបាល តាមមណ្ឌលវិទ្យាល័យ ដែលបានត្រៀមទុក តាមស្រុក ក្រុង ក្នុងខេត្ត។ បច្ចុប្បន្ន ចំនួនភាគច្រើន បានធ្វើចត្តាឡីស័ក គ្រប់ចំនួនថ្ងៃ បានចេញជាបន្តបន្ទាប់៕

## លោកជំទាវនាយឧត្តមសេនីយ៍ យក់ សុខា ៖ ដើម្បីមានសមត្ថភាពជំនាញយកទៅបំរើអង្គភាព និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពលើការកំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវអនុវត្តចំពោះអនីតិជនទំនាស់និងច្បាប់ និងយល់ឲ្យច្បាស់នូវពាក្យ កុមារទំនាស់និងច្បាប់

http://cambodiapolice.com/policekh/ 4:15 pm 26 មករា 2021

រាជធានីភ្នំពេញ ៖ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានលើកឡើងថា ដើម្បីឲ្យសិក្ខាកាមមានសមត្ថភាពជំនាញយកទៅបំរើអង្គភាព និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព លើការកំណត់អត្តសញ្ញាណជនរងគ្រោះត្រូវអនុវត្តចំពោះអនីតិជនទំនាស់និងច្បាប់និងយល់ឲ្យច្បាស់នូវពាក្យកុមារទំនាស់ និងច្បាប់។ ការលើកឡើងរបស់លោកជំទាវ អគ្គស្នងការរងនគរបាលជាតិ ក្នុងឱកាសដែល លោកជំទាវអញ្ជើញជាអធិបតី បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងការឆ្លើយតបបែបកុមារមេត្រីក្នុងនីតិវិធីស៊ើបអង្កេត នាព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។

ពិធីនេះក៏មានការអញ្ជើញចូលរួមពី ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន លោក សំលៀង សីលា នាយកប្រតិបត្តិអង្គការ អេផល (APLE) លោក-លោកស្រី អនុប្រធាននាយកដ្ឋាន និងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀតផងដែរ ។

លោកជំទាវ នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ បានមានប្រសាសន៍ទៀតថា «បើទោះបីជាមានការចូលរួមយ៉ាងសកម្មពីស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ក្នុងការបង្ការទប់ស្កាត់ និងមានការបង្ក្រាបជាបន្តបន្ទាប់ពីកងកម្លាំងសមត្ថកិច្ច និងស្ថិតក្នុងស្ថានភាពវិបត្តិកូវីដ-១៩យ៉ាងណាក្តី ក៏ស្ថានភាពបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ មិនបានបញ្ឈប់ទេ ផ្ទុយទៅវិញនៅកម្ពុជាស្ត្រីរងគ្រោះដែលត្រូវបានជួញដូរនៅក្រៅប្រទេស និងពលករចំណាកស្រុកខុសច្បាប់ ដែលបានជួយសង្គ្រោះត្រលប់មកកម្ពុជាវិញ ក៏នៅមានការកើនឡើងជារៀងរាល់ថ្ងៃនៅឡើយ»។ ក្នុងឱកាសនោះដែរ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា បានមានប្រសាសន៍ថា ក្នុងនាមឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងក្នុងនាមលោកជំទាវផ្ទាល់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ អេផល (APLE) ដែលមានលោក សំលៀង សីលា នាយកប្រតិបត្តិអង្គការ អេផល (APLE) និងបុគ្គលិករបស់អង្គការ អេផល (APLE) ដែលបានសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ជាពិសេសនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន លើការងារពង្រឹងសមត្ថភាពដល់កងកម្លាំងនគរបាលជាតិ ដែលជាក់ស្តែងទាំងកិច្ចសហប្រតិបត្តិការរបស់អង្គការ អេផល (APLE) ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ គឺមិនមែនមានតែថ្ងៃនេះ ឬឆ្នាំនេះទេ គឺមានយូរឆ្នាំមកហើយ និងមិនមែនលើការពង្រឹងសមត្ថភាពនេះដែរ គឺអង្គការបានសហការលើការផ្តល់ព័ត៌មាន ក្នុងករណីបទល្មើស

ជាច្រើនកន្លងមក បានទទួលនូវជោគជ័យ ក្នុងការបង្ក្រាបបទល្មើសទាន់ពេលវេលាជាបន្តបន្ទាប់ និងធ្លាប់បាន MOU ជាមួយគ្នាផង។

ក្នុងឱកាសនោះដែរ លោក សំលៀង សីលា នាយកប្រតិបត្តិអង្គការ អេផល (APLE) បានមានប្រសាសន៍ថា ក្រោមជំនួយឧបត្ថម្ភរបស់រដ្ឋាភិបាលហូឡង់ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គការសកម្មភាពដើម្បីកុមារ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ នៃអំពើជួញដូរមនុស្ស និងការឆ្លើយតបបែបកុមារមេត្រីក្នុងនីតិវិធីស៊ើបអង្កេតរបស់នគរបាល ជូនដល់មន្ត្រីនគរបាលរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន វគ្គបណ្តុះបណ្តាលនេះមានគោលបំណងដូចជា ៖

១-បង្កើនចំណេះដឹង និងជំនាញពាក់ព័ន្ធកំណត់អត្តសញ្ញាណជនរងគ្រោះ ការអនុវត្តនីតិវិធី ដែលមានចែងក្នុងច្បាប់ ស្តីពីច្បាប់យុត្តិធម៌អនីតិជន និងបច្ចេកទេសម្ភាសន៍បែបកុមារមេត្រី ។

២-ចែករំលែកព័ត៌មានបច្ចុប្បន្នភាពអំពីស្ថានភាព និន្នាការ នៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ ។

៣-ផ្លាស់ប្តូរបទពិសោធន៍ វិធីសាស្ត្រ ការអនុវត្តល្អៗក្នុងការដោះស្រាយបញ្ហាប្រឈម។

គួរបញ្ជាក់ផងដែរថា វគ្គបណ្តុះបណ្តាលនេះ មានរយៈពេល០៣ថ្ងៃ ចាប់ពីថ្ងៃទី២៦ ខែមករា ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ និងមានសិក្ខាកាមចូលរួមសរុបចំនួន៣០នាក់ ៕

## ជម្រុញដល់មន្ត្រីជំនាញទាំងអស់ត្រូវបង្កើនកិច្ចការងារទប់ស្កាត់អំពើហិង្សា ការជួញដូរស្ត្រី និងកុមារ ការជួញដូរគ្រឿងញៀន និងការពារជំងឺកូវីដ ១៩

https://grandnewsasia.com/ 26-01-2021

កំពង់ឆ្នាំង៖ លោកស្រី តុង ណារី សមាជិកក្រុមប្រឹក្សាខេត្ត និងជាប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខេត្តកំពង់ឆ្នាំង បានជំរុញដល់សមាជិក សមាជិកា របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ត្រូវសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងមន្ទីរ អង្គភាពពាក់ព័ន្ធក្នុងការផ្សព្វផ្សាយប្រយុទ្ធប្រឆាំងទប់ស្កាត់ និងការពារជំងឺកូវីដ១៩ ដែលជាកិច្ចការចំពោះមុខរបស់យើងទាំងអស់គ្នា និងការចូលរួមទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ, ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ, ការកេងប្រវ៉ាញ់កំលាំងពលកម្មលើកុមារ, ការជួញដូរគ្រឿងញៀន និងចូលរួមរក្សាស្ថេរភាពជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានទទួលខុសត្រូវរបស់ខ្លួន និងផ្សព្វផ្សាយអោយប្រជាពលរដ្ឋចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នាផងដែរ។ លោកស្រីបានជំរុញបែបនេះនៅព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ នៅសាលប្រជុំ "គ" សាលាខេត្តកំពង់ឆ្នាំង ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំ ខែមករា និងលើកទិសដៅការងារអនុវត្តបន្តសម្រាប់ខែបន្ទាប់ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ដោយមានការចូលរួមពី សមាជិក សមាជិកា និងមន្ទីរអង្គភាព អង្គការដៃគូពាក់ព័ន្ធក្នុងខេត្តចូលរួមផងដែរ។

ក្នុងឱកាសនោះដែរលោកស្រី តុង ណារី ក៏បានណែនាំដល់សមាជិកក្រុមការងារ សូមធ្វើការតាមដានសភាពការណ៍ របស់បងប្អូនប្រជាពលរដ្ឋដែលបានមកពីបណ្តាប្រទេសនានាដែលកំពុងតែមានជំងឺកូវីដ១៩ តាមរយៈការសហការ ជាមួយលោកមេឃុំ ចៅសង្កាត់ អាជ្ញាធរក្រុង ស្រុក ដើម្បីត្រួតពិនិត្យពី សុខភាពរបស់ពលរដ្ឋ និងបន្តអប់រំប្រជាពលរដ្ឋ ឱ្យគាត់យល់ដឹងពីសុខភាព និងថែរក្សាសុខភាពដើម្បីកុំឱ្យមានឆ្លងជំងឺកូវីដ១៩ ចូលរួមផ្សព្វផ្សាយពីការការពារនៃជំងឺផ្សេងៗដែលកើតមានលើសត្វបក្សី និង៣ហនៈ ៕

## អាជ្ញាធរខេត្តត្បូងឃ្មុំពង្រឹងសមត្ថភាពទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រីនិងកុមារ

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ វិទ្យុជាតិកម្ពុជា៖ ខេត្តត្បូងឃ្មុំ

MC៖ អាជ្ញាធរខេត្តត្បូងឃ្មុំពង្រឹងសមត្ថភាពទប់ស្កាត់ការ រំលោភបំពាន និងកេង ប្រវ័ញ្ចផ្លូវភេទលើស្ត្រីនិងកុមារ ដើម្បីជានាសុវត្ថិភាពនិងឧត្តមប្រ យោជន៍របស់ស្ត្រីនិងកុមារ ។ ក្នុងកិច្ចប្រជុំសាមញ្ញលើកទី ១៦ អាណត្តិទី៣ នៅព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ លោកស្រី ខៀវ សាមួន ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ ខេត្តត្បូងឃ្មុំ បានមានប្រសាសន៍ថា កិច្ចប្រជុំគឺដើម្បីធ្វើការពិនិត្យ អនុម័ត និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ ទិសដៅបន្ត របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ (គ ក ស ក) ដើម្បីលើកកម្ពស់ការយល់ដឹង និងការប្រើប្រាស់បទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ដែលមាន ស្រាប់ សំដៅការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ របស់ខេត្តត្បូងឃ្មុំ ដែលអនុវត្តនាពេលកន្លងមក។

លោកស្រី មានប្រសាសន៍បន្តថា កិច្ចប្រជុំនាពេលនេះ ពិត ជាមានសារៈសំខាន់ចំពោះ ការសិក្សាលើភាពខ្វះចន្លោះនៃច្បាប់ និងការអនុវត្ត បញ្ហាប្រឈមដែលរាំងស្ទះដល់ប្រសិទ្ធភាព នៃការអនុវត្ត និងការតាក់តែងនូវឯកសារសម្រាប់កិច្ចប្រជុំ ពិសេសគឺធ្វើឡើងដើម្បីស្វែងរកនូវចំនុចខ្វះខាត ដោយសមាជិកដែលចូលរួមទាំងអស់ អាចលើកឡើងក្នុងអង្គប្រជុំ ធ្វើយ៉ាងណាកែលម្អអោយកាន់តែប្រសើរឡើង សម្រាប់ទុកជាឯកសារដ៏ល្អទាំងអក្ខរាវិរុទ្ធ ឃ្លោងឃ្លា និងខ្លឹមសារពោរពេញដោយអត្ថន័យ។ លោកស្រី ខៀវ សាមួន បានកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះអ្នកពាក់ព័ន្ធទាំង អស់ ដែលខិតខំបំពេញការ ងារនាពេលកន្លងមក ពិសេសឯកឧត្តម លោកជំទាវ ក្នុងជួរគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ ដែលបានជួយជំរុញអោយការងារស្ត្រី ដោយកំណត់រកដំណោះស្រាយជាយុទ្ធសាស្ត្រ និងឱកាសនៃកិច្ច សហការរវាងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការឆ្លើយតប និងអន្តរាគមន៍ របស់ខេត្តត្បូងឃ្មុំ សម្រេចបានលទ្ធផលយ៉ាងល្អប្រសើរ ។

សូមជម្រាបថា ក្នុងកិច្ចប្រជុំបានលើកឡើងនូវរបៀបវារៈចំនួន០៣ ដើម្បីពិនិត្យ និងអនុម័ត រួមមាន ១.ពិនិត្យនិងអនុម័តលើសេចក្តីព្រាងកំណត់ហេតុ នៃកិច្ចប្រជុំសាមញ្ញលើកទី ១៤ អាណត្តិទី៣ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ២.ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយ ការណ៍ខែមករា ឆ្នាំ ២០២១ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារខេត្ត ៣.បញ្ហាផ្សេងៗ សេចក្តីជូនដំណឹងពីរបៀបវារៈកាលបរិច្ឆេទ និងទីកន្លែងសម្រាប់កិច្ចប្រជុំសាមញ្ញលើកទី១៧ របស់គណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារខេត្ត ៕

## ពលករកម្ពុជានៅថៃប្រឈមហានិភ័យកូវីដនិងចំណូលធ្លាក់ចុះ

https://khmer.voanews.com/ 26 មករា 2021

ភ្នំពេញ៖ នៅថ្ងៃអង្គារនេះ លោក ជឹម ចេង ដែលកំពុងបម្រើការងារនៅរោងចក្រផលិតសាច់នៅខេត្តសារបុរី (Saraburi) ប្រទេសថៃជាងបីឆ្នាំហើយនោះ សុំច្បាប់ថៅកែរោងចក្ររបស់លោកសម្រាកមួយព្រឹក ដើម្បីសម្អាតបន្ទប់ស្នាក់នៅ និងឆ្លៀតជិះកង់ទៅផ្ញើលុយជូនម្តាយនៅកម្ពុជា។ លោក ជឹម ចេង ផ្ញើប្រាក់ប្រមាណ ៦ពាន់បាត (ឬ ៨០ម៉ឺនរៀល) ក្នុងមួយខែ ជូនម្តាយដែលរស់នៅស្រុកភ្នំព្រឹកខេត្តបាត់ដំបង ឲ្យផ្គត់ផ្គង់ចិញ្ចឹមកូនប្រុសលោកមានអាយុ ៣ឆ្នាំ។ បុរសវ័យ ២៦ឆ្នាំ រូបនេះលើកឡើងថា ស្ថានភាពនៃការឆ្លងរាលដាលក្នុងសហគមន៍នៃជំងឺកូវីដ១៩ ក្នុងប្រទេសថៃ បានបង្ខំឲ្យពលករខ្មែរដែលរស់នៅតំបន់ដែលលោកធ្វើការ ចាកចេញទៅស្រុកកំណើតវិញអស់សឹង

តែពាក់កណ្ដាល ហើយរោងចក្រខ្លះក៏ត្រូវបង្ខំបិទទ្វារ។ តែរូបលោកនិងភរិយាដែលមានវ័យ ២៣ឆ្នាំ ទ្រាំបន្តរស់នៅធ្វើការនៅប្រទេសថៃ ដោយសារចង់បន្តរកចំណូល។ លោក ជឹម ចេង ថ្លែងប្រាប់វីអូអេតាមទូរសព្ទថា៖ «អារម្មណ៍ចង់ទៅផ្ទះនឹងគេដែរតែគិតទៅ យើងទៅផ្ទះយើងអត់ការងារធ្វើដូចខ្ញុំនិយាយខាងដើមអីចឹង។ ឃើញគេទៅអារម្មណ៍យើងចង់ទៅដែរនឹកកូន នឹកម៉ែ នឹកប៉ាដែរបង»។ ពលករកម្ពុជាដែលបន្តរស់នៅក្នុងប្រទេសថៃ ដូចជាលោក ជឹម ចេង និងភរិយា ត្រូវប្រឈមនឹងសម្ពាធសេដ្ឋកិច្ចនិងក្ដីបារម្ភអំពីហានិភ័យសុខភាព ខណៈប្រទេសថៃកំពុងប្រឈមនឹងការផ្ទុះឆ្លងជំងឺកូវីដ១៩ ទ្រង់ទ្រាយធំក្នុងសហគមន៍ ដែលរាតត្បាតខ្លាំងពីពាក់កណ្ដាលខែធ្នូមក។

ពេញមួយថ្ងៃអង្គារនេះ ប្រទេសថៃប្រកាសអំពីករណីឆ្លងថ្មី ៩០០ករណី ក្នុងចំណោមករណីឆ្លងសរុប ១៤.៦៤៦ករណី និងស្លាប់យ៉ាងហោច ៧៥នាក់។ ខេត្តចំនួនប្រាំនៅថៃ គឺសមុទ្រសាខន(Samut Sakhon) រយ៉ង់ (Rayong) ជុនបុរី (Chonburi) ចន្ទបុរី (Chanthaburi) និងត្រាត (Trat) ត្រូវបានរឹតបន្តឹងក្នុងការធ្វើដំណើរ។

ស្ថិតិដែលផ្ដល់ដោយលោកឧត្តមសេនីយ៍ឯក កែវ វណ្ណថន អគ្គនាយករងអន្តោប្រវេសន៍ក្រសួងមហាផ្ទៃកម្ពុជា បង្ហាញថា ចាប់ពីថ្ងៃទី២០ ខែធ្នូមក ដល់ថ្ងៃទី២៥ ខែមករានេះ មានពលរដ្ឋកម្ពុជាប្រមាណ ៨.០៣១នាក់ហើយដែលបានឆ្លងព្រំដែនវិលត្រឡប់ពីប្រទេសថៃមកដល់កម្ពុជាវិញ។

ការភ័យខ្លាចជំងឺកូវីដ១៩ និងវិធានការរឹតបន្តឹងលិខិតស្នាមរបស់ថៃនាពេលកន្លងមក បានធ្វើឱ្យពលករខ្មែរជាច្រើនចាកចេញមកប្រទេសខ្លួនវិញ។ នេះបើយោងតាមលោក សឿម ប៊ុនរិទ្ធ អភិបាលរងខេត្តបាត់ដំបង។ មន្ត្រីជាន់ខ្ពស់ខេត្តជាប់ព្រំដែនថៃរូបនេះប្រាប់វីអូអេថា៖ «ខ្ញុំបានសួរនាំគាត់ហើយ ទី១គាត់ថា គាត់នឹកផ្ទះសម្បែង ទី២គាត់មានធុរៈក្នុងគ្រួសារ ដូចថាឪពុកម្ដាយឈឺ ឬគាត់នឹកកូនចៅគាត់ ហើយអ្នកខ្លះគាត់ថា មករៀបការញាតិមិត្ត។ ហើយអ្នកខ្លះទៀតគាត់ថា អត់មានការងារធ្វើនៅហ្នឹង ដល់ពេលមានបញ្ហាកូវីដស្រុកគេអត់ការងារធ្វើ មិនដឹងនៅធ្វើអីត្រូវតែមក»។

លោក លឹង សុផុន មន្ត្រីអង្គការសង់ត្រាល់បានឱ្យដឹងថា ពលករខ្មែរដែលនៅថៃរងការលំបាកលើការចំណាយបន្ថែមជាច្រើន ដើម្បីបន្តការស្នាក់នៅរួមមានទាំងការពន្យារសុពលភាពលិខិតឆ្លងដែន និងទិដ្ឋាការការចំណាយលើការពិនិត្យកូវីដ មុនចូលធ្វើការកន្លែងថ្មីជាដើម ប្រសិនករណីរោងចក្រពួកគេកាត់បុគ្គលិកនិងប្ដូរទៅរោងចក្រផ្សេង។ មន្ត្រីសង្គមស៊ីវិលដែលប្រចាំការនៅប្រទេសថៃរូបនេះថ្លែងថា ការណ៍ទាំងនោះជំរុញឲ្យពលករជ្រើសរើសមកស្រុកវិញ។ «មួយទៀតពលករដែលមិនស្របច្បាប់ថៅកែអត់ទទួលខុសត្រូវទេ។ អាជ្ញាធរខ្លះប៉ូលិសតាមតំបន់ផ្សេងៗខ្លះ បានចុះត្រួតចុះពិនិត្យរឹតបន្តឹងនរណាដាច់ប៉ាស្ព័រអី គេចាប់ផាកពិន័យ។ ដោយសារអាជ្ញាធរថៃរឹតបន្តឹងអញ្ចឹង បានធ្វើឲ្យប្រជាពលរដ្ឋរាប់ពាន់រយនាក់ចុះមកប្រទេសកំណើតវិញ»។ គិតត្រឹមព្រឹកថ្ងៃអង្គារនេះ ក្នុងចំណោមពលករកម្ពុជាទាំងជាង ៨ពាន់នាក់ ដែលទើបធ្វើមាតុភូមិនិវត្តន៍ជាបន្តបន្ទាប់នោះ មាន ៨៧នាក់ ត្រូវបានរកឃើញថាមានផ្ទុកវីរុសកូវីដ១៩។

ពលករខ្មែរដែលកំពុងបន្តធ្វើការនៅប្រទេសថៃបានប្រាប់វីអូអេថា ពួកគេបារម្ភអំពីបញ្ហាជីវភាព ដោយសារតែស្ថានភាពសេដ្ឋកិច្ចថៃមិនល្អនៅទីនោះ និងបរិមាណការងារធ្លាក់ចុះខ្លាំង។ អ្នកស្រី សុខ ស៊ីណាត អាយុ ៣២ឆ្នាំបច្ចុប្បន្នរស់នៅ និងធ្វើការនៅរោងចក្រផលិតទឹកម្នាស់ប្រអប់នៅខេត្តរយ៉ង ស្ថិតក្នុងចំណោមខេត្តដែលមានការរឹតបន្តឹង។ ពលករចំណាកស្រុកទៅពីខេត្តប៉ៃលិនរូបនេះ ប្រាប់វីអូអេថា ចំណូលរបស់ស្រីធ្លាក់ចុះជិតពាក់កណ្ដាលដែលឥឡូវអ្នកស្រីរកបានតែ ៦ពាន់បាត (ឬ៨០ម៉ឺនរៀល) ក្នុងមួយខែ។ «ដោយសារគេបិទផ្អាកការងារមួយខែ ពីរខែដោយសារកូវីដអញ្ចឹងណា។ ដល់អញ្ចឹង[ពលករ] អត់នៅគាត់ទៅរកកន្លែងផ្សេង។ រោងចក្រដែលខ្ញុំនៅក៏អញ្ចឹងដែរ ដូចថាកូវីដអញ្ចឹងមួយអាទិត្យ គេឲ្យយើងធ្វើការតែ ៥ថ្ងៃ ហើយអត់មានថែមម៉ោងទេ»។ អ្នកស្រី ស៊ីណាត ដែលចង់មកស្រុកកំណើតវិញនោះស្ទាក់ស្ទើរ ព្រោះខ្លាចត្រូវបន្តធ្វើចត្តាឡីស័កច្រើនថ្ងៃ និងប្រឈមនឹងការគ្មានចំណូល

នៅក្នុងស្រុក។ «គ្រាន់តែនឹកបងប្អូនអញ្ចឹង។ ណាមួយយើងនៅនេះ យើងរកលុយដូចថា មិនបានអញ្ចឹងដូចចង់ទៅខ្មែរ។ប៉ុន្តែថាទៅច្រកគេមិនបើកយើងជិះទៅអស់លុយច្រើនទៀតមិនស្រួលទេ ៣៥០០ បាតអីនោះគ្រាន់ពីកន្លែងយើងនៅទៅច្រកព្រំដែន។ ហើយយើងចេញទៅឆ្លងខុសច្បាប់យើងខ្មែរទៅខ្មែរអស់លុយបង់លុយច្រើន អញ្ចឹងមិនបាច់ទៅគ្រាន់តែផ្ញើរលុយ»។

លោក ឆៃ លី ជាអ្នករត់ការសម្រួលកម្លាំងកម្មករទៅធ្វើការនៅតាមបណ្ដារោងចក្រនៅថៃ បានឲ្យថាពលករកម្ពុជាជាច្រើនបានចាកចេញមកស្រុកកំណើតវិញនៅថៃ សម្បូរការងារធ្វើនៅឡើយទេ គ្រាន់តែថាពលករមួយចំនួនដែលប្រឈមនឹងការជម្រុះចេញ ត្រូវសង្វាតរកការងារធ្វើទៀត។ លោក ឆៃ លី ដែលកំពុងអង្គុយចាំកម្មករពិនិត្យសុខភាពមុនចូលធ្វើការបានឲ្យដឹងថា៖ «ភាគច្រើនពលករខ្មែរយើងធ្លាក់ការងារច្រើនដែរ ដោយសាររោងចក្រមួយចំនួនជម្រុះចោលខ្លះ។ ហើយខាងខ្ញុំនេះ គឺអ្នកណាដែលអត់ការងារធ្វើហើយមានរោងចក្រណាទទួលខ្ញុំនាំពួកគាត់ចូលតាមរោងចក្រផ្សេង»។ បុរសរូបនេះថ្លែងថា ក្នុងមួយថ្ងៃៗ ពលករយ៉ាងហោចណាស់ ជាង ២០នាក់ ទាក់ទងសួរលោកជាក្រុមៗដើម្បីរកប្ដូរការងារ។ «[ពលករ]បាត់បង់ច្រើនដែរអូនចូល ៤០% ទៅ ៥០%។ ជួនគាត់អត់មានលុយនៅទៀត គាត់ទៅខ្មែរវិញ រកការងារធ្វើអត់បានទៅខ្មែរ។ អ្នកខ្លះគាត់អត់មានលុយគាត់ស៊ូគាត់ថាធ្វើការងារអីក៏បាន ឲ្យតែបានលុយ»។

លោក ជឹម ចេង ដែលចេញទៅធ្វើការនៅប្រទេសថៃតាំងពីបីឆ្នាំមុន និងក្រោយមកភរិយាលោកទៅតាមក្រោយពេលសម្រាលកូនរួចប្រមាណជិតមួយឆ្នាំ បាននិយាយថា ពួកគេមិនសម្រេចចិត្តទៅស្រុកកំណើតវិញនៅពេលនេះ ដោយសារពួកគេត្រូវបន្តសន្សំលុយ បង់សងការប្រាក់នៅធនាគារដែលពួកគេបានខ្ចីសម្រាប់ដាំដំណាំដំឡូងមី នៅក្នុងលក្ខណៈគ្រួសារ ដែលដំណាំមិនបានហុចផលល្អឲ្យគ្រួសារលោកទេ។ «គិតគូរជាមួយគ្រួសារ ក៏យកលុយអង្គការធ្វើប៉ាស្ព័រឡើងទៅរោងចក្រ CP ទៅបានកម្រៃគួរសម្យ។ ល្មមទប់ទល់ដោះស្រាយជីវភាពបានស្រួលជាងមុន»។ ទោះជាយ៉ាងណាលោក ជឹម ចេង ដែលលិខិតឆ្លងដែនលោកដែលជិតផុតសុពលភាពហើយ នៅរយៈពេលពីរខែទៀត តែត្រូវថៅកែរោងចក្រជួយសម្របសម្រួលបន្តសុពលភាពឲ្យលោក ដោយសាររោងចក្រត្រូវការកម្លាំងពលកម្ម ក្រោយការចាកចេញទៅនៃពលករជាច្រើន។ បុរសរូបនេះទន្ទឹងរង់ចាំរយៈពេលមួយឆ្នាំទៀត ទើបសម្រេចមកស្រុកកំណើតវិញ ជួបកូនប្រុសអាយុបីឆ្នាំ ដែលលោកស្គាល់មុខតែតាមការនិយាយទូរសព្ទ៕

## ពលករខ្មែរនៅតែបន្តចំណាកស្រុកទៅរកការងារធ្វើក្នុងប្រទេសថៃ ទោះបីប្រទេសទាំងពីរបន្តបិទច្រកចេញចូល និងកំពុងប្រឈមការរីករាលដាលនៃជម្ងឺកូវីដ១៩ក្តី

https://www.facebook.com/CentralCambodiaOrg 26-01-2021

ប្រទេសថៃ៖ ពលករខ្មែរនៅតែបន្តចំណាកស្រុកទៅរកការងារធ្វើក្នុងប្រទេសថៃ ទោះបីប្រទេសទាំងពីរបន្តបិទច្រកចេញចូល និងកំពុងប្រឈមការរីករាលដាលនៃជម្ងឺកូវីដ១៩ក្តី។ ជាក់ស្តែង ថ្ងៃទី 26 មករា 2021នេះ ទាហានថៃបានចាប់ពលករខ្មែរ ចំនួន 37នាក់ ដែលបានចូលមកក្នុងប្រទេសថៃតាមផ្លូវធម្មជាតិតាមច្រកព្រំដែនកម្ពុជា-ថៃ ក្នុងតំបន់ ភូមិខៅឌីន ស្រុកក្លងហាត ខេត្តស្រះកែវប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើ។ បន្ទាប់ពីបានសួរនាំពលករខ្មែរចំនួន37នាក់នោះ គឺគ្មានពលករណាម្នាក់មានឯកសារស្រប់ច្បាប់ ដើម្បីចូលមកក្នុងប្រទេសថៃទេ ហើយកងទាហានក៏បានបញ្ជូនពលករខ្មែរទាំង 37នាក់ ជូនប៉ុស្តិប៉ូលីសអន្តោប្រវេសន៍ខេត្តស្រះកែវ ដើម្បីបន្តដំណើរតាមច្បាប់នៃប្រទេសថៃ អំឡុងពេលcovid-19៕

ក្រុមការងារសង់ត្រាល់ លោក លឹង សុផុន មន្ត្រីកម្មវិធីផ្នែកទេសន្តោប្រវេសន៍ប្រចាំប្រទេសថៃបានឲ្យដឹងថា« ពួកគាត់នៅកម្ពុជាប្រឈមបញ្ហាជំពាក់បំណុល និងអត់ការងារធ្វើក្នុងស្រុក បានជាប្រថុយប្រថានចំណាកស្រុកទាំងខុសច្បាប់ ដើម្បីបានថវិកាសង់បំណុលត្រឡប់ និងដោះស្រាយជីវភាពនឹងគ្រួសារ»៕

## ថ្ងៃទី២៩ ខែ មករា ឆ្នាំ២០២១

### សម្តេចក្រឡាហោម ស ខេង: គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពថ្មី មាន ៧ ចំណុចសំខាន់ៗ

https://www.rasmeinews.com/ 27 January, 2021

**ដោយៈ មុនីរ័ត្ន / ភ្នំពេញ:** *សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថាៈ ដោយបានការអនុញ្ញាត ពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី សម្តេចបានរៀបចំកែលំអ គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពថ្មី ដោយខ្លឹមសារ ផ្អែកលើមូលដ្ឋានចាស់ និងមានអត្ថន័យ និងគ្រប់ជ្រុងជ្រោយជាង ហើយគោលនយោបាយនេះ មិនមែនរបស់ក្រសួងណាមួយទេ គឺជារបស់រាជរដ្ឋាភិបាល ដែលមកដល់ពេលនេះ សម្តេចតេជោ ហ៊ុន សែន បានចុះហត្ថលេខាហើយ បន្ទាប់ពីបានកែសម្រួល តាមស្មារតី នៃកិច្ចប្រជុំអន្តរក្រសួង ដែលបំពេញបន្ថែម ដោយមន្ត្រីជំនាញ ដែលក្នុងនោះ មានតែ ៧ ចំណុច សំខាន់ៗ ។*

សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថាៈ គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពថ្មី ដែលក្នុងនោះមានតែ ៧ ចំណុច សំខាន់ៗនោះគឺៈ ទី១. ការផ្តល់សេវាសាធារណៈ ពិសេសសេវារដ្ឋបាល , ទី២. បញ្ហាសន្តិសុខ , ទី៣. សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍ , ៤. ការដោះស្រាយវិវាទ នៅមូលដ្ឋាន ក្រៅប្រព័ន្ធតុលាការ , ទី៥. បរិស្ថាន , ទី៦. គ្រោះមហន្តរាយ និងទី៧. អំពើអនាចារ ឬការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ និងក្មេងទំនើង។ កាបញ្ជាក់របស់ សម្តេចក្រឡាហោម ស ខេង បានធ្វើឡើង នៅក្នុងជំនួបពិភាក្សាការងារជាមួយក្រុមប្រឹក្សា គណៈមេធាវី ចូលជួប និងសម្តែងការគួរសម នៅរសៀល ថ្ងៃទី២៧ ខែមករា នេះ នៅទីស្តីការក្រសួងមហាផ្ទៃ។ សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍បន្តថាៈ ខ្លឹមសារទាំង ៧ចំណុចនេះ គឺជាសារនយោបាយមួយដ៏សំខាន់ សម្រាប់បម្រើឲ្យការបោះឆ្នោត នៅពេលខាងមុខ។ ពាក់ព័ន្ធនឹងការលើកកម្រិត ចេញជាគោលនយោបាយនេះ គឺដោយសារមានសំណូមពរ និងគោលនយោបាយ របស់រាជរដ្ឋាភិបាល ដូច្នេះការងារនេះ ត្រូវតែធ្វើឡើង ជាសមូហភាព ដោយមានស្ថាប័នទាំងអស់ ចូលរួម ដើម្បីបាញ់ឆ្ពោះទៅមូលដ្ឋាន ។

សម្តេចក្រឡាហោម បានបន្តថាៈ ពេលនេះ យើងសរសេរគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ហើយការថែមសង្កាត់នេះ គឺដោយសារបណ្តាក្រុង តាមខេត្ត ក៏មានសង្កាត់ដែរ ម្យ៉ាងនៅរាជធានីភ្នំពេញ ក៏មានសង្កាត់ដូចគ្នាដែរ។ សម្តេចបានបន្តថាៈ គោលនយោបាយនេះ បានសរសេរច្បាស់ៗ គ្មានពាក្យបង្ការ លុបបំបាត់ ឬកាត់បន្ថយអ្វីទេ ។ សម្តេច បានពន្យល់ទៀតថាៈ ការដាក់ច្បាស់ៗ នូវអ្វីដែលចង់បាន ក្នុងគោលនយោបាយនេះ គឺដើម្បីបញ្ចប់ភាពស្រពិចស្រពិល ដូច្នេះគោលនយោបាយ កែសម្រួលនេះ បានកំណត់ឱ្យច្បាស់តែម្តង ដូចជាពាក្យគ្មានបទល្មើសគ្រប់ប្រភេទ ជាពិសេស សកម្មភាពលួចឆក់ប្លន់ ឬគ្មានបទល្មើសគ្រឿងញៀន ជាដើម ដោយមានផ្នែកបន្ទាប់ ពន្យល់យ៉ាងលម្អិត។

យោងតាមសេចក្តីព្រាង លក្ខណៈសម្បត្តិ គោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព មានគោលបំណង បន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខមាលភាពប្រជាជន និងកាត់បន្ថយគ្រោះថ្នាក់ ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាត គ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្ត ឱ្យមានការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ នៅមូលដ្ឋាន ។ គ្រប់ចំណុចនៃ គោលនយោបាយ

នេះ គឺដើម្បីបង្កភាពអនុគ្រោះ ដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច នៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ ព្រមទាំងកសាងបាន ជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ដោយបំផុសឱ្យមានកិច្ចសហការ ចូលរួមជាមួយ សមត្ថកិច្ច ផ្នែកសាធារណៈ ផ្នែកឯកជន ផ្នែកពាក់ព័ន្ធ និងប្រជាជនទូទាំងប្រទេស ។/V

## លោកស្រី ជូ ប៊ុនអេង ខកចិត្តចំពោះអាជ្ញាធររាជធានី-ខេត្ត ដែលធ្វេសប្រហែសឲ្យពលរដ្ឋចំណាកស្រុកដោយខុសច្បាប់បាន

http://www.freshnewsasia.com/ 2021-01-28 05:13pm

**(ភ្នំពេញ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ បានសម្តែងការខកចិត្តយ៉ាងខ្លាំងចំពោះអាជ្ញាធររាជធានី-ខេត្តមួយចំនួន ដែលធ្វេសប្រហែសឲ្យប្រជាពលរដ្ឋក្នុងដែនដីរបស់ខ្លួន ធ្វើចំណាកស្រុកដោយខុសច្បាប់បាន ស្របពេលពិភពលោកកំពុងរឹតបន្តឹងការធ្វើដំណើរ ដោយសារវិបត្តិកូវីដ១៩។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃបានសម្តែងការខកចិត្តយ៉ាងដូច្នេះ ក្នុងឱកាសលោកស្រី អញ្ជើញជាតំណាង សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បើកកិច្ចប្រជុំឆ្លងរបាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ នៅក្រសួងមហាផ្ទៃ។

នៅចំពោះមុខអគ្គលេខាធិការ អគ្គលេខាធការរង ទីប្រឹក្សាបច្ចេកទេស ប្រធានលេខាធិការដ្ឋានរដ្ឋបាល ប្រធានក្រុមជំនួយកិច្ចការ នៃគណៈកម្មាធិការជាតិប្រយុត្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងតំណាង រាជធានី-ខេត្តទូទាំងប្រទេស លោកស្រី ជូ ប៊ុនអេង បានលើកឡើងថា ការធ្វើប្រហែសរបស់អាជ្ញាធរទាំងនោះ បានធ្វើឲ្យប្រទេសកម្ពុជាខាតបង់យ៉ាងខ្លាំង។ ខាតបង់ដោយសារតែកម្ពុជាកំពុងតែស្ថិតក្នុងចំណាត់ថ្នាក់លេខ២ ផ្នែកការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្រោមការវាយតម្លៃរបស់សហរដ្ឋអាមេរិក ហើយលោកស្រីថ្លែងទៀតថា បើនៅបន្តយ៉ាងដូច្នេះទៀតកម្ពុជា នឹងធ្លាក់ទៅលេខ៣ ដោយស្វ័យប្រវត្តិមិនខាន។ បើតាម លោកស្រី ជូ ប៊ុនអេង, ការធ្វេសប្រហែសនោះ ដោយសារនៅតែមានមេខ្យល់នាំប្រជាពលរដ្ឋចំណាកស្រុកដោយខុសច្បាប់ ដែលលោកស្រីចាត់ទុកថា នេះជារឿងអសមត្ថភាពមួយរបស់អាជ្ញាធរមូលដ្ឋាន ដែលធ្វើការងារមិនបានល្អ។

លោកស្រីថា មានករណីខ្លះរកឃើញស្ត្រីអាយុ ១៨ឆ្នាំ ឬ ១៩ឆ្នាំ មានផ្ទៃពោះនៅក្នុងប្រទេសចិន ស្រែកអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាជួយទៀតផង។ លោកស្រីបន្តដោយដាក់សំណួរថា «ទៅដោយរបៀបណា? គ្រាន់តែនិយាយថារកឃើញជនរងគ្រោះនៅប្រទេសគេនោះ យើងសាកគិតពីដំណើរផ្សងព្រេងរបស់គាត់ ចេញទៅដោយរបៀបណា? បើយើងបិទព្រំដែនបានល្អ ឬមួយបើយើងឃុំគ្រងប្រជាពលរដ្ឋនៅមូលដ្ឋានយើងបានល្អ បើសិនជាយើងធ្វើការអប់រំផ្សព្វផ្សាយបានល្អ វាមិនអាចទៅរួច»។ លោកស្រីរដ្ឋលេខាធិការ បានលើកឡើងបន្តថា អំឡុងពេលមានវិបត្តិកូវីដ១៩នេះ អំពើជួញដូរមនុស្សចាប់ផ្តើមកម្រើកឡើងមិនថានៅប្រទេសណានោះទេ ក្នុងនោះកម្ពុជាក៏មានបញ្ហានេះកើតឡើងផងដែរ។ លោកស្រីថ្លែងថា នៅកម្ពុជាសកម្មភាពសម្តែងអំពើជួញដូរមនុស្សអំឡុងពេលវិបត្តិកូវីដ១៩នេះ មាន២មុខសញ្ញា គឺទី១៖ ការនាំមនុស្សចេញឆ្លងដែនដោយខុសច្បាប់ ដោយមានគោលដៅ និងធ្វើការកេងប្រវ័ញ្ច និងទី២គឺ៖ ការនាំមនុស្សទៅរៀបអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ។

លោកស្រីបញ្ជាក់បន្ថែមយ៉ាងដូច្នេះ **«អញ្ចឹងបើវាទៅរួច បានន័យថា មានភាពចន្លោះប្រហោងហើយ។ ហើយបើនិយាយពីករណីដែលយើងរកឃើញ ពីឆ្នាំកន្លងទៅនេះ គឺមិនមែនមានតែ ១ខេត្ត ឬ ២ខេត្ត នោះទេ គឺសឹងតែទូ**

**ទាំងប្រទេស។ នេះដោយសារតែយើងចាញ់ប្រៀបមេខ្យល់ ដែលយើងមានមន្ត្រីជ្រោងគ្រប់កន្លែង មានទាំងសមត្ថកិច្ច មានទាំងអាជ្ញាធរ មានទាំងមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ខ្សែភ្នែក NGO (អង្គការក្រៅរដ្ឋាភិបាល) ដូចភ្នែកម្ចាស់ ប៉ុន្តែទីបំផុតយើងមានជង្គរុក បានន័យថាមានជនដែលឆ្លៀតឱកាសធ្វើកកូរកកាយពេញស្រុក...»**។ ទន្ទឹមនឹងសម្តែងការខកចិត្តរបស់ខ្លួន លោកស្រី ជូ ប៊ុនអេង ថែមទាំងស្តីបន្ទោសអាជ្ញាធររាជធានី-ខេត្តមួយចំនួនទៀតផង ដែលមិនសូវសកម្មនៅក្នុងសកម្មភាព ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ខណៈខេត្តគោលដៅមួយចំនួន ក៏សឹងមិនមានសកម្មភាពថែមទៀត។ ក្នុងន័យនេះដែរ លោកស្រីបានណែនាំដល់អាជ្ញាធររាជធានី-ខេត្ត ត្រូវខិតខំពង្រឹងការងាររបស់ខ្លួនឡើងវិញ ព្រោះថាការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនេះ មានសារៈសំខាន់ខ្លាំងណាស់។

ទោះជាយ៉ាងណាក៏ដោយ លោកស្រីរដ្ឋលេខាធិការ បានសម្តែងក្តីសោមនស្សរីករាយផងដែរ ដែលសង្កេតឃើញថា សកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនៅកម្ពុជា កាន់តែមានភាពល្អប្រសើរ រហូតដល់អង្គការសហប្រជាជាតិ តាមរយៈអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) សម្រេចដាក់កម្ពុជាបញ្ចូលជាបេក្ខភាពប្រទេសជ័យលាភី ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ លោកស្រីអះអាងថា នៅអាស៊ីនេះផងដែរ មានប្រទេស ២ប៉ុណ្ណោះ ដែលក្លាយជាបេក្ខភាពជ័យលាភីនៃរង្វាន់ខាងលើ។ ជាការកត់សម្គាល់ ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាលកម្ពុជា តែងតែអន្តរាគមន៍ជួយសង្គ្រោះប្រជាពលរដ្ឋរាប់រយនាក់ ដែលចាញ់បោកមេខ្យល់នាំធ្វើចំណាកស្រុក។ មានប្រជាពលរដ្ឋខ្លះ ត្រូវគេយកទៅធ្វើបាបរហូតក្លាយជាមនុស្សវិបល្លាសស្មារតីក៏មាន៕

## IOM **ស្នើឲ្យកម្ពុជា ដាក់បេក្ខភាពទទួលយកជ័យ លាភីទាក់ទងនឹងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស**

http://btv.com.kh/ 28/01/2021

ភ្នំពេញ ៖ អង្គការទេសន្តរប្រវេសក៍អន្តរជាតិ ដែលហៅកាត់ថា IOM បានស្នើដល់រាជរដ្ឋាភិបាលកម្ពុជា ដាក់បេក្ខភាពរបស់ខ្លួនប្រឡងជ័យលាភី ទាក់ទងនឹងករណី នៃការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ខណៈអង្គការនេះបានមើលឃើញប្រទេសកម្ពុជា ជាប្រទេសមួយដែលស្ទិតស្វាញ និងសកម្មបំផុតក្នុងការទប់ស្កាត់ការជួញដូរមនុស្សនេះ។

ថ្លែងនៅក្នុងកិច្ចប្រជុំឆ្លងរបាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ នាព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ ២០២១នេះ លោក ជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស (គ.ជ.ប.ជ) បានឲ្យដឹងថា អង្គការ IOM បានជួយដល់ពលករខ្មែររងគ្រោះជាច្រើន ពីសំណាក់មេខ្យល់ ដែលបានបោកពួកគេឲ្យទៅធ្វើការនៅក្រៅប្រទេស ហើយអង្គការអន្តរជាតិមួយនេះ ក៏បានចូលរួមយ៉ាងសកម្មបំផុត ជាមួយប្រទេសកម្ពុជាផងដែរ ក្នុងកិច្ចការនេះ ដោយទទួលបានលទ្ធផលយ៉ាងច្រើន តាំងពីដើម រហូតដល់បច្ចុប្បន្ននេះ។ លោកជំទាវ បានអះអាងថា «អង្គការIOM បានមើលឃើញកិច្ចប្រឹងប្រែងរបស់កម្ពុជា សកម្មក្នុងការប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស ហើយទទួលបានលទ្ធផលល្អ ហើយបានស្នើឲ្យកម្ពុជាដាក់ក្នុងបញ្ជីបេក្ខភាពក្នុងប្រទេសដែលទទួលបានជ័យលាភីនៅលើពិភពលោក ហើយករណីនេះ ហើយទាក់ទងនឹងការស្នើនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លោកបានចុះហត្ថលេខារួចហើយដែរ ដើម្បីដាក់បេក្ខភាពនេះ ប៉ុន្តែយើងមិនទាន់ដឹងថា នឹងត្រូវដាក់ នៅពេលណានោះទេ»។

ទាក់ទងនឹងការងារនៃការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះដែរ លោកជំទាវ ជូ ប៊ុនអេង បានឲ្យដឹងទៀតថា ក្នុងឆ្នាំ២០២០ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ស្ថាប័ន រាជធានី-ខេត្ត បានបន្តសកម្មភាពរបស់ខ្លួនទៅតាមទិសដៅដែលបានគ្រោងទុក ទោះបីមានបញ្ហាជំងឺកូវីដ-១៩ និងបញ្ហាប្រឈមមួយចំនួនទៀតក៏ដោយ។ លោកជំទាវ បន្ថែមថា ដើម្បីឲ្យការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សនៅកម្ពុជា មានប្រសិទ្ធភាព ភាគីពាក់ព័ន្ធត្រូវប្រកាន់គោលការណ៍សកម្មភាពមួយចំនួន ដូចជា ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស, ជួយជនរងគ្រោះ និងការអនុវត្តច្បាប់ជាដើម។ ជាងនេះទៅទៀត លោកជំទាវ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ក៏បានលើកឡើងទៀតថា ក្នុងដំណាក់កាលកម្ពុជាកំពុងប្រឈមទៅនឹងជំងឺកូវីដ-១៩ វិបត្តិសេដ្ឋកិច្ច ពលករអត់ការងារធ្វើ ដោយមានការបិទរោងចក្រជាដើម ហើយទីបំផុតមានពលករខ្មែរត្រឡប់មកវិញ ជាង១៣ម៉ឺននាក់។ ប៉ុន្តែឱកាសនេះឯង ដែលជនជួញដូរមនុស្សគេឆ្លៀតឱកាសនេះ ដើម្បីយកផលចំណេញពី កម្មករ-កម្មការិនីដែលអត់ការងារធ្វើ ដូច្នេះ សមត្ថកិច្ចត្រូវមានវិធានការបន្ថែមទៀត ដើម្បីទប់ស្កាត់ការនាំមនុស្សចេញដោយខុសច្បាប់ ខណៈបញ្ហានេះ នៅបន្តមាននៅឡើយនោះ៕ អត្ថបទ ៖ បានចក់

## លោកជំទាវ ជូ ប៊ុនអេង ៖ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា មានប្រសិទ្ធភាព ជួយជនរងគ្រោះ និងការអនុវត្តច្បាប់

https://www.cen.com.kh/ January 29, 2021

ភ្នំពេញ៖ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងមហាផ្ទៃ បានថ្លែងថា ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា មានប្រសិទ្ធភាព ភាគីពាក់ព័ន្ធត្រូវប្រកាន់គោលការណ៍សកម្មភាពមួយចំនួន ដូចជា ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស, ជួយជនរងគ្រោះ និងការអនុវត្តច្បាប់ជាដើម។ ទីស្តីការក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃសុក្រ ទី២៨ ខែមករា ឆ្នាំ២០២១ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រសួងមហាផ្ទៃ បានបើកកិច្ចប្រជុំឆ្លងរបាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដោយមានការចូលរួម អគ្គលេខាធិការរង នៃគ.ជ.ប.ជ អភិបាលរងរាជធានី-ខេត្ត ស្នងការរងរាជធានី-ខេត្ត ព្រមទាំងអ្នកពាក់ព័ន្ធជាច្រើនរូបទៀតផងដែរ។

នាឱកាសនោះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគ.ជ.ប.ជ បានលើកឡើងថា របាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ គឺជារបាយការណ៍ជាតិ ដូច្នេះអ្នកចូលកិច្ចប្រជុំនាពេលនេះ ត្រូវតែពិភាក្សាឲ្យបានត្រឹមត្រូវបំផុត ហើយដាក់គោរពជូនសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ពិនិត្យ និងសម្រេច ដើម្បីចេញផ្សាយជូនសាធារណៈជនឲ្យបានជ្រាប់ជាព័ត៌មានផងដែរ។ លោកជំទាវបន្តថា ក្នុងឆ្នាំ២០២០ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ស្ថាប័ន រាជធានី-ខេត្ត បានបន្តសកម្មភាពរបស់ខ្លួនទៅតាមទិសដៅដែលបានគ្រោងទុក ទោះបីមានបញ្ហាជំងឺកូវីដ-១៩ និងបញ្ហាប្រឈមមួយចំនួនទៀតក៏ដោយ។ លោកជំទាវ បន្ថែមថា ដើម្បីឲ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា មានប្រសិទ្ធភាព ភាគីពាក់ព័ន្ធត្រូវប្រកាន់គោលការណ៍សកម្មភាពមួយចំនួន ដូចជា ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស, ជួយជនរងគ្រោះ និងការអនុវត្តច្បាប់ជាដើម។

ជាងនេះទៅទៀត លោកជំទាវ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ក៏បានលើកឡើងបន្តថា ក្នុងដំណាក់កាលកម្ពុជាកំពុងប្រឈមទៅនឹងជំងឺកូវីដ-១៩ វិបត្តិសេដ្ឋកិច្ច ពលករអត់ការងារធ្វើ ដោយមានការបិទរោងចក្រជាដើម ហើយទីបំផុតមានពលករខ្មែរត្រឡប់មកវិញ ជាង១០ម៉ឺននាក់។ ប៉ុន្តែឱកាសនេះឯង ដែលជនជួញដូរមនុស្សគេឆ្លៀតឱកាសនេះ ដើម្បីយកផលចំណេញពី កម្មករ-កម្មការិនី ដែលអត់ការងារធ្វើ ដូច្នេះ សមត្ថកិច្ចត្រូវមានវិធានការបន្ថែមទៀត ដើម្បីទប់ស្កាតការនាំមនុស្សចេញដោយខុសច្បាប់។

របាយការណ៍ថ្នាក់ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ បានឆ្លុះបញ្ចាំងអំពីកិច្ចការងារបង្ការទប់ស្កាត់ អនុវត្តច្បាប់ យុត្តិធម៌ និងកិច្ចសហការគ្នារវាងក្រសួង ស្ថាប័ន អង្គភាពសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមទាំងលេខាធិការដ្ឋាន នៃគណៈកម្មាធិកាថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) និងអង្គការដៃគូទាំងឡាយ ដែលមានសកម្មភាព និងគោលដៅរួម។ លោកជំទាវបានលើកឡើងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តដោះស្រាយរាល់បញ្ហាប្រឆាំងបទល្មើសជួញដូរមនុស្ស និងជួយផ្គត់ផ្គង់គាំទ្រទៅដល់ពលករទេសន្តរប្រវេសន៍ដែលបានវិលត្រលប់ តាមរយៈគម្រោងរួមគ្នារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល ក្នុងដំណាក់កាលការរីករាលដាលកូវីដ-១៩ ជាសកល៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស ចាប់ខ្លួនមេខ្យល់ម្នាក់ នាំនារីជាក់ឲ្យភ្ញៀវ នៅតាមផ្ទះសំណាក់ និងសណ្ឋាគារ

https://www.cen.com.kh/ January 28, 2021

ភ្នំពេញ៖ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៣ម៉ោង៥០នាទី កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចុះអនុវត្តចំណារអនុញ្ញាតិឲ្យបង្ក្រាបជាក់ស្តែងលេខ ០២៨ អ.យ.ឋ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ របស់លោក គុជ គឹមឡុង ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ធ្វើការឃាត់ខ្លួនជនសង្ស័យ ០១នាក់ និងជនរងគ្រោះចំនួន ០៧នាក់ ស្រី (អនីតិជន ០៥នាក់) ករណី ប្រព្រឹត្តអំពើសញ្ញារកម្មមានស្ថានទម្ងន់ទោស (នាំនារីក្មេងៗឲ្យរួមភេទជាមួយភ្ញៀវនៅតាមផ្ទះសំណាក់ និងសណ្ឋាគារ) នៅចំណុច ០២ គោលដៅផ្សេងគ្នា ។

កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស បានឲ្យដឹងថា ១. នៅចំណុចភោជនីយ៍ដ្ឋាន តាឳ ផ្លូវជាតិលេខ៦ ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ ឃាត់ខ្លួនជនសង្ស័យ ០១នាក់ ឈ្មោះ ឆយ ចន្ថា ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ និងជនរងគ្រោះចំនួន ០៣នាក់ ស្រី (អនីតិជន ០២នាក់) ។

២. នៅចំណុចផ្ទះសំណាក់ ហេង មហាសាល ផ្លូវជាតិលេខ៦A ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ ជនរងគ្រោះ ចំនួន ០៤នាក់ ស្រី (អនីតិជន ០៣នាក់) មកកាន់ការិយាល័យ ដើម្បីធ្វើការសាកសួរ និងស្រាវជ្រាវបន្ត ។

តាមប្រភពព័ត៌មានពីសមត្ថកិច្ចបានឱ្យដឹងថា មេខ្យល់ ឈ្មោះ ឆយ ចន្ថា អាយុ ៣៣ឆ្នាំ ជនជាតិ ខ្មែរ ស្នាក់នៅ ផ្ទះជួល ផ្លូវបេតុង សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងនារីរងគ្រោះចំនួន០៣នាក់ ឃាត់ខ្លួននៅចំណុចភោជនីយ៍ដ្ឋាន តាឳ ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ និង នារីជនរងគ្រោះចំនួន០៤នាក់ បន្ថែមទៀត ឃាត់ខ្លួននៅ ចំណុចផ្ទះសំណាក់ ហេងមហាសាល ផ្លូវជាតិលេខ៦A សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

យោងតាមនារីរងគ្រោះបានឲ្យដឹងថា ភោជនីយដ្ឋាន តាឳ ចាប់ផ្តើមបើកដំណើរការពីវេលាម៉ោង១១ថ្ងៃត្រង់ រហូតដល់ម៉ោង៩យប់ ដោយមាននារីៗក្មេងជាច្រើននៅ បំរើភ្ញៀវនៅហាង ចំពោះភ្ញៀវ ដែលចូលមកហាង ពេលត្រូវការនារីក្មេងៗ មកអង្គុយកំដរនិងទៅរួមភេទនៅខាងក្រៅ គឺមេការឈ្មោះ ឆយ ចន្ថា អាចធ្វើការទំនាក់ទំនង តាម

រយៈទូរស័ព្ទ បាននាំមកឲ្យភ្ញៀវមើលនិងសម្រាប់រួមភេទ ដោយក្មេងៗនារី មានអាយុចន្លោះពី១៥ឆ្នាំ ១៦ឆ្នាំ ឡើងទៅ ដោយក្នុងតម្លៃការរួមភេទក្នុង១ដង ចាប់ពី១០០$ដល់ ១៥០$ ចំពោះលុយបានមក គឺត្រូវឲ្យទៅមេខ្យល់ចំនួន ១៥$ទៅ២០$ បន្ថែមទៀតនោះ មេខ្យល់បានសុំលុយធីបពីភ្ញៀវចំនួនពី ២០$ទៅ៥០$ ជាកម្រៃជើងសារដែលខ្លួនបាននាំនារី មកអោយរួមភេទជាមួយភ្ញៀវផងដែរ។

បច្ចុប្បន្នសមត្ថកិច្ចការិយាល័យកំពុងកសាងសំណុំរឿង និងបញ្ជូនជនសង្ស័យទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ចំណែកឯជនរងគ្រោះចំនួន ០៧នាក់ (អនីតិជន ០៥នាក់) ប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២១

(សៀមរាប)៖ នៅថ្ងៃព្រហស្បតិ៍ ទី២៨ ខែមករា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៣នាក់ ស្រី ២៨នាក់ ក្នុងនោះកុមារ ១នាក់ កុមារី ៦នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៣នាក់ ស្រី ៦នាក់ កុមារ ១នាក់ កុមារី ០០នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២២នាក់ ស្រី ១១នាក់ កុមារ ១នាក់ កុមារី ០០នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៧នាក់ ស្រី ១២នាក់ កុមារ ០០នាក់ កុមារី នាក់។

៥- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់។

សូមបញ្ជាក់ថា ពួកគាត់ទាំង ៦៣នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣៦នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យ ចំនួន ២៧នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ប្រភព: ក្រុមការងារប្រចាំការរបស់រដ្ឋបាលខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ក្រសួងការបរទេស៖ ពលករខ្មែរ៦នាក់ នៅម៉ាឡេស៊ី ដែលទើបសង្គ្រោះ បានមកដល់មាតុភូមិហើយ, ជាអ្នកឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2021-01-28 05:18pm

**(ភ្នំពេញ)៖** ពលករខ្មែរចំនួន ៦នាក់ នៅប្រទេសម៉ាឡេស៊ី ដែលទើបត្រូវបានស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីជួយសង្គ្រោះ បានមកដល់មាតុភូមិវិញហើយ។ នេះបើតាមលោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ថ្លែងប្រាប់បណ្តាញព័ត៌មាន Fresh News នៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១នេះ លោក កុយ គួង បានឲ្យដឹងថា ផ្អែកតាមកាលវិភាគ ពលករទាំង ៦នាក់នោះ បានមកដល់មាតិភូមិវិញ នៅល្ងាចថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ម្សិលមិញ ហើយពួកគេគឺជាអ្នកឆ្លងដែនខុសច្បាប់។

សូមជម្រាបថា ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅម៉ាឡេស៊ី បានអន្តរាគមន៍ជួយពលករខ្មែរ ៦នាក់ និងទារិកាម្នាក់ ឲ្យបានធ្វើមាតុភូមិនិវត្តន៍វិញ នៅល្ងាចថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១នេះ។ នេះបើតាមការបញ្ជាក់ពី

លោក កុយ គួង។ លោក កុយ គួង បានឲ្យដឹងទៀតថា ដោយមានកិច្ចអន្តរាគមន៍របស់ស្ថានទូត ពលករ ពលការិនី ខ្មែរចំនួន០៦នាក់ និងទារិកា០១នាក់ មកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះ អាកាសចរណ៍សិង្ហបូរីលេខ SQ5008 នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩៖៣៥នាទីល្ងាច។ បើតាមលោក កុយ គួង, ស្ថានទូតបានជួយរៀបចំឯកសារទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ម៉ាឡេស៊ី ជូនទៅធ្វើតេស្ត កូវីដ១៩ ព្រមទាំងបានចាត់មន្ត្រី ជូនពលករ ពលការិនី និងទារិកាខាងលើ ទៅអាកាសយានដ្ឋាន អន្តរជាតិ KLIA ផងដែរ។

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅម៉ាឡេស៊ី នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ក៏បានអំពាវនាវដល់ពលករខ្មែរនានា ឱ្យឈប់ធ្វើចំណាកស្រុកដោយខុសច្បាប់ទៀត បន្ទាប់ពីស្ថានទូតទើបនឹងអន្តរាគមន៍ជួយសង្គ្រោះពលករខុសច្បាប់ជាច្រើនរូប ដែលរងគ្រោះនៅប្រទេសម៉ាឡេស៊ី។ នេះមិនមែនជាលើកទី១ទេ ដែលរាជរដ្ឋាភិបាលកម្ពុជា តាមរយៈស្ថានទូតនៅក្រៅប្រទេស បានជួយសង្គ្រោះប្រជាពលរដ្ឋ ដែលចាញ់បញ្ឆោតមេខ្យល់ ក្នុងការធ្វើចំណាកស្រុក៕

## ពលករមកពីថៃ ចាប់ផ្តើមស្វែងរកការងារធ្វើតាមរយៈមជ្ឈមណ្ឌលការងារខេត្តបាត់ដំបង

http://btv.com.kh/ 27/01/2021

បាត់ដំបង ៖ មន្ត្រីនៃមជ្ឈមណ្ឌលការងារខេត្តបាត់ដំបង បានឱ្យដឹងថា បន្ទាប់ពីមានការផ្សព្វផ្សាយដល់មូលដ្ឋានជាបន្តបន្ទាប់ ស្តីពីការផ្តល់ឱកាសការងារដល់ពលរដ្ឋ ឬពលករបាត់បង់ការងារធ្វើ ក្នុងអំឡុងវិបត្តិកូវីដ១៩នេះ គឺពលរដ្ឋ និងពលករ ច្រើនជាងមុន ចាប់ផ្តើមចាប់អារម្មណ៍សួរនាំ ឬទាក់ទង ដើម្បីបានការងារធ្វើ។

អ្នកស្រី ស៊ឹម ស៊ីសូលី ប្រធានមជ្ឈមណ្ឌលការងារខេត្តបាត់ដំបង បានប្រាប់BTVថា បច្ចុប្បន្ន នៅក្នុងខេត្តនេះ មានការងារជាង៥០០កន្លែង ត្រៀមសម្រាប់ផ្តល់ជូនពលរដ្ឋ ពលករ ឬសិស្សនិស្សិត ដែលគ្មានការងារធ្វើ ដែលកន្លែងការងារទាំងនោះ មាននៅតាមស្ថាប័នឯកជន ដូចជា មីក្រូហិរញ្ញវត្ថុ អង្គការ និងហាងលក់ទំនិញ ។ល។ អ្នកស្រី បានបញ្ជាក់ថា ការងារគឺនឹងផ្តល់ជូនចំពោះតែពលរដ្ឋ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ដោយមិនគិតកម្រិតវប្បធម៌នោះទេ តាមលទ្ធភាព ឬសមត្ថភាពរបស់បុគ្គលម្នាក់ៗ ទើបមជ្ឈមណ្ឌលការងារបញ្ជូនទៅកន្លែងការងារនីមួយៗ ដែលគេចង់បាន។ អ្នកស្រី បានបន្ថែមថា ពេលអាជ្ញាធរ និងក្រុមការងារចុះផ្សព្វផ្សាយពីការផ្តល់ឱកាសការងារនៅមូលដ្ឋាន មិនទាន់ជួបពលករផ្ទាល់នោះទេ ប៉ុន្តែបន្ទាប់ចេញពីធ្វើចត្តាឡីស័ក ពួកគេ បានទាក់ទងជាបន្តបន្ទាប់ តាមរយៈព័ត៌មានដឹងពីឪពុកម្តាយ ឬសាច់ញាតិ ដើម្បីស្វែងការងារធ្វើ។ អ្នកស្រី ស៊ឹម ស៊ីសូលី បានអំពាវនាវ និងជំរុញឱ្យពលរដ្ឋ ពលករ និងសិស្សនិស្សិត ដែលពុំមានការងារធ្វើ ធ្វើការទំនាក់ទំនងជាមួយមជ្ឈមណ្ឌលការងារ រៀងរាល់ពេលម៉ោងធ្វើការ ឬតាមប្រព័ន្ធទូរស័ព្ទ ដើម្បីសាកសួរពីកន្លែងការងារ ខណៈខេត្តនៅជិតៗបាត់ដំបង ដែលគ្មានមជ្ឈមណ្ឌលការងារទេនោះ ក៏អាច មកទាក់ទងនៅខេត្តបាត់ដំបងបានដែរ។

ចាប់តាំងពីមានការផ្ទុះរីករាលដាលនៃមេរោគកូវីដ១៩ ក្នុងសហគមន៍ ខេត្តសាមុទសាខន ប្រទេសថៃ មានពលករទើបត្រឡប់មកពីប្រទេសថៃ តាមច្រកនានាជាប់ខេត្តបាត់ដំបង មានចំនួនជាង ៣៥០០នាក់ អ្នកបញ្ចប់ការធ្វើចត្តាឡីស័ក អនុញ្ញាតឲ្យទៅផ្ទះ ចំនួនជាង២២០០នាក់ កំពុងធ្វើចត្តាឡីស័កចំនួន៩៩០នាក់ និងការធ្វើសំណាកចំនួនជាង៣៣០០នាក់៕ អត្ថបទ ៖ បាន សុខរិទ្ធ

# បំណុលគឺជាមូលហេតុចំបងដែលធ្វើឲ្យប្រជាជនកម្ពុជាស្វែងរកការងារធ្វើនៅប្រទេសថៃ

https://www.khmertimeskh.com/ Khmer Times January 27, 2021

បំណុលដែលមិនអាចដោះស្រាយបាន គឺជាហេតុផលចំបងមួយក្នុងចំណោមហេតុផលផ្សេងដែលប្រជាជនកម្ពុជាជាច្រើនបានបង្ខំចិត្តចាកចេញពីផ្ទះ និងស្វែងរកការងារធ្វើនៅតាមព្រំដែនថៃ។ ការរកឃើញនេះត្រូវបានបង្ហាញឲ្យដឹងនៅក្នុងការស្ទង់មតិមួយ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ( សង់ត្រាល់ ) លើពលករចំណាកស្រុកចំនួន ៤៧២ នាក់ដែលបានវិលត្រឡប់មកពីប្រទេសថៃ នៅក្នុងខេត្តកំពង់ធំ សៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ និងបាត់ដំបង កាលពីខែកញ្ញា ឆ្នាំមុន។ ហេតុផលផ្សេងទៀតដែលត្រូវបានលើកឡើងក្នុងចំណោមអ្នកមួយចំនួនផ្សេង គឺការមិនមានការងារធ្វើ និងភាពក្រីក្រខ្លាំង។

ក្នុងអំឡុងពេលនៃការស្ទង់មតិ សំណួរទីមួយគឺ ហេតុអ្វីបានជាអ្នកធ្វើចំណាកស្រុក? (ពីកម្ពុជាទៅថៃ) ការឆ្លើយតបដែលទទួលបានចំនួន ៣ ធំៗគឺការជំពាក់បំណុល (អ្នកឆ្លើយតប ៣០៩ នាក់ ស្មើនឹង៦៥,៥ ភាគរយ) ភាពអត់ការងារធ្វើ (អ្នកឆ្លើយតប ២៩៥ នាក់ ស្មើនឹង៦២.៥ ភាគរយ) និងភាពក្រីក្រខ្លាំង (អ្នកកឆ្លើយតប ២៦៦ នាក់ ស្មើនឹង៥៦.៣ ភាគរយ) ។ ហេតុផលផ្សេងទៀតរួមមានដីស្រែតិចពេក (អ្នកឆ្លើយតប ២១១ នាក់ ស្មើនឹង ៤៥ ភាគរយ) មិនមានដីស្រែ (អ្នកឆ្លើយតប ២១២ នាក់ស្មើនឹង១១ ភាគរយ) និងត្រូវការចំណូលបន្ថែម (អ្នកឆ្លើយតប ១៧៥ នាក់ ស្មើនឹង៣៧,១ ភាគរយ) មិនទទួលបានប្រាក់ចំណេញពីផលិតផលរបស់ពួកគេ (អ្នកឆ្លើយតប ៤៤ នាក់ ស្មើនឹង ៩,៣ ភាគរយ) និងខ្លះទៀតឆ្លងព្រំដែនទៅតាមគេ (អ្នកឆ្លើយតប ៣៨ នាក់ ស្មើនឹង១១ ភាគរយ) ។

សង់ត្រាល់ប៉ាន់ស្មានថាមានពលករចំណាកស្រុកចំនួន ២ លាននាក់នៅក្នុងប្រទេសថៃ ដែលជាប្រទេសមានចំនួនដ៏ច្រើនបំផុតនៃពលករចំណាកស្រុកកម្ពុជា។ ការប្រមូលផ្តុំពលករចំណាកស្រុកធំជាងគេទី ២ គឺនៅប្រទេសម៉ាឡេស៊ីដែលមានចំនួនពលករចំណាកស្រុកប្រមាណ ១១ ម៉ឺននាក់។ សង់ត្រាល់ជឿជាក់ថា មានពលករដែលមានឯកសារប្រហែល ១ ៦០០ ០០០ នាក់និងពលករគ្មានឯកសារចំនួន ៤០០ ០០០ នាក់នៅក្នុងប្រទេសថៃ។ លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុកនៃអង្គការសង់ត្រាល់បាននិយាយថាឯកសារពលករចំណាកស្រុករាប់រយរាប់ពាន់នាក់នឹងផុតកំណត់នៅថ្ងៃទី ៣១ ខែមីនាឆ្នាំនេះហើយភាគច្រើននឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដែលមូលហេតុដោយសារតែឱកាសតិចតួចដែលពួកគេមានក្នុងការបន្តឯកសាររបស់ពួកគេទាន់ពេលវេលា។

យោងតាមបទបង្ហាញដែលសង់ត្រាល់បានផ្តល់ជូនកាសែតខ្មែរថាមស៍ អង្គការក្រៅរដ្ឋាភិបាលបានរកឃើញថាជំងឺកូវីដ-១៩ បានប៉ះពាល់ដល់ពលករចំណាកស្រុកកម្ពុជាតាមមធ្យោបាយមួយចំនួននៅក្នុងប្រទេសថៃពោលគឺអ្នកខ្លះត្រូវបានបញ្ឈប់ពីការងារដោយគ្មានសំណង អ្នកខ្លះមានប្រាក់ចំណូលតែត្រូវកាត់ម៉ោងធ្វើការ ចំណែកខ្លះទៀតបាត់បង់ការងារនៅពេលរោងចក្ររបស់ពួកគេត្រូវបានបិទ។ យោងតាមសង់ត្រាល់ អ្នកផ្សេងទៀតមិនអាចដាក់ពាក្យសុំឯកសារស្របច្បាប់បានទេ ខណៈការជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្មបានកើនឡើង។ សង់ត្រាល់បានប៉ាន់ប្រមាណថាកាលពីឆ្នាំមុនមានពលករចំណាកស្រុកប្រហែល ១៣០ ០០០ នាក់វិលត្រឡប់មកប្រទេសកម្ពុជាវិញ ដោយពួកគេប្រឈមនឹងថ្លៃដឹកជញ្ជូនខ្ពស់ក៏ដូចជាថ្លៃដើមផ្សេងទៀតដែលទាក់ទងនឹងការវិលត្រឡប់ដូចជាការដឹកទំនិញ។ ជាការឆ្លើយតបទៅនឹងការរកឃើញនេះ សង់ត្រាល់បានចេញនូវអនុសាសន៍មួយចំនួនដល់រដ្ឋាភិបាលដែលរួមមានការផ្តល់ដីកសិកម្មក៏ដូចជាការបណ្តុះបណ្តាលជំនាញ។

អង្គការមិនមែនរដ្ឋាភិបាលបានស្នើឲ្យធានានូវតម្លៃទំនិញដែលផលិតដោយកសិករ និងធ្វើឲ្យដំណើរការជ្រើសរើសពលករចំណាកស្រុកមានលក្ខណៈស្តង់ដារ។

សង់គ្រាល់ក៏បានធ្វើការតស៊ូមតិសម្រាប់ពលករចំណាកស្រុកដែលវិលត្រឡប់ ដោយភាពក្រីក្រ ដើម្បីត្រូវបានគេកំណត់ថាជាជនក្រីក្រដើម្បីឲ្យពួកគេអាចទទួលបានអត្ថប្រយោជន៍ពីរដ្ឋាភិបាល។ សង់គ្រាល់ក៏បានស្នើសុំព្យួរការទូទាត់ទៅធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុផងដែរ។ លោក ថេហ្សូយ៉ា និយាយថាសំណាញ់សុវត្ថិភាពសង្គមមិនត្រូវបានផ្តល់ជូនដល់ពលករចំណាកស្រុកដែលវិលត្រឡប់មកវិញទេ។ នៅពេលត្រូវបានសួរថាតើជម្រើសអ្វីដែលពលករដែលបានវិលត្រឡប់នោះមាន លោកថា៖ «នៅកម្ពុជាពួកគេអាចធ្វើស្រែ។ អ្នកមួយចំនួនធ្វើចំណាកស្រុកទៅភ្នំពេញដើម្បីរកការងារធ្វើ។ សម្រាប់អ្នកណាដែលមិនមានការងារ ឬស្រែធ្វើ ពួកគេត្រូវបង្ខំចិត្តត្រឡប់ទៅប្រទេសថៃវិញ»។ មិនអាចទាក់ទងសុំការអត្ថាធិប្បាយមន្ត្រីក្រសួងការងារបានទេ៕ *ប្រែសម្រួលដោយ សៀវ គួយអ៊ី*

## អាជ្ញាធរកម្ពុជា-ថៃ ចុះចែកអំណោយដល់ពលករខ្មែរ ៧០គ្រួសារ ដែលរងផលប៉ះពាល់ពីជំងឺកូវីដ១៩

https://dap-news.com/ ByKD102 Posted on January 27, 2021

ភ្នំពេញ៖ លោក អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ និងមន្ត្រីការទូត បានសហការជាមួយអាជ្ញាធរស្រុកបាងគ្លី ខេត្តសាមុទ្រប្រាកាន ដែលមានការចូលរួមពីអភិបាលស្រុក ប៉ូលីសស្រុក និងតំណាងមន្ទីរសុខាភិបាល នៅព្រឹកថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១នេះ បានចុះចែកអំណោយជាគ្រឿង ឧបភោគបរិភោគរួមមានអង្ករមី ត្រីខ ទឹកស៊ីអ៊ីវ ប្រេងឆា អំបិល និងម៉ាស់ ដល់ពលករខ្មែរចំនួន ៧០គ្រួសារ និងថវិកាមួយចំនួនដល់ក្មេងៗជាង ៣០នាក់ ដែលរងផលប៉ះពាល់ដោយសារ ការរីករាលដាលជំងឺកូវីដ១៩ ស្ថិតនៅឃុំបាងផ្លា ស្រុកបាងគ្លី ខេត្តសមុទ្រប្រាកាន ។ ទន្ទឹមនេះ លោកទូតក៏បានពាំនាំនូវ ការសួរសុខទុក្ខពីសំណាក់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងលោករដ្ឋមន្ត្រីការងារ អ៊ិត សំហេង ដែលតែងតែយកចិត្តទុកដាក់និងគិតគូរ សុខទុក្ខបងប្អូនប្រជាពលរដ្ឋខ្មែរ ទាំងក្នុងនិងក្រៅប្រទេស ជាពិសេសតែងតែបានណែនាំ ឲ្យស្ថានទូតជួយពលរដ្ឋខ្មែរ នៅក្រៅប្រទេសឲ្យអស់ពីលទ្ធភាព។

ក្នុងនោះ លោកឯកអគ្គរាជទូត បានណែនាំបងប្អូនពលករ បន្តចូលរួមសហការ ជាមួយអាជ្ញាធរពាក់ព័ន្ធថៃ ក្នុងការអនុវត្តតាមវិធានការនានា របស់រាជរដ្ឋាភិបាលថៃ អោយបានខ្ជាប់ខ្ជួន និងកាន់តែសកម្មថែមទៀត ដើម្បីចូលរួមទប់ស្កាត់ការ រីករាលដាលនៃជំងឺកូវីដ១៩ ឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងករណីបងប្អូនពលករ មានបញ្ហាសូមធ្វើការទំនាក់ទំនង មកស្ថានទូតតាមរយៈលេខទូរស័ព្ទ និងហ្វេសប៊ុកផេកស្ថានទូត ដើម្បីជួយដោះស្រាយបងប្អូន ៕